# ថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ២០២៣

## ឆបោកស្នេហាតាមអ៊ីនធើណេត៖ អាជ្ញាធរខ្មែរ ស្នើជនរងគ្រោះក្លាហានស្វែងរកជំនួយ

https://www.rfi.fr/km//20230831-?utm_medium=social&utm_campaign=telegram&utm_source=shorty ចុះផ្សាយនៅថ្ងៃ៖ 31/08/2023 - 12:25

មកដល់ពេលនេះ បណ្ដឹងពីពលរដ្ឋខ្មែរ ដែលរងគ្រោះដោយការឆបោកស្នេហាតាមអ៊ីនធើណេត មានចំនួនទាបនៅឡើយ ដែលបើតាមលោកស្រី ជូ ប៊ុនអេង កត្តាមួយ អាចមកពីជនរងគ្រោះមានភាពខ្មាស់អៀន ក្នុងការរាយការណ៍ទៅកាន់សមត្ថកិច្ច។ នៅចំពោះមុខនេះ គណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស អះអាងថានឹងធ្វើការងារនេះជូនជនរងគ្រោះដោយសម្ងាត់ និងដោយលក្ខណៈបច្ចេកទេស។

លោកស្រី ជូ ប៊ុនអេង បានថ្លែងប្រាប់វិទ្យុបារាំងRFI នៅថ្ងៃព្រហស្បត្តិ៍នេះថា ករណីចាញ់បោកតាមបែបស្នេហាក្នុងប្រទេសកម្ពុជា មិនមែនគ្មានសោះនោះទេ ក៏ប៉ុន្តែបណ្ដឹងជុំវិញករណីនេះហាក់មិនសូវលេចឮនោះឡើយ។ បើតាមអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សរូបនេះ កត្តាមួយ គឺអាចមកពីជនរងគ្រោះ មានភាពអៀនខ្មាស ក្នុងការរាយការណ៍មកកាន់អាជ្ញាធរពាក់ព័ន្ធ។ ដោយឡែក ជនរងគ្រោះក្នុងករណីឆបោកតាមបែបទំនាក់ទំនងស្នេហានេះ ភាគច្រើនជាយុវវ័យ ឬក្មេងស្រីជំទង់ ដែលលោកស្រី លើកទឹកចិត្តឲ្យមានភាពក្លាហានស្វែងរកជំនួយ ដើម្បីឲ្យអាជ្ញាធរពាក់ព័ន្ធជួយផ្ដល់កិច្ចអន្តរាគមន៍បាន។

ទន្ទឹមគ្នានេះ លោកស្រី Pia Oberoi ទីប្រឹក្សាជាន់ខ្ពស់ផ្នែកចំណាកស្រុកនិងសិទ្ធិមនុស្សនៃការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំអង្គការសហប្រជាជាតិ បានគូសបញ្ជាក់ថា ការឆបោកដែលនិយមលេចឮមួយនោះគឺ ជាការឆបោកដែលត្រូវបានគេឲ្យឈ្មោះថា ‛Pig Butchering Scheme′។ ‛Pig Butchering Scheme′នេះ ជាទូទៅគឺជាការឆបោក ដែលអ្នកឆបោកធ្វើជាបង្កើតទំនាក់ទំនងស្នេហាជាមួយជនរងគ្រោះ រួចហើយល្បួងឲ្យផ្ញើប្រាក់ក្រោមហេតុផលផ្សេងៗ។ ជាក់ស្ដែងបើតាមលោកស្រី Pia Oberoi កាលពីឆ្នាំមុន មានមនុស្សម្នាក់មកពីប្រទេសម៉ាឡេស៊ីបានស្លាប់ ក្រោយបានចាញ់បោក ឲ្យធ្វើដំណើរទៅប្រទេសថៃ ហើយបន្ទាប់មកត្រូវបានគេជួញដូរទៅប្រទេសភូមា។

ស្រដៀងគ្នានឹងលោកស្រីជូ ប៊ុន អេងដែរ លោកស្រី Pia Oberoiថា ជនរងគ្រោះក្នុងបទល្មើសមួយនេះ ភាគច្រើន សុខចិត្តរងគ្រោះ ដោយមិនជ្រើសរើសរាយការណ៍ឡើយ ដោយសារតែភាពអៀនខ្មាស និងខ្លាចរងការមាក់ងាយពីអ្នកដទៃ។ ជនរងគ្រោះ មិនត្រឹមតែរងគ្រោះផ្នែករាងកាយ ឬផ្លូវចិត្តទេ តែនឹងជាប់បំណុលតៗគ្នាយ៉ាងធ្ងន់ធ្ងរថែមទៀត។ មិនតែប៉ុណ្ណោះ លោកស្រីគូសបញ្ជាក់

ដែរថា ជាទូទៅ ជនឆបោកតាមប្រព័ន្ធអនឡាញជាច្រើន កើតមានអំឡុងវិបត្តិកូវីដ១៩មក ដែលអំឡុងពេលនោះ មានការរាំងខ្ទប់បិទកាស៊ីណូ ដែលជាផ្នែកមួយនៃសេដ្ឋកិច្ចតាមតំបន់ជាប់ព្រំដែន និងនៅក្នុងប្រទេសកម្ពុជា។

គួរជម្រាបថា ក្នុងឆ្នាំ២០១៩ គណៈកម្មការពាណិជ្ជកម្មសហព័ន្ធ FTC ដែលជាទីភ្នាក់ងារឯករាជ្យអាមេរិកាំង បានប្រកាសថា បទល្មើសឆបោកដែលពាក់ព័ន្ធនឹងទំនាក់ទំនងស្នេហានេះ បាននាំឲ្យមានការខាតបង់ទឹកប្រាក់ជាច្រើន ជាងទម្រង់នៃការឆបោកដទៃទៀត។ ចំណែក នៅថ្ងៃពុធម្សិលមិញ នគរបាលឥណ្ឌូណេស៊ី បានចាប់ខ្លួនជនជាតិចិនប្រមាណ៩០នាក់ ដែលជាប់ពាក់ព័ន្ធនឹងការឆបោកតាមទូរសព្ទឆ្លងព្រំដែន និងឆបោកបែបស្នេហាតាមប្រព័ន្ធអ៊ីនធើណេតនេះ៕

## តម្រួតថៃចាប់ស្ត្រីខ្មែរ ៣ នាក់ រឿងធ្វើត្រីងៀតលក់

https://www.kampucheathmey.com/security/569544 ថ្ងៃព្រហស្បតិ៍ ៣១ សីហា ២០២៣

ដោយ deth leng

ស្ត្រីខ្មែរចំនួន ៣ នាក់ ដែលបម្រើការងារជាមួយស្វាមីនៅក្នុងប្រទេសថៃ ត្រូវបានតម្រួតថៃចាប់ខ្លួន ដោយពិន័យជាប្រាក់ក្នុងម្នាក់១ម៉ឺនបាត ពីបទធ្វើត្រីងៀតលក់ ដោយគ្មានច្បាប់អនុញ្ញាត។ ក្នុងចំណោមស្ត្រីទាំង៣នាក់ ដែលកំពុងជាប់ក្នុងកន្លែងឃុំឃាំងបណ្តោះអាសន្នក្នុងខេត្ត ភិតបុរី គឺនាង វ៉ាន់ស៊ី ធែដា អាយុ២៥ឆ្នាំ បានបង្ហោះហ្វេសប៊ុកដោយបានលើកឡើងថា កាលពីថ្ងៃទី ២៥ សីហា កន្លងទៅថ្មីៗនេះ រូបនាងជាមួយ និងស្វាមីបានចូលមកធ្វើការនៅក្នុងរោងចក្រមួយកន្លែង។ នាងបានបន្តថា ក្រៅម៉ោងធ្វើការប្តីរបស់នាងបានចេញទៅរកត្រីព្រោះនៅក្បែកន្លែងដែលនាងស្នាក់នៅ មានបឹងមួយកន្លែងសំបូរត្រី។ ក្រៅពីបរិភោគ ដោយសារត្រីសល់ច្រើនពេក នាងក៏បែកគំនិតធ្វើជាត្រីប្រលាក់ និងវះងៀតហាលឱ្យស្ងួតទើបនាំយកទៅលក់ក្នុងផ្សារក្បែរផ្ទះដើម្បីបានលុយខ្វះទុកចិញ្ចឹមក្រពះ។

នៅពេលនោះដែរក៏ស្រាប់តែមានតម្រួតចុះមកចាប់នាងរួមទាំងស្ត្រី២នាក់ទៀត ដែលលក់ត្រីងៀតដូចគ្នា ដោយចោទប្រកាន់ថា ធ្វើត្រីប្រលាក់ និងត្រីងៀតលក់ដោយគ្មានច្បាប់អនុញ្ញាត ព្រោះអាចខ្វះអនាម័យផង និងប៉ះពាល់ដល់មុខរបរពលរដ្ឋថៃផង ដោយច្បាប់នៅក្នុងប្រទេសថៃមិនអនុញ្ញាតឱ្យជនអន្តោប្រវេសន៍ប្រកបមុខរបរឯកជនណាមួយ ជាន់គ្នាជាមួយមុខរបរជនជាតិថៃឡើយ ដោយតម្រួតបាននាំខ្លួនស្ត្រីទាំង៣នាក់ យកទៅឃុំខ្លួនជាបណ្តោះអាសន្ន និងដាក់ពិន័យក្នុងម្នាក់ៗចំនួន១ម៉ឺនបាត។

ក្រោយមកស្ត្រីខ្មែរទាំង៣នាក់ បានព្រមប្រគល់ប្រាក់ចំនួន៣ម៉ឺនបាតទៅឱ្យតម្រួតហើយ ដើម្បីបានរួចផុតពីទោសទណ្ឌ ប៉ុន្តែផ្ទុយទៅវិញ តម្រួតមិនបានដោះលែងតាមពាក្យដែលបានសន្យា

*នោះទេ ដោយគេបានបញ្ជូនឯកសារទៅតុលាការថែមទៀតផង និងបានសម្រេចបញ្ជូនខ្លួនស្ត្រីទាំងនេះមកកម្ពុជាវិញក្នុងអំឡុងសប្តាហ៍ក្រោយ ទើបស្ត្រីទាំង៣នាក់ សម្រេចបង្ហោះហ្វេសប៊ុកសុំឱ្យស្ថានទូតខ្មែរប្រចាំប្រទេសថៃជួយអន្តរាគមន៍។ នៅទីបំផុតការឃុំខ្លួនបានតែ១២ម៉ោងប៉ុណ្ណោះក៏ត្រូវបានដោះលែងដោយសារមានការអន្តរាគមន៍ពីស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ និងបានធ្វើការងារនៅទីនោះជាបន្តទៀត៕ អត្ថបទ៖ សោ និយមរ័ត្ន*

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៨នាក់

https://freshnewsasia.com/index.php/en/localnews/308174-2023-08-31-11-04-54.html 2023-08-31 06:04pm

**(ភ្នំពេញ)៖** *គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី៣០ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៨នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។* ***បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ រួមមាន៖***

**១៖** *សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ១០៤៧ករណី មានមនុស្ស ២,៦៦១នាក់។*

**២៖** *បានស្រាវជ្រាវស៊ើបអង្កេតបឋម ១០១៤សំណើ និងបិទសំណុំរឿង ៣៤៦សំណើ (រកឃើញមនុស្ស ១,៩៧១នាក់, ឃាត់ខ្លួនជនសង្ស័យ ១៤២នាក់, បិទក្រុមហ៊ុន ៩ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)។*

**៣៖** *កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៣ករណី៕*

## ឃាតកម្មសម្លាប់១គ្រួសារ៖
## មន្ត្រីប៉ូលីសជាន់ខ្ពស់ថៃ ចុះមករួមបង្ក្រាបមេក្លោងឆបោកចិន ក្នុងក្រុងប៉ោយប៉ែត

https://www.rfi.fr/km//20230831-?utm_medium=social&utm_campaign=telegram&utm_source=shorty *ចុះផ្សាយនៅថ្ងៃ៖* 31/08/2023 - 08:00

*អគ្គស្នងការរងនគរបាលជាតិថៃ ធ្វើដំណើរមកប្រទេសកម្ពុជា នៅថ្ងៃព្រហស្បត្តិ៍នេះ ដើម្បីសហការជាមួយអាជ្ញាធរខ្មែរ បង្ក្រាបមេក្លោងឆបោកជនជាតិចិន ក្នុងក្រុងប៉ោយប៉ែត។ មេក្លោង*

ឆបោកជនជាតិចិនដែល ត្រូវបានគេជឿជាក់ថា ពាក់ព័ន្ធក្នុងករណីឃាតកម្មសម្លាប់ជនជាតិថៃមួយគ្រួសារ ក្នុងខេត្តសាមុត ប្រាកាន។ យោងតាមកាសែតបាងកកប៉ុស្តិ៍ នៅថ្ងៃទី៣០ខែសីហាម្សិលមិញ អគ្គស្នងការនគរបាលជាតិថៃ លោកនាយឧត្តមសេនីយ៍ សុរៈចេត ហាក់ផាន ឬមានរហ័សនាមថា Big Joke នឹងចុះមកកម្ពុជាដោយផ្ទាល់នៅថ្ងៃព្រហស្បត្តិ៍នេះ ដើម្បីសហការជាមួយអាជ្ញាធរកម្ពុជា ក្នុងបេសកកម្ម តាមបង្ក្រាប មេក្លោងឆបោកជនជាតិចិន ក្នុងក្រុងប៉ោយប៉ែត ដែលជាប់ពាក់ព័ន្ធនឹងឃាតកម្មសម្លាប់ជនជាតិថៃមួយគ្រួសារក្នុងខេត្ត សាមុត ប្រាកាន។

ឃាតកម្មដ៏សោកសៅ បានកើតឡើងកាលពីថ្ងៃច័ន្ទ បង្កឡើងបុរសជាប្តីមានឈ្មោះសានីត ដកម៉ែ វ័យ៤១ឆ្នាំ ដែលបានសម្លាប់ប្រពន្ធនិងកូនប្រុសៗរបស់ពួកគេទាំង២នាក់។ ឃាតករដែលជាប្តីក៏បានព្យាយាមធ្វើអត្តឃាត តែមិនបានជោគជ័យឡើយ និងកំពុងតែសម្រាកព្យាបាលនៅឯមន្ទីរពេទ្យ។

យោងតាមប៉ូលីសថៃ កាលដើមឡើយ ជនបង្កគឺជាអ្នកជានាកម្ចីរបស់មិត្តគាត់ម្នាក់ចំនួន ៤០ម៉ឺនបាត ឬស្មើប្រមាណ១១២០០ដុល្លារ។ ក្រោយមក មិត្តរបស់គាត់ក៏បានរត់គេចខ្លួន ហើយដែលធ្វើលោកសានីត ត្រូវរ៉ាប់រងសងបំណុលមួយនេះ។ ដោយចង់ជួយសម្រាលបំណុលរបស់ប្តី អ្នកស្រីវីផាផន រ៉ាធាដែលជាភរិយាបានទៅស្វែងរកកម្ចីអនឡាញ រួចបានចាញ់អស់ប្រាក់ប្រមាណ១លាន៧សែនបាត ឬស្មើនឹងប្រមាណ៤៨០០០ដុល្លារថែមទៀត។ នៅចំពោះមុខនៃបំណុលវ័ន្តករនេះ ទើបជំរុញឲ្យមានឃាតកម្មសម្លាប់គ្រួសារនេះកើតឡើង ដែលអង្រួនឲ្យមានការចាប់អារម្មណ៍ពីសាធារណជន ស្តីពីឥទ្ធិពលដ៏គួរឲ្យបារម្ភនៃអំពើឆបោកតាមប្រព័ន្ធអនឡាញ។

ដោយឡែក មេក្លោងឆបោកជនជាតិចិន ដែលអាជ្ញាធរខ្មែរនិងថៃតាមចាប់នេះ គឺជាជនសង្ស័យដឹកនាំ មនុស្សយ៉ាងតិច១១នាក់ មានជនជាតិថៃចំនួន៩នាក់ ជនជាតិខ្មែរ២នាក់ រួមសហការឆបោកប្រាក់ ពីជនរងគ្រោះដែលជាប្រពន្ធនេះ។

គួរជម្រាបថា ក្នុងឆ្នាំ២០២២ ប៉ូលីសថៃថា ខ្លួនបានទទួលសេចក្តីរាយការណ៍ ពីករណីចាញ់បោកប្រាក់តាមប្រព័ន្ធអនឡាញសរុបជាង២០ម៉ឺនករណី ស្មើនឹងទឹកប្រាក់ប្រមាណ៣០ពាន់លានបាត ឬ៨៥៥លានដុល្លារ។ អំពើឆបោកតាមប្រព័ន្ធអនឡាញ គឺជាបញ្ហាធំមួយ ដែលកំពុងរីកឡើងក្នុងតំបន់អាស៊ីអាគ្នេយ៍ ដោយបើយោងតាមរបាយការណ៍របស់អង្គការសហប្រជាជាតិ មនុស្សយ៉ាងតិច១២ម៉ឺននាក់ ក្នុងប្រទេសភូមា អាចត្រូវបានគេបង្ខំឲ្យធ្វើការឆបោក ខណៈទន្ទឹមគ្នានេះ មនុស្សប្រមាណ១០ម៉ឺននាក់ អាចត្រូវបានគេធ្វើការឆបោកដោយបង្ខំដូចគ្នា ក្នុងប្រទេសកម្ពុជា។ ដោយឡែក ប្រទេសផ្សេងៗទៀតនៅក្នុងតំបន់ ដូចជា ឡាវ ហ្វីលីពីន និងថៃ ជារឿយៗក៏ត្រូវបានគេកំណត់ជាទិសដៅដែលជនល្មើសប្រើសម្រាប់ធ្វើការឆបោក ឬជាច្រកចេញចូលផងដែរ។

## អ.ស.ប រកឃើញថា
## មនុស្សប្រមាណ ១សែននាក់ត្រូវបានបង្ខំឱ្យធ្វើការបោកប្រាស់តាមអនឡាញនៅកម្ពុជា

https://www.rfa.org/khmer/news/human-rights/un-report-about-100k-people-forced-into-online-fraud-in-cambodia-08312023092834.html ដោយ សេក បណ្ឌិត2023.08.31

អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស ចេញផ្សាយរបាយការណ៍ថ្មីមួយរកឃើញថា មានមនុស្សរាប់សែននាក់ត្រូវបានក្រុមឧក្រិដ្ឋជនបង្ខំឱ្យធ្វើការឆោតតាមប្រព័ន្ធអ៊ីនធឺណិតនៅតំបន់អាស៊ីអាគ្នេយ៍ ក្នុងនោះនៅកម្ពុជាផងដែរ។ មន្ត្រីសង្គមស៊ីវិល និងមន្ត្រីបក្សប្រឆាំងលើកឡើងថា រឿងនេះជាហានិភ័យមួយសម្រាប់កម្ពុជាដែលរដ្ឋាភិបាលគួរតែដោះស្រាយជាបន្ទាន់។

រូបភាពនៃការបោកប្រាស់ទាំងនោះរួមមាន តាមរយៈស្នេហា ការវិនិយោគ និងការក្លែងបន្លំតាមរយៈការលេងល្បែងខុសច្បាប់ជាដើម។ របាយការណ៍របស់អង្គការសហប្រជាជាតិផ្នែកសិទ្ធិមនុស្សចុះផ្សាយ កាលពីថ្ងៃទី២៩ សីហា **ឱ្យដឹងថា** ជនរងគ្រោះប្រឈមមុខនឹងការរំលោភបំពានធ្ងន់ធ្ងរជាច្រើន រួមទាំងការគំរាមកំហែងដល់សុវត្ថិភាព និងសន្តិសុខ ហើយមនុស្សជាច្រើនបានទទួលរងការធ្វើទារុណកម្ម និងប្រព្រឹត្តិដោយឃោរឃៅ អមនុស្សធម៌ និងថោកទាប ការឃុំខ្លួនដោយបំពាន អំពើហិង្សាផ្លូវភេទ ពលកម្មដោយបង្ខំ និងការរំលោភសិទ្ធិមនុស្សផ្សេងៗទៀត។ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស លោក វ៉ុលគើ ទើក (Volker Türk) ឱ្យដឹងនៅក្នុងរបាយការណ៍ថា អ្នកដែលត្រូវបានគេបង្ខិតបង្ខំឱ្យធ្វើការក្នុងប្រតិបត្តិការបោកប្រាស់ទាំងនោះ ស៊ូទ្រាំនឹងការប្រព្រឹត្តដោយអមនុស្សធម៌ ខណៈដែលពួកគេត្រូវបានគេបង្ខំឱ្យប្រព្រឹត្តបទឧក្រិដ្ឋ។

អ្នកនាំពាក្យការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំទីក្រុងហ្សឺណែវ (Geneva) ប្រទេសស្វីស (Switzerland) លោក ជេរីមី ឡូរែនស៍ (Jeremy Laurence) ថ្លែងក្នុងសន្និសីទសារព័ត៌មានកាលពីថ្ងៃទី២៩ ខែសីហា ថា នៅភូមា និងនៅកម្ពុជា មានជនរងគ្រោះមិនតិចជាង ១សែននាក់ឡើយក្នុងប្រទេសនីមួយៗ។ លោក ជេរីមី ឡូរែនស៍៖ «របាយការណ៍លើកឡើងថា ភាពធំធេងនៃការជួញដូរការបោកប្រាស់តាមអនឡាញនៅអាស៊ីអាគ្នេយ៍គឺពិបាកនឹងប៉ាន់ស្មាន ដោយសារតែលក្ខណៈបែបលាក់កំបាំង និងភាពចន្លោះប្រហោងក្នុងការឆ្លើយតបជាផ្លូវការ។ ប្រភពដែលអាចជឿទុកចិត្តបាន បង្ហាញថា យ៉ាងហោចណាស់មនុស្ស ១សែន២ម៉ឺននាក់ នៅទូទាំងប្រទេសមីយ៉ាន់ម៉ាអាចត្រូវបានឃុំខ្លួនក្នុងស្ថានភាពដែលពួកគេត្រូវបានគេបង្ខំឱ្យអនុវត្តការបោកប្រាស់តាមអនឡាញៗ។ ជាមួយគ្នានេះ ការប៉ាន់ប្រមាណស្រដៀងគ្នានៅក្នុងប្រទេសកម្ពុជាបង្ហាញថា ជនរងគ្រោះមានចំនួនប្រហែល ១សែននាក់»។

ប្រភពដដែលឱ្យដឹងទៀតថា សកម្មភាពទាំងនេះបានជះឥទ្ធិពលខ្លាំងក្នុងអំឡុងការរាតត្បាតជំងឺកូវីដ១៩ ដែលពេលនោះមានវិធានការសុខភាពសាធារណៈបានបិទកាស៊ីណូនៅក្នុងប្រទេសជា

ច្រើន ហើយជាការឆ្លើយតប ប្រតិបត្តិករកាស៊ីណូបានផ្លាស់ប្តូរប្រតិបត្តិការទៅកាន់កន្លែងដែលមិនសូវមានការគ្រប់គ្រង រួមទាំងតំបន់ព្រំដែនដែលរងផលប៉ះពាល់ដោយជម្លោះ និងតំបន់សេដ្ឋកិច្ចពិសេស ។

របាយការណ៍រកឃើញទៀតថា ឧក្រិដ្ឋជនបានកំណត់គោលដៅចំពោះជនចំណាកស្រុកក្នុងស្ថានភាពងាយរងគ្រោះ ដែលបានជាប់គាំងនៅក្នុងប្រទេសទាំងនោះ និងគ្មានការងារធ្វើដោយសារតែការបិទព្រំដែន និងការបិទអាជីវកម្ម ដែលធ្វើឱ្យក្រុមឧក្រិដ្ឋជនងាយស្រួលប្រតិបត្តិការឧក្រិដ្ឋកម្មក្រោមរូបភាពការក្លែងបន្លំផ្តល់ការងារពិតដល់ពួកគេ។ របាយការណ៍បន្ថែមថា ក្រុមឧក្រិដ្ឋជនឆបោកនេះអាចរកចំណូលរាប់ពាន់លានដុល្លារក្នុងមួយឆ្នាំៗ។

ប្រធានអង្គការសម្ព័ន្ធគណនេយ្យភាពសង្គមកម្ពុជា លោក សន ជ័យ មានប្រសាសន៍ថា របាយការណ៍នេះឆ្លុះបញ្ចាំងការពិត និងជាហានិភ័យដ៏ធំធេង ដែលរដ្ឋាភិបាលគួរតែដោះស្រាយជាបន្ទាន់។ លោក សន ជ័យ៖ «យើងចង់ឃើញវិធានការបន្ទាន់ហើយមានប្រសិទ្ធភាព ដើម្បីឆ្លើយតបធ្វើយ៉ាងណាយកចាប់ជនល្មើសមកផ្តន្ទាទោសតាមច្បាប់នេះជាវិធានការសម្រាប់ការបង្ក្រាប។ រីឯវិធានការបង្ការវិញយើងចង់ឱ្យមានការត្រួតពិនិត្យការចេញចូល ការស្នាក់នៅរបស់ជនបរទេស។ ឧទាហរណ៍ថា ជនបង្កនឹងភាគច្រើនជាជនជាតិចិនគឺត្រូវមានប្រព័ន្ធគ្រប់គ្រងរដ្ឋបាលមួយទៅលើការរស់នៅរបស់ជនជាតិចិននៅកម្ពុជាឱ្យបានហ្មត់ចត់»។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងអ្នកនាំពាក្យអគ្គស្នងការនគរបាលជាតិ លោក ឆាយ គឹមខឿន និងប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាល លោក ប៉ែន ប៊ុណ្ណា ដើម្បីសុំអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេនៅថ្ងៃទី៣១ សីហា។

ប៉ុន្តែរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង បានប្រាប់សារព័ត៌មានក្នុងស្រុកថា ការលើកឡើងរបស់អង្គការសហប្រជាជាតិនេះ មិនឆ្លុះបញ្ចាំងការពិតនោះទេ ហើយអ្នកស្រីថា រឿងនេះជាការធ្វើឱ្យកម្ពុជាបាក់មុខមាត់នៅលើអន្តរជាតិ។ ទោះបីជាយ៉ាងណា កន្លងទៅអតីតរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង ធ្លាប់ទទួលស្គាល់ថា កម្ពុជាជាកន្លែងរងគ្រោះនៃបទល្មើសឆបោកតាមប្រព័ន្ធអ៊ីនធឺណិត ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ លោកបន្ថែមថា បទល្មើសឆបោកតាមប្រព័ន្ធទូរគមនាគមន៍ដែលកើតនៅកម្ពុជា គឺពុំមែនជនជាតិខ្មែរជាអ្នកប្រព្រឹត្តនោះទេ។ ផ្ទុយទៅវិញ អ្នកប្រព្រឹត្តនិងមេខ្យល់ គឺជាជនបរទេសដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា។ ទោះយ៉ាងណា លោក ស ខេង ថា នេះជាក្តីបារម្ភមួយដែលអាជ្ញាធរត្រូវដោះស្រាយឱ្យបានហ្មត់ចត់។

របាយការណ៍បន្តថា មនុស្សភាគច្រើនដែលត្រូវបានជួញដូរក្នុងប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិតគឺជាបុរស ហើយបើទោះបីជាស្ត្រី និងក្មេងជំទង់ក៏ស្ថិតក្នុងចំណោមជនរងគ្រោះដែរ ហើយជនរងគ្រោះភាគច្រើនមានចំណេះដឹង ដោយចេះកុំព្យូទ័រ និងភាសាបរទេស។ ប្រភពដដែលថា ជនរងគ្រោះភាគច្រើនមកពីទូទាំងតំបន់អាស៊ាន រួមមានប្រទេសឥណ្ឌូណេស៊ី(Indonesia) ឡាវ ម៉ាឡេស៊ី(Malaysia) មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី (Singapore) ថៃ និងវៀតណាម(Vietnamese)។ក្រៅពីនេះក៏ប្រទេសចិនដីគោក(Chinese) ហុងកុង (Hong Kong) និងតៃវ៉ាន់ (Taiwan) អាស៊ីខាងត្បូង ជាដើម។

ជុំវិញរឿងនេះមន្ត្រីជាន់ខ្ពស់គណបក្សសង្គ្រោះជាតិ លោក អ៊ុំ សំអាន យល់ឃើញថា ការដែលមានមនុស្សរាប់ម៉ឺននាក់ ត្រូវបានឧក្រិដ្ឋជនបង្ខំឱ្យធ្វើការឆបោកតាមប្រព័ន្ធអ៊ីនធឺណិត នៅកម្ពុជានេះដោយសារការប្រព្រឹត្តអំពើពុករលួយជាប្រព័ន្ធរបស់អាជ្ញាធរខ្មែរ។ លោក អ៊ុំ សំអាន៖ « ព្រោះខ្ញុំយល់ថាប្រាកដជាមានមន្ត្រីធំមួយចំនួនពាក់ព័ន្ធក្នុងរឿងនឹងបានអត់ហ៊ានចាត់ការកន្លងមក។ ដូច្នេះត្រូវហ៊ានអាសាច់ចោល ទោះបីអ្នកនឹងកូនអ្នកធំខ្សែអ្នកធំមន្ត្រីធំប៉ុនណាក៏ដោយ ត្រូវតែចាត់វិធានការ។ហើយតុលាការនឹងឯកពជ្យទៅប្រាកដជាអាចចាត់វិធានការនឹងបាន ជាពិសេសគឺបំបាត់នូវបក្ខពួកនិយមគ្រួសារនិយមហើយនឹងអំពើពុករលួយនឹងជារឿងសំខាន់»។

របាយការណ៍ថា បញ្ហាទាំងនេះកើតឡើងដោយសារ ការអនុវត្តមិនមានស្តង់ដារអន្តរជាតិ ដែលធ្វើឱ្យមិនឆ្លើយតបឱ្យបានគ្រប់បរិបទ។ ជនរងគ្រោះនៃការជួញដូរ និងការរំលោភបំពានសិទ្ធិមនុស្សផ្សេងទៀតត្រូវបានកំណត់អត្តសញ្ញាណដោយខុសឆ្គងថា ជាឧក្រិដ្ឋជន ឬជាជនល្មើសអន្តោប្រវេសន៍ ជាជាងត្រូវបានការពារ និងផ្តល់សិទ្ធិក្នុងដំណើរការស្តារនីតិសម្បទា និងសំណងដែលពួកគេត្រូវការ ពួកគេត្រូវបានទទួលរងនូវការកាត់ទោសព្រហ្មទណ្ឌ ឬការពិន័យអន្តោប្រវេសន៍។

មន្ត្រីអង្គការសហប្រជាជាតិឱ្យដឹងថា ដើម្បីដោះស្រាយបញ្ហានេះប្រទេសដែលរងផលប៉ះពាល់ទាំងអស់ត្រូវមានឆន្ទៈនយោបាយដើម្បីពង្រឹងសិទ្ធិមនុស្ស និងកែលំអអភិបាលកិច្ច និងនីតិរដ្ឋ រួមទាំងការដោះស្រាយអំពើពុករលួយ៕

# ថ្ងៃទី០៥ ខែ កញ្ញា ឆ្នាំ២០២៣

## កម្ពុជាច្រានចោលរបាយការណ៍របស់ UN ដែលថាមនុស្ស១០ម៉ឺននាក់ស្ថិតក្នុងការឆបោកតាមអនឡាញ

https://khmer.voanews.com/a/cambodia-rejects-the-un-report-that-found-100-000-people-are-involved-in-online-fraud/7250385.html ០១ កញ្ញា ២០២៣

ភ្នំពេញ៖ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ ច្រានចោលរបាយការណ៍របស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNHCHR) ដែលរកឃើញថា មនុស្សប្រមាណជា ១០ ម៉ឺននាក់ ត្រូវបានបង្ខំឱ្យធ្វើការឆបោកតាមប្រព័ន្ធអនឡាញនៅក្នុងប្រទេសកម្ពុជា។

របាយការណ៍របស់អង្គការសហប្រជាជាតិ ដែលចេញកាលពីថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០២៣ រកឃើញមានករណីឆបោកតាមអនឡាញនេះក្នុងប្រទេសចំនួន ៥ នៅតំបន់អាស៊ីអាគ្នេយ៍។ ក្នុងនោះ ប្រទេសមីយ៉ាន់ម៉ាមានចំនួនច្រើនជាងគេ ប្រមាណជា ១២ ម៉ឺននាក់។ ចំណែកនៅកម្ពុជាត្រូវបានរកឃើញថាមានប្រមាណជា ១០ ម៉ឺននាក់។ របាយការណ៍ដែលមានកម្រាស់ ៣៨ ទំព័រនោះបន្ថែមថា ករណីជនរងគ្រោះ នៃការឆបោកតាមប្រព័ន្ធអនឡាញបានប្រឈមនឹងការគំរាមកំហែង និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ដោយពួកគេទទួលរងការធ្វើទារុណកម្មយ៉ាងឃោរឃៅ អមនុស្សធម៌ និងថោកទាប ការឃុំខ្លួនដោយបំពាន អំពើហិង្សាផ្លូវភេទ ពលកម្មដោយបង្ខំ និងការរំលោភសិទ្ធិមនុស្សផ្សេងៗទៀត។

អ្នកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រាប់វីអូអេនាថ្ងៃសុក្រនេះថា របាយការណ៍របស់អង្គការសហប្រជាជាតិ គឺធ្វើឡើងតាមការប៉ាន់ស្មាន ដោយមិនបានបង្ហាញពីទឡ្ហីករណ៍ណាមួយច្បាស់លាស់នោះទេ។ អ្នកស្រីថ្លែងថា៖ «ហើយយើងដឹងស្រាប់ហើយថា កម្ពុជាមិនធំទេ ហើយចំពោះអាជីវកម្ម ទាំងទីតាំងនៅតាមបណ្តាខេត្តនានាក៏មិនច្រើនដែរ អ៊ីចឹងចំនួនដែលយើងគ្រាន់តែអ្នកដែលសង្ស័យថាជាប់នៅក្នុងនោះវា ១០ ម៉ឺននាក់ទៅហើយ អ៊ីចឹងយើងសួរថា មនុស្សហ្នឹងនៅឯណា?» អ្នកស្រីបន្តថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបើកការរុករកមនុស្សតាមរយៈសំណើផ្សេងៗមកកាន់ក្រសួងមហាផ្ទៃ ហើយសំណើ ដែលទទួលបានមានចំនួន ១០៤៧ ដែលគិតជាចំនួនមនុស្សមានប្រមាណ ២.៥០០ នាក់ប៉ុណ្ណោះ។ អ្នកស្រីប្រាប់វីអូអេបន្ថែមថា ស្ថិតក្នុងចំណោមសំណើទាំងអស់នោះមាន ១.០១១ សំណើ ដែលបានការ ហើយមនុស្សដែលត្រូវបានរកឃើញមានចំនួន ១.៥៦៩នាក់ និងមាន ១៤ សញ្ជាតិផ្សេងគ្នា។

អ្នកស្រី ជូ ប៊ុនអេង បន្ថែមថា កម្ពុជាកំពុងតែរៀបចំស៊ើបអង្កេតជាមួយក្រុមជំនាញ ហើយបញ្ជូនរបាយការណ៍ទាំងនោះទៅអង្គការសហប្រជាជាតិវិញ។ អ្នកស្រីថ្លែងថា៖ «យើងកំពុងតែរៀបចំកិច្ចប្រជុំជាមួយនឹងជំនាញដែលគាត់ចុះប្រតិបត្តិការផ្ទាល់ ដើម្បីរកទឡ្ហីករណ៍ឱ្យច្បាស់ ពីព្រោះយើងនិយាយអំពីទិន្នន័យដែលជាក់លាក់ ដើម្បីឱ្យមានការឆ្លើយឆ្លង...គ្រាន់តែថាយើងបដិសេធមិនទទួលស្គាល់ ប៉ុន្តែសួរថា យកអីមកសំអាង? អ៊ីចឹងដោយសារតែប្រតិបត្តិការយើងចុះជាក់ស្តែង គឺយើងនឹងធ្វើជារបាយការណ៍ដើម្បីដាក់បញ្ជូនទៅវិញ ជូនទៅអង្គការសហប្រជាជាតិ»។

របាយការណ៍ដដែលបន្ថែមថា ក្នុងអំឡុងមានវិបត្តិជំងឺរាតត្បាតកូវីដ១៩ មនុស្សភាគច្រើនបានចំណាយពេលវេលាលើប្រព័ន្ធអនឡាញ ហើយការឆបោកនានាបានប្រព្រឹត្ត និងកើតមានឡើងអំឡុងពេលនោះ។ ជនរងគ្រោះនៃការឆបោកតាមប្រព័ន្ធអនឡាញភាគច្រើនជាជនដែលចំណាកស្រុក ហើយត្រូវបានឧក្រិដ្ឋជនបន្លំតាមរយៈការជ្រើសរើសបុគ្គលិកធ្វើការតាមអ៊ីនធឺណិតជាដើម។ របាយការណ៍របស់អង្គការសហប្រជាជាតិដដែលបានបន្ថែមថា មនុស្សភាគច្រើនដែលត្រូវបានជួញដូរក្នុងប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិតគឺជាបុរស ទោះបីជាស្ត្រី និងក្មេងជំទង់ក៏ស្ថិតក្នុងចំណោមជនរងគ្រោះដែរ ដោយភាគច្រើនជនរងគ្រោះនៃការឆបោកអនឡាញនេះមិនមែនជាប្រជាជនក្នុងប្រទេសនោះឡើយ។ ជនរងគ្រោះទាំងនោះជាច្រើនមានការអប់រំល្អ មានជំនាញការងារវិជ្ជាជីវៈត្រឹមត្រូវ ឬបញ្ចប់ការសិក្សា ឬបញ្ចប់បរិញ្ញាបត្រ ចេះប្រើប្រាស់កុំព្យូទ័រ និងចេះនិយាយច្រើនភាសា។

ជនរងគ្រោះទាំងនោះមកពីទូទាំងតំបន់អាស៊ីអាគ្នេយ៍ (ពីប្រទេសឥណ្ឌូណេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម) ក៏ដូចជាប្រទេសចិនដីគោក ហុងកុង និងតៃវ៉ាន់ អាស៊ីខាងត្បូង និងសូម្បីតែនៅឆ្ងាយរួមមានអាហ្វ្រិក និងអាមេរិកឡាទីន។ ក្រោយវត្តមាននៃជនជាតិចិនហូរចូលមកក្នុងប្រទេសកម្ពុជាយ៉ាងគំហុក ជាពិសេសក្នុងខេត្តព្រះសីហនុ គេឃើញមានការរាយការណ៍អំពីករណីបង្ខាំងមនុស្ស និងការឆបោកតាមអនឡាញកើតមានឡើងជាញឹកញាប់។ ថ្មីៗនេះវីដេអូឃ្លីបដែលបង្ហាញថា ជនបរទេសត្រូវបានធ្វើទារុណកម្មពីសំណាក់ជនបរទេសដូចគ្នាក្នុងករណីបង្ខំឱ្យប្រព្រឹត្តសកម្មភាពឆបោកតាមអនឡាញ ត្រូវបានចែកចាយជាញឹកញាប់ និងមានការអះអាងថា ជារូបភាពដែលកើតឡើងក្នុងប្រទេសកម្ពុជា។

នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការការពារសិទ្ធិមនុស្សលីកាដូ លោក អំ សំអាត លើកឡើងថា របាយការណ៍របស់អង្គការសហប្រជាជាតិធ្វើឡើងដោយមានទឡ្ហីកណ៍ និងការសិក្សាច្បាស់លាស់ ហើយថា ការបង្ហាញក្នុងរបាយការណ៍នេះបានធ្វើឱ្យទិដ្ឋភាពរបស់ប្រទេសកម្ពុជាស្ថិតក្នុងរូបភាពមិនសូវល្អ។ លោកបន្តថា ការឆបោកតាមប្រព័ន្ធអនឡាញជាបទល្មើសថ្មីមួយសម្រាប់

ប្រទេសកម្ពុជា ហើយអាជ្ញាធរគួរតែយកចិត្តទុកដាក់ឱ្យបានខ្ពស់លើបញ្ហានេះ។ លោកថ្លែងថា៖ «ការឆបោកតាមប្រព័ន្ធនេះជាបទល្មើសមួយថ្មីដែលអាជ្ញាធរកម្ពុជា ឬក៏សមត្ថកិច្ចពាក់ព័ន្ធហ្នឹងត្រូវតែទទួលបាននូវការបណ្តុះបណ្តាលបន្ថែមទៀត ដើម្បីតាមទាន់នៃបទល្មើស ហើយមើលឃើញថា អ្វីជាបទល្មើស ព្រោះកាលណាប្រសិនបើយើងគ្មានជំនាញបន្ថែមសម្រាប់ពិនិត្យមើលថា ហ្នឹងជាបទល្មើសទេ បទល្មើសហ្នឹងនៅតែបន្តកើតអញ្ចឹង»។

របាយការណ៍របស់ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានផ្តល់អនុសាសន៍មួយចំនួនទៅកាន់ប្រទេសក្នុងតំបន់អាស៊ានដូចជា៖

- ការផ្តល់សច្ចាប័ន និងអនុវត្តប្រកបដោយប្រសិទ្ធភាពនូវរាល់សិទ្ធិមនុស្សអន្តរជាតិជាស្នូល ព្រមទាំងសន្ធិសញ្ញាអន្តរជាតិ និងតំបន់ផ្សេងទៀតដែលពាក់ព័ន្ធនឹងការការពារជនរងគ្រោះនៃការជួញដូរ និងជនចំណាកស្រុកផ្សេងទៀតក្នុងស្ថានភាពងាយរងគ្រោះ និងចូលរួមជាមួយយន្តការសិទ្ធិមនុស្សអន្តរជាតិពាក់ព័ន្ធ ដូចជាអ្នករាយការណ៍ពិសេសស្តីពីមនុស្សសិទ្ធិជនចំណាកស្រុក និងលើការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ។
- ពិនិត្យឡើងវិញជាចាំបាច់នូវច្បាប់ប្រឆាំងការជួញដូរ គោលនយោបាយ ឬវិធានការផ្សេងទៀត ហើយតម្រឹមធនធានឡើងវិញ ដើម្បីគិតគូរពីការណ៍ពិតដែលបានផ្លាស់ប្តូរប្រទេសជាគោលដៅមួយនៃគោលដៅរបស់មនុស្សដែលត្រូវបានជួញដូរ និងជនចំណាកស្រុកផ្សេងទៀតនៅក្នុងស្ថានភាពងាយរងគ្រោះ។
- អនុវត្តដោយត្រឹមត្រូវក្នុងការកំណត់អត្តសញ្ញាណ និងលុបបំបាត់ការពាក់ព័ន្ធក្នុងវិស័យសាធារណៈ ឬភាពស្មុគស្មាញក្នុងការជួញដូរមនុស្ស និងការទប់ស្កាត់ និងកាត់បន្ថយអំពើពុករលួយ និងការសូកប៉ាន់តាមគ្រប់រូបភាព។ មន្ត្រីសាធារណៈទាំងអស់ដែលសង្ស័យថា ជាប់ពាក់ព័ន្ធក្នុងការជួញដូរ ឬប្រព្រឹត្តអំពើពុករលួយដែលជួយសម្រួលដល់ការជួញដូរគួរតែត្រូវបានស៊ើបអង្កេត និងកាត់ទោសស្របតាមដំណើរការត្រឹមត្រូវ និងស្តង់ដារកាត់ក្តីដោយយុត្តិធម៌។
- ព្រមទាំងអនុវត្តការការពារសិទ្ធិមនុស្សនៅក្នុងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត និងការគ្រប់គ្រងអ៊ីនធឺណិតនៅកម្រិតជាតិ តំបន់ និងពិភពលោក៕

# មន្ត្រីជំនាញអំពាវនាវឱ្យពលរដ្ឋចៀសវាងការធ្វើចំណាកស្រុកដោយខុសច្បាប់ អាចប្រឈមការជួញដូរកម្លាំងពលកម្ម និងជួញដូរមនុស្ស

https://www.postkhmer.com/national/2023-09-02-1259-254140.html គីម យុត្តារ៉ូ | Publication date 02 September 2023 | 12:59 ICT

មន្ត្រីជំនាញដែលធ្វើការពាក់ព័ន្ធការជួញដូរមនុស្ស បានអំពាវនាវដល់ប្រជាពលរដ្ឋចៀសវាងធ្វើចំណាកស្រុកដោយខុសច្បាប់ ឬប្រថុយប្រថាន ដែលអាចធ្លាក់ចូលក្នុងស្ថានភាពនៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ខណៈណែនាំពលរដ្ឋត្រូវតាមដានព័ត៌មានឱ្យបានច្បាស់លាស់មុនធ្វើការសម្រេចចំណាកស្រុកខុសច្បាប់។

លោកស្រី ឈឹម វណ្ណនី ស្នងការរងនគរបាលខេត្តកណ្ដាល និងជាអនុប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) បានអំពាវនាវបែបនេះនៅក្នុងវេទិកាផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ជូនដល់ប្រជាពលរដ្ឋ និងសិស្សានុសិស្សជាង ៣០០នាក់ រស់នៅឃុំប្រាសាទ ស្រុកស្អាង កាលពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ ២០២៣។

លោកស្រីបានថ្លែងថា គោលបំណង នៃការបើកវេទិកានេះឡើង គឺដើម្បីឱ្យប្រជាពលរដ្ឋបានយល់កាន់តែច្បាស់អំពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន តាមការឃោសនារបស់មេខ្យល់អូសទាញនិងដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្សតាមគ្រប់រូបភាព។ នេះបើតាមមន្ទីរព័ត៌មានខេត្តសៀមរាប។

ក្នុងវេទិកានេះ លោកស្រីបានធ្វើការផ្សព្វផ្សាយខ្លឹមសារ និងមាត្រាសំខាន់ៗដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តរបស់ជនល្មើស ទោសទណ្ឌដែលត្រូវទទួល តាមច្បាប់បានកំណត់ និងជាតុផ្សំដែលនាំឱ្យមានកើតបទល្មើស។ ជាមួយគ្នានេះលោកស្រីបានអំពាវនាវថា៖«សូមអ្នកចូលរួមទាំងអស់ ត្រូវខិតខំត្រងត្រាប់ស្ដាប់ ដើម្បីផ្សព្វផ្សាយបន្តទុកជាមេរៀន បទពិសោធន៍ សម្រាប់អប់រំកូនចៅ កុំឱ្យធ្លាក់ក្នុងការលួងលោម បោកបញ្ឆោត ឬជឿតាមការសន្យារបស់ជនខិលខូចមួយចំនួន ដែលជាដើមហេតុធ្វើឱ្យងាយធ្លាក់ទៅក្នុងស្ថានភាពនៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម»។

លោកស្រី ក៏បានណែនាំដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យយល់ពីផលប៉ះពាល់ ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ ចំពោះមេខ្យល់តាមគ្រប់រូបភាព ត្រូវរាយការណ៍បន្ទាន់ទៅក្រុមការងារថ្នាក់ស្រុក ឃុំ ភូមិ ប៉ុស្តិ៍ ដែលនៅជិត ចំពោះករណីសង្ស័យ មាន

ជនណាមកឃោសនា និងត្រូវចូលរួមសាមគ្គីសហការគ្នាជួយគ្នាទៅវិញទៅមកដោយមិនមានការរើសអើង។

យោងតាមរបាយការណ៍ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ និងទិសដៅអនុវត្តបន្តឆ្នាំ២០២៣ មិនត្រឹមតែប្រជាជនកម្ពុជាទេ តែប្រជាជនដទៃទៀតក្នុងតំបន់រហូតដល់បណ្តាប្រទេសធំៗក្នុងពិភពលោក ក៏ធ្លាក់ក្នុងភាពរងគ្រោះដោយកលល្បិចឧក្រិដ្ឋជន។ ក្នុងរបាយការណ៍ដដែលបញ្ជាក់ថា បញ្ហាជួញដូរមនុស្ស បានក្លាយជាវិបត្តិសកល ដែលស្ទើរតែគ្រប់ប្រទេសក្នុងសកលលោកកំពុងប្រឈម ដោះស្រាយ និងកាន់តែស្មុគស្មាញខ្លាំងឡើង៕

## អង្គការILO៖ កម្ពុជាមានអត្រានៃអ្នកមានការងារធ្វើ ៩៩.៥ ភាគរយ

https://www.information.gov.kh/articles/112402 AKP ភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៣

អង្គការអន្តរជាតិខាងការងារ ILO បានបង្ហាញលើវេបសាយផ្លូវការរបស់ខ្លួនថា កម្ពុជាជាប្រទេសដែលមានអត្រាអត់ការងារធ្វើតិចបំផុតត្រឹម ០.៥ភាគរយ ដែលមានន័យថា អ្នកមានការងារធ្វើមានរហូតដល់ ៩៩.៥ភាគរយ ដែលឈរនៅលំដាប់ទី២ បន្ទាប់ពីប្រទេសកាតា (០,១%) ដែលមានអត្រាអ្នកអត់ការងារទាបជាងគេ ក្នុងចំណោម១៨៥ប្រទេស។ តាមរយៈរបាយការណ៍ដែលអង្គការអន្តរជាតិខាងការងារ ILO បានរកឃើញនេះ គឺធ្វើឡើងនៅក្នុងឆ្នាំ២០១៩ ដោយអង្គការ ILO បានគូសបញ្ជាក់ថា ប្រទេសដែលមានអត្រាការងារធ្វើខ្ពស់ផ្សេងៗទៀត រួមមាន៖ កាតា, ម៉ូលឌូវ៉ា, ម៉ាឡាវី, ប៊ូរុនឌី, ឆាដ, ថៃ, អាល្លឺម៉ង់ ជាដើមសុទ្ធតែជាប្រទេសដែលមានអត្រាអត់ការងារធ្វើតិចតួច។

បើតាមនិយមន័យក្នុងការកំណត់អត្រាអ្នកអត់ការងារធ្វើ ឬភាពមានការងារធ្វើសម្រាប់ប្រទេសកម្ពុជា គឺមិនខុសពីបណ្តាប្រទេសនានានៅលើពិភពលោក រួមបញ្ចូលទាំងប្រទេសជប៉ុនសហរដ្ឋអាម៉េរិក ឡាវ វៀតណាម ជាដើម ដោយប្រើប្រាស់នូវនិយមតែមួយរបស់អង្គការអន្តរជាតិខាងការងារ (ILO) ដែលបានកំណត់ថា អ្នកមានការងារធ្វើគឺសំដៅលើបុគ្គលទាំងឡាយណាដែលស្ថិតនៅក្នុងវ័យធ្វើការ ដែលក្នុងរយៈពេលកំណត់ណាមួយ (មួយអាទិត្យ ឬ៧ថ្ងៃចុងក្រោយ) បានចូលរួមទៅក្នុងសកម្មភាពនានាក្នុងការផលិតផលិតផល ឬផ្តល់សេវាកម្ម ដើម្បីទទួលបានប្រាក់ខែ ឬការបង្កើតជាប្រាក់ចំណេញ ដែលក្នុងនោះរួមបញ្ចូលទាំងអ្នកដែលមានវត្តមាននៅកន្លែងធ្វើការ និងអ្នកដែលអវត្តមាននៅកន្លែងធ្វើការដោយសារ តែការឈប់សម្រាកដោយសារមានជំងឺ ជាប់រវល់ធ្វើការសិក្សា ឬកត្តាផ្សេងៗ។

ដោយឡែក អ្នកគ្មានការងារធ្វើសំដៅលើ គឺសំដៅលើបុគ្គលទាំងឡាយណាដែលស្ថិតនៅក្នុងវ័យធ្វើការ ដែល ១. មិនមានការងារ ២. កំពុងស្វែងរកការងារ និង ៣. អាចទទួលយកឱកាសការងារ

ប្រសិនបើមាន។ ដោយផ្អែកលើនិយមន័យនេះ តាមសង្កេតឃើញថា ប្រទេសនៅលើពិភពលោកបានទទួលជំនួយបច្ចេកទេសពីអង្គការអន្តរជាតិខាងការងារ ក្នុងបានប្រមូលនិងផលិតនូវទិន្នន័យទាក់ទងនឹងអ្នកមានការងារធ្វើ និងអ្នកគ្មានការងារធ្វើ។ យោងតាមប្រភពទិន្នន័យរបស់អង្គការ ILO បានបង្ហាញថា ចាប់តាំងពីឆ្នាំ១៩៩១ ប្រទេសកម្ពុជារក្សាបាននូវអត្រាអ្នកអត់ការងារធ្វើ នៅក្នុងកម្រិតមួយទាបជាង ១ភាគរយ ហើយកម្រិតនៃអត្រាអ្នកអត់ការងារធ្វើនេះគឺទាបជាងគេប្រសិនបើប្រៀបធៀបជាមួយនឹងបណ្តាក្រុមប្រទេស ដែលមានសេដ្ឋកិច្ចប្រហាក់ប្រហែលកម្ពុជា និងទាបជាងបណ្តាប្រទេសនានា នៅក្នុងតំបន់ ដូចជាប្រទេសថៃ វៀតណាម និងឡាវ៕ដោយៈ រិទ្ធី, ប្រភពៈ ILO, សម្រួលផ្សាយៈ កន ចំណាន

## ៨ខែ វៀតណាម បញ្ជូនពលករជិត ១០ម៉ឺននាក់ទៅក្រៅប្រទេស

https://www.kampucheathmey.com/global-news/570481 ថ្ងៃសៅរ៍ ២ កញ្ញា ២០២៣ដោយ Sok Sovann

ក្រសួងការងារ ជនពិការ និងសង្គមកិច្ចរាយការណ៍ថា ប្រទេសវៀតណាម បានបញ្ជូនពលករទៅក្រៅប្រទេសចំនួន ៩៧២៣៤នាក់ ក្នុងរយៈពេល ៨ខែដើមឆ្នាំ២០២៣ ពោលគឺស្មើនឹងជាង ៨៨% នៃគោលដៅឆ្នាំនេះ។ ជប៉ុន នៅតែជាប្រទេសទទួលពលករវៀតណាមច្រើនជាងគេ ពោលគឺចំនួន៤៧២១៥នាក់ បន្ទាប់មកគឺតៃវ៉ាន់ (៤១៦៥៤នាក់), សាធារណរដ្ឋកូរ៉េ (១៩៤៤នាក់) ចិនដីគោក (១១៦៣នាក់) ហុងគ្រី (១០០២នាក់) សិង្ហបុរី (៩៦៤នាក់) និងរ៉ូម៉ានី (៦២៧នាក់)។ ត្រឹមមួយខែសីហា ពលករវៀតណាមជាង ១២០០០នាក់ បានទៅធ្វើការនៅបរទេសក្រោមកិច្ចសន្យា ក្នុងនោះរួមមាន ៦០៧៦នាក់ទៅជប៉ុន, ៤៦៩៨នាក់ទៅតៃវ៉ាន់, ២០០នាក់ទៅហុងគ្រី, ១៦៤នាក់ទៅសិង្ហបុរី, ១៤៥នាក់ទៅកូរ៉េ, ១៣៩នាក់ទៅចិនដីគោក និង៩០នាក់ទៅរ៉ូម៉ានី។

គួរបញ្ជាក់ថា ប្រទេសជប៉ុន នៅតែជាគោលដៅកំពូលរបស់ពលករវៀតណាម ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ ប្រទេសទាំងពីរ បានសម្របសម្រួលគ្នាដើម្បីអនុវត្ត គម្រោងជួយពលករវៀតណាមឲ្យស្វែងរកការងារសមរម្យនៅប្រទេសជប៉ុន និងទទួលបានព័ត៌មានការងារបន្ទាប់ពីត្រលប់មកប្រទេសកំណើតវិញ៕ **ប្រែសម្រួលៈ** Vann Vann **ប្រភពៈ** VN Express

## ប៉ូលិសថៃចាប់ខ្លួនជនជាតិចិន ១៦ នាក់ ពីបទឆបោកតាមទូរស័ព្ទនៅប៉ាតាយ៉ា

https://www.kampucheathmey.com/global-news/570937 ថ្ងៃអាទិត្យ ៣ កញ្ញា ២០២៣ដោយ Boa Sokunveary

កាលពីថ្ងៃទី២ ខែកញ្ញា ប៉ូលិសថៃបានចាប់ខ្លួនជនជាតិចិន ១៦នាក់ ដែលជាជនឆបោកតាមទូរស័ព្ទ ក្នុងផ្ទះ ៤ខ្នង នៅសង្កាត់ Bang Lamung ប៉ែកខាងកើតនៃទីក្រុងប៉ាតាយ៉ា។ កម្លាំងស៊ើបអង្កេតនៃស្នងការដ្ឋាននគរបាលខេត្តឈុនបុរី បានឆែកឆេរផ្ទះទាំង ៤ ខ្នង បន្ទាប់ពីទទួលព័ត៌មានថា មានជនឆបោកតាមទូរស័ព្ទជនជាតិចិន ជួលទីតាំងនោះអស់រយៈពេលជាង ៣ ខែមកហើយ។ ជនសង្ស័យទាំង ១៦នាក់ មានបុរស ១២នាក់ និងស្ត្រី ៤នាក់។ ក្រៅពីជនជាតិចិនទាំង ១៦នាក់ ក៏មានស្ត្រីជនជាតិថៃម្នាក់ផងដែរ ដែលជាអ្នកថៃទាំផ្ទះឲ្យពួកគេ។

ស្ត្រីជនជាតិថៃរូបនោះ បានប្រាប់ប៉ូលិសថា នាងទទួលប្រាក់ឈ្នួល ៧០០០ បាតក្នុងមួយខែ ដើម្បីទិញអាហារ និងសម្អាតផ្ទះឲ្យពួកគេ ហើយមិនសួរដឹងរឿងជនជាតិចិនទាំងនោះទេ។ នាងដឹងត្រឹមថា ពួកគេមានប្រាក់ខែម្នាក់ ៤៨ ៦០០ បាត ប៉ុណ្ណោះ ។

ចំពោះករណីខាងលើ ប៉ូលិសបានរឹបអូសកុំព្យូទ័រ ១ គ្រឿង ទូរស័ព្ទដៃ ១ គ្រឿង ទូដែក ១ និងរថយន្ត Toyota Alphard ថ្មីមួយគ្រឿងទៀតដែលចតចោលក្នុងបរិវេណផ្ទះនោះ។ បច្ចុប្បន្នមនុស្សទាំង ១៧ នាក់កំពុងត្រូវសមត្ថកិច្ចឃុំខ្លួន ដើម្បីធ្វើការសាកសួរនិងចាត់ការតាមផ្លូវច្បាប់ ។ ប្រែសម្រួល៖ វារី ប្រភព៖ Bangkokpost

## បើកការស៊ើបអង្កេតលើការកេងប្រវ័ញ្ចជនពិការសុំទានតាមដងផ្លូវ

https://www.khmertimeskh.com/501353657// Khmer September 3, 2023

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ បានអំពាវនាវឱ្យមានការស៊ើបអង្កេតឱ្យបានហ្មត់ចត់ ចំពោះសកម្មភាពរបស់មេខ្យល់ ដែលកេងប្រវ័ញ្ចលើជនពិការ ដើម្បីកេងចំណេញថវិកា។ សកម្មភាពខុសច្បាប់ទាំងនេះរួមមាន ការបង្ខិតបង្ខំជនងាយរងគ្រោះ រួមទាំងជនអនាថា និងជនពិការ ឱ្យច្រៀង និងសម្តែងនៅទីសាធារណៈ ជាពិសេសនៅភ្លើងស្តុបក្នុងរាជធានីភ្នំពេញ ដើម្បីសុំប្រាក់ពីអ្នកធ្វើដំណើរតាមផ្លូវ។

បញ្ហានេះបានកើតឡើងក្នុងកិច្ចប្រជុំមួយដែលធ្វើឡើងនៅថ្ងៃទី១ ខែកញ្ញា ដែលផ្តោតលើការដោះស្រាយបញ្ហាដែលត្រូវបានប្រឈមដោយជនអនាថា អ្នកប្រើប្រាស់គ្រឿងញៀន និងអ្នកដែលមានបញ្ហាផ្លូវចិត្ត។ ក្នុងកិច្ចប្រជុំនេះ មន្ទីរសង្គមកិច្ចបានលើកឡើងពីតម្រូវការក្នុងការកំណត់អត្ត

សញ្ញាណ និងដោះស្រាយការកេងប្រវ័ញ្ចលើជនពិការ ជាពិសេសការបង្ខំឱ្យច្រៀង និងសុំលុយនៅតាមភ្លើងស្តុប។

ប្រធានមន្ទីរសង្គមកិច្ច អ្នកស្រី មុំ ចាន់ដានី សម្តែងការព្រួយបារម្ភដែលឈ្មួញដាប់ពាក់ព័ន្ធដឹកជញ្ជូនជនពិការទៅសម្តែងនៅភ្លើងស្តុប។ សកម្មភាពខុសច្បាប់នេះមិនត្រឹមតែកេងប្រវ័ញ្ចទេពកោសល្យរបស់ជនពិការប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យប៉ះពាល់ដល់សុខុមាលភាព និងសុវត្ថិភាពរបស់ពួកគេទៀតផង។ បន្ថែមពីលើនេះ ការកេងប្រវ័ញ្ចស្រដៀងគ្នានេះត្រូវបានគេសង្កេតឃើញក្នុងករណីកុមារអនាថា ដែលត្រូវបានបង្ខិតបង្ខំឱ្យដើរសុំទានតាមដងផ្លូវសាធារណៈផងដែរ។

ដើម្បីដោះស្រាយបញ្ហានេះប្រកបដោយប្រសិទ្ធភាព អ្នកស្រីបានស្នើដល់អាជ្ញាធរពាក់ព័ន្ធត្រូវកំណត់អត្តសញ្ញាណជនអនាថាឲ្យបានច្បាស់លាស់ និងផ្ញើលិខិតទៅមន្ទីរសង្គមកិច្ច អប់រំពួកគេពីហានិភ័យ និងផ្តល់ជំនួយចាំបាច់។ លើសពីនេះ លោកស្រីបានសង្កត់ធ្ងន់លើតម្រូវការបញ្ជូនអ្នកប្រើប្រាស់គ្រឿងញៀនទៅកាន់មណ្ឌលស្តារនីតិសម្បទា ដើម្បីដោះស្រាយការញៀនរបស់ពួកគេឱ្យបានត្រឹមត្រូវ។ អ្នកស្រីក៏បានគូសបញ្ជាក់ពីអ្នកប្រើប្រាស់គ្រឿងញៀនដែលត្រឡប់ទៅរកការញៀនរបស់ពួកគេវិញ បើទោះបីជាត្រូវបានបញ្ជូនទៅកាន់ការស្តារនីតិសម្បទាក៏ដោយ។ នេះបង្ហាញពីតម្រូវការក្នុងការបង្កើតវិធីសាស្ត្រដ៏ទូលំទូលាយដែលរួមមានការគាំទ្ររយៈពេលវែង និងការថែទាំដើម្បីការពារកុំអោយកើតមានឡើងវិញ និងធានាឱ្យមានការជាសះស្បើយឡើងវិញដោយជោគជ័យ។

ការកេងប្រវ័ញ្ចលើជនពិការ និងជនអនាថានេះ មិនត្រឹមតែជាការរំលោភសិទ្ធិរបស់ពួកគេប៉ុណ្ណោះទេ ថែមទាំងធ្វើអោយពួកគេប្រឈមភាពងាយរងគ្រោះ។ វាជាការចាំបាច់ដែលទាំងវិធានការបង្ការនិងការដាក់ទណ្ឌកម្មត្រូវបានអនុវត្ត ដើម្បីការពារបុគ្គលទាំងនេះពីគ្រោះថ្នាក់បន្ថែមទៀត។ អ្នកស្រីបានបន្តថា៖ «ពាក់ព័ន្ធករណីជនពិការដែលច្រៀងនៅតាមភ្លើងស្តុបធំៗ ក៏មានឈ្មួញដឹកជញ្ជូនពួកគេមកច្រៀងសុំលុយដើម្បីដោះស្រាយជីវភាព នេះជាករណីឆបោកពិតប្រាកដមែន។

## តារាម៉ូដែលសិចស៊ីម្នាក់ ចូលដៃជាមួយចិន១ក្រុម បោកនារីៗថៃច្រើននាក់

https://kohsantepheapdaily.com.kh/article/1795528.html?fbclid=IwAR2XCLT5cmBYEbKovN0ub2DztVuQAaJhS42XmOuSTML-0ULhzFQsK19D_8s ៣១ ខែ សីហា ឆ្នាំ ២០២៣ ម៉ោង ១៤:៥២

ថៃ ៖ មន្ត្រីនគរបាល និងមន្ត្រីជំនាញជាង២០០នាក់ មកពីការិយាល័យប្រឆាំងការលាងលុយកខ្វក់ (AMLO) និងការិយាល័យអគ្គមេធាវី (OAG) របស់ប្រទេសថៃ បានចុះទៅបង្រ្កាបទីតាំងប្រមាណ៣០កន្លែង នៅក្នុងទីក្រុងបាងកក និងខេត្តចំនួន២ផ្សេងទៀត ខណៈដែលការវាយឆ្មក់កាលពីព្រឹកថ្ងៃទី៣០ ខែសីហា កន្លងទៅ បានរឹបអូសផ្ទះប្រណីត និងរថយន្តទំនើបៗតម្លៃរាប់លាន

ដុល្លារអាមេរិក ដែលជាកម្មសិទ្ធិរបស់សមាជិកក្រុមឆបោកជនជាតិចិនមួយក្រុម។ នេះបើតាមប្រភពពីសារព័ត៌មានថៃ Nation Thailand ចេញផ្សាយនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣។

ប្រតិបត្តិការទ្រង់ទ្រាយធំនេះ ដឹកនាំដោយឧត្តមសេនីយ Atip Pongsiwaphai ប្រធាននាយកដ្ឋានប្រឆាំងឧក្រិដ្ឋកម្មបច្ចេកវិទ្យា (TCSD) អនុវត្តតាមបញ្ជាឧត្តមសេនីយ៍ឯក Jirapop Phuridet ស្នងការនៃការិយាល័យស៊ើបអង្កេតកណ្តាល។ ការវាយឆ្មក់នៅទីតាំងចំនួន៣០ នៅក្នុងទីក្រុងបាងកក ខេត្តសាមុតប្រាកាន និងខេត្តអ៊ូដនថានី ត្រូវបានធ្វើឡើងបន្ទាប់ពី TCSD ទទួលបានដីកាចាប់ខ្លួនចំនួន១៤ផ្សេងគ្នា ប្រឆាំងនឹងក្រុមឆបោកជនជាតិចិន ដែលត្រូវស្គាល់ថា ក្រុមឆបោកស្នេហា ដោយត្រូវបានចោទប្រកាន់ រួមនឹងសហការីជនជាតិថៃរបស់ពួកគេផងដែរ។ ក្រុមឆបោកទាំងនោះ ត្រូវបានចោទប្រកាន់ថា បានល្បួងស្ត្រីជនជាតិថៃជាច្រើននាក់ឱ្យលង់ស្នេហ៍ក្រុមក្មេងទំនើងជនជាតិចិន មុនពេលស្ត្រីទាំងនោះ ត្រូវបានបោកបញ្ឆោតឱ្យវិនិយោគលើរូបិយប័ណ្ណឌីជីថល ឬគ្រីបតូ ហើយទីបំផុតស្ត្រីទាំងនោះ ចាញ់បោកអស់ប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់។

បើយោងតាមប្រភពពីប៉ូលិសបានអះអាងថា សហការីជនជាតិថៃម្នាក់ ដែលត្រូវបានចោទប្រកាន់គឺជា តារាម៉ូដែលសិចស៊ីថៃ នាង Chakrina Chukhaosri ដែលត្រូវបានស្គាល់ឈ្មោះសិល្បៈថា «Kiki Maxim»។ ប៉ូលិសបានបន្តថា នាង Chakrina និងសមាជិកមួយចំនួននៃក្រុមក្មេងទំនើងចិនត្រូវបានចាប់ខ្លួន ហើយប៉ូលិសបានរឹបអូសផ្ទះជាច្រើនខ្នង និងរថយន្តស៊េរីទំនើបៗ ដែលទិញដោយទទួលបានផលចំណេញក្នុងការប៉ុនប៉ងលាងលុយខ្មៅ។ នាង Chakrina បានក្លាយជាតារាបង្ហាញម៉ូតដ៏មានប្រជាប្រិយភាព បន្ទាប់ពីចូលរួមក្នុងការប្រជែងដណ្តើមមកុដ Miss Maxim Sexy Icon កាលពីឆ្នាំ ២០១៦។

ទីតាំងមួយ ដែលបានវាយឆ្មក់ គឺនៅបុរីលំនៅឋានដ៏ប្រណីតមួយកន្លែង ស្ថិតនៅផ្លូវ Krungthep Kreetha ក្នុងសង្កាត់ Bang Kapi ទីក្រុងបាងកក។ នៅទីនោះ មន្ត្រីបានរឹបអូសផ្ទះចំនួន ១២ខ្នង ដែល១ខ្នងមានតម្លៃ៥០លានបាត ដែលស្មើនឹង ១.៤លានដុល្លារ។ ក្រុមមន្ត្រីជំនាញបន្តឆែកឆេរទីតាំងចំនួន៤ផ្សេងទៀត នៅតំបន់នោះ និងរឹបអូសបានផ្ទះមួយចំនួនទៀតផងដែរ។ ផ្ទះទាំងនោះភាគច្រើនត្រូវបានរកឃើញថា បានទិញតាមរយៈក្រុមហ៊ុនច្បាប់គ្រប់គ្រងដោយជនជាតិចិន។

ជាលទ្ធផល ក្រុមមន្ត្រីក៏បានឆ្មក់ចូលក្រុមហ៊ុនច្បាប់ខាងលើ ដើម្បីស្វែងរកភស្តុតាងបន្ថែមទៀត ខណៈដែលពួកគេជឿថា វាអាចត្រូវបានគេប្រើប្រាស់សម្រាប់ការលាងលុយខ្មៅឱ្យក្រុមក្មេងទំនើងជនជាតិចិន។ ក្រុមហ៊ុនច្បាប់នេះ ក៏ជាប់សង្ស័យថា បានជួយក្រុមក្មេងទំនើងចិន បើកក្រុមហ៊ុននៅក្នុងប្រទេសថៃ តាមរយៈអ្នកឈរឈ្មោះជាជនជាតិថៃផងដែរ។

ប្រភពពីប៉ូលិសបាននិយាយថា TCSD បានតាមដានក្រុមក្មេងទំនើងនេះ អស់រយៈពេលជាច្រើនខែមកហើយ បន្ទាប់ពីស្ត្រីជនជាតិថៃមួយចំនួនបានដាក់ពាក្យប្តឹងប៉ូលិសដោយនិយាយថា ពួកគេបានបាត់បង់ប្រាក់ជាច្រើន បន្ទាប់ពីត្រូវបានគេល្បួងឱ្យមានទំនាក់ទំនងលើបុរសជនជាតិចិនមួយចំនួន។ ករណីនេះបានកើតឡើងដំបូង នៅពេលដែលជនរងគ្រោះម្នាក់ បានដាក់ពាក្យបណ្ដឹងនៅប៉ុស្តិ៍នគរបាលខេត្តសាមុតប្រាកាន។

ប៉ូលិសបានហៅការអនុវត្តនេះថា ជាការឆបោកកូនកាត់ ដែលជនរងគ្រោះត្រូវបានទាក់ទាញឱ្យលង់ស្នេហ៍ក្រុមក្មេងទំនើងជនជាតិចិន ហើយបន្ទាប់មកមិត្តប្រុសពួកនាងបានលើកទឹកចិត្តពួកនាងឱ្យវិនិយោគលើការជួញដូររូបិយប័ណ្ណគ្រីបតូ។ ប៉ូលិសបានតាមដានរូបិយប័ណ្ណគ្រីបតូ ដែលជនរងគ្រោះទិញចូល ហើយរកឃើញថា លុយទាំងនោះបានជួញដូរ ឬផ្លាស់ប្តូរដៃជាច្រើនដងមុននឹងប្តូរជាលុយបាត ហើយពេលនោះលុយបាតត្រូវបានគេប្រើដើម្បីទិញទ្រព្យសម្បត្តិ រួមមានទាំងអចលនទ្រព្យ នៅក្នុងទីក្រុងបាងកក និងខេត្តក្បែរនោះផងដែរ។ (ប្រភពពី Nation Thailand)

## ពលកម្មកុមារកំពុងកើនឡើង ខណៈកុមាររាប់លាននាក់ត្រូវបានជំរុញឱ្យចូលធ្វើការ

https://news.btv.com.kh/article/29552 2023/09/04 05:28:25 pm

ប្រធានអង្គការពលកម្មរបស់អង្គការសហប្រជាជាតិបានប្រាប់សារព័ត៌មាន BBC ថា អនាគតរបស់កុមាររាប់លាននាក់គឺស្ថិតក្នុងហានិភ័យ ខណៈតួលេខកុមារ ដែលត្រូវបានដកចេញពីសាលារៀន និងចូលធ្វើការ មានចំនួនកើនឡើង។

លោក Gilbert Houngbo អគ្គនាយកនៃអង្គការពលកម្មអន្តរជាតិ (ILO) បាននិយាយថា មានកំណើនពលកម្មកុមារនៅក្នុងតំបន់ជុំវិញពិភពលោក ស្របពេលមានបញ្ហាសេដ្ឋកិច្ច ហើយទម្រង់ការងារដ៏អាក្រក់បំផុតមួយចំនួន គឺពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទ។ ទិន្នន័យដែលបានចងក្រងដោយអង្គការសហប្រជាជាតិនៅដើមឆ្នាំ២០២០ បានរកឃើញថា កុមារប្រហែល១៦០លាននាក់ត្រូវបានទទួលរងនូវពលកម្មកុមារ ហើយថាវិធានការសកលដើម្បីបញ្ចប់បញ្ហានោះ បានជាប់គាំងជាលើកដំបូងក្នុងរយៈពេល២០ឆ្នាំមកនេះ។

ស្ថានភាពពលកម្មកុមារពិតប្រាកដនៅក្នុងប្រទេសផ្សេងៗគ្នាមានភាពខុសប្លែកគ្នា ប៉ុន្តែមូលនិធិកុមាររបស់អង្គការសហប្រជាជាតិ (Unicef) និយាយថា អតិផរណា និងវិបត្តិក្នុងការចំណាយប្រចាំថ្ងៃ គឺជា «ក្តីបារម្ភសកល» ដែលជះឥទ្ធិពលដល់កុមារតាមវិធីជាច្រើន។

# ថ្ងៃទី០៦ ខែ កញ្ញា ឆ្នាំ២០២៣

## ឧបនាយករដ្ឋមន្ត្រី ស សុខា ៖ អាណត្តិទី៧នេះ ក្រសួងយកចិត្តទុកដាក់លើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងបទល្មើសផ្សេងៗ

https://dap-news.com/national/2023/09/05/356295/ BySKK106Posted on September 5, 2023 9:31 am

*ភ្នំពេញ ៖ លោកបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងថា ក្នុងអាណត្តិទី៧នេះ ក្រសួងមហាផ្ទៃបានយកចិត្តទុកដាក់ទៅលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ពង្រឹងសមត្ថភាពចរាចរណ៍ ការទប់ស្កាត់នូវអំពើចោរកម្ម និងបទល្មើសផ្សេងៗទៀត។*

*នាឱកាសអនុញ្ញាតឲ្យលោក UENO Atsushi ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម នារសៀលថ្ងៃ៤ កញ្ញា លោកឧបនាយករដ្ឋមន្ត្រី ស សុខា បានប្រាប់ឯកអគ្គរាជទូតជប៉ុននូវការដាក់ចេញយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។ លោកឧបនាយករដ្ឋមន្ត្រី មានប្រសាសន៍ថា «កិច្ចការសំខាន់ដែលស្ថិតក្រោមសមត្ថកិច្ចក្រសួងមហាផ្ទៃ ហើយក្រសួងមហាផ្ទៃផ្តោតការយកចិត្តទុកដាក់ សម្រាប់អាណត្តិទី៧នេះ រួមមាន៖*

*ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ការពង្រឹងនូវសមត្ថភាពចរាចរណ៍ ការទប់ស្កាត់នូវអំពើចោរកម្ម និងអំពើល្មើសផ្សេងៗ ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ក៏ដូចជា ការខិតខំពង្រឹងការគ្រប់គ្រងសុវត្ថិភាព និងការពារតាមព្រំដែនផងដែរ»។*

*ជាការឆ្លើយតប លោកឯកអគ្គរាជទូតជប៉ុនថា រដ្ឋាភិបាលជប៉ុន ក៏បានផ្តោតការយកចិត្តទុកដាក់ចំពោះយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើយ៉ាងណាផ្សារភ្ជាប់អ្វីដែលជាការគាំទ្រពីសំណាក់រដ្ឋាភិបាល និងប្រជាជនជប៉ុន មកលើយុទ្ធសាស្ត្រ និងគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា។ ឯកអគ្គរាជទូតជប៉ុនបន្តថា កិច្ចការដែលក្រសួងមហាផ្ទៃបានផ្តោត ក៏ស្របទៅនឹងកិច្ចការសមត្ថកិច្ចរបស់នគរបាលជប៉ុន ។ កិច្ចការនេះ នឹងចូលរួមចំណែកក្នុងកិច្ចសហប្រតិបត្តិការរវាងកម្លាំងអនុវត្តច្បាប់នៃប្រទេសទាំងពីរ។*

*សូមបញ្ជាក់ថា ក្នុងជំនួបនេះដែរ បណ្ឌិត ស សុខា និងឯកអគ្គរាជទូតជប៉ុន ក៏បានពិភាក្សាព្រមទាំងផ្លាស់ប្តូរយោបល់លើកិច្ចការងារមួយចំនួនទៀត រួមមាន៖ ការបណ្តុះបណ្តាលធនធានមនុស្សកម្ពុជា ការលើកកម្ពស់ការផ្តល់សេវាក្នុងពន្ធនាគារ ព្រមទាំងជំរុញនិងអភិវឌ្ឍន៍ទីក្រុងឆ្លាតវៃស្របតាមបរិបទ នៃការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល៕*

## រដ្ឋមន្ត្រីមហាផ្ទៃ ណែនាំឱ្យមន្ត្រីគ្រប់លំដាប់ថ្នាក់ស្រាក់ដៃគ្នាធ្វើការ ខណៈក្រសួងដាក់ចេញទិសដៅ ៦ ចំណុច

https://www.postkhmer.com/national/2023-09-05-1040-254195.html បូរ ពេជ្យហ្វាលីន।

Publication date 05 September 2023 | 10:40 ICT

*ភ្នំពេញៈ លោក ស សុខា ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានជំរុញឱ្យមន្ត្រីគ្រប់លំដាប់ថ្នាក់ត្រូវស្រាក់ដៃគ្នាធ្វើការ ដើម្បីសម្រេចឱ្យបានទិសដៅចម្បងៗរបស់ក្រសួង ក្នុងការបម្រើការពារប្រជាពលរដ្ឋឱ្យអស់ពីកម្លាំងកាយចិត្ត។ លោកបានថ្លែងបែបនេះ ក្នុងពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង និងប្រធាននាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ នៅថ្ងៃទី ៤ ខែកញ្ញា នាក្រសួងមហាផ្ទៃ។*

*តាមរយៈហ្វេសប៊ុកក្រសួងមហាផ្ទៃលោក ស សុខា បានលើកឡើងដោយដាក់ទិសដៅចម្បងៗ ៦ ចំណុច ដែលទាមទារឱ្យមន្ត្រីគ្រប់លំដាប់ថ្នាក់ត្រូវតែធ្វើឱ្យសម្រេចបាន ដែលក្នុងនោះរួមមាន៖ បញ្ហាគ្រឿងញៀន, បញ្ហាចរាចរណ៍, បញ្ហាចោរកម្ម និងបទល្មើសព្រហ្មទណ្ឌផ្សេងៗ, បញ្ហាក្រុមក្មេងទំនើង, បញ្ហាជួញដូរមនុស្សគ្រប់ប្រភេទ និងបញ្ហាតាមបណ្តោយព្រំដែនទាំងគោកនិងទឹក។*

*លោកថ្លែងថា៖ «ដើម្បីបន្តបម្រើការពារប្រជាពលរដ្ឋឱ្យអស់ពីកម្លាំងកាយចិត្ត ដោយត្រូវផ្តោតសំខាន់លើការងារបម្រើប្រជាពលរដ្ឋ រួមគ្នាបន្តខិតខំប្រឹងប្រែងពង្រឹងការអនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់ និងប្រកាន់ខ្ជាប់នូវវិន័យ ឥរិយាបថទន់ភ្លន់ ធ្វើយ៉ាងណាទប់ស្កាត់ បង្ការ និងបង្ក្រាបបទល្មើសនានាដែលកើតឡើងឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត»។*

*លោក ស សុខា លើកឡើងថា៖ «ខ្ញុំសូមបញ្ជាក់ជូនដោយស្មោះថា ខ្ញុំមកទីនេះ ពុំមែនមកដើម្បីដាក់សម្ពាធណាមួយលើមន្ត្រីទាំងផ្នែកស៊ីវិល នគរបាល និងពន្ធនាគារនោះទេ។ វត្តមានរបស់ខ្ញុំដើម្បីរួមគ្នាជាមួយមន្ត្រីទាំងអស់ ក្នុងទិសដៅជិះទូកតែមួយ ធ្វើឱ្យក្រសួងមហាផ្ទៃ កាន់តែមានកិត្យានុភាព រីកចម្រើន រឹងមាំ បានជាឧត្តមប្រយោជន៍ជូនប្រជាពលរដ្ឋ»។*

*ទាក់ទងនឹងការណែនាំរបស់រដ្ឋមន្ត្រីមហាផ្ទៃ លោក សាំង គឹមស៊ន មេឃុំធ្នុកទ្រូ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង បានថ្លែងនៅថ្ងៃទី ៤ ខែកញ្ញាថា កន្លងមករដ្ឋបាលឃុំធ្នុកទ្រូ តែងតែអនុវត្តយ៉ាងខ្ជាប់ខ្ជួន តាមទិសដៅរបស់រាជរដ្ឋាភិបាលនានាដែលបានដាក់ចេញ។ជាក់ស្តែង កន្លងមករដ្ឋបាលឃុំ តែងតែសហការទប់ស្កាត់រាល់បទល្មើសនានា ពិសេសបទល្មើសគ្រឿងញៀនសំដៅការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។*

*ជុំវិញរឿងនេះដែរ លោក អំ សំអាត នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការលីកាដូបានថ្លែងថា ការប្រកាសដាក់ចេញទិសដៅណែនាំទាំងនោះ គឺជារឿងមួយល្អ ប៉ុន្តែលោកចង់ឱ្យបង្កើនការយកចិត្តទុកដាក់បន្ថែមលើការពង្រឹង និងទប់ស្កាត់បទល្មើសឆ្លងដែននានា ការពង្រឹងភូមិ ឃុំ*

មានសុវត្ថិភាពឱ្យមានប្រសិទ្ធភាពបន្ថែមទៀត។ លោកថា៖ «អ្វីដែលជាកិច្ចការសំខាន់នោះ គឺផ្ដើមចេញពីឆន្ទៈរបស់មន្ត្រីដែលអនុវត្តផ្ទាល់ ថាគាត់ចង់អនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពឬអត់ ហើយខ្ញុំក៏សូមឱ្យមានកិច្ចសហការផ្ទៃក្នុងឱ្យបានល្អ...ពិសេសខ្ញុំសូមឱ្យលុបបំបាត់អំពើពុករលួយឱ្យបាន ទើបអាចធ្វើឱ្យទិសដៅទាំងនេះ មានប្រសិទ្ធភាពទៅបាន»៕

## កម្ពុជា-ថៃ ឯកភាពគ្នាទប់ស្កាត់ និងប្រឆាំងបទល្មើស ឧក្រិដ្ឋឆ្លងដែនគ្រប់ប្រភេទ

https://dap-news.com/national/2023/09/05/356238/ ByPH104Posted on September 5, 2023 7:32

**ភ្នំពេញ ៖ នាយឧត្តមសេនីយ៍ ស ថេត អគ្គស្នងការ នគរបាលជាតិកម្ពុជា និងនាយឧត្តមសេនីយ៍ Surachate Hakparn អគ្គស្នងការរងនគរបាលភូមិន្ទថៃ បានឯកភាពគ្នា ដើម្បីបង្ការទប់ស្កាត់ និងប្រឆាំងបទល្មើស ឧក្រិដ្ឋឆ្លងដែនគ្រប់ប្រភេទ ។**

ក្នុងជំនួបពិភាក្សាការងារជាមួយ នាយឧត្តមសេនីយ៍ ស ថេត នៅទីស្ដីការក្រសួងមហាផ្ទៃ នារសៀលថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ នាយឧត្តមសេនីយ៍ Surachate Hakparn បានបញ្ជាក់អំពីការបន្តពង្រឹង និងពង្រីកទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងនគរបាលជាតិកម្ពុជា និងនគរបាលភូមិន្ទថៃ ឱ្យមានភាពរឹង មាំជិតស្និទបន្ថែមទៀត សំដៅសម្រេចឱ្យបាននូវលទ្ធផលធំៗ ក្នុងកិច្ចសហប្រតិបត្តិការបង្ការទប់ស្កាត់ និងប្រឆាំងបទល្មើស ឧក្រិដ្ឋឆ្លងដែនគ្រប់ប្រភេទ។

ជាការឆ្លើយតប នាយឧត្តមសេនីយ៍ ស ថេត អគ្គស្នងការនគរបាលជាតិ បានថ្លែងអំណរគុណចំពោះ នាយឧត្តមសេនីយ៍ Surachate Hakparn អគ្គស្នងការរងនគរបាលភូមិន្ទថៃ និងគណៈប្រតិភូ ដែលបានមកបំពេញទស្សនកិច្ចការងារនៅកម្ពុជា ដោយបាននាំមកនូវការជូនពរ អបអរសាទរ ដែលជាសក្ខីភាពផ្ទុះបញ្ចាំងឱ្យឃើញនូវស្មារតីគោរពស្រឡាញ់ រាប់អានគ្នាយ៉ាងជិតស្និទ្ធ ក្នុងនាមកងកម្លាំង នគរបាលអាស៊ាន។

ក្នុងជំនួបនោះដែរ នាយឧត្តមសេនីយ៍ ស ថេត ក៏បានឯកភាពគ្នា ក្នុងការបន្តពង្រឹង និងពង្រីកទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងនគរបាលជាតិកម្ពុជា និងនគរបាលភូមិន្ទថៃ ដើម្បីបង្ការទប់ស្កាត់ និងប្រឆាំងបទល្មើសឧក្រិដ្ឋឆ្លងដែនគ្រប់ប្រភេទ៕

# ប្រមុខរដ្ឋាភិបាលកម្ពុជា-ម៉ាឡេស៊ី ប្តេជ្ញាពង្រឹងនូវកិច្ចសហប្រតិបត្តិការ ក្នុងការប្រយុទ្ធប្រឆាំងនឹងបទឧក្រិដ្ឋកម្មឆ្លងដែន និងបទឧក្រិដ្ឋកម្មសាយប័រ

https://kohsantepheapdaily.com.kh/article/1798447.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ០៥ ខែ កញ្ញា ឆ្នាំ ២០២៣ ម៉ោង ១៧:៥៦

ឥណ្ឌូនេស៊ី៖ នៅក្រៅកិច្ចប្រជុំកំពូលអាស៊ាន នៅប្រទេសឥណ្ឌូនេស៊ី នាថ្ងៃទី៥ ខែកញ្ញា ឆ្នាំ ២០២៣ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីកម្ពុជា បានជួបពិភាក្សាការងារជាមួយលោក អាន់វ៉ា អ៊ីប្រាហ៊ីម នាយករដ្ឋមន្ត្រីម៉ាឡេស៊ី។ ក្នុងកិច្ចប្រជុំ ប្រមុខរដ្ឋាភិបាលកម្ពុជា-ម៉ាឡេស៊ី បានប្តេជ្ញាពង្រឹងនូវកិច្ចសហប្រតិបត្តិការ ក្នុងការប្រយុទ្ធប្រឆាំងនឹងបទឧក្រិដ្ឋកម្មឆ្លងដែន និងបទឧក្រិដ្ឋកម្មសាយប័រ។

បន្ទាប់ពីការអបអរសាទរ និងកិច្ចស្វាគមន៍ទៅវិញទៅមក, ថ្នាក់ដឹកនាំទាំងពីរ បានពិភាក្សាបន្ថែមអំពីការបង្កើនកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងម៉ាឡេស៊ី ក្នុងទិដ្ឋភាពនយោបាយ, ពាណិជ្ជកម្មការវិនិយោគការអប់រំសន្តិសុខថាមពល, ការងារ និងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន។ ចំពោះវិស័យសន្តិសុខថាមពល, សម្តេចមហាបវរធិបតី បានស្នើសុំកិច្ចគាំទ្រពីរដ្ឋាភិបាលម៉ាឡេស៊ី ដល់គម្រោងនៃការសាងសង់ខ្សែបញ្ជូនថាមពលក្រោមសមុទ្រ ពីប្រទេសឡាវ កាត់តាមប្រទេសថៃ និងឆ្លោះទៅប្រទេសសិង្ហបុរី ដែលត្រូវឆ្លងកាត់ព្រំដែនសមុទ្រម៉ាឡេស៊ី។ ជាមួយគ្នានេះ, ប្រមុខរដ្ឋាភិបាលទាំងពីរ ក៏បានប្តេជ្ញាចិត្ត ក្នុងការពង្រឹងនូវកិច្ចសហប្រតិបត្តិការ ក្នុងការប្រយុទ្ធប្រឆាំងនឹងបទឧក្រិដ្ឋកម្មឆ្លងដែន និងបទឧក្រិដ្ឋកម្មសាយប័រ (Cyber Crime)បង្កើនបន្ថែមទៀត នូវការធ្វើពាណិជ្ជកម្ម និងលើកទឹកចិត្តចំពោះការវិនិយោគពីប្រទេសម៉ាឡេស៊ី នៅកម្ពុជា។

ជាចុងបញ្ចប់ សម្តេចមហាបវរធិបតី ក៏បានសម្តែងនូវអំណរគុណ ចំពោះរាជរដ្ឋាភិបាល ម៉ាឡេស៊ី ដែលបានគាំទ្របេក្ខភាពរបស់កម្ពុជា សម្រាប់ជាសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម (ECOSOC) សម្រាប់អាណត្តិ ២០២៨-២០៣០ និងសមាជិកគណៈកម្មាធិការកសាងសន្តិភាព (OCPBC) សម្រាប់អាណត្តិ ២០២៥-២០២៦ នៅក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ៕

# និស្សិតជនជាតិចិនម្នាក់
# ត្រូវបានសមត្ថកិច្ចកម្ពុជា ជួយសង្គ្រោះ ក្រោយចាញ់ឧបាយកលជនឆបោកឆ្លងប្រទេស

https://freshnewsasia.com/index.php/en/localnews/309172-2023-09-05-11-54-38.html 2023-09-05 06:54pm

***(ភ្នំពេញ)៖*** *យុវជនជានិស្សិតជនជាតិចិន បន្តការសិក្សានៅប្រទេសសិង្ហបុរីម្នាក់ ត្រូវបានកម្លាំងសមត្ថកិច្ច នៃនាយកដ្ឋានចារកម្ម ក្រសួងមហាផ្ទៃ សហការជាមួយមន្ត្រីស្ថានទូតចិនប្រចាំកម្ពុជា ជួយសង្គ្រោះបន្ទាប់ពីរូបគេ បានលង់ជឿក្នុងឧបាយកលរបស់ក្រុមជនទុច្ចរិត ដែលបានបន្លំជាសមត្ថកិច្ចសិង្ហបុរី និងរដ្ឋអាជ្ញា លួងលោមឱ្យជនរងគ្រោះគ្រាប់សកម្មភាពជាអ្នករងគ្រោះក្នុងអំពើចាប់ជំរិត រួចបញ្ជូនវីឌីអូរឃ្លីបទៅអាណាព្យាបាល ដើម្បីគំរាមទារប្រាក់ ចំនួន៧១ម៉ឺនដុល្លារ។*

*ជនរងគ្រោះ ជានិស្សិតជនជាតិចិន កំពុងបន្តការសិក្សាបរិញ្ញាបត្រ ផ្នែកទីផ្សារភាគហ៊ុន ឆ្នាំទី១ នៅសកលវិទ្យាល័យគ្រប់គ្រង ប្រទេសសិង្ហបុរី។ ផ្អែកតាមការរៀបរាប់របស់ជនរងគ្រោះ ក្នុងសន្និសិទសារព័ត៌មាន កាលពីរសៀលថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣កន្លងទៅ ដែលសមត្ថកិច្ចកម្ពុជាអនុញ្ញាតឱ្យរូបគេ ធ្វើការរៀបរាប់ដំណើររឿងបានឱ្យដឹងថា កាលពីថ្ងៃទី០៣ សីហា ឆ្នាំ២០២៣ មានជនបុរសមិនស្គាល់អត្តសញ្ញាណម្នាក់ បានទាក់ទងទូរស័ព្ទទៅរូបខ្លួន ដោយអះអាងថា រូបគេជានគរបាលអន្តោប្រវេសន៍របស់ប្រទេសសិង្ហបុរី ក្នុងការសន្ទនាគ្នាជាភាសាចិន ដោយប្រាប់ថា ជនរងគ្រោះមានជាប់ពាក់ព័ន្ធនឹងអំពើឆបោកជាច្រើនករណី។*

*ជនដដែលដែលតាំងខ្លួនជាមន្ត្រីសមត្ថកិច្ចនោះ បានប្រើវិធីសាស្ត្រនិយាយបំភ័យឱ្យជនរងគ្រោះ ធ្វើការទំនាក់ទំនងបន្តទៅកាន់បក្ខពួករបស់គេ០៣នាក់បន្ថែមទៀត ដោយអ្នកទាំងនោះសុទ្ធតែអះអាងថា ជាសមត្ថកិច្ច និងជារដ្ឋអាជ្ញាជាដើម។ បន្ទាប់មក ជនរងគ្រោះក៏បានទាក់ទងទៅពួកគេជាបន្តបន្ទាប់ ហើយក៏ត្រូវបានក្រុមទាំងនោះ ក៏បានណែនាំតម្រូវឱ្យជនរងគ្រោះធ្វើជា វីឌីអូរឃ្លីបខ្លីៗ បញ្ជូនទៅឱ្យពួកគេ ដើម្បីជាលុបលាងកំហុស និងសបញ្ជាក់ពីភាពស្អាតស្អំរបស់ខ្លួន ដោយការធ្វើវីឌីអូរនេះ គឺតម្រូវឱ្យជនរងគ្រោះចាកចេញពីប្រទេសសិង្ហបុរី ធ្វើដំណើរទៅកាន់ប្រទេសកម្ពុជា។*

*ប្រភពបន្តថា ក្រុមជនឆបោកខាងលើ បានប្រើពាក្យបំផិតបំភ័យផង លួងលោមផង រហូតជនរងគ្រោះមានការភ័យខ្លាចនឹងការជាប់ទោសទណ្ឌ ក៏បានធ្វើតាមការណែនាំរបស់ក្រុមជនសង្ស័យ ដោយជនរងគ្រោះបានធ្វើដំណើរ មកដល់ប្រទេសកម្ពុជា នៅថ្ងៃទី១០ ខែសីហា តាមការណែនាំរបស់ពួកគេ ដើម្បីរកបន្ទប់សណ្ឋាគារមួយស្នាក់នៅបណ្តោះអាសន្ន ហើយថតជាឃ្លីបវីឌីអូរខ្លីៗជាច្រើនឃ្លីប ដោយដើរតួជាអ្នកកំពុងរងគ្រោះក្នុងអំពើចាប់ជំរិត រួចបញ្ជូនវីឌីអូរ ទៅកាន់ក្រុមជនសង្ស័យ។*

ក្រោយទទួលបានឃ្លីបវីឌីអូរជាច្រើនពីជនរងគ្រោះរួចមក ក្រុមជនសង្ស័យបានបញ្ជូនឌីអូរទាំងនោះ បន្តទៅកាន់ឪពុកម្តាយរបស់ជនរងគ្រោះ (ស្នាក់នៅប្រទេសចិន) ដោយគំរាមទារប្រាក់ចំនួន៧១ម៉ឺនដុល្លារ ប៉ុន្តែត្រូវបានឪពុកម្តាយ ជនរងគ្រោះផ្ញើរឱ្យបានតែ៥ពាន់ដុល្លារ ហើយក៏បានប្តឹងទៅកាន់សមត្ថកិច្ចប្រទេសសិង្ហបុរី និងស្ថានទូតចិន ដើម្បីសុំកិច្ចអន្តរាគមន៍។

ក្រោយទទួលបណ្តឹងរួចមក សមត្ថកិច្ច នៃប្រទេសសិង្ហបុរី បានស្រាវជ្រាវ និងពិនិត្យទៅឃើញថា ជនរងគ្រោះបានធ្វើដំណើរចូលមកកម្ពុជា ទើបឪពុកម្តាយរបស់ជនរងគ្រោះ និងមន្ត្រីស្ថានទូតចិន បានសហការគ្នាជាមួយ នគរបាលកម្ពុជា បើកការស្រាវជ្រាវ រហូតតាមរកជនរងគ្រោះឃើញនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ នៅក្នុងផ្សារទំនើបអ៊ីអន២ ក្នុងខណ្ឌសែនសុខ គ្រាដែលជនរងគ្រោះដើរថតពីសកម្មភាពរបស់ខ្លួន ដើម្បីរាយការណ៍បន្តទៅក្រុមជនសង្ស័យ។

តាមការបញ្ជាក់របស់ជនរងគ្រោះ បានឱ្យដឹងបន្ថែមថា ក្រុមជនសង្ស័យមានជំនាញណាស់ពិសេសមានទិចនិច និងចិត្តសាស្ត្រខ្ពស់ក្នុងការនិយាយលួងលោមបំភិតបភ័យ រហូតរូបគេបាត់បង់ភាពម្ចាស់ការលើខ្លួនឯង ព្រមជឿជាក់នឹងសម្តីរបស់ក្រុមនេះ រហូតព្រមធ្វើតាមគ្រប់យ៉ាងដូចដែលពួកគេបានប្រាប់ ដោយមិនបានប្តឹងសមត្ថកិច្ច នៃប្រទេសសិង្ហបុរីជាមុនសិន ពិសេសនោះ ក៏មិនបានពិភាក្សាជាមួយឪពុកម្តាយទៅទៀត។ យ៉ាងណាមិញ បច្ចុប្បន្ន ជនរងគ្រោះត្រូវបានសមត្ថកិច្ចកម្ពុជាបំពេញសំណុំបែបបទ អនុញ្ញាតឱ្យត្រឡប់ទៅកាន់ប្រទេសកំណើតវិញហើយផងដែរ៕

# ថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ២០២៣

## សម្តេចធិបតី ហ៊ុន ម៉ាណែត
## និងព្រះចៅស៊ុលតង់ ឯកភាពបង្កើនកិច្ចសហប្រតិបត្តិការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន

https://www.kampucheathmey.com/local-news/573168 ថ្ងៃពុធ ៦ កញ្ញា ២០២៣ដោយ sopheak khoun

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃកម្ពុជា និងព្រះចៅស៊ុលតង់ ព្រះមហាក្សត្រ នៃប្រទេសព្រុយណេដារូស្សាឡាម បានឯកភាពក្នុងការបង្កើនកិច្ចសហប្រតិបត្តិការ លើការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន។

ការឯកភាពគ្នានេះ បានធ្វើឡើងដែលសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត បានជួបសម្តែងការគួរសមជាមួយព្រះចៅស៊ុលតង់ ហាជី ហាសសាណាល់ បុលគីយ៉ាស់ មុយអ៊ីហ្សាឌីន វ៉ាឌូឡាហ៍ ព្រះមហាក្សត្រ នៃប្រទេសព្រុយណេដារូស្សាឡាម កាលពីព្រឹកថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០២៣ នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូណេស៊ី។

សម្តេចធិបតី ហ៊ុន ម៉ាណែត បានបង្ហាញការស្វាគមន៍ចំពោះជំនួបនេះ និងបាននាំយកនូវការសួរសុខទុក្ខយ៉ាងកក់ក្តៅពីសំណាក់សម្តេចតេជោ ហ៊ុន សែន ប្រធានឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ថ្វាយជូនចំពោះ ព្រះចៅស៊ុលតង់ ផងដែរ។ សម្តេចធិបតី ហ៊ុន ម៉ាណែត បានលើកឡើងអំពីទំនាក់ទំនងដ៏ល្អរវាងកម្ពុជា និងព្រុយណេ ជាពិសេស ក្នុងទិដ្ឋភាព នៃវិស័យការពារជាតិ ដែលសម្តេចធិបតី បានធ្វើទស្សនកិច្ចមកកាន់ព្រុយណេ កាលពីសម្តេចធិបតី នៅជាមេបញ្ជាការកងទ័ពជើងគោក។

ជាកិច្ចឆ្លើយតប ព្រះចៅស៊ុលតង់ សម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះសម្តេចធិបតី និង បានរំលឹកអំពីមិត្តភាពដ៏ជិតស្និទ្ធរវាង ព្រះចៅស៊ុលតង់ និងសម្តេចតេជោ ប្រធានឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ។

នៅក្នុងជំនួបនេះដែរ សម្តេចធិបតី និងព្រះចៅស៊ុលតង់ បានពិភាក្សាទៅលើទិសដៅអនាគតនៃការបង្កើនកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងព្រុយណេ ដែលផ្តោតជាពិសេសទៅលើវិស័យការពារជាតិ, សន្តិសុខ, អប់រំ និងបណ្តុះបណ្តាលធនធានមនុស្ស, កសិកម្ម ក៏ដូចជាការផ្សារភ្ជាប់ទំនាក់ទំនងរវាងប្រជាជន និង ប្រជាជន នៃប្រទេសទាំងពីរ។ បន្ថែមពីលើនេះទៀត សម្តេចធិបតី និងព្រះចៅស៊ុលតង់ បានឯកភាពក្នុងការបង្កើនកិច្ចសហប្រតិបត្តិការលើការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន, ការផ្សារភ្ជាប់វិស័យឯកជន តាមរយៈសភាពាណិជ្ជកម្ម, និងការគាំទ្រអនុវត្តយន្តការសន្ទនាទ្វេភាគីរវាងរដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងពីរ។

មុននឹងបញ្ចប់ជំនួប ព្រះចៅស៊ុលតង់ បានអញ្ជើញសម្តេចធិបតី ទៅបំពេញទស្សនកិច្ចផ្លូវការនៅព្រុយណេ នាពេលខាងមុខនេះ ហើយសម្តេចធិបតី បានឆ្លើយតបដោយវិជ្ជមានចំពោះការអញ្ជើញនេះ និង បានអញ្ជើញ ព្រះចៅស៊ុលតង់ មកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជាវិញផងដែរ នាថ្ងៃអនាគត៕

## ប្រមុខការទូតខ្មែរ៖
## អាស៊ាន ត្រូវតែយកចិត្តទុកដាក់រួមគ្នា ប្រយុទ្ធប្រឆាំង ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់រូបភាព

https://dap-news.com/national/2023/09/06/356562/ BySS107Posted on September 6, 2023 8:57

ភ្នំពេញ៖ ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន លើកទី២៧ នាថ្ងៃទី ៤ កញ្ញា ឧបនាយករដ្ឋមន្ត្រី សុខ ចិន្តាសោភា រដ្ឋមន្ត្រីការបរទេសកម្ពុជា បានថ្លែងថា ប្រទេសសមាជិកអាស៊ាន ត្រូវតែយកចិត្តទុកដាក់រួមគ្នា ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្ម ឆ្លងដែនគ្រប់រូបភាព ដែលត្រូវបានមើលឃើញថា មាននិន្នាការកើនឡើង ក្រោមជំនួយផ្នែកបច្ចេកវិទ្យា ។

បើតាមសេចក្តីប្រកាសព័ត៌មាន របស់ក្រសួងការបរទេសខ្មែរ នាថ្ងៃទី៥ កញ្ញា បានឲ្យដឹងថា កិច្ចប្រជុំនេះបានស្វាគមន៍ ចំពោះការខិតខំប្រឹងប្រែង របស់ប្រទេសសមាជិកអាស៊ាន ក៏ដូចជាស្ថាប័នពាក់ព័ន្ធ និងលេខាធិការដ្ឋានអាស៊ាន ដែលបានអនុវត្តបន្ទាត់សកម្មភាព នៃផែនការលម្អិតស្តីពីសហគមន៍នយោបាយ-សន្តិសុខអាស៊ានឆ្នាំ២០២៥ ដោយសម្រេចដល់ទៅ ៩៩% ដែលសកម្មភាពទាំងនោះក៏បានគ្រប់ដណ្តប់លើវិស័យពាក់ព័ន្ធនឹងទស្សនវិស័យអាស៊ាន ស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក (AOIP) សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណេត បញ្ញាសិប្បនិម្មិត បដិវត្តន៍ឧស្សាហកម្មទី៤ សេដ្ឋកិច្ចបៃតង ការឆ្លើយតបរបស់អាស៊ានចំពោះការរីករាលដាលនៃជំងឺកូវីដ-១៩ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ (WPS) និងរបៀបវារៈយុវជន សន្តិភាព និងសន្តិសុខ (YPS) ផងដែរ។

ក្នុងកិច្ចប្រជុំនោះឧបនាយករដ្ឋមន្ត្រី សុខ ចិន្តាសោភា បានវាយតម្លៃថា «សន្តិភាព និងស្ថិរភាពគឺជាថ្នឹងខ្នងដ៏សំខាន់នៃរាល់ការអភិវឌ្ឍទាំងអស់ ហើយយន្តការដែលដឹកនាំដោយអាស៊ានត្រូវបន្តលើកកម្ពស់សន្តិភាព និងស្ថិរភាព នៅក្នុងតំបន់ ជាពិសេស បញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងបញ្ហាដែលនឹងកើតឡើងនាពេលអនាគត។ ស្របពេលជាមួយគ្នានេះដែរ ប្រទេសសមាជិកអាស៊ានត្រូវតែយកចិត្តទុកដាក់រួមគ្នា ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់រូបភាព ដែលត្រូវបានមើលឃើញថា មាននិន្នាការកើនឡើងក្រោមជំនួយផ្នែកបច្ចេកវិទ្យា» ។

ធៀតក្នុងឱកាសនេះផងដែរ លោកឧបនាយករដ្ឋមន្ត្រី ក៏បានថ្លែងអំណរគុណដល់ប្រទេសសមាជិកអាស៊ាន ដែលបានរួមចំណែកដល់ដំណើរការមជ្ឈមណ្ឌលសកម្មភាពមីនតំបន់អាស៊ាន (ARMAC) និងអំពាវប្រទេសសមាជិកអាស៊ានទាំងអស់ផ្តល់ ការគាំទ្រចាំបាច់នានាដល់មជ្ឈមណ្ឌល ARMAC ៕

## ស្នងការរងនគរបាលថៃស្នើឱ្យមានកិច្ចសហការបង្ក្រាបក្រុមឆបោកមជ្ឈមណ្ឌលហៅទូរស័ព្ទ

https://www.khmertimeskh.com/501355786// Khmer Times September 6, 2023

អគ្គស្នងការរងនគរបាលជាតិ នាយឧត្តមសេនីយ៍ ស៊ូរ៉ាឆាត ហាក់ផាន (Surachate Hakparn) កំពុងមានវត្តមាននៅក្នុងប្រទេសកម្ពុជា ដើម្បីស្វែងរកកិច្ចសហការពីនគរបាលកម្ពុជា ក្នុងការតាមចាប់ខ្លួនជនសង្ស័យជនជាតិថៃ និងចិន ៩នាក់ ដែលធ្វើការក្នុងក្រុមឆបោកមជ្ឈមណ្ឌលហៅទូរស័ព្ទ ។ ពួកគេត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងការស្លាប់របស់សមាជិកគ្រួសារថៃបីនាក់និងការប៉ុនប៉ងធ្វើអត្តឃាតរបស់មេគ្រួសារ។ លោក ស៊ូ រ៉ាឆាត មានដីកាចាប់ខ្លួនដែលចេញដោយតុលាការថៃ។

ហេតុការណ៍ឆបោករបស់មជ្ឈមណ្ឌលហៅទូរស័ព្ទនៅប្រទេសកម្ពុជា បានកើតឡើងនៅពេលដែលបុរសម្នាក់នៅខេត្តសាមុតប្រាកាន (Samut Prakan) បានសម្លាប់ប្រពន្ធ និងកូនពីរនាក់ដោយកាំបិត ហើយប៉ុនប៉ងធ្វើអត្តឃាត ដោយកាំបិតដូចគ្នានៅផ្ទះរបស់ពួកគេកាលពីថ្ងៃទី២៨ ខែសីហា។ បុរសនោះបានរួចផុតពីការប៉ុនប៉ងធ្វើអត្តឃាតនោះ។

នគរបាលស៊ើបអង្កេតបានរកឃើញថាប្រពន្ធបានខ្ចីប្រាក់ពីវេទិកាអនឡាញមួយដែលដំណើរការដោយក្រុមឆបោក ដែលសន្យាថា មិនយកការប្រាក់។ ក្រោយមក ក្រុមជនឆបោកនោះ បានគិតការប្រាក់គាត់ច្រើនលើសលប់ រហូតដល់បំណុលរបស់គាត់កើនឡើងដល់ប្រហែល ១,៧ លានបាត។ ប្ដីរបស់គាត់ត្រូវបញ្ចាំផ្ទះ ប៉ុន្តែនៅតែមិនអាចសងបំណុលគេបាន។ ដោយក្ដីអស់សង្ឃឹម គាត់បានសម្រេចចិត្តសម្លាប់មនុស្សជាទីស្រលាញ់របស់គាត់ និងបានធ្វើអត្តឃាត។ ស្ត្រីម្នាក់ដែលបើកគណនីធនាគារ«មេ»(mule bank account) ឲ្យក្រុមឆបោកនេះត្រូវបានចាប់ខ្លួននៅច្រកព្រំដែនក្នុងស្រុកអារញ្ញប្រាថេត កាលពីថ្ងៃទី៣០ សីហា នៅពេលស្ត្រីនោះព្យាយាមគេចខ្លួនមកកម្ពុជា។

នាយឧត្តមសេនីយ៍ ស៊ូរ៉ាឆាត បានប្រាប់អ្នកសារព័ត៌មានថា លោកសង្ឃឹមថា នឹងមានកិច្ចសហប្រតិបត្តិការល្អពីនគរបាលកម្ពុជា។ លោកក៏បានជួបជាមួយឯកអគ្គរាជទូតថៃ ប្រចាំនៅកម្ពុជា ដើម្បីពិភាក្សាអំពីវិធីជួយជនជាតិថៃជាច្រើននាក់ ដែលត្រូវបានគេបោកបញ្ឆោតឱ្យធ្វើការឱ្យក្រុមឆបោកមជ្ឈមណ្ឌលហៅទូរស័ព្ទនៅក្នុងប្រទេសកម្ពុជា។ Thai PBS World

## ឥណ្ឌូនេស៊ីស្នើកម្ពុជាពង្រឹងការសហការដើម្បីបង្ក្រាបបញ្ហាឆបោកតាមប្រព័ន្ធអ៊ីនធឺណេត

https://www.rfi.fr/km//20230906-?utm_medium=social&utm_campaign=telegram&utm_source=shorty ចុះផ្សាយនៅថ្ងៃ៖ 06/09/2023 - 08:27

ឥណ្ឌូនេស៊ី បានគូសបញ្ជាក់ប្រាប់កម្ពុជា អំពីសារៈសំខាន់នៃការសហប្រតិបត្តិដើម្បីបង្ក្រាបបទល្មើសឆបោកតាមប្រព័ន្ធអ៊ីនធឺណេត។ ការបញ្ជាក់នេះ ធ្វើឡើងតាមរយៈកិច្ចប្រជុំដាច់ដោយឡែករវាងមេដឹកនាំនៃប្រទេសទាំងពីរ អំឡុងពេលដែលឥណ្ឌូនេស៊ីកំពុងរៀបចំកិច្ចប្រជុំកំពូលអាស៊ាន នៅទីក្រុងហ្សាកាតា។

បើតាមសេចក្ដីប្រកាសព័ត៌មាន ពីសំណាក់ក្រសួងការបរទេសឥណ្ឌូនេស៊ី គឺលោក ចូកូ វីដូដូ ប្រធានាធិបតីឥណ្ឌូនេស៊ី បានបញ្ជាក់ប្រាប់លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ថា ចាប់ពីខែមករា ដល់ខែកក្កដា ក្នុងឆ្នាំ២០២៣នេះ មានករណីចំនួន ៧៧៧ ត្រូវបានដោះស្រាយនៅក្នុងប្រទេសកម្ពុជា។ ដោយក្នុងនោះមាន៥១៥ ករណីពាក់ព័ន្ធនឹងការឆបោកតាមអ៊ីនធឺណិត។

ក្នុងជំនួបទ្វេភាគីជាមួយកម្ពុជា លោក ចូកូ វីដូដូ បានសង្កត់ធ្ងន់ទៅលើការសហការរវាងប្រទេសទាំងពីរ ដើម្បីបង្ក្រាបបទល្មើសទាំងនោះ។ បើតាមលោកប្រធានាធិបតីឥណ្ឌូនេស៊ី មេដឹកនាំទាំងពីរបានពិភាក្សាអំពីសារៈសំខាន់ នៃការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការការពារពលរដ្ឋឥណ្ឌូនេស៊ី ជាពិសេសអ្នក ដែលបានក្លាយជាជនរងគ្រោះ នៃការបោកប្រាស់តាមអ៊ីនធឺណិត ឬការក្លែងបន្លំតាមអ៊ីនធឺណិត។

ដោយឡែក បើតាមសេចក្តីប្រកាសនៅលើប្រព័ន្ធតេលេក្រាម របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត បានអះអាងថា ភាគីទាំងពីរបានពិភាក្សាយ៉ាងជិតស្និទ្ធ ទៅលើទិដ្ឋភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម ការបណ្តុះបណ្តាលធនធានមនុស្ស ការប្រយុទ្ធប្រឆាំងភេរវកម្ម និង ឧក្រិដ្ឋកម្មឆ្លងដែន ជាដើម ។ ឧក្រិដ្ឋកម្មឆ្លងដែន ដែលខាងកម្ពុជា បានបញ្ជាក់ទៀតថា កម្ពុជានិងឥណ្ឌូនេស៊ីនឹងបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ ឱ្យកាន់តែស្អិតរមួតបន្ថែមទៀត។

ជាការកត់សម្គាល់ ការលើកឡើងពីបញ្ហាបទល្មើសឆបោកតាមប្រព័ន្ធអ៊ីនធឺណេត នេះកើតឡើងនៅស្របពេលដែលសារព័ត៌មានអន្តរជាតិមួយចំនួន បានចុះផ្សាយជាបន្ត អំពីករណីជួញដូរមនុស្សមួយចំនួនចូលមកប្រទេសកម្ពុជា។ ករណីចុងក្រោយ តាមការចុះផ្សាយរបស់សារព័ត៌មាន Reuters មានការចាប់ខ្លួនមនុស្ស១២នាក់ ពាក់ព័ន្ធនឹងបទជួញដូរមនុស្ស ១២២នាក់មកកម្ពុជា ដើម្បីលក់ក្រលៀន។ ផ្អែកតាមចម្លើយសារភាពរបស់ក្រុមជនសង្ស័យ បានឲ្យដឹងថា ការជួញដូរក្រលៀននោះ ធ្វើឡើងនៅឯមន្ទីរពេទ្យ ព្រះកេតុមាលា កណ្តាលក្រុងភ្នំពេញ៕

## បច្ចុប្បន្នមានពលរដ្ឋនិងនិស្សិតខ្មែរជាង២.២ម៉ឺននាក់បានទៅធ្វើការ និងសិក្សានៅម៉ាឡេស៊ី

https://freshnewsasia.com/index.php/en/localnews/309273-2023-09-06-09-37-43.html 2023-09-06 04:37pm

**(ភ្នំពេញ)៖** តាមរយៈកិច្ចសហប្រតិបត្តិការល្អរវាងកម្ពុជា-ម៉ាឡេស៊ី ពិសេសលើវិស័យការងារ និងវិស័យអប់រំ ជួយឱ្យប្រជាពលរដ្ឋនិងនិស្សិតខ្មែរជាង២.២ម៉ឺននាក់បានទៅធ្វើការ និងសិក្សានៅប្រទេសម៉ាឡេស៊ី ដើម្បីកសាងសមត្ថភាព និងស្វែងរកចំណូលផ្គត់ផ្គង់គ្រួសារ។ នេះបើតាមការបញ្ជាក់របស់លោក ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ក្នុងឱកាសចូលរួមក្នុងពិធីបុណ្យជាតិលើកទី៦៦នៃប្រជាជនម៉ាឡេស៊ី នាល្ងាចថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣ លោករដ្ឋមន្ត្រី ហេង សួរ ក្នុងនាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជារដ្ឋាភិបាលកម្ពុជាបានថ្លែងអំណរគុណដល់រដ្ឋាភិបាលនិងប្រជាជនម៉ាឡេស៊ី ដែលបានយកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋនិងនិស្សិតខ្មែរដែលកំពុងមានវត្តមាននៅទីនោះ។ លោកបានបញ្ជាក់ថា «ប្រជា

ពលរដ្ឋនិងនិស្សិតខ្មែរជាង ២.២ម៉ឺននាក់ កំពុងធ្វើការនិងសិក្សានៅប្រទេសម៉ាឡេស៊ី ដើម្បីកសាងសមត្ថភាព និងស្វែងរកចំណូលផ្គត់ផ្គង់គ្រួសារ»។

លោករដ្ឋមន្ត្រីបានបន្តថា កម្ពុជានិងម៉ាឡេស៊ីបានខិតខំកសាងនូវមិត្តភាពដ៏ល្អនិងយូរអង្វែង និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធបំផុតមួយក្នុងតំបន់អាស៊ាន។ ប្រទេសទាំងពីរនៅតែបន្តពង្រឹងពាណិជ្ជកម្មទ្វេភាគី បន្តពង្រឹងទំនាក់ទំនងប្រជាជននិងប្រជាជនយ៉ាងស្អិតល្មួតជាមួយគ្នា។ ជាក់ស្តែង ទំហំពាណិជ្ជកម្មបានកើនឡើងពី ៥០០លានដុល្លារ នៅឆ្នាំ២០២១ ដល់ ៦២០លានដុល្លារ នៅឆ្នាំ២០២២ ហើយ៧ខែ ដើមឆ្នាំ២០២៣នេះ ទំហំពាណិជ្ជកម្មបានកើនដល់ ៣៧៧លានដុល្លារអាមេរិក។ ក្នុងនោះដែរ យើងឃើញថាម៉ាឡេស៊ីឈរលំដាប់ថ្នាក់ទី៦ ក្នុងចំណោមប្រទេសដែលបោះទុនវិនិយោគច្រើនជាងគេនៅកម្ពុជា។

មួយវិញទៀត ភ្ញៀវទេសចរម៉ាឡេស៊ីដែលមកទស្សនានៅកម្ពុជាបានកើនឡើងជាលំដាប់ពោលគឺចាប់ពីជាង ២.៥ម៉ឺននាក់ នៅឆ្នាំ២០២០ កើនឡើងមកដល់ជាង ៥.៣ម៉ឺននាក់ នៅឆ្នាំ២០២២។ បើគិតត្រឹម៧ខែ ដើមឆ្នាំ២០២៣នេះ ភ្ញៀវទេសចរម៉ាឡេស៊ីជាង ៥.២ម៉ឺននាក់ បានមកទស្សនានៅកម្ពុជា៕

# ថ្ងៃទី០៨ ខែ កញ្ញា ឆ្នាំ២០២៣

## ប្រធានរដ្ឋសភាកូរ៉េខាងត្បូង
## សន្យាជំរុញការផ្តល់ជំនួយនានា និងបង្កើនកូតាពលករដល់កម្ពុជា

https://www.kampucheathmey.com/local-news/573827 ថ្ងៃព្រហស្បតិ៍ ៧ កញ្ញា ២០២៣ដោយ sopheak khoun

នៅចំពោះមុខប្រធានរដ្ឋសភាកម្ពុជា ប្រធានរដ្ឋសភាកូរ៉េខាងត្បូង បានសន្យាថា នឹងខិតខំជំរុញការផ្តល់ជំនួយនានាដល់កម្ពុជា។ ក្នុងនោះ ក៏មានការបង្កើនកូតាពលករ និងបច្ចេកទេសកសិកម្ម ជាដើម។ ការសន្យានេះ បានធ្វើឡើងបានលើកឡើងនៅក្នុងជំនួបទ្វេភាគីរវាង សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោក គីម ជីន ព្យ៉ូ ប្រធានរដ្ឋសភា នៃសាធារណរដ្ឋកូរ៉េ នាព្រឹកថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០២៣នេះ នៅវិមានរដ្ឋសភា។

នៅក្នុងជំនួបសម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា បានស្នើលោក គីម ជីន ព្យ៉ូ (Kim Jin Pyo) ប្រធានរដ្ឋសភា នៃសាធារណរដ្ឋកូរ៉េ ជួយជំរុញលើកកម្ពស់ទំនាក់ទំនងកម្ពុជា និងសាធារណរដ្ឋកូរ៉េ ឲ្យកាន់តែរឹងមាំ និងគ្រប់ជ្រុងជ្រោយ ទាំងស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ។ ពោលធ្វើយ៉ាងណាឲ្យទំនាក់ទំនង នៃប្រទេសទាំងពីរ បានឈានដល់ "ដៃគូសហប្រតិបត្តិការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ" រួមទាំងវិនិយោគ និងពាណិជ្ជកម្ម។

សម្តេចរដ្ឋសភាធិបតី ក៏បានស្នើដល់ភាគីរដ្ឋសភាកូរ៉េបន្តគាំទ្រកិច្ចព្រមព្រៀង និងអនុស្សរណៈយោគយល់នានា ដែលរដ្ឋាភិបាលប្រទេសទាំងពីរ (កម្ពុជា-កូរ៉េ) បានធ្វើកន្លងមក ដូចជាការនាំចូលផលិតផលពីកម្ពុជា អភិវឌ្ឍន៍វិស័យកសិ-ឧស្សាហកម្មកែច្នៃ និងបន្តជួយជំរុញនិងគាំទ្ររដ្ឋាភិបាលកូរ៉េ បន្តការគាំទ្រដល់ពលករ និងពលរដ្ឋកម្ពុជា ដែលកំពុងបម្រើការនិងស្នាក់នៅក្នុងប្រទេសកូរ៉េ។ លើសពីនេះ សម្តេចរដ្ឋសភាធិបតី ក៏បានលើកជាសំណើដល់ប្រធានរដ្ឋសភាកូរ៉េ បង្កើនកិច្ចសហប្រតិបត្តិការជាមួយរដ្ឋសភាកម្ពុជា ឲ្យកាន់តែស៊ីជម្រៅ និងជិតស្និទ្ធថែមទៀតនៅគ្រប់កម្រិត តាំងពីកម្រិតថ្នាក់ដឹកនាំ គណៈកម្មការជំនាញ ក្រុមមិត្តភាពសភា រហូតដល់កម្រិតមន្ត្រីជំនាញ រួមទាំងការបណ្តុះបណ្តាលធនធានមនុស្ស ដល់មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា ផ្នែកព័ត៌មានវិទ្យា និងការស្រាវជ្រាវ ជាដើម។

ក្នុងជំនួបទ្វេភាគីនេះ លោក គីម ជីន ព្យូ បានសម្តែងការអបអរសាទរចំពោះការបង្កើតនូវរាជរដ្ឋាភិបាលនិងរដ្ឋសភាអាណត្តិថ្មី ដែលជាអ្នកបន្តវេនពោរពេញដោយថាមពល នៅក្នុងការកសាងអភិវឌ្ឍន៍ប្រទេសជាតិ។ លោកប្រធានរដ្ឋសភា បានអបអរសាទរចំពោះសម្តេចរដ្ឋសភាធិបតី ដែលជាស្ត្រីដំបូងនៅកម្ពុជា បានក្លាយជាប្រធានរដ្ឋសភា។ លោក គីម ជីន ព្យូ បានគូសបញ្ជាក់ថា រដ្ឋសភាសាធារណរដ្ឋកូរ៉េត្រៀមខ្លួនជានិច្ច នៅក្នុងការពង្រឹងពង្រីកចំណងមិត្តភាព រវាងរដ្ឋសភា និងរដ្ឋាភិបាលប្រទេសទាំងពីរ ឲ្យកាន់តែរឹងមាំឡើង។

លោក គីម ជីន ព្យូ បានលើកឡើងថា ទំនាក់ទំនងប្រទេសកម្ពុជា និងកូរ៉េ មានការរីកចម្រើនជាលំដាប់ ទាំងវិស័យការទូត និងពាណិជ្ជកម្ម។ ការវិនិយោគនៅកម្ពុជារបស់កូរ៉េ បានកើនឡើងគួរឲ្យកត់សម្គាល់នៅក្នុងវិស័យកសិកម្ម និងឧស្សាហកម្មរថយន្ត។ ប្រធានរដ្ឋសភាកូរ៉េ បានសន្យាថានឹងខិតខំជំរុញការផ្តល់ជំនួយនានាដល់កម្ពុជា នៅក្នុងនោះក៏មានការបង្កើនកូតាពលករ បច្ចេកទេសកសិកម្ម និងការបណ្តុះបណ្តាល សមត្ថភាពមន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា ជាដើម។

សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនរដ្ឋាភិបាល និងប្រជាជន នៃសាធារណរដ្ឋកូរ៉េ ដែលជានិច្ចកាលតែងតែជួយឧបត្ថម្ភ គាំទ្រការអភិវឌ្ឍនៅកម្ពុជាលើគ្រប់វិស័យ។ សម្តេចរដ្ឋសភាធិបតី បានគូសបញ្ជាក់ថា ជាការពិតណាស់ គោលដៅអភិវឌ្ឍន៍របស់កម្ពុជានឹងមិនអាចសម្រេចបានទេ ប្រសិនបើមិនមានកិច្ចសហប្រតិបត្តិការល្អ ជាមួយបណ្តាប្រទេសជាមិត្ត និង ដៃគូអន្តរជាតិ ដូចជាសាធារណរដ្ឋកូរ៉េ ជាដើម៕

# នៅចំពោះមុខសម្ដេចធិបតី ហ៊ុន ម៉ាណែត, ប្រធានាធិបតីកូរ៉េខាងត្បូង សន្យាពិចារណា បង្កើនកូតាពលករកម្ពុជា

https://freshnewsasia.com/index.php/en/localnews/309482-2023-09-08-02-31-12.html 2023-09-08 09:31am

**(ភ្នំពេញ)៖** ប្រធានាធិបតីសាធារណរដ្ឋកូរ៉េ (កូរ៉េខាងត្បូង) លោក យូន ស៊ុក យ៉ុល (Yoon Sok Yeol) បានសន្យាពិចារណាបង្កើនកូតា ពោលគឺបង្កើនចំនួនពលករខ្មែរចូលទៅធ្វើការនៅប្រទេសកូរ៉េ ឱ្យបានកាន់តែច្រើនថែមទៀត។

ការសន្យារបស់លោកប្រធានាធិបតី បានធ្វើឡើងនៅក្នុងជំនួបពិភាក្សាការងារជាមួយសម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី កាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣។ ទន្ទឹមនឹងការសន្យាបង្កើនកូតាពលករខ្មែរចូលទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូងហើយនោះ លោកប្រធានាធិបតីកូរ៉េខាងត្បូង ក៏បានសន្យាបន្តលើកទឹកចិត្តក្រុមហ៊ុនកូរ៉េ ឱ្យមកវិនិយោគនៅកម្ពុជា ជាពិសេសក្នុងវិស័យបច្ចេកវិទ្យាឌីជីថល។

ក្នុងឱកាសនោះ សម្ដេចធិបតី ហ៊ុន ម៉ាណែត បានអរគុណរដ្ឋាភិបាលកូរ៉េខាងត្បូង ដែលបានយកចិត្តទុកដាក់ ចំពោះពលករកម្ពុជា កំពុងស្នាក់នៅ និងធ្វើការងារនៅកូរ៉េ។ សូមបញ្ជាក់ថា គោលនយោបាយស្វះស្វែងរកការងារធ្វើជូនប្រជាពលរដ្ឋ គឺជានយោបាយអាទិភាពមួយ។ សម្រាប់ការងារទៀតសោតមិនថានៅក្នុងប្រទេស ឬក្រៅប្រទេសនោះទេ ឱ្យតែអាចផ្ដល់ប្រាក់ឈ្នួលល្អប្រសើរ ផ្ដល់ចំណូលទ្រទ្រង់ជីវភាពជូនប្រជាពលរដ្ឋ គឺរាជរដ្ឋាភិបាលតែងស្វះស្វែងរកជូនប្រជាពលរដ្ឋធ្វើ។

សម្រាប់ប្រទេសកូរ៉េខាងត្បូង គឺជាប្រទេសផ្ដល់លក្ខខណ្ឌការងារល្អប្រសើរ ហើយផ្ដល់នូវប្រាក់ឈ្នួលខ្ពស់ បានរួមចំណែកធ្វើឱ្យជីវភាពពលករកម្ពុជាបានល្អប្រសើរ។ សម្រាប់ប្រទេសកូរ៉េខាងត្បូង មិនត្រឹមតែកម្ពុជានោះទេ ដែលបានបញ្ជូនពលរដ្ឋទៅធ្វើការនៅទីនោះ មានប្រទេសក្នុងតំបន់អាស៊ីជាច្រើនបាននាំគ្នាសុំការអនុញ្ញាតពីកូរ៉េបញ្ជូនពលរដ្ឋទៅធ្វើការ។

យោងតាមរបាយការណ៍របស់ក្រសួងការងារ បានឱ្យដឹងថា ពលករខ្មែរដែលបម្រើការងារនៅកូរ៉េខាងត្បូង មានចំនួនប្រមាណ ៥ម៉ឺននាក់៕

## អភិបាលខេត្តកណ្ដាល
## ជំរុញឱ្យអាជ្ញាធរពាក់ព័ន្ធពង្រឹងការអនុវត្តច្បាប់ និងបង្រ្កាបបទល្មើសគ្រប់ប្រភេទ

https://www.postkhmer.com/national/2023-09-07-1605-254283.html បូរ ពេជ្យហ្វាលីន।

Publication date 07 September 2023 | 16:05 ICT

*កណ្ដាល:* អភិបាលខេត្តកណ្ដាល លោក គង់ សោភ័ណ្ឌ បានជំរុញឱ្យកងកម្លាំង អាជ្ញាធរក្រុង-ស្រុកទាំង ១៣ មន្ទីរអង្គភាពជុំវិញខេត្ត និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានខេត្តកណ្ដាទាំងអស់ឱ្យខិតខំពង្រឹងការអនុវត្តច្បាប់ និងត្រូវចាត់វិធានការទប់ស្កាត់ និងបង្រ្កាបបទល្មើសគ្រប់ប្រភេទឱ្យមានប្រសិទ្ធភាពថែមទៀត។ ការជំរុញនេះ បានធ្វើឡើងនៅក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែសីហា និងលើកទិសដៅអនុវត្តបន្តសម្រាប់ខែកញ្ញា ឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តកណ្ដាល កាលថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ដើម្បីពិនិត្យលើសមិទ្ធផលការងារជាច្រើន រួមជាមួយសំណូមពរ បញ្ហាប្រឈម និងទិសដៅការងារអនុវត្តបន្ត។

ក្នុងឱកាសនោះ លោក គង់ សោភ័ណ្ឌ បានណែនាំដល់អភិបាលក្រុង-ស្រុកទាំង១៣ ពិសេសអាជ្ញាធរពាក់ព័ន្ធនៅក្នុងខេត្ត ត្រូវពង្រឹងការអនុវត្តច្បាប់ និងត្រូវចាត់វិធានការបង្រ្កាបបទល្មើសគ្រប់ប្រភេទ។ លោកថ្លែងថា៖ «សូមឱ្យអាជ្ញាធរពាក់ព័ន្ធទាំងអស់ត្រូវពង្រឹងច្បាប់ និងត្រូវចាត់វិធានការបង្រ្កាបបទល្មើសគ្រប់ប្រភេទដូចជា ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ បញ្ហាគ្រឿងញៀន ការជួញដូរមនុស្ស និងការបង្ខិតបង្ខំពលកម្ម ឱ្យមានប្រសិទ្ធភាពនិងឱ្យបានតឹងរ៉ឹងជាប់ជាប្រចាំថែមទៀត»។

ជាមួយគ្នានេះ លោកក៏ណែនាំឱ្យអាជ្ញាធរបន្តចុះមូលដ្ឋានឱ្យបានជាប្រចាំ និងត្រូវបន្តរួមគ្នាខិតខំដោះស្រាយសំណូមពរ និងបញ្ហាប្រឈមនានា នៅតាមមូលដ្ឋាន ប្រកបដោយតម្លាភាព ជាពិសេសដោះស្រាយរាល់សំណូមពរ និងបញ្ហាប្រឈមដែលត្រូវបានលើកឡើងក្នុងវេទិកាសាធារណ: នាពេលកន្លងមកផងដែរ។

អភិបាលខេត្តកណ្ដាលបានបន្តថា៖« អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងមន្ទីរអង្គភាពជុំវិញខេត្តត្រូវបន្តយកចិត្តទុកដាក់ក្នុងការផ្ដល់សេវាសាធារណ:នានា ជូនប្រជាពលរដ្ឋ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ដែលកាន់តែមានការកើនឡើង ហើយចំពោះការផ្ដល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែ១វិញក៏ត្រូវបន្តលើកកម្ពស់ស្មារតីទទួលខុសត្រូវលើកិច្ចការងារ ដើម្បីធានាថា ប្រជាពលរដ្ឋគ្រប់រូបទទួលបានសេវារដ្ឋបាល កាន់តែងាយស្រួល និងកាន់តែឆាប់ប្រកបដោយតម្លាភាព»។

ជុំវិញរឿងនេះ នាយកទទួលបន្ទុកកិច្ចការទូទៅ នៃអង្គការលីកាដូ លោក អំ សំអាត បានថ្លែងថា ការជំរុញឱ្យមានការពង្រឹងការអនុវត្តច្បាប់ និងត្រូវចាត់វិធានការបង្រ្កាបបទល្មើសគ្រប់ប្រភេទ ពិសេសបទល្មើសល្បែងស៊ីសងខុសច្បាប់ បញ្ហាគ្រឿងញៀន និងការជួញដូរមនុស្សគឺជាកិច្ចការ

សំខាន់ ដែលអាជ្ញាធរពាក់ព័ន្ធត្រូវចាត់វិធានការបន្ទាន់។ លោកបានបញ្ជាក់ថា៖ «ដើម្បីសម្រេចកិច្ចការងារនេះ បញ្ហានេះ គឺទាមទារឱ្យពង្រឹងការអនុវត្តច្បាប់របស់សមត្ថកិច្ច ជាពិសេសការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ឱ្យកាន់តែល្អ និងមានប្រសិទ្ធភាពថែមទៀត និងត្រូវបង្កើនកិច្ចសហការល្អជាមួយភាគីពាក់ព័ន្ធឱ្យបានកាន់តែរឹងមាំថែមទៀត»។

រដ្ឋបាលខេត្តកណ្តាលបានឱ្យដឹងដែរថា ពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ដោយសារមានការខិតខំប្រឹងប្រែងពីអាជ្ញាធរបានធ្វើឱ្យបទល្មើសនានាថយចុះគួរឱ្យកត់សម្គាល់។ ជាក់ស្តែងក្នុងឆ្នាំ២០២២ បទល្មើសមានការថយចុះ៧៨ភាគរយ គួបផ្សំប្រតិបត្តិការបង្ក្រាបទទួលបានលទ្ធផលខ្ពស់រហូតដល់ ៩៦ភាគរយ លើកលែងតែគ្រោះថ្នាក់ចរាចរណ៍ ដែលមានការកើនឡើង១៩លើក ស្មើនឹង១០ភាគរយ។

នៅក្នុងកិច្ចប្រជុំនេះ ក្រៅពីស្នើឱ្យអាជ្ញាធរពាក់ព័ន្ធពង្រឹងការអនុវត្តច្បាប់ និងត្រូវចាត់វិធានការបង្ក្រាបបទល្មើសគ្រប់ប្រភេទហើយនោះ លោក គង់ សោភ័ណ្ឌ ក៏បានណែនាំដល់អភិបាលក្រុង-ស្រុកទាំង១៣ នៅក្នុងខេត្ត រួមជាមួយខណ្ឌរដ្ឋបាលជលផលខេត្តត្រូវបង្ក្រាបឱ្យបានបទល្មើសនេសាទខុសច្បាប់នៅតាមស្ទឹង បឹង ព្រែក ពិសេសបទល្មើសឆក់ត្រីតាមដងទន្លេនៅក្នុងភូមិសាស្ត្រខេត្តកណ្តាលផងដែរ៕

# ថ្ងៃទី១១ ខែ កញ្ញា ឆ្នាំ២០២៣

## រាជរដ្ឋាភិបាល នឹងធ្វើលិខិតឆ្លងដែនជូនពលករដែលធ្វើការនៅក្រៅប្រទេសដល់ទីកន្លែង

https://btv.com.kh/article/29963 2023/09/09 10:46:11 am

ភ្នំពេញ ៖ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃកម្ពុជា បានប្រកាសថា រាជរដ្ឋាភិបាល នឹងធ្វើការសម្របសម្រួលលិខិតឆ្លងដែនដល់បងប្អូនពលករដែលកំពុងធ្វើការនៅក្រៅប្រទេស ឲ្យដល់ប្រទេសដែលពួកគាត់ធ្វើការនៅទីនោះតែម្តង ដើម្បីសម្រួលដល់ការធ្វើដំណើរឡើងចុះ ខណៈគម្រោងនេះនឹងចាប់ផ្តើមធ្វើនៅប្រទេសកូរ៉េមុនគេតែម្តង។

ថ្ងៃនៅក្នុងឱកាសអញ្ជើញសំណេះសំណាលជាមួយកម្មករនិយោជិត ជិត២ម៉ឺននាក់ មកពីរោងចក្រសហគ្រាសចំនួន១៤ នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣នេះ សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីបានបញ្ជាក់ថា សម្តេចបានពិភាក្សាគ្នាជាមួយស្ថាប័នពាក់ព័ន្ធរួចខ្លះមកហើយដើម្បី សម្របសម្រួលលិខិតឆ្លងដែន ឬលិខិតស្នាមផ្សេងៗសម្រាប់បងប្អូនពលករខ្មែរដែលកំពុងធ្វើការនៅក្រៅប្រទេស ដើម្បីកុំឲ្យពួកគាត់ជួបការលំបាកក្នុងការចំណាយ

ថវិកាទៅមក ដោយសម្តេចធិបតីនាយករដ្ឋមន្ត្រី បានសម្រេចឲ្យមានការបង្កើតការិយាល័យនៅសាមីប្រទេសដែលពួកគាត់កំពុងធ្វើការតែម្តង។

ជាមួយគ្នានោះដែរ សម្តេចធិបតីនាយករដ្ឋមន្ត្រី ក៏បានបញ្ជាឲ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការគ្នាជាមួយក្រសួងពាក់ព័ន្ធ រៀបចំបង្កើតអគ្គកុងស៊ុលបន្ថែមទៀត នៅប្រទេសថៃ ដើម្បីផ្តល់ភាពងាយស្រួលដល់បងប្អូនពលករខ្មែរ ដែលកំពុងធ្វើការនៅទីនោះ ដោយសម្តេចធិបតីនាយករដ្ឋមន្ត្រី បានបញ្ជាក់ថា អគ្គកុងស៊ុល ដែលគ្រោងនឹងបង្កើតថ្មីបន្ថែមទៀតនេះ គឺមាននៅទីក្រុងបាងកក និងតំបន់ភាគខាងត្បូងប្រទេសថៃ។ អត្ថបទៈ បាន ចក់

## នាយករដ្ឋមន្ត្រីចេញបញ្ជាដោះស្រាយរឿងតម្លៃក្រៅផ្លូវការក្នុងការធ្វើលិខិតស្នាមតាមព្រំដែន

https://kohsantepheapdaily.com.kh/article/1800734.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ០៩ ខែ កញ្ញា ឆ្នាំ ២០២៣ ម៉ោង ១៣:៥០

រាជធានីភ្នំពេញ ៖ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី បានចេញបទបញ្ជាឲ្យស្ថាប័នពាក់ព័ន្ធដោះស្រាយការធ្វើលិខិតស្នាមផ្សេងៗ នៅតាមច្រកព្រំដែន ដែលមានការយកតម្លៃក្រៅផ្លូវការច្រើន។ ការចេញបញ្ជានេះ ដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់កម្មករ និងយោជិក ក៏ដូចជាប្រជាពលរដ្ឋ ដែលចង់ធ្វើដំណើរឆ្លងដែនទៅប្រទេសជិតខាងក្នុងគោលបំណងផ្សេងៗ ឱ្យមានភាពងាយស្រួល ។

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត បានថ្លែងយ៉ាងដូចនេះ នៅព្រឹកថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០២៣នេះ ក្នុងឱកាសបន្តជួបសំណេះសំណាលជាមួយកម្មករ និយោជិតសរុប១៨,២៦៥នាក់ទៀត មកពីរោងចក្រ សហគ្រាសនានា ក្នុងខេត្តកំពង់ស្ពឺ បានណែនាំឱ្យឧបនាយករដ្ឋមន្ត្រី នេត សាវឿន ធ្វើការ ជាមួយស្ថាប័នពាក់ព័ន្ធ ជាពិសេសខេត្តជាប់ព្រំដែន សំដៅធ្វើយ៉ាងណាផ្តល់ភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋធ្វើដំណើរឆ្លងកាត់ព្រំដែន ជាពិសេស ដោះស្រាយរឿងកម្រៃក្រៅសេវាពាក់ព័ន្ធនឹងការធ្វើលិខិតស្នាម សម្រាប់ការឆ្លងដែនទៅប្រទេសជិតខាង ។

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត បានបញ្ជាក់យ៉ាងដូច្នេះថា៖ «ខ្ញុំសុំប្រគល់ភារកិច្ចបន្ថិចដល់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី នេត សាវឿន សុំធ្វើការជាមួយនឹងគ្រប់ស្ថាប័ន នឹងខេត្តជាប់ព្រំដែន ដែលពាក់ព័ន្ធទៅលើគ្រប់ច្រកចេញ-ចូល ខ្ញុំស្តាប់ឮពីប្រជាពលរដ្ឋ ពលករ រឿងតម្លៃក្រៅផ្លូវការនេះច្រើនណាស់ ដែលគាត់ឆ្លងកាត់ត្រូវប្រឈម, ត្រូវរកវិធីនឹងដំណោះស្រាយដើម្បីកុំឱ្យពិបាកដល់បងប្អូនដែលត្រូវឆ្លងកាត់សុំជួយធ្វើនឹងមួយ» ។ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ក៏បានជំរុញឱ្យឧបនាយករដ្ឋមន្ត្រី នេត សាវឿន ជួយធ្វើការសម្របសម្រួលជាមួយក្រសួងការពារជាតិ, ក្រសួង

មហាផ្ទៃ , អគ្គនាយកដ្ឋានគយ និងរដ្ឋករផ្សេងៗ និងបណ្តាស្ថាប័នផ្សេងៗ ដែលពាក់ព័ន្ធជាមួយនឹងខេត្តជាប់ព្រំដែន ដើម្បីធ្វើយ៉ាងណាជួយរកដំណោះស្រាយណាមួយ ជួយសម្រួលដល់ការឆ្លងកាត់របស់ពលករ ដើម្បីកុំឱ្យមានការប្រឈមនឹងការលំបាកលើតម្លៃ ក្នុងការឆ្លងកាត់ព្រំដែននីមួយៗ ។

សម្តេចធិបតី ហ៊ុន ម៉ាណែត ក៏បានបញ្ជាក់ដែរថា កងកម្លាំងគ្រប់លំដាប់ថ្នាក់ រួមទាំងមន្ត្រីពាក់ព័ន្ធផ្សេងៗ គឺបានខិតខំប្រឹងប្រែងធ្វើការងារណាស់ ក្នុងរយៈពេលកូវីដ១៩ កន្លងមក ដើម្បីធានានូវប្រក្រតីភាពទំនាក់ទំនង ជាមួយនឹងបណ្តាប្រទេសជិតខាង ដែលរួមមានការខិតខំទាំងបណ្តាអាជ្ញាធរខេត្ត ប៉ូលិស អាវុធហត្ថ គយ ដើម្បីសម្រួលនិងគ្រប់គ្រង លើការធ្វើដំណើរឆ្លងកាត់ព្រំដែននេះ ។ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត បានឱ្យដឹងទៀតថា នាពេលកន្លងមក កងកម្លាំងគ្រប់លំដាប់ថ្នាក់ រួមទាំងមន្ត្រីពាក់ព័ន្ធទាំងអស់ បានខិតខំធ្វើការងារជាច្រើន តែក៏នៅមានការងារមួយចំនួន ជាពិសេសរឿងពាក់ព័ន្ធនឹងតម្លៃប្រជាពលរដ្ឋឆ្លងកាត់ព្រំដែននេះ សុំធ្វើយ៉ាងណារកដំណោះស្រាយមួយឱ្យមានថេរភាពតែម្តង ដើម្បីជួយដល់ពលករ ដែលធ្វើដំណើរទៅធ្វើការនៅក្រៅប្រទេសឱ្យមានភាពងាយស្រួល ។

## Nikkei Asia៖ កេរ្តិ៍ឈ្មោះជាជម្រកនៃបទល្មើសឆបោក គឺជារនាំងលំហូរទេសចរចិនមកកម្ពុជា

https://www.rfi.fr/km//20230908-nikkei-asia៖-?utm_medium=social&utm_campaign=telegram&utm_source=shorty

ចុះផ្សាយនៅថ្ងៃ៖ 08/09/2023 - 10:11

ការលេចឡើងជាទីតាំងសម្ងំលាក់ខ្លួនរបស់ក្រុមឧក្រិដ្ឋជនឆបោកអនឡាញ បានប៉ះពាល់ដល់រូបភាពកម្ពុជា ក្នុងខ្សែភ្នែកទេសចរចិន ហើយដែលប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជាក្នុងការទាក់ទាញទេសចរចិនឡើងវិញ ក្រោយវិបត្តិកូវីដ១៩។ នេះបើតាមអត្ថបទព័ត៌មានមួយ របស់កាសែតជប៉ុនNikkei Asiaនៅថ្ងៃសុក្រនេះ។ នៅចំពោះមុខនេះ លោកធួន ស៊ីណាន ប្រធានសមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិកកម្ពុជា បានឯកភាពថា បញ្ហាឆបោកតាមប្រព័ន្ធអនឡាញនេះ អាចជះផលអវិជ្ជមានលើវិស័យទេសចរណ៍របស់កម្ពុជានេះមែន ដែលលោកស្នើឲ្យមានការស្រាវជ្រាវបន្ថែមលើបញ្ហានេះ។

កេរ្តិ៍ឈ្មោះកម្ពុជាក្នុងប្រទេសចិន បានរងការបំផ្លិចបំផ្លាញ ដោយមានការលើកឡើងថាកម្ពុជាគឺជាជម្រកលាក់ខ្លួន របស់ក្រុមឆបោកអនឡាញ និងដែលជាមួយគ្នានេះនាំឲ្យមានហានិភ័យនៃការធ្លាក់ចូលទៅក្នុងការឆបោកឲ្យធ្វើការដោយបង្ខំ។ នេះបើយោងតាមការលើកឡើងនៅក្នុងអត្ថបទព័ត៌មានមួយរបស់កាសែតជប៉ុន Nikkei Asia នៅថ្ងៃទី៨ ខែកញ្ញានេះ ដោយសង្កត់ធ្ងន់ថា បញ្ហានេះ បានប៉ះពាល់វិស័យទេសចរកម្ពុជា ខណៈដែលរដ្ឋាភិបាលកម្ពុជាខិតខំស្តារវិស័យដ៏សំខាន់សម្រាប់សេដ្ឋកិច្ចជាតិមួយនេះ ដោយទាក់ទាញទេសចរចិនឡើងវិញ ក្រោយចិនបើកច្រក

ព្រំដែនរបស់ខ្លួនបន្ទាប់ពីវិបត្តិកូវីដកាលពីដើមឆ្នាំ២០២៣។ ជាមួយគ្នានេះ តាមNikkei Asia ទីតាំងប្រព្រឹត្តបទល្មើសឆបោកជាច្រើននៅក្នុងប្រទេសកម្ពុជានេះ នៅតែត្រូវបានគេមើលឃើញថាបន្តដំណើរការ បើទោះបីជាអាជ្ញាធរកម្ពុជា បានបើកបេសកម្មបង្ក្រាបអំពើឆបោកនេះកាលពីខែកញ្ញាឆ្នាំ២០២២ក្តី ។

ភ្នាក់ងារទេសចរចិនក្នុងប្រទេសកម្ពុជា លោក Yang Ming បានថ្លែងប្រាប់កាសែត Nikkei Asia ថា បន្ទាប់ពីចិនបានដកចោលគោលនយោបាយសូន្យកូវីដមក ស្ទើរតែគ្មានក្រុមអ្នកទេសចរចិន ឬភ្ញៀវទេសចរចិនសុទ្ធសាធមកលេងនោះទេ ក្រៅតែពីជាគណៈប្រតិភូឬភ្ញៀវ ដែលធ្វើដំណើរក្នុងគោលបំណងបេសកម្មការងារតែប៉ុណ្ណោះ។ លោកYang Ming យល់ថា កត្តាមួយដែលនាំឲ្យការរៀបចំដំណើរទេសចរនេះ បានជួបផលលំបាក គឺដោយសារតែកេរ្តិ៍ឈ្មោះរបស់ប្រទេសកម្ពុជានេះ។ តាមបទពិសោធន៍របស់ភ្នាក់ងារទេសចររូបនេះ កាលពីខែឧសភា គឺអ្នកដំណើរចិនដល់១០០នាក់ ក្នុងចំណោម២៤០នាក់ បានសម្រេចមិនធ្វើដំណើរមកកម្ពុជាវិញ ក្រោយប៉ូលីសចិនបានប្រាប់ពួកគេថា ប្រទេសកម្ពុជាជាប្រទេសមិនសុវត្ថិភាពនោះឡើយ។

បញ្ហាប្រព្រឹត្តអំពើឆបោកអនឡាញក្នុងប្រទេសកម្ពុជានេះទៀតសោត ក៏ត្រូវបានគេសង្កេតឃើញថា ទទួលបានការចាប់អារម្មណ៍ពីសំណាក់អន្តរជាតិផងដែរ។ កាលពីខែមិថុនាកន្លងទៅនេះ អង្គការប៉ូលីសឧក្រិដ្ឋកម្មអន្តរជាតិ អាំងទែប៉ូល (Interpol) បានព្រមានថា ទីតាំងប្រព្រឹត្តអំពើឆបោកទ្រង់ទ្រាយធំ ដែលបានរីកដាលពីប្រទេសកម្ពុជា ទៅប្រទេសឡាវ និងភូមានេះ គឺជាការគំរាមកំហែងសកលមួយ។ របាយការណ៍មួយរបស់អង្គការសហប្រជាជាតិ ក៏បានប៉ាន់ប្រមាណថា មានមនុស្សប្រមាណ១០ម៉ឺននាក់ ត្រូវបានឆបោកចូលក្នុងប្រទេសកម្ពុជាផងដែរ។ ជាងនេះទៅទៀត យុទ្ធនាការផ្សព្វផ្សាយពីបញ្ហាឆបោកតាមប្រព័ន្ធអនឡាញរបស់រដ្ឋាភិបាលចិនធំមួយ គឺធ្វើឡើងតាមរយៈ ភាពយន្តមួយដែលមានចំណងជើងថា «No More Bets» ដែលបានរៀបរាប់ពីរឿងរ៉ាវរបស់អ្នកសរសេរកម្មវិធី និងតារាម៉ូដែល ដែលត្រូវបានគេបោកបញ្ឆោត ចូលមកក្នុងទីតាំងឆបោកមួយកន្លែង ក្នុងតំបន់អាស៊ីអាគ្នេយ៍។ បើទោះបីជាមិនបញ្ជាក់ថាច្បាស់ថាជាប្រទេសណាក្តី ក៏ប៉ុន្តែ ឈុតមួយក្នុងភាពយន្តនេះ បានបង្ហាញពីតួអង្គម្នាក់មានពាក់អាវយឺតមួយ ដែលមានអក្សរខ្មែរ។

សូមបញ្ជាក់ថា យោងតាមក្រសួងទេសចរណ៍កម្ពុជា មុនវិបត្តិកូវីដ១៩ កម្ពុជាទទួលបានភ្ញៀវទេសចរចិនចំនួន២.៣៦លាននាក់ក្នុងឆ្នាំ២០១៩ ដែលបង្កើតប្រាក់ចំណូលបានប្រហែល ១.៨ពាន់លានដុល្លារ ខណៈដែលការវិនិយោគរបស់ចិនក្នុងវិស័យដែលទាក់ទងនឹងទេសចរណ៍តំណាងឱ្យជាង ៩០ ភាគរយនៃការវិនិយោគផ្ទាល់ពីបរទេស (FDI) សរុបរបស់កម្ពុជា។ ចំណែក

អំឡុងកូវីដ១៩ ក្នុងឆ្នាំ២០២១ កម្ពុជាទទួលបានភ្ញៀវទេសចរចិនតែប្រមាណ៤ម៉ឺន៥ពាន់នាក់ប៉ុណ្ណោះ ក៏ប៉ុន្តែបានកើនដល់ប្រមាណ១០ម៉ឺននាក់វិញ ក្នុងឆ្នាំ២០២២។ ដោយឡែកនៅដើមឆ្នាំ២០២៣នេះ កម្ពុជាបានដាក់គោលដៅទាក់ទាញភ្ញៀវទេសចរចិន ឲ្យបានចំនួន១លាននាក់ ខណៈមានភ្ញៀវទេសចរចិនសរុបប្រមាណជិត២សែន៧ម៉ឺននាក់ បានធ្វើដំណើរមកប្រទេសកម្ពុជាក្នុងឆមាសទី១កន្លងទៅនេះ៕

## លោកស្រី ឆាយ ស៊ីវលីនៈ
## ករណីឆបោកនិងចាប់ជំរិតក្នុងកម្ពុជា ពិតជារាំងខ្ទប់លំហូរទេសចរចិន

https://www.rfi.fr/km//20230908-?utm_medium=social&utm_campaign=telegram&utm_source=shorty ចុះផ្សាយនៅថ្ងៃ៖ 08/09/2023 - 14:37

ថ្លែងប្រាប់វិទ្យុបារាំងអន្តរជាតិ RFI នៅថ្ងៃសុក្រនេះ លោកស្រីឆាយ ស៊ីវលីន ប្រធានសមាគមទេសចរណ៍កម្ពុជា បានឯកភាពថា ករណីឆបោកនិងចាប់ជំរិតក្នុងប្រទេសកម្ពុជា ពិតជារនាំងមួយរាំងខ្ទប់លំហូរទេសចរចិនមកកម្ពុជា ក្រោយករណីទាំងនេះ ត្រូវបានផ្សព្វផ្សាយដល់សាធារណជនចិនទាំងមូល។ ទន្ទឹមគ្នានេះ លោកស្រីគូសបញ្ជាក់ដែរថា លំហូរទេសចរចិនមកកម្ពុជា បច្ចុប្បន្ននេះនៅមានកម្រិតនៅឡើយ ខណៈអ្នកដំណើរភាគច្រើនមកកម្ពុជា គឺដើម្បីបំពេញបេសកកម្មការងារប៉ុណ្ណោះ ដោយមិនមែនក្នុងគោលដៅទេសចរសុទ្ធសាធឡើយ។ ការបញ្ជាក់ពីលោកស្រី ឆាយ ស៊ីវលីន យ៉ាងដូច្នេះ ធ្វើឡើងនៅចំពោះមុខកាសែតជប៉ុន Nikkei Asia ដែលបានចុះផ្សាយអត្ថបទមួយក្រោមចំណងជើងថា «កេរ្តិ៍ឈ្មោះកម្ពុជាជាជម្រកនៃបទល្មើសឆបោក គឺជារនាំងលំហូរទេសចរចិនមកកម្ពុជា»។

## ការដាក់ពាក្យ
## ស្នើសុំកូតាបុគ្គលិកបរទេសមកធ្វើការនៅកម្ពុជាឆ្នាំ២០២៤ ឥឡូវត្រូវបានបើក

https://www.khmertimeskh.com/501357685//?p=1357685 Khmer Times September 9, 2023

កម្ពុជាបានបើកកម្មវិធីសម្រាប់អាជីវកម្ម ដើម្បីដាក់ពាក្យស្នើសុំកូតាបុគ្គលិកបរទេស។ នៅក្រោមប្រព័ន្ធកូតា ក្រុមហ៊ុនក្នុងស្រុកដែលមានបុគ្គលិកបរទេស អាចមានត្រឹម ១០ភាគរយ។ រដ្ឋាភិបាលកម្ពុជាបានបើកកម្មវិធីសម្រាប់អាជីវកម្ម ដើម្បីដាក់ពាក្យសុំកូតាបុគ្គលិកបរទេស។ ការដាក់ពាក្យស្នើសុំ នឹងផុតកំណត់ នៅចុងខែវិច្ឆិកា ឆ្នាំ២០២៣។ យោងតាមច្បាប់ការងាររបស់កម្ពុជា អាជីវកម្ម ដែលចង់ជួលបុគ្គលិកបរទេស ត្រូវដាក់ពាក្យសុំកូតានិយោជិតបរទេសពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

វិធីគណនាមានដូចខាងក្រោម:

- បុគ្គលិកការិយាល័យ បីភាគរយ
- កម្មករជំនាញ ប្រាំមួយភាគរយ និង
- កម្មករគ្មានជំនាញ មួយភាគរយ។

បន្ទាប់ពីទទួលបានកូតារួច ក្រុមហ៊ុនអាចស្នើសុំបណ្ណការងារតាមរយៈប្រព័ន្ធគ្រប់គ្រងទិន្នន័យពលករបរទេសរបស់កម្ពុជាឬហៅកាត់ (FWCMS)។

**តើក្រុមហ៊ុនអាចមានកូតាបុគ្គលិកបរទេសលើសពីនេះបានទេ?**

អាជីវកម្មនៅក្នុងប្រទេសកម្ពុជាអាចមានកូតានិយោជិតបរទេសលើសបាន ប្រសិនបើពួកគេគោរពតាមច្បាប់ដូចខាងក្រោម:

- ម្ចាស់ ឬនាយកក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីជួលបុគ្គលិកបរទេសបន្ថែម ដោយមានកិច្ចសន្យាការងាររបស់ពួកគេភ្ជាប់មកជាមួយ។
- បំពេញពាក្យសុំប័ណ្ណការងារតាមរយៈប្រព័ន្ធគ្រប់គ្រងទិន្នន័យពលករបរទេសរបស់កម្ពុជា
- បង់ថ្លៃប័ណ្ណការងារ។
- និងមានទិដ្ឋាការ ឬប័ណ្ណស្នាក់នៅដែលមានសុពលភាពសម្រាប់បុគ្គលិកបរទេស។

**អធិការកិច្ចបណ្ណពលករបរទេស**

ធុរកិច្ចបរទេសដែលកំពុងប្រតិបត្តិការក្នុងប្រទេសកម្ពុជាគួរតែដឹងថារដ្ឋាភិបាល ចុះត្រួតពិនិត្យលិខិតអនុញ្ញាតពលករបរទេសតាមរយៈក្រុមអធិការកិច្ចពលកម្មបរទេសចម្រុះ (JFWIT)។ ការចុះត្រួតពិនិត្យនេះអាចត្រូវបានធ្វើឡើងដោយមានឬគ្មានការជូនដំណឹងជាមុន។

មន្ត្រីអធិការកិច្ចអាចស្នើពិនិត្យច្បាប់ចម្លងឯកសារសំខាន់ៗមួយចំនួនដូចជា៖

- លក្ខន្តិកៈក្រុមហ៊ុន
- លិខិតអនុញ្ញាតកូតាដើម្បីជួលបុគ្គលិកបរទេស
- កិច្ចសន្យាការងាររបស់និយោជិតបរទេស
- លិខិតឆ្លងដែន និងទិដ្ឋាការរបស់និយោជិតបរទេស ឬប័ណ្ណការងារ និងសៀវភៅការងាររបស់និយោជិតបរទេស ក្នុងចំណោមឯកសារផ្សេងៗទៀត។
- របៀបទទួលបានប័ណ្ណការងារនៅកម្ពុជា

ពលករបរទេសដែលកំពុងស្វែងរកការងារក្នុងប្រទេសកម្ពុជានឹងត្រូវមានទិដ្ឋាការអាជីវកម្មដែលមានសុពលភាពប្រភេទ(ង) (E-class visa)។ ទិដ្ឋាការប្រភេទ(ង) ឬE-class មានសុពលភាពដំបូងសម្រាប់

រយៈពេល៣០ថ្ងៃ។ ទិដ្ឋាការអាចបន្តបានក្នុងរយៈពេលមួយខែ បីខែ ប្រាំមួយខែ ឬអតិបរមាមួយឆ្នាំក្នុងពេលតែមួយ ដោយដាក់ពាក្យសុំនៅនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ។

ទិដ្ឋាការរយៈពេល៦ខែ និង១២ ខែអនុញ្ញាតឱ្យអ្នកដាក់ពាក្យស្នើសុំចូលប្រទេសកម្ពុជាបានច្រើនលើកខណៈដែលទិដ្ឋាការរយៈពេល១ខែ និង៣ខែ អាចចូលបានតែមួយលើក។ ទិដ្ឋាការអេឡិចត្រូនិកអាចទទួលបាននៅស្ថានទូតកម្ពុជាដែលនៅជិតបំផុតរបស់និយោជិត និងពេលមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ បន្ថែមពីលើ E-visa ពលករបរទេសក៏ត្រូវមានប័ណ្ណការងារ និងសៀវភៅការងារផងដែរ។ នេះគឺជាការទទួលខុសត្រូវរបស់និយោជកដែលនឹងដាក់ពាក្យតាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ក្រុមហ៊ុននឹងត្រូវផ្តល់ព័ត៌មានខាងក្រោមដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖

- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មប៉ាតង់ដោយមានត្រាក្រុមហ៊ុន
- អាសយដ្ឋានអាជីវកម្មដែលបានចុះបញ្ជី
- ប៉ាតង់ពន្ធជាមួយត្រាក្រុមហ៊ុន
- លិខិតអនុញ្ញាតកូតានិយោជិតបរទេស
- លិខិតអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម; និង
- លក្ខន្តិកៈក្រុមហ៊ុន។

ឯកសារដែលត្រូវការនៅកម្រិតបុគ្គលិក៖

- សំណុំបែបបទពាក្យសុំចំនួនបីដែលចេញដោយក្រសួងមហាផ្ទៃ
- ច្បាប់ចម្លងលិខិតឆ្លងដែនដែលមានទិដ្ឋាការសុពលភាព
- រូបថតបីសន្លឹក (4 × 6)
- វិញ្ញាបនប័ត្រសុខភាព; និង
- កិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរពីនិយោជក។

*ASEAN Briefing*

# គុយបាចាប់ខ្លួនមនុស្ស ១៧នាក់ ពាក់ព័ន្ធនឹងការជួញដូរក្រុមបុរសឲ្យទៅប្រយុទ្ធនៅអ៊ុយក្រែន

https://freshnewsasia.com/index.php/en/internationalnews/309532-2023-09-08-08-14-59.html

2023-09-08 03:14pm

*(ឡាហាវ៉ា)៖ អាជ្ញាធររបស់ប្រទេសគុយបា បានចាប់ខ្លួនមនុស្សចំនួន ១៧នាក់ ពីបទជួញដូរមនុស្ស ដោយចោទប្រកាន់ពីការព្យាយាម ទាក់ទាញក្រុមបុរសៗវ័យក្មេងគុយបា ឲ្យចូលរួមជាមួយយោធារុស្ស៊ីទៅប្រយុទ្ធនៅអ៊ុយក្រែន។ នេះបើយោងតាមការចេញផ្សាយ ដោយទីភ្នាក់ងារសារព័ត៌មាន AFP នៅថ្ងៃសុក្រ ទី៨ ខែកញ្ញា ឆ្នាំ២០២៣។*

*ក្រសួងការបរទេសគុយបា បានឲ្យដឹងថា អាជ្ញាធរកំពុងធ្វើការដើម្បីរុះរើបណ្ដាញធ្វើប្រតិបត្តិការនៅគុយបា និងរុស្ស៊ី។ លោក សេសា រ៉ូឌ្រីហ្គេស (Cesar Rodriguez) វរសេនីយ៍ក្រសួងមហាផ្ទៃ បានបញ្ជាក់ថា ជាលទ្ធផលនៃការស៊ើបអង្កេតមនុស្ស ១៧នាក់ ត្រូវបានចាប់ខ្លួនមកទល់នឹងពេលនេះ ដោយក្នុងចំណោមពួកគេក៏មានអ្នករៀបចំសកម្មភាពខាងផ្ទៃក្នុងផងដែរ។ មេដឹកនាំក្រុមនេះ ពឹងផ្អែកលើមនុស្ស ២នាក់ ដែលរស់នៅគុយបា ឲ្យជ្រើសរើសជនជាតិគុយបា ដើម្បីទៅចូលរួមប្រយុទ្ធនៅអ៊ុយក្រែនក្នុងនាមរុស្ស៊ី ជាថ្នូរនឹងការបង់ប្រាក់។*

*បើតាមរដ្ឋអាជ្ញាគុយបា លោក ចូស លូអ៊ីស (Jose Luis Reyes) អ្នកដែលជាប់ពាក់ព័ន្ធក្នុងរឿងនេះ អាចនឹងត្រូវផ្ដន្ទាទោស ដាក់ពន្ធនាគាររហូតដល់ ៣០ឆ្នាំ ឬទោសប្រហារជីវិត អាស្រ័យលើភាពធ្ងន់ធ្ងរ និងប្រភេទនៃបទឧក្រិដ្ឋ ដូចជាការជួញដូរមនុស្ស ការប្រយុទ្ធគ្នាក្នុងនាមជាទាហានស៊ីឈ្នួល ក៏ដូចជាការប្រព្រឹត្តសកម្មភាពអរិភាពប្រឆាំងនឹងរដ្ឋបរទេស ជាដើម។*

*គួរបញ្ជាក់ថា រុស្ស៊ី គឺជាគោលដៅដ៏សំខាន់សម្រាប់គុយបា ដែលស្វែងរកការគេចចេញពីភាពជាប់គាំងសេដ្ឋកិច្ច ជាយូរមកហើយ។ គុយបា បានបដិសេធរួមចំណែកក្នុងសង្គ្រាមនៅអ៊ុយក្រែន និងការប្រើពលរដ្ឋរបស់ខ្លួនជាទាហានស៊ីឈ្នួល៕*

# ថ្ងៃទី១៣ ខែ កញ្ញា ឆ្នាំ២០២៣

## សម្តេចធិបតី ហ៊ុន ម៉ាណែត៖ នៅលើលោកនេះ គ្មានប្រទេសណារាំងខ្ទប់ពលរដ្ឋមិនឱ្យចេញទៅធ្វើការនៅក្រៅប្រទេសឡើយ

https://freshnewsasia.com/index.php/en/localnews/309626-2023-09-09-06-22-50.html 2023-09-09 01:22pm

**(កំពង់ស្ពឺ)៖** *សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃកម្ពុជា បានថ្លែងថា នៅលើពិភពលោកនេះ គ្មានប្រទេសណារាំងខ្ទប់ប្រជាពលរដ្ឋរបស់ខ្លួនមិនឱ្យចេញទៅធ្វើការនៅក្រៅប្រទេសនោះឡើយ ព្រោះការងារនៅក្រៅប្រទេស គឺជាជម្រើសការងារសម្បូរបែប សម្រាប់ប្រជាពលរដ្ឋ បង្កើនប្រាក់ចំណូល។ ការថ្លែងបែបនេះរបស់សម្តេចធិបតី ហ៊ុន ម៉ាណែត ធ្វើឡើងក្នុងឱកាសជួបសំណេះសំណាលជាមួយកម្មករនិយោជិតប្រមាណជិត២ម៉ឺននាក់ នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣។*

*សម្តេចធិបតីបានឱ្យដឹងថា «**យើងខិតខំបង្កើនការងារជូនប្រជាជននៅក្នុងប្រទេស តែក៏មិនហាមឃាត់អ្នកទៅធ្វើការនៅក្រៅប្រទេសដែរ ហើយនៅលើពិភពលោកនេះ គ្មានគោលនយោបាយណា ដែលហាមឃាត់ពលករមិនឱ្យចេញទៅក្រៅប្រទេសទៅធ្វើការនោះទេ**»។ សម្តេចធិបតីនាយករដ្ឋមន្ត្រីបានបន្តថា រដ្ឋាភិបាលនៃប្រទេសនៅលើពិភពលោកនេះ មានតែការខិតខំជំរុញរំហូរពលករកម្ម រំហូរផលិតផល ទំនិញ ខិតខំលើកទឹកចិត្ត ដើម្បីឱ្យប្រជាពលរដ្ឋមានជម្រើសការងារកាន់តែច្រើន។ រាជរដ្ឋាភិបាលកម្ពុជានៅតែខិតខំទាក់ទាញវិនិយោគនៅក្នុងប្រទេស ពង្រីកឱកាសការងារជូនប្រជាពលរដ្ឋ លើកកម្ពស់ជីវភាពប្រជាពលរដ្ឋ ដើម្បីកុំឱ្យប្រជាពលរដ្ឋពិបាករកការងារធ្វើការ តែយ៉ាងណាកម្ពុជាមិនអាចលើកកម្រិតប្រាក់បៀវត្សរ៍ស្មើប្រាក់បៀវត្សរ៍នៅសហរដ្ឋអាម៉េរិក សូម្បីតែកូរ៉េខាងត្បូងក៏មិនអាចស្មើអាម៉េរិកបានដែរ។*

*សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត បានបញ្ជាក់ទៀតថា ប្រទេសខ្លះត្រូវការកម្លាំងពលកម្មក្នុងប្រទេស ដោយសារកំណើនប្រជាជនទាប អត្រាមនុស្សចាស់កើនឡើង ដូច្នេះត្រូវបើករំហូរពលកម្មពីក្រៅប្រទេស តួយ៉ាងដូចជាប្រទេសសិង្ហបុរី ដែលកំពុងត្រូវកម្លាំងពលកម្មពីម៉ាឡេស៊ី ពីឥណ្ឌូណេស៊ី ពីកម្ពុជា ពីវៀតណាមជាដើម ហើយនៅប្រទេសជប៉ុនក៏ត្រូវការកម្លាំងពលកម្មពីក្រៅប្រទេសដូចគ្នា។ សម្តេចធិបតីបានបន្តទៀតថា សូម្បីប្រទេសដែលកំពុងមានពលករកម្ពុជា ក៏មានការបញ្ជូនពលកររបស់ខ្លួនទៅធ្វើការនៅក្រៅប្រទេសដែរ ដូចជា ពលករថៃទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូង ចក្រភពអង់គ្លេសជាដើម។*

គួរជម្រាបថា ពលករខ្មែរដែលកំពុងធ្វើការងារនៅក្រៅប្រទេស គឺមាននៅប្រទេសថៃជាង១.២លាននាក់ កូរ៉េខាងត្បូងមានជាង៥ម៉ឺននាក់ ជប៉ុនជាង២ម៉ឺននាក់ ក្រៅពីនេះមាននៅម៉ាឡេស៊ី សិង្ហបុរី តំបន់រដ្ឋបាលពិសេសហុងកុងជាដើម។

## ឆបោកការងារ៖ ស្ត្រីវៀតណាមម្នាក់ រងទារុណកម្មដល់ស្លាប់ ក្នុងប្រទេសកម្ពុជា

https://www.rfi.fr/km//20230909-?utm_medium=social&utm_campaign=telegram&utm_source=shorty ចុះផ្សាយនៅថ្ងៃ៖ 09/09/2023 - 07:15

ស្ត្រីជនជាតិវៀតណាមម្នាក់ ក្នុងចំណោម៥នាក់ ត្រូវបានធ្វើទារុណកម្មដល់ស្លាប់ ក្រោយត្រូវបានក្រុមឆបោក រត់ពន្ធមកចាប់ជំរិតក្នុងប្រទេសកម្ពុជា។ ជនឆបោកបានរត់ពន្ធជនរងគ្រោះទាំង៥នាក់នេះ ចូលក្នុងប្រទេសកម្ពុជា កាលពីថ្ងៃទី២៥សីហាកន្លងទៅ ក្រោមការសន្យាថាពួកគេនឹងបានការងារល្អធ្វើនៅកោះតៃវ៉ាន់។ អំឡុងជាប់ឃុំឃាំងក្នុងស្រុកកោះធំ ខេត្តកណ្ដាល សាច់ញាតិរបស់ជនរងគ្រោះ៣នាក់ ក៏ត្រូវបានជំរិតទារប្រាក់អស់ប្រមាណ២០៨០០ដុល្លារផងដែរ។

យោងតាមការផ្សាយរបស់កាសែតវៀតណាម VN Express នៅថ្ងៃព្រហស្បតិ៍ ទី៧ ខែកញ្ញា ឆ្នាំ២០២៣ ពលរដ្ឋរស់នៅភាគខាងជើងវៀតណាមចំនួន៥នាក់ ត្រូវបានរត់ពន្ធចូលមកក្នុងប្រទេសកម្ពុជា កាលពីថ្ងៃទី២៥ ខែសីហា ថ្មីៗនេះ ហើយក៏ត្រូវបានគេចាប់ជំរិត ធ្វើទារុណកម្មរហូតដល់មានស្ត្រីម្នាក់បានរបួសផ្នែកខួរក្បាលយ៉ាងធ្ងន់ធ្ងរ ស្លាប់បាត់បង់ជីវិត។ យោងតាមប៉ូលីសវៀតណាម ពួកគេបានចាញ់បោកជនឆបោកដែលជាជនជាតិវៀតណាមដូចគ្នា ក្រោមការសន្យាថានឹងរកការងារឲ្យពួកគេបានធ្វើនៅកោះតៃវ៉ាន់។ ជនរងគ្រោះទាំង៥ មានវ័យចន្លោះពី៣២ទៅ៣៩ឆ្នាំ ក្នុងនោះមានបុរសចំនួន៣នាក់ និងស្ត្រី២នាក់។

យោងតាមប៉ូលីសវៀតណាម ក្នុងខែសីហា ឆ្នាំ២០២៣ ជនរងគ្រោះទាំង៥ បានទាក់ទងជនឆបោកដែលឈ្មោះ Truong Van Chung ដោយស្នើសុំឲ្យជនឆបោករូបនេះ ជួយបញ្ជូនពួកគេទៅធ្វើការងារខុសច្បាប់ក្នុងកោះតៃវ៉ាន់។ លុះដល់ថ្ងៃទី២៥ ខែសីហា លោក Chung និងប្រពន្ធបាននាំពួកគេមកស្នាក់នៅសណ្ឋាគារមួយក្នុងក្រុងហូជីមិញ ដើម្បីបញ្ជូនបន្តទៅឆ្លងព្រំដែនចូលប្រទេសកម្ពុជា ក្នុងខេត្ត An Giang។ ជាថ្ងៃដែលពួកគេត្រូវបានរត់ពន្ធ ចូលមកឃុំឃាំងក្នុងផ្ទះមួយដែលស្ថិតនៅស្រុកកោះធំ ខេត្តកណ្ដាល។ នៅទីនោះ ជនចាប់ជំរិតដែលសុទ្ធតែបានពាក់ម៉ាសលាក់បាំងអត្តសញ្ញាណ បានប្រើកាំភ្លើងនិងកាំបិត គំរាមពួកគេ វាយដំច្រំជាក់ ព្រមទាំងចងពួកគេទុកឲ្យជាប់ឃុំឃាំង។ បន្ទាប់មក ជនចាប់ជំរិតដែលបំពាក់ដោយអាវុធ បានទាក់ទងទៅគ្រួសារ

ជនរងគ្រោះតាមបណ្តាញទំនាក់ទំនងសង្គម ដើម្បីជំរិតទារប្រាក់ ដោយបានផ្ញើវីដេអូជនរងគ្រោះ ដែលរងការធ្វើទារុណកម្ម។

ប្រឈមបែបនេះ គ្រួសាររបស់ជនរងគ្រោះ៣នាក់ បានយល់ព្រមផ្ញើប្រាក់សរុប៥០០លាន VND ឬស្មើប្រមាណ២០៨០០ដុល្លារ ទៅឲ្យជនចាប់ជំរិត។ ក៏ប៉ុន្តែគ្រួសាររបស់ជនរងគ្រោះ២នាក់ទៀត រួមទាំងគ្រួសាររបស់ជនរងគ្រោះដែលបានបាត់បង់ជីវិត មិនបានផ្ញើប្រាក់ទៅតាមការទាមទាររបស់ជនចាប់ជំរិតនោះទេ។ បែបនេះហើយដែលនាំឲ្យស្ត្រីវៀតណាមម្នាក់នេះ បានរងការវាយដំច្រំជាក់ ប៉ះពាល់សរីរាង្គខួរក្បាល រហូតដល់បាត់បង់ជីវិត។ ជាសំណាងមួយក្នុងចំណោមគ្រោះថ្នាក់ ឆ្លៀតក្នុងពេលដែលជនចាប់ជំរិតធ្វេសប្រហែល ជនរងគ្រោះ៤នាក់ផ្សេងទៀត ក៏បានលួចរត់គេចខ្លួន ហើយក៏បានហែលឆ្លងទឹកទន្លេបន្តឆ្លងទៅច្រកទ្វារអន្តរជាតិ Long Binh ក្នុងខេត្ត An Giang។

គិតមកទល់នឹងពេលនេះ ប៉ូលីសវៀតណាមបានចាប់ខ្លួនជនចាប់ជំរិតចំនួន៣នាក់ និងប្តីប្រពន្ធវៀតណាម២នាក់ ដែលរត់ពន្ធពួកគេចូលក្នុងប្រទេសកម្ពុជានេះ។ ប៉ូលីសវៀតណាមក៏បានអះអាងថា បានសហការជាមួយប៉ូលីសខ្មែរ បញ្ជូនសាកសពជនរងគ្រោះមកប្រទេសវៀតណាមវិញផងដែរ។ លើសពីនេះ ប៉ូលីសវៀតណាម អះអាងថា កំពុងបន្តការស៊ើបអង្កេត ស្វែងរកបក្សពួកបន្ថែមពាក់ព័ន្ធនៅក្នុងករណីនេះ។

យោងតាម VN Express ករណីពលករវៀតណាមដែលបានព្រមព្រៀងជាមួយជនឆបោកជួយនាំពួកគេទៅប្រទេសមួយ ដើម្បីបានធ្វើការខុសច្បាប់ក្នុងប្រទេសមួយផ្សេងទៀត មិនមែនជាករណីកម្រនោះទេ។ ក៏ប៉ុន្តែ ស្ទើរតែគ្រប់ករណីហើយ ដែលនេះគឺដោយសារជនរងគ្រោះ មិនបានដឹងមុនពីល្បិចកលបន្តទៅមុខទៀត របស់ជនឆបោកទាំងនេះនោះទេ៕

## នគរបាលជាតិកម្ពុជា
## និងនគរបាលភូមិន្ទថៃ សហប្រតិបត្តិការឃាត់ខ្លួនមុខសញ្ញាជនជាតិថៃចំនួន ៤នាក់

https://www.kampucheathmey.com/security/575511 ថ្ងៃចន្ទ ១១ កញ្ញា ២០២៣ដោយ Sokhom Khon

នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ នគរបាលជាតិកម្ពុជាបានសហការជាមួយនគរបាលភូមិន្ទថៃ បើកប្រតិបត្តិការស្រាវជ្រាវ រហូតឈានដល់កំណត់បាន និងឃាត់ខ្លួនមុខសញ្ញាជាជនជាតិថៃ ចំនួន ០៤នាក់ ដែលកំពុងសំងំលាក់ខ្លួនក្នុងភូមិសាស្ត្រ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ពាក់ព័ន្ធនឹងអំពើឆបោកតាមប្រព័ន្ធអនឡាញ បណ្តាលឲ្យកើតមានអំពើឃាតកម្មពលរដ្ឋថៃមួយគ្រួសារនៅខេត្តសាមុតប្រកាន កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣ និងមានមនុស្សស្លាប់ចំនួន ០៣នាក់។

ក្រោមបទបញ្ជាដ៏ម៉ឺងម៉ាត់របស់ ឯកឧត្តមនាយឧត្តមសេនីយ៍ ស ថេត អគ្គស្នងការនគរបាលជាតិកម្ពុជា ប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ និងមានការចង្អុលដឹកនាំពី ឯកឧត្តម ឧត្តមសេនីយ៍ឯក ឌី វិជ្ជា អគ្គស្នងការរង នាយកដ្ឋានកណ្តាលសន្តិសុខបានសហការជាមួយនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា នាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម និងស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានធ្វើការផ្លាស់ប្តូរព័ត៌មានជាមួយនគរបាលភូមិន្ទថៃរហូតកំណត់បាន និងឃាត់ខ្លួនមុខសញ្ញាជាជនជាតិថៃចំនួន០៤នាក់ ដែលកំពុងរត់គេច និងសំងំលាក់ខ្លួនពីការតាមចាប់របស់សមត្ថកិច្ច ក្រោយធ្វើសកម្មភាពឆបោកតាមប្រព័ន្ធអនឡាញ បណ្តាលអោយជនរងគ្រោះជាជនជាតិថៃសម្លាប់គ្រួសាររបស់ខ្លួនឯង ដែលមានម្តាយនិងកូនពីរនាក់ រួចព្យាយាមធ្វើអត្តឃាតខ្លួនតាមក្រោយ ក្រោមកិច្ចសម្របសម្រួលនីតិវិធីដោយអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

ប្រតិបត្តិការនេះបានធ្វើឡើងតែមួយសប្តាហ៍ប៉ុណ្ណោះ បន្ទាប់ពីឯកឧត្តម នាយឧត្តមសេនីយ៍ ស ថេត ទទួលជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ ឯកឧត្តម នាយឧត្តមសេនីយ៍ Surachate Hakparn អគ្គស្នងការរងនគរបាលភូមិន្ទថៃ និងគណៈប្រតិភូកាលពីថ្ងៃទី៤ ខែកញ្ញា ឆ្នាំ ២០២៣ ខណៈកិច្ចពិភាក្សានេះបានផ្តោតសំខាន់ អំពីការបន្តពង្រឹង និងពង្រីកទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងនគរបាលជាតិកម្ពុជា និងនគរបាលភូមិន្ទថៃ ឲ្យមានភាពរឹងមាំជិតស្និទ្ធបន្ថែមទៀត សំដៅសម្រេចឲ្យបាននូវលទ្ធផលធំៗ ក្នុងកិច្ចសហប្រតិបត្តិការបង្ការទប់ស្កាត់ និងប្រឆាំងបទល្មើសឧក្រិដ្ឋឆ្លងដែនគ្រប់ប្រភេទ៕

## បុរសម្នាក់មកពី Odisha បានត្រឡប់មកផ្ទះវិញបន្ទាប់ពីត្រូវបានជាប់បង្ខាំងនៅកម្ពុជា

https://www.khmertimeskh.com/501358285/-odisha-/ Khmer Times September 11, 2023

សមាជិកគ្រួសាររបស់បុរសឈ្មោះ Dinabandhu Sahu រស់នៅក្នុងភូមិ Biswanathpur នៃប្រទេសឥណ្ឌាទទួលបានភាពសប្បាយរីករាយឡើងនៅពេលដែលគាត់បានត្រឡប់មកផ្ទះវិញបន្ទាប់ពីត្រូវបានជាប់បង្ខាំងនៅកម្ពុជា ដោយគាត់បានបដិសេធមិនធ្វើការឱ្យក្រុមដែលជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត និងការក្លែងបន្លំ។ កន្លងមក Dinabandhu និងក្រុមគ្រួសាររបស់គាត់បានស្នើសុំលោកនាយករដ្ឋមន្ត្រី Narendra Modi និងមន្ត្រីពាក់ព័ន្ធជាន់ខ្ពស់ជាច្រើនរូបទៀតឱ្យចាត់វិធានការជួយអោយខ្លួនត្រឡប់មកផ្ទះវិញដោយសុវត្ថិភាព។ Dinabandhu បាននិយាយរៀបរាប់រឿងរ៉ាវរបស់ខ្លួនថា "ខ្ញុំបានទាក់ទងភ្នាក់ងារក្នុងស្រុក ហើយគាត់បានប្រគល់លិខិតដែលក្រុមហ៊ុនមួយនៅប្រទេសវៀតណាមបានផ្តល់ការងារមកអោយខ្ញុំ។ ប៉ុន្តែជំនួសឱ្យការផ្តល់ការងារជាប្រតិបត្តិករកុំព្យូទ័រ ខ្ញុំតម្រូវអោយធ្វើការងារផ្សេងទៅវិញ។ ប៉ុន្តែខ្ញុំបានបដិសេធ ហើយខ្ញុំត្រូវបានគេបង្ខាំងអស់រយៈ១០ថ្ងៃនៅកម្ពុជា។

Dinabandhu បានអោយដឹងទៀតថា ខ្លួនត្រូវបានផ្តល់ការបណ្តុះបណ្តាលប្រហែល ១០ ទៅ ១៥ ថ្ងៃ។ "ក្រោយមកខ្ញុំផ្សព្វផ្សាយថា ការងារនេះគឺដើម្បីស្វែងរកការវិនិយោគ។ បន្ទាប់ពីពួកគេបានដាក់ប្រាក់ ប័ណ្ណសម្គាល់ផ្សេងៗត្រូវបានបិត។ កន្លែងដែលខ្ញុំបានធ្វើការ ការបោកប្រាស់ផ្តោតលើមនុស្សមួយចំនួននៅក្នុងប្រទេសហ្វីលីពីន និងឥណ្ឌា។ ការជ្រើសរើសមនុស្សបានប្រព្រឹត្តិទៅនៅលើហ្វេសប៊ុក ដោយបានផ្ញើសារសុំធ្វើជាមិត្ត និងការជជែកគ្នា។

ម្តាយរបស់ Dinabandhu បាននិយាយថា "កូនប្រុសរបស់ខ្ញុំបានបង់ប្រាក់ចំនួន Rs ១.៥០ លានទៅភ្នាក់ងារ ដើម្បីបានការងារធ្វើនៅបរទេស។ ប៉ុន្តែកូនខ្ញុំបានទៅធ្វើការងារផ្សេងទៀតជំនួសឱ្យអ្វីដែលបានសន្យា។ ក្រោយមកទៀតកូនខ្ញុំត្រូវបានគេបង្ខាំងខ្លួន ហើយក្រុមហ៊ុនបានទាមទារប្រាក់ជាថ្នូរនឹងការដោះលែងខ្លួន។

ប្រពន្ធរបស់ Dinabandhu បាននិយាយថា "បន្ទាប់ពីមួយខែ យើងបានដឹងថាប្តីរបស់ខ្ញុំត្រូវបានគេបង្ខាំង។ យើងព្រួយបារម្ភអំពីសុវត្ថិភាពរបស់គាត់ ខណៈដែលយើងត្រូវបង់លុយដើម្បីជាថ្នូរនឹងការដោះលែងគាត់" ។ Odishatv.in

## អនុពន្ធការងារប្រចាំស្ថានទូតកម្ពុជា នាទីក្រុងបាងកក សាទរចំពោះការបង្កើតអគ្គកុងស៊ុលខ្មែរនៅប៉ែកខាងត្បូងប្រទេសថៃ

https://www.postkhmer.com/national/2023-09-10-1844-254361.html វណ្ណ សុជាតា។ Publication date 10 September 2023 । 18:44 ICT

***ភ្នំពេញ:*** *អនុពន្ធការងារកម្ពុជាប្រចាំស្ថានទូតកម្ពុជា នៅទីក្រុងបាងកក បានប្រកាសគាំទ្រពេញទំហឹងចំពោះការបង្កើតអគ្គកុងស៊ុលកម្ពុជានៅប៉ែកខាងត្បូងប្រទេសថៃ ដើម្បីជួយសម្រួលដល់ការលំបាក ក៏ដូចជាការបង្កិតសេវារបស់រដ្ឋាភិបាល ទៅកាន់ពលករខ្មែរ ដែលកំពុងតែរស់នៅ និងធ្វើការនៅទីនោះ។ អនុពន្ធការងារកម្ពុជាប្រចាំស្ថានទូតខ្មែរនៅទីក្រុងបាងកក លោក ឈឹម វិបុល បានថ្លែងកាលពីថ្ងៃទី១០ កញ្ញាថា ការបង្កើតអគ្គកុងស៊ុលនៅប៉ែកខាត្បូងថៃ គឺជាការដាក់ថ្នាំចំជំងឺ ដោយលោកបានប្រកាសគាំទ្រពេញទំហឹងចំពោះការបង្កើតអគ្គកុងស៊ុលនៅតំបន់នោះ ព្រោះថា ជាគោលនយោបាយដែលត្រឹមត្រូវ និងមានប្រសិទ្ធភាព ដោយសារកន្លងមក ពលរដ្ឋខ្មែរនៅប៉ែកខាងត្បូងត្រូវចំណាយពេលវេលាច្រើន និងសោហ៊ុយដើម្បីទទួលបានសេវាគាំទ្ររបស់រដ្ឋាភិបាលដែលមានទីតាំងនៅក្រុងបាងកក។*

*លោកបាននិយាយថា៖«នេះគឺជាអ្វីដែលពលករនៅប៉ែកខាងត្បូងគាត់ត្រូវការខ្លាំងណាស់ ទាំងការផ្តល់សេវា ទាំងការគាំពារ ដែលវាត្រូវតែមានសម្រាប់បងប្អូនយើង។ បងប្អូនពលករនៅខេត្តដទៃទៀត និងបាងកកជាដើម ក៏សប្បាយរីករាយចំពោះដំណឹងនេះដែរ ព្រោះនេះ ជាបង្ហាញពីការ*

យកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំយើង»។ លោកឈឹម វិបុល បានបន្តថា ការបង្កើតនេះអាចជួយដល់ការបន្ថយការចំណាយ កាត់បន្ថយពេលវេលាក្នុងការដោះស្រាយបញ្ហាដែលកើតមានចំពោះពលករ។ លោកបញ្ជាក់ថា៖«ពលករភាគច្រើនមានតម្រូវការច្រើន លើការធ្វើឯកសារបញ្ជាក់អត្តសញ្ញាណ ឬលិខិតបញ្ជាក់ការងារធ្វើដំណើរក្នុងនាមជាពលករស្របច្បាប់,លិខិតបញ្ជាក់ដើម្បីទទួលការជានារ៉ាប់រង ឬអត្ថប្រយោជន៍ផ្សេងៗពីរោងចក្រ និងការកែតម្រូវឯកសារផ្សេងៗ និងការដោះស្រាយបញ្ហាថៅកែ មិនបើកប្រាក់ខែឱ្យជាដើម មិនចាំបាច់ធ្វើដំណើរមកឆ្ងាយ ដើម្បីទទួលសេវាទាំងនេះទៀតទេ»។

ប្រធានសហភាពការងារកម្ពុជា (CLC) លោក អាត់ ធន់ ក៏បានសាទរផងដែរដោយថ្លែងថា ជាអ្វីដែលពលករខ្មែរនៅប្រទេសថៃកំពុងមានតម្រូវការ។ លោក អាត់ ធន់ បាននិយាយដូច្នេះថា៖«ខ្ញុំគិតថា វាជាការល្អណាស់សម្រាប់ការបង្កើតអគ្គកុងស៊ុលនៅតំបន់ខាងត្បូងប្រទេសថៃនេះ ដើម្បីជួយសម្រួលដល់ការរៀបចំឯកសារ ជូនបងប្អូនប្រជាពលរដ្ឋយើង ខណៈដែលប្រជាពលរដ្ឋដែលរស់នៅតាមបណ្ដាខេត្តក្នុងតំបន់ភាគត្បូងនិងខេត្តជាប់នោះ មិនទាន់មានឯកសារគ្រប់គ្រាន់ និងមួយចំនួនរស់នៅធ្វើការដោយខុសច្បាប់នៅឡើយ»។

សូមរំឭកថា លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត កាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ នៅអំឡុងពេលជួបសំណេះសំណាលជាមួយកម្មករនៅខេត្តកំពង់ស្ពឺ ប្រមាណជិត២ម៉ឺននាក់ បានប្រកាសបង្កើតអគ្គកុងស៊ុលខ្មែរ នៅប៉ែកខាងត្បូងប្រទេសថៃដើម្បីជួយសម្រួលដល់ការលំបាក ក៏ដូចជាការបង្កិតសេវារបស់រដ្ឋាភិបាលទៅកាន់ពលករខ្មែរ ខណៈដែលប្រជាពលរដ្ឋ ដែលធ្វើការនៅប្រទេសថៃមានចំនួនច្រើនជាងនៅបណ្ដាប្រទេសដទៃទៀត។ លោកបញ្ជាក់ថា៖«នៅភាគខាងត្បូងប្រទេសថៃ យើងអត់ទាន់មានកុងស៊ុលនៅឡើយទេ នៅម៉ុំស៊ុងខ្លា ហាតយ៉ៃ យ៉ាឡា ជាដើម។ឥឡូវខ្ញុំបានជជែកជាមួយឯកឧត្តម អ៊ុច បូរិទ្ធ ហើយ គឺសូមឱ្យបង្កើតអគ្គកុងស៊ុលយើងមួយនៅទីនោះ ហើយរៀបចំមនុស្សបន្ថែមទៀត ដោយមានទីប្រឹក្សាការងារ ទៅអមនៅទីនោះផងដែរ ដោយនេះជាការពង្រឹងសេវាជូនពលរដ្ឋយើង»។

យោងតាមរបាយការណ៍ពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរ បាននិងកំពុងរស់នៅនិងធ្វើការនៅប្រទេសថៃ មានប្រមាណជាង១,២លាននាក់ ដែលភាគច្រើនធ្វើការនៅក្នុងវិស័យឧស្សាហកម្ម សេវាកម្ម កសិកម្ម និងនេសាទជាដើម៕

# ថ្ងៃទី១៤ ខែ កញ្ញា ឆ្នាំ២០២៣

## លោក ហ៊ុន ម៉ាណែត
## ជំរុញអភិបាលរាជធានី-ខេត្ត បង្រ្កាបបទល្មើសជួញដូរមនុស្ស និងគ្រឿងញៀន

https://www.khmertimeskh.com/501360203// *ហង្ស ពណ្ណរាយ* / Khmer Times September 14, 2023

*ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លោកនាយករដ្ឋមន្រ្តី ហ៊ុន ម៉ាណែត បានជួបជាមួយអភិបាលរាជធានី ខេត្ត ទាំង២៥ កាលពីម្សិលមិញ ដើម្បីជំរុញឱ្យមានការបង្រ្កាបបទល្មើសជួញដូរមនុស្ស ជួញដូរគ្រឿងញៀន និងផ្តល់សេវាសាធារណៈល្អសម្រាប់បម្រើប្រជាពលរដ្ឋក្នុងមូលដ្ឋាន។*

*លោក វ៉ី សំណាង អភិបាលខេត្តកំពង់ស្ពឺ ប្រាប់កាសែតខ្មែរថាមស៍ កាលពីម្សិលមិញថា កាលពីអាណត្តិទី៦ រដ្ឋាភិបាលអនុវត្តយុទ្ធសាស្រ្តចតុកោណ តែសម្រាប់អាណត្តិទី៧ រដ្ឋាភិបាលមានយុទ្ធសាស្រ្តបញ្ចកោណ ដែលមានគោលដៅធ្វើយ៉ាងណា ឱ្យរដ្ឋាភិបាលថ្នាក់ជាតិ សហការជាមួយថ្នាក់ក្រោមជាតិ ដើម្បីបម្រើសេវាសាធារណៈប្រកបដោយគុណភាព និងប្រសិទ្ធភាព។ លោកបន្ថែមថា ការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព និងប្រសិទ្ធភាពសម្រាប់ប្រជាពលរដ្ឋ គឺធ្វើឡើងទាំងផ្តល់សេវាតម្រូវការ សេវាសំណូមពរ និងសេវាផ្សេងៗជាច្រើនទៀត។ លោកបន្តថា ចំពោះការអនុវត្តតួនាទី និងភារកិច្ចរបស់គណៈអភិបាលខេត្ត គឺពង្រឹងលើការផ្តល់សេវាសាធារណៈ និងសន្តិសុខសុវត្ថិភាពជូនប្រជាពលរដ្ឋ ជាពិសេសទប់ស្កាត់ការជួញដូរមនុស្ស និងបង្រ្កាបរាល់បទល្មើសជួញដូរគ្រឿងញៀន។*

*អភិបាលខេត្តកំពង់ស្ពឺ បញ្ជាក់ថា ការប្រព្រឹត្តរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក គឺមានផែនការសកម្មភាពរបស់ខ្លួនជាដំណាក់កាល។ មានន័យថា ឆ្នាំណាត្រូវធ្វើអ្វី? ខែណាត្រូវធ្វើអ្វីខ្លះ? ហើយក៏មានផែនការរយៈពេលខ្លី និងរយៈពេលវែងដូចជាផែនការរយៈពេល ៣ឆ្នាំ ៥ឆ្នាំ ជាដើម។ លោក វ៉ី សំណាង បន្ថែមថា៖ «ជាគោលការណ៍យើងស៊ីប្រាក់ខែរដ្ឋ ត្រូវបម្រើប្រជាពលរដ្ឋ នេះជាគោលដៅរបស់យើង ហើយមេ (លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត) បានផ្តល់សេចក្តីទុកចិត្តដល់អភិបាលខេត្ត និងក្រុមប្រឹក្សាខេត្ត ដើម្បីបម្រើប្រជាពលរដ្ឋឱ្យបានល្អ»។ លោកបញ្ជាក់ថា៖ «យើងត្រូវតែប្តេជ្ញាចិត្តចូលរួមអនុវត្តតាមផែនការថ្នាក់ជាតិ ឱ្យបានខ្ជាប់ខ្ជួន និងឱ្យបានម៉ឺងម៉ាត់តាមការចង្អុលបង្ហាញ ដើម្បីសម្រេចតាមគោលដៅរបស់យើង គឺបម្រើសេវាសាធារណជូនប្រជាពលរដ្ឋ ក៏ដូចជាចូលរួមថែរក្សាសន្តិសុខ និងកៀងគរអ្នកវិនិយោគ ដើម្បីមកអភិវឌ្ឍក្នុងខេត្តរបស់យើង»។*

លោក វ៉ា ថន អភិបាលខេត្តក្រចេះ បានឱ្យដឹងថា ចំពោះការបង្ក្រាបបទល្មើសគ្រឿងញៀន និងជួញដូរមនុស្ស គឺរដ្ឋបាលខេត្តធ្វើជាប្រចាំ។ លោកបន្ថែមថា៖ «ក្នុងភូមិសាស្ត្រខេត្តរបស់យើងនៅតែបន្តអនុវត្តការបង្ក្រាបបទល្មើសគ្រឿងញៀន គឺធ្វើជាសកម្ម ប៉ុន្តែសម្តេចធិបតី ហ៊ុន ម៉ាណែត បានបញ្ជាក់បន្ថែមថា ចំពោះបទល្មើសជួញដូរគ្រឿងញៀននេះ ត្រូវតែបង្ក្រាបឱ្យខ្លាំងជាងមុន»។ លោកបន្តថា បច្ចុប្បន្ន ការជួញដូរគ្រឿងញៀននៅក្នុងខេត្តក្រចេះ មិនមានការកើនឡើងច្រើននោះទេ ប៉ុន្តែមានការថយចុះតិចតួច។ ចំពោះការជួញដូរគ្រឿងញៀននេះ គឺមិនមានលក្ខណៈទ្រង់ទ្រាយធំៗនោះទេ កើតឡើងករណីតូចតាចតែប៉ុណ្ណោះ។ អភិបាលខេត្តក្រចេះបញ្ជាក់ថា ចំពោះការជួញដូរមនុស្សក្នុងភូមិសាស្ត្រខេត្តក្រចេះ គឺគ្មានករណីនេះកើតឡើងទេ គឺដោយសារខេត្តក្រចេះ ជាខេត្តតូចមួយ ហើយសេដ្ឋកិច្ច ក៏តូចដែរ ជាខេត្តជនបទ។

លោក វ៉ា ថន បន្ថែមថា បច្ចុប្បន្ន ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ គឺមានលក្ខណៈល្អប្រសើរច្រើន ពីមួយថ្ងៃទៅមួយថ្ងៃ ដោយសារមានយន្តការណ៍ច្បាស់លាស់ និងដាក់ឱ្យមានការបម្រើសេវាច្រកចេញច្រកចូលតែមួយ គឺចាប់ពីរដ្ឋបាលឃុំ ស្រុក ខេត្ត។ លោកបានបន្ថែមថា ក្នុងកិច្ចប្រជុំកាលពីម្សិលមិញ លោកនាយករដ្ឋមន្ត្រី ក៏បានជំរុញឱ្យអភិបាលខេត្តពង្រឹងសមត្ថភាពមន្ត្រីបន្ថែម គឺត្រូវជុះខាត់សមត្ថភាពរបស់មន្ត្រី ដើម្បីអនុវត្តការកិច្ចរបស់រដ្ឋាភិបាលឱ្យមានប្រសិទ្ធភាព និងគុណភាព។ លោកបន្តថា បច្ចុប្បន្ន រដ្ឋាភិបាលឌីជីថល បើសិនមិនចេះប្រព័ន្ធឌីជីថល ធ្វើការមិនទាន់គេនោះទេ ដូច្នេះ ត្រូវពង្រឹងបន្ថែមទៀត ជាពិសេសបណ្តុះបណ្តាលសមត្ថភាពមន្ត្រីបន្ថែមជាបន្តបន្ទាប់។

អភិបាលរាជធានីភ្នំពេញ លោក ឃួង ស្រេង បានថ្លែងថា បច្ចុប្បន្ន ការបង្ក្រាបបទល្មើសគ្រឿងញៀន គឺមានលក្ខណៈល្អប្រសើរ ប៉ុន្តែបន្តសកម្មភាពរបស់ខ្លួនជាប្រចាំ ដើម្បីធានាសុខសុវត្ថិភាពជូនប្រជាពលរដ្ឋតាមមូលដ្ឋាន។ លោកបន្ថែមថា៖ «រដ្ឋបាលរាជធានីប្តេជ្ញាពង្រឹងការបង្ក្រាបបទល្មើសគ្រឿងញៀន និងការជួញដូរមនុស្ស ដើម្បីឆ្លើយតបទៅនឹងម្ចាស់ឆ្នោតដែលមានជំនឿចិត្តលើរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧»។ លោកបញ្ជាក់ថា សម្រាប់ការផ្តល់សេវាសាធារណៈក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានីភ្នំពេញ ក៏មានភាពល្អប្រសើរនាពេលបច្ចុប្បន្ន ប៉ុន្តែរដ្ឋបាលរាជធានីនៅតែប្រឹងប្រែងបន្ថែមទៀត ដើម្បីបម្រើប្រជាពលរដ្ឋ៕

## ក្រសួងការងារ តម្រង់ទិសដល់ពលករ និងកម្មសិក្សាការីមុនទៅបម្រើការនៅជប៉ុន

https://www.tvk.gov.kh/?p=31491 ចេញផ្សាយ ថ្ងៃទី 12 ខែ កញ្ញា ឆ្នាំ 2023

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃអង្គារ ទី១២ ខែកញ្ញា ឆ្នាំ២០២៣នេះ បានបើកវគ្គតម្រង់ទិសដល់ពលករជំនាញ និងកម្មសិក្សាការីចំនួន១០៣នាក់ មុនចេញទៅបម្រើការនៅប្រទេសជប៉ុន។ ក្នុងនោះ ពលករជំនាញមានបីនាក់ និងកម្មសិក្សាការីចំនួន១០១នាក់។

ក្នុងវគ្គតម្រង់ទិសដែលធ្វើនៅទីស្តីការក្រសួង ឯកឧត្តម ឡេង តុង ទីប្រឹក្សាក្រសួង និងជាប្រធាននាយកដ្ឋានពេទ្យការងារ បានអបអរសាទរដល់ពលករ និងកម្មសិក្សាការីទាំងអស់ ដែលបានទៅធ្វើការនៅប្រទេសជប៉ុន។ ទន្ទឹមនឹងនេះ ឯកឧត្តមទីប្រឹក្សា បានណែនាំឱ្យកម្មសិក្សាការី និងពលករជំនាញត្រូវគោរពច្បាប់ និងវិន័យនៅកន្លែងធ្វើការ ហើយស្តាប់តាមការណែនាំរបស់និយោជកជាពិសេសពាក់ព័ន្ធនឹងសុវត្ថិភាពការងារ ក៏ដូចជាការសម្របខ្លួនទៅតាមទំនៀមទំលាប់ប្រពៃណីរបស់ជប៉ុន។ ក្រៅពីការផ្តាំឱ្យមើលថែសុខភាពខ្លួនឯង ឯកឧត្តមឡេង តុង បានផ្តាំដាច់ខាតឱ្យជៀសឆ្ងាយពីគ្រឿងញៀន និងត្រូវចេះសន្សំប្រាក់ និងគ្រប់គ្រងចំណូលនិងចំណាយប្រចាំខែ ដើម្បីអាចសន្សំប្រាក់សម្រាប់ផ្ញើមកកាន់ប្រទេសកំណើត ឬសន្សំទុកប្រកបរបរផ្សេងៗពេលធ្វើមាតុភូមិនិវត្តន៍។

សូមបញ្ជាក់ថា ចាប់ពីខែតុលា ឆ្នាំ២០២៣ខាងមុខតទៅ ប្រទេសជប៉ុននឹងផ្តល់ប្រាក់ឈ្នួលអប្បបរមាដល់កម្មសិក្សាការី និងពលករជំនាញទាំងអស់ចំនួន៧ដុល្លារ ក្នុងពេលធ្វើការមួយម៉ោង ដែលជាមធ្យមទទួលបាន១៤០០ដល់១៦០០ដុល្លារក្នុងមួយខែ។ គិតត្រឹមថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០២៣នេះ កម្មសិក្សាការី និងពលករជំនាញ ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសជប៉ុនមានប្រមាណជាង ២ម៉ឺននាក់ដែលធ្វើការលើវិស័យមួយចំនួនដូចជាវិស័យ កសិកម្ម វិស័យសំណង់ វិស័យឧស្សាហកម្ម និងវិស័យផ្សេងៗទៀត៕

## ៣ចំណុចគោលសំខាន់ដែលរាជរដ្ឋាភិបាលដាក់ចេញដើម្បីការពារពលករនៅក្រៅប្រទេស

https://www.information.gov.kh/articles/113407 ចេញផ្សាយ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០២៣

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ចេញ ៣ចំណុចសំខាន់ៗ ដើម្បីផ្តល់សេវាកម្ម ការពារសិទ្ធិ និងការពារផលប្រយោជន៍ជូនពលករនៅក្រៅប្រទេស។

ចំណុចសំខាន់ៗទាំងនោះរួមមាន ទី១ ការពង្រឹងសេវាអនុពន្ធការងារអមស្ថានឯកអគ្គរាជទូតកម្ពុជា ព្រមទាំងសហការយ៉ាងជិតស្និទ្ធជាមួយមជ្ឈមណ្ឌលគាំពារពលករបរទេស តាមបណ្តាប្រទេសគោលដៅ។ បន្ថែមពីនេះ ក្រសួងការងារ និងវិជ្ជាជីវៈកំពុងបន្តពង្រឹងយន្តការចុះត្រួតពិនិត្យ

និងធ្វើអធិការកិច្ចការងារទីភ្នាក់ងារជ្រើសរើសឯកជន ដើម្បីធានាពីប្រសិទ្ធិភាពកិច្ចការងារជ្រើសពលករ។ បន្ថែមពីនេះចំណុចទី៣ ក្រសួង ក៏បានផ្តល់ការគាំទ្រ និងភាពងាយស្រួលជូនបងប្អូនពលករធ្វើការនៅក្រៅប្រទេស តាមរយៈការសម្រួលបែបបទឯកសារ ការគាំពារតាមផ្លូវច្បាប់ អន្តរាគមន៍សង្គ្រោះនៅពេលមានហានិភ័យនិងការជួបសួរសុខទុក្ខជាប្រចាំ។

សូមបញ្ជាក់ថា ដើម្បីពង្រឹងអត្ថប្រយោជន៍ពលករនៅក្រៅប្រទេស ជាពិសេសក្នុងតំបន់អាស៊ាន កម្ពុជាក្នុងនាមជាប្រធានអាស៊ានលើកទី៤១ កម្ពុជាបានផ្តួចផ្តើមឲ្យមានការធានាចល័តភាពរបបសន្តិសុខសង្គម ក្នុងតំបន់អាស៊ាន និងសម្រេចបានចេញ « សេចក្តីថ្លែងការអាស៊ាន ស្តីពីចល័តភាពនៃអត្ថប្រយោជន៍របបសន្តិសុខសង្គម»។

គួររំលឹកថា ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ពីឆ្នាំ២០១៨ ដល់ ឆ្នាំ២០២២ ក្រសួងជួយអន្តរាគមន៍សម្របសម្រួលពលករ និង ដោះស្រាយបញ្ហាទូទៅរបស់ពលករជួបការលំបាក ដែលសរុបចំនួន ១៤៨៥១ករណី។ ដោយឡែកក្នុងបរិបទកូវីដ១៩ ដែលជាវិបត្តិសុខភាពសកល ក្រសួងការងារ បានចូលរួមសម្របសម្រួល និងផ្តល់ជំនួយជាថ្នាំព្យាបាល និងស្បៀងអាហារដល់ពលករដែលជួបការលំបាកនៅប្រទេសថៃ។

ក្រៅពីការងារខាងលើ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំពង្រឹង និង ពង្រីកកិច្ចសហការជាមួយបណ្តាលប្រទេសទទួល ដោយពង្រីកឱកាសការងារបន្ថែមជូនប្រជាពលរដ្ឋនៅក្រៅប្រទេសប្រមាណ ១,៣ លាននាក់ និងបានប្រាក់បញ្ញើបញ្ជូនមកប្រទេសវិញប្រមាណ ២,៧ ពាន់លានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ។ ក្នុងនោះប្រទេសថៃ មានចំនួនពលករ ១,២៣១, ៥០៨ នាក់ ; សាធារណរដ្ឋកូរ៉េ ចំនួន ៤៩,៧៣៨ នាក់ ; ម៉ាឡេស៊ីចំនួន ២២,៦២១ នាក់ ; ជប៉ុន ១៦,៥៦២ នាក់ ; សិង្ហបុរីចំនួន ៨៥១នាក់ ; ហុងកុង ចំនួន ២១៥នាក់ និង អារ៉ាប់ប៊ីសាអូឌីតចំនួន ១១នាក់។ ប្រភព៖ RNK, សម្រួលផ្សាយដោយ៖ ប៉ោ កុសល

# ថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ២០២៣

## នាយករដ្ឋមន្ត្រីកម្ពុជា
## បង្កើតគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូល របស់ពលករខ្មែរតាមព្រំដែន, ឧបនាយករដ្ឋមន្ត្រី នេត សាវឿន ជាប្រធាន

https://freshnewsasia.com/index.php/en/localnews/310129-2023-09-14-05-21-28.html 2023-09-14 12:21pm

**(ភ្នំពេញ)៖** *សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃកម្ពុជា បានចេញសេចក្តីសម្រេចបង្កើតគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ ចូលរបស់ពលករខ្មែរតាមព្រំដែនកម្ពុជា។ ក្នុងសេចក្តីសម្រេច ដែលចុះហត្ថលេខានៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០២៣ ហើយបណ្តាញព័ត៌មាន Fresh News ទទួលបាននៅព្រឹកថ្ងៃទី១៤ ខែកញ្ញានេះ បានឲ្យដឹងថា គណៈកម្មការចំពោះកិច្ចនេះ មានលោកសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី ជាប្រធានអមដោយអនុប្រធានប្រចាំការ១រូប អនុប្រធាន២រូប និងសមាជិកជាច្រើនរូបផ្សេងទៀត។*

***គណៈកម្មការចំពោះកិច្ចមានតួនាទី និងភារកិច្ចដូចខាងក្រោម៖***

** តាមដាន និងត្រួតពិនិត្យការអនុវត្តវិធានការនានាដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ដើម្បីលុបបំបាត់ភាពមិនប្រក្រតី និងបាតុភាពផ្សេងៗ ក៏ដូចជាបញ្ហាប្រឈមនានាចំពោះពលករខ្មែរ ក្នុងការចេញ ចូល និងឆ្លងកាត់ព្រំដែន*

** ជំរុញដល់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៅតាមព្រំដែន ដើម្បីជួយសម្រួលដំណើរចេញ ចូលរបស់ពលករខ្មែរឲ្យបានត្រឹមត្រូវ*

** ទទួល និងដោះស្រាយបណ្តឹងតវ៉ានានារបស់ពលករខ្មែរពាក់ព័ន្ធនឹងដំណើរឆ្លងកាត់ព្រំដែន*

** សិក្សាស្រាវជ្រាវលើប្រភពបញ្ហា ឬភាពមិនប្រក្រតីនានា ដែលបង្កការរំខានដល់ដំណើរចេញចូល ឬប៉ះពាល់ដល់ផលប្រយោជន៍របស់ពលករខ្មែរតាមព្រំដែន*

** រៀបចំឲ្យមានប្រព័ន្ធឆ្លើយតបបន្ទាន់មិនប្រក្រតី*

** ធ្វើការត្រួតពិនិត្យដើម្បីសម្រួលឲ្យពលករអាចទំនាក់ទំនង និងរាយការណ៍ភាពតាមដានការអនុវត្តតួនាទីភារកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធក្នុងករណីមានបណ្តឹងមិនសុខចិត្តពីពលករ*

** ចុះពិនិត្យ សិក្សា និងវាយតម្លៃអំពីស្ថានភាពនៃការយកកម្រៃក្រៅផ្លូវការសម្រាប់ការធ្វើដំណើរចេញ ចូលនៅច្រកទ្វារព្រំដែន*

** ដាក់ចេញវិធានការ ចុះប្រតិបត្តិការ ឬចេញសេចក្តីណែនាំ ដើម្បីលុបបំបាត់ការយកកម្រៃក្រៅ ផ្លូវការសម្រាប់ការធ្វើដំណើរចេញចូលនៅច្រកទ្វារព្រំដែន សំដៅសម្រួលដល់ការធ្វើដំណើរចេញ ចូល*

របស់ពលករនៅតាមព្រំដែន
* ធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលអំពីវឌ្ឍនភាពការងារ និងបញ្ហាប្រឈមទាក់ទងនឹងការងារ
* លុបបំបាត់ការយកកម្រៃក្រៅផ្លូវការសម្រាប់ការធ្វើដំណើរចេញចូលនៅច្រកទ្វារព្រំដែន
* អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល៕

## អ្នកនាំពាក្យក្រសួងការងារ៖ ពលករធ្វើការនៅប្រទេសថៃ ជាមធ្យមទទួលបានប្រាក់ខែ ៤០០ដុល្លារ ក្នុង១ខែ

https://cen.com.kh/archives/694679.html Posted ByCENSeptember 14, 2023

ភ្នំពេញ៖ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងថា គិតត្រឹមខែសីហា ឆ្នាំ២០២៣នេះ កម្ពុជាមានពលករកំពុងស្នាក់នៅ និងធ្វើការនៅក្រៅប្រទេសមានចំនួន ១លាន ៣សែន ៤ម៉ឺន ២៩៦៣ នាក់ ស្រី ៥៤ម៉ឺន ៦៩៨១ នាក់ ក្នុងនោះ ប្រទេសថៃចំនួន ១លាន ២សែន ៤៨២៤៥ នាក់ ស្រី ៥០ម៉ឺន២២៥០ នាក់ ប្រទេសម៉ាឡេស៊ីចំនួន ២២៥៧២ នាក់ ,ស្រី ២១៦៥៤ នាក់ ប្រទេសជប៉ុនមាន ២០៨១២ នាក់ ស្រី ៩៦៧៦ នាក់, ប្រទេសសិង្ហបុរីមាន ៨៦៤ នាក់ ស្រ្តីទាំងអស់, កូរ៉េខាងត្បូងមាន ៥០២២៥ នាក់, តំបន់សេដ្ឋកិច្ចពិសេសហុងកុងមាន ២១៦ នាក់ ស្រីទាំងអស់ និងប្រទេសអារ៉ាប៊ីសាអូឌីត មាន ២៩ នាក់ ។ គិតត្រឹមខែសីហា ឆ្នាំ២០២៣នេះ កម្ពុជា មានពលករកំពុងស្នាក់នៅ និងធ្វើការនៅក្រៅ ហើយជាពិសេសនៅប្រទេសថៃ មានពលករច្រើនជាងគេ រហូតដល់ទៅជាង ១ លាន ២ សែននាក់។

លោក កត្តា អ៊ន អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងថា ក្នុងចំណោមពលករជាង ១លាន ៣ សែននាក់ ក្នុងនោះ ទៅធ្វើការផ្នែកកសិកម្មមានចំនួន ២៦ម៉ឺន ២៤១៨ នាក់ ផ្នែកឧស្សាហកម្មចំនួន ៥៦ម៉ឺន៥៨១០ នាក់ ផ្នែកសំណង់ចំនួន ៣៧ម៉ឺន៨៦២១ នាក់ ផ្នែកការងារផ្ទះចំនួន ១៦៧០៩ នាក់ និងការងារផ្សេងៗចំនួន ១១ម៉ឺន៩៤០៥ នាក់ ដោយពួកគេបានផ្ញើប្រាក់ត្រឡប់មកប្រទេសកម្ពុជាវិញ មានចំនួន ២៩១៨,៨៧៤,១៩៩ ដុល្លារ។

លោក កត្តា អ៊ន គូសបញ្ជាក់ថា ពលករដែលទៅធ្វើការនៅប្រទេសថៃជាមធ្យមទទួលបានប្រាក់ខែ ៤០០ ដុល្លារ ក្នុង ១ ខែ ប្រទេសម៉ាឡេស៊ីទទួលបានប្រាក់ខែ ៣៤០ ដុល្លារ ប្រទេសអារ៉ាប៊ីសាអូឌីតទទួលបានប្រាក់ខែ ៤០០ ដុល្លារ ប្រទេសជប៉ុនទទួលបានប្រាក់ខែ ១៤០០ ដុល្លារ ប្រទេសសិង្ហបុរីទទួលបានប្រាក់ខែ ៥០០ ដុល្លារ កូរ៉េខាងត្បូងទទួលបានប្រាក់ខែ ១៥០០ ដុល្លារ និងតំបន់សេដ្ឋកិច្ចពិសេសហុងកុងទទួលបានប្រាក់ខែ ៥៩១ ដុល្លារ៕

## មីយ៉ាន់ម៉ា តម្រូវឲ្យពលករចំណាកស្រុកបង់ប្រាក់ ២៥ ភាគរយចូលរដ្ឋ

https://www.kampucheathmey.com/global-news/577860 *ថ្ងៃព្រហស្បតិ៍ ១៤ កញ្ញា ២០២៣*

*ដោយ* ratanak neang

*មេដឹកនាំមីយ៉ាន់ម៉ាទាមទារឲ្យពលករធ្វើការនៅក្រៅប្រទេសបង់ប្រាក់យ៉ាងតិច ២៥ ភាគរយនៃប្រាក់ចំណូលរូបិយប័ណ្ណបរទេសប្រចាំខែរបស់ពួកគេចូលរដ្ឋ ហើយត្រូវតែផ្ទេរតាមរយៈធនាគារ* CB Bank *ដែលជាធនាគារឯកជនធំបំផុតរបស់ប្រទេសរៀងរាល់ខែ ឬ ៣ ខែម្តង ។ បទបញ្ញត្តិថ្មីនេះបានចូលជាធរមាននៅថ្ងៃទី១ ខែកញ្ញា ដោយតម្រូវឲ្យពលករបើកគណនីផ្ទេរប្រាក់តាមធនាគារ* CB Bank *ដែលគ្រប់គ្រងដោយធនាគារកណ្តាលមីយ៉ាន់ម៉ា ខណៈមានអត្រាប្តូរប្រាក់ផ្លូវការត្រឹមតែ ២,១០០ គីយ៉ាត ក្នុងមួយដុល្លារអាមេរិកប៉ុណ្ណោះ ស្របពេលដែលអត្រាប្តូរប្រាក់លើទីផ្សារខ្ពស់ជាងដល់ទៅ ៣,៤០០ គីយ៉ាតឯណោះ ។*

*ចំពោះច្បាប់ថ្មីនេះផងដែរព្រមានថា ពលករចំណាកស្រុកដែលមិនគោរពតាម នឹងត្រូវហាមឃាត់មិនឲ្យធ្វើការនៅបរទេសរយៈពេល ៣ ឆ្នាំ បន្ទាប់ពីប័ណ្ណការងារបច្ចុប្បន្នរបស់ពួកគេផុតកំណត់ ។ ទន្ទឹមនោះ លក្ខខណ្ឌនៃការផ្ទេរប្រាក់នេះ ក៏នឹងផ្តល់ផលប៉ះពាល់ដល់ពលករចំណាកស្រុកមីយ៉ាន់ម៉ា ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ក្រោមអនុស្សរណៈនៃការយោគយល់គ្នា* (MoU) *រវាងរដ្ឋាភិបាលទាំងពីរ ។*

*យោងតាមទិន្នន័យក្រសួងការងារថៃបានឲ្យដឹងថា ជនចំណាកស្រុកមីយ៉ាន់ម៉ាជិត ២ លាននាក់កំពុងធ្វើការដោយស្របច្បាប់នៅក្នុងប្រទេសថៃកាលពីឆ្នាំមុន ៕* ***ប្រែសម្រួល៖ នាង រតនៈ***

## កម្ពុជា និង សហរដ្ឋអាមេរិក ប្តេជ្ញាបន្តពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ និងយុត្តិធម៌

https://www.postkhmer.com/national/2023-09-14-0850-254450.html *សំបាន ច័ន្ទដារ៉ា* | Publication date 14 September 2023 | 08:50 ICT

***ភ្នំពេញ:*** *កម្ពុជានិងសហរដ្ឋអាមេរិក ប្តេជ្ញាចិត្តបន្តពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យច្បាប់ និងយុត្តិធម៌ ជាពិសេសនៅក្នុងអាណត្តិរដ្ឋាភិបាលកម្ពុជាថ្មី ហើយភាគីទាំង ២ ក៏បានបង្ហាញឆន្ទៈខិតខំធ្វើឱ្យទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការនេះកាន់តែប្រសើរឡើង ដើម្បីជាប្រយោជន៍ប្រទេសទាំង ២។ ការប្តេជ្ញារវាងប្រទេសទាំង២នេះ ធ្វើឡើងតាមរយៈជំនួបពិភាក្សាការងាររវាងលោក កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងលោក* W. Patrick Murphy *ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជានៅទីស្តីការក្រសួងយុត្តិធម៌កាលពីថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០២៣។*

*លោក ជិន ម៉ាលីន អ្នកនាំពាក្យក្រសួងយុត្តិធម៌ បានប្រាប់ឱ្យដឹងនៅថ្ងៃទី ១៣ ខែកញ្ញាថា រដ្ឋមន្ត្រីយុត្តិធម៌ និងឯកអគ្គរដ្ឋទូតអាមេរិក បានសាទរចំពោះកិច្ចសហប្រតិបត្តិការជោគជ័យកន្លងមក*

រវាងប្រទេសទាំង ២ លើផ្នែកច្បាប់ ហើយភាគីទាំង ២ បានពិភាក្សាបន្ថែម ពីយន្តការពង្រឹង និងពង្រីកទំនាក់ទំនង និងកិច្ចសហការនេះបន្តទៅទៀត ពិសេសភាគីទាំង ២ បានបង្ហាញសុច្ឆន្ទៈរៀងៗខ្លួន។ លោក ជិន ម៉ាលីន បានបន្តថា៖ «ជាក្តីរំពឹង នៅក្នុងអាណត្តិរដ្ឋាភិបាលថ្មី ដែលដឹកនាំដោយសម្តេចធិបតី ហ៊ុន ម៉ាណែត ទំនាក់ទំនងកម្ពុជា និងអាមេរិកកាន់តែប្រសើរឡើង ហើយពាក់ព័ន្ធនឹងវិស័យច្បាប់ និងយុត្តិធម៌វិញ យើងមានកិច្ចសហប្រតិបត្តិការជាមួយគ្នាច្រើន ដែលភាគីទាំង ២ សង្ឃឹមថា នឹងកាន់តែមានភាពប្រសើរឡើងថែមទៀត»។

កន្លងមកកម្ពុជា និងសហរដ្ឋអាមេរិក បានសហការគ្នាលើបញ្ហានានាតួយ៉ាង ការទប់ស្កាត់បទល្មើសឆ្លងដែន ការជួយគ្នាទៅវិញទៅមកលើផ្នែកច្បាប់ ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់នៅកម្ពុជា និងការអនុវត្តសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ការទប់ស្កាត់និងបង្ក្រាបបទល្មើសជួញដូរមនុស្សជាដើម។ នេះបើតាមការបញ្ជាក់បន្ថែមពីលោកជិន ម៉ាលីន។

ពាក់ព័ន្ធនឹងបញ្ហានេះ លោក ថុង ម៉េងដាវិត អ្នកសិក្សាស្រាវជ្រាវ នៅមជ្ឈមណ្ឌលមេគង្គសម្រាប់សិក្សាយុទ្ធសាស្ត្រនៃវិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI) យល់ថា ជំនួបរវាងលោក Patrick Murphy និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌កម្ពុជា ជាជំនួបសំខាន់លើកិច្ចសហប្រតិបត្តិការផ្នែកច្បាប់និងយុត្តិធម៌ ដើម្បីជាឱកាសសម្រាប់កសាងសមត្ថភាពស្ថាប័ន និងការកសាងធនធានមនុស្សនៅកម្ពុជាក្នុងវិស័យនេះ ហើយក៏ជាឱកាសដើម្បីពន្យល់ និងបង្ហាញពីជំហរកម្ពុជាលើលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ទៅកាន់ភាគីអាមេរិកផងដែរ។ លោកបានប្រាប់ថា៖ «ជំនួបរវាងឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ជាមួយនឹងបណ្តារដ្ឋមន្ត្រីក្រសួងនៅកម្ពុជា ក្នុងរយៈពេលប៉ុន្មានសប្តាហ៍ចុងក្រោយនេះ ក៏បានបង្ហាញពីការប្តេជ្ញាចិត្តរបស់សហរដ្ឋអាមេរិកក្នុងការស្តារទំនាក់ទំនងជាមួយកម្ពុជាផងដែរ»។

លោក ម៉េងដាវិត យល់ថា សហរដ្ឋអាមេរិកគួរតែមានជំនួបបែបនេះកាន់តែច្រើនជាមួយថ្នាក់ដឹកនាំកម្ពុជា ដើម្បីបន្តស្វែងយល់ កាន់តែច្បាស់ ពីស្ថានភាពកម្ពុជា ទាំងវប្បធម៌ អភិបាលកិច្ច ដំណើរការច្បាប់ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ជាជាងពិនិត្យ តែរបាយការណ៍១ជ្រុងណាមួយ។

សម្រាប់លោកសុក សំអឿន ប្រធានក្រុមអ្នកច្បាប់អមរិន្ទ និងជាទីប្រឹក្សាច្បាប់នៃអង្គការតម្លាភាពកម្ពុជា បានសម្តែងការសាទរ ចំពោះកិច្ចសហការរវាងកម្ពុជា និងសហរដ្ឋអាមេរិក លើវិស័យច្បាប់ និងយុត្តិធម៌ប៉ុន្តែលោកបញ្ជាក់ថា វាអាស្រ័យទៅលើសកម្មភាពជាក់ស្តែង និងការអនុវត្តចំគោលដៅ ដើម្បីឱ្យវិស័យនេះប្រសើរឡើង ហើយលោកចង់ឱ្យភាគីទាំង ២ បង្កើនការជជែកគ្នាទៅលើឧបសគ្គនៃការអនុវត្តច្បាប់រួមគ្នាកន្លងមក។

ស្រដៀងគ្នានេះ លោក កង ឫទ្ធិគីរី ជាមេធាវី និងជាសាស្ត្រាចារ្យផ្នែកច្បាប់ ព្រមទាំងជាអតីតមេធាវីតំណាងក្នុងសំណុំរឿង ០១ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) វាយតម្លៃ

ខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការលើវិស័យយុត្តិធម៌ និងច្បាប់រវាងប្រទេសទាំង ២ ដែលជាទិដ្ឋភាពវិជ្ជមាន។ លោក កង ឫទ្ធិគីរី បានថ្លែងថា បើសិនសហរដ្ឋអាមេរិក និងកម្ពុជា បន្តធ្វើការជាមួយគ្នាលើវិស័យយុត្តិធម៌នេះ កម្ពុជានឹងអាចដើរចេញឆ្ងាយពីភាពអសកម្មហើយអាចគោរពគោលការណ៍សិទ្ធិមនុស្ស និងច្បាប់អន្តរជាតិបានល្អ ដោយសារសហរដ្ឋអាមេរិកប្រកាន់គោលការណ៍សិទ្ធិមនុស្ស និងច្បាប់អន្តរជាតិនេះ។

លោកមានប្រសាសន៍ថា៖ «តាមរយៈភាពជោគជ័យជាក់ស្តែងដែលសហរដ្ឋអាមេរិកបានចូលរួមចំណែកក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) សម្រាប់បញ្ហាខ្មែរក្រហមកន្លងទៅនោះជាសញ្ញាវិជ្ជមានមួយដែលកម្ពុជាគួរមានការទុកចិត្ត និងពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាមួយអាមេរិក ដើម្បីពង្រឹងនីតិរដ្ឋកម្ពុជា»។

## ភាគីជប៉ុននិងកម្ពុជា បានពិភាក្សាអំពីប្រព័ន្ធបញ្ជូនពលករជំនាញ និងកម្មសិក្សាការីពីកម្ពុជា ទៅប្រទេសជប៉ុន ដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពរបស់ពលករជំនាញ

https://cen.com.kh/archives/695050.html Posted ByPen Srey NeatSeptember 15, 2023

ភ្នំពេញ ៖ រដ្ឋាភិបាលជប៉ុននៅតែបន្តគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យកាន់តែរីកចម្រើន ស្របទៅតាមទស្សនវិស័យគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ឆ្នាំ ២០១៥-២០២៥ ដែលជាចំណុចគន្លឹះរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេស ដែលមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។

ការគាំទ្រនេះធ្វើឡើងក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងាររវាងឯកឧត្តម ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារ និបណ្តុះបណ្តាលវិជ្ជាជីវៈ និងឯកឧត្តម អ៊ូអិណូ អាត់ស៊ុស៊ី (UENO Atsushi ) ឯកអគ្គរដ្ឋទូតជប៉ុនប្រចាំកម្ពុជា នារសៀលថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងការងារ។ នាឱកាសនោះ ឯកឧត្តមរដ្ឋមន្ត្រីបានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលជប៉ុន ដែលបានចូលរួមចំណែកអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា ពិសេសជប៉ុនគឺជាប្រទេសទី១ ដែលបានផ្តល់អាហារូបករណ៍ដល់ប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩២ ដែលរហូតមកដល់ពេលនេះ អតីតសិស្ស និស្សិតអាហារូបករណ៍ជប៉ុនមួយចំនួនបាននិងកំពុងបម្រើការនៅក្នុងគណៈរដ្ឋមន្ត្រីថ្មី និងកំពុងកាន់តួនាទីសំខាន់នៅក្នុងរាជរដ្ឋាភិបាលនីតិកាលទី៧។

ជាការឆ្លើយតប ឯកឧត្តមឯកអគ្គរាជទូតជប៉ុន បានគូសបញ្ជាក់ពីកិច្ចសហប្រតិបត្តិរវាងប្រទេសទាំងពីរ ដែលបានដំឡើងដល់កម្រិតដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ។ ឯកឧត្តមឯកអគ្គរាជទូតជប៉ុនក៏បានសន្យាបន្តគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជាឱ្យកាន់តែរីកចម្រើន ជាក់

ស្តែងតាមរយៈការផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិតកម្ពុជាឱ្យទៅសិក្សានៅប្រទេសជប៉ុន ការបណ្តុះបណ្តាលជំនាញនៅក្នុងប្រទេស ដែលបាននិងកំពុងក្លាយជាស្ពានចម្លងដ៏សំខាន់នៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរយ៉ាងជិតស្និទ្ធ។

ក្នុងឱកាសនោះ ភាគីទាំងពីរ ក៏បានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការលើការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដើម្បីពង្រឹងចំណេះ ជំនាញដល់សិស្ស និស្សិតខ្មែរ ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាសម័យថ្មី។

ឯកឧត្តមរដ្ឋមន្ត្រី ហេង សួរ ក៏បានថ្លែងអំណរគុណដល់ក្រុមហ៊ុនជប៉ុននៅកម្ពុជា ដែលតែងតែយកចិត្តទុកដាក់ដល់សិស្ស និស្សិតកម្ពុជា ដែលកំពុងសិក្សាបច្ចេកទេស និងធ្វើការនៅក្រុមហ៊ុនជប៉ុន ដើម្បីពង្រឹងសមត្ថភាព ចំណេះ ជំនាញបច្ចេកវិទ្យាថ្មីៗបន្ថែមពីក្រុមហ៊ុនទាំងនោះ។ លើសពីនេះទៀត ភាគីទាំងពីរក៏បានពិភាក្សាអំពីប្រព័ន្ធបញ្ជូនពលករជំនាញ និងកម្មសិក្សាការីពីកម្ពុជាទៅប្រទេសជប៉ុន ដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពរបស់ពលករជំនាញ និងកម្មសិក្សាការីដែលកំពុងធ្វើការនៅប្រទេសជប៉ុន។

ឯកឧត្តមរដ្ឋមន្ត្រីបានបញ្ជាក់ជូនឯកឧត្តមឯកអគ្គរាជទូតជប៉ុនថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រៀមខ្លួនរួចជាស្រេច ដើម្បីសហការជាមួយស្ថានទូតជប៉ុន ក្រុមហ៊ុនជប៉ុន និងសមាគមអាជីវកម្មជប៉ុនដែលមានវត្តមាននៅកម្ពុជា៕ រក្សាសិទ្ធដោយ ៖ សុទ្ធលី

## ពលករខ្មែរឆ្លងដែនទៅប្រទេសថៃជួបបញ្ហាសុវត្ថិភាព

https://www.rfa.org/khmer/news/human-rights/cambodian-workers-facing-safety-during-illegal-crossing-to-thailand-09102023224709.html ដោយ សេក បណ្ឌិត2023.09.10

ពលករខ្មែរមួយចំនួន ឆ្លងដែនទៅប្រទេសថៃ ទាំងប្រថុយប្រថាន ដោយសារតែបញ្ហាជីវភាព គ្មានទីផ្សារលក់ទិន្នផលកសិកម្ម ភាពគ្មានការងារធ្វើសមរម្យ និងបញ្ហាជំពាក់បំណុលធនាគារ។ ពួកគាត់ថា គ្មានពលករណាម្នាក់ចង់ឃ្លាតឆ្ងាយពីក្រុមគ្រួសារ ធ្វើការរសាត់អណ្តែតនៅក្រៅប្រទេសនោះទេ ប្រសិនបើនៅក្នុងប្រទេសសម្បូរការងារធ្វើ និងទិន្នផលលក់បានតម្លៃថ្លៃ។ ពលករមួយចំនួនមិនអាចទ្រាំនឹងកត្តាទាំងនេះបាន ពួកគាត់បានចងការប្រាក់នាយទុន មួយចំនួន ដើម្បីឲ្យទៅមេខ្យល់នាំពលករទៅប្រទេសថៃ។ ក្នុងដំណើរឆ្លងដែន ពលករទាំងនោះ ឆ្លងដែនទាំងប្រថុយប្រថាន ដោយពុំស្គាល់ទិសតំបន់ និងច្បាប់នៅក្នុងប្រទេសថៃឡើយ។

ពលករនៅប្រទេសថៃ លោក លោក គូ សារឿន ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី៩ កញ្ញាថា លោកចំណាកស្រុកច្រើនលើកច្រើនសា អស់រយៈពេលជិត២០ឆ្នាំមកហើយ ដើម្បីធ្វើជាពលករក្រៅ

ប្រទេស ព្រោះកត្តាជីវភាព និងគ្មានលទ្ធភាពសងបំណុលធនាគារ។ លោកបន្តថា ការធ្វើចំណាកស្រុកទៅក្រៅប្រទេសនេះ លោកតែងជួបប្រទះការរត់ពួនលូនក្រាបពីសមត្ថកិច្ចថៃតាមឃាត់ខ្លួនរបស់គេ។ លោក គូ សារឿន៖ «ទីមួយយើងចំណាកស្រុកពីប្រទេសយើងចូលមកប្រទេសថៃ ទី១ណា។ ពេលហ្នឹងខ្ញុំត្រូវគេ យកទៅលក់នៅប្រទេសម៉ាឡេស៊ីទៀត ខ្ញុំមានការប្រឈមជាច្រើនអ៊ីចឹងហើយ បានជាខ្ញុំមានភាពតស៊ូ អារឿងពលករបងប្អូនយើង ខ្ញុំចេះតែទទូចរាល់គ្រប់ពេលវេលា ដែលបញ្ហា ដែលខ្ញុំជួបផ្ទាល់អីចឹងហា»។

ពលករនៅប្រទេសថៃម្នាក់ទៀត កញ្ញា គឹម ហុង ថ្លែងថា កញ្ញាធ្លាប់លួចឆ្លងដែនដោយខុសច្បាប់ ដើម្បីធ្វើជាពលករនៅប្រទេសថៃ បើទោះបីជាមានការភ័យខ្លាចសមត្ថកិច្ចថៃឃាត់ខ្លួនក៏ដោយ។ កញ្ញាបន្តថា ក្នុងពេលឆ្លងដែននោះ មេខ្យល់បានឲ្យកញ្ញាដើរថ្មើរជើងឆ្លងព្រំដែន ដែលមានចម្ងាយឆ្ងាយ និងត្រូវរង់ចាំនៅទឹកដីថៃ ដើម្បីរង់ចាំរហូតឡានថៃ មកដឹកទៅគោលដៅ។ កញ្ញា គឹម ហុង៖ «ពិបាក ពេលខ្លះយើងដើរឆ្ងាយហ៉ាបង ដើរកាត់ព្រៃកាត់បន្ទាកាត់អី អ៊ីចឹងហា ឆ្លងទឹកអ្នកខ្លះឆ្លងទឹកក៏មានដែរ អ្នកខ្លះដាច់បាយដាច់ទឹក២ ៣ថ្ងៃដេកក្នុងព្រៃក៏មានចាំ រត់កាត់ព្រៃក៏មាន។ គេអ្នកខ្លះទៅប៉ះទាហានដេញក៏មានដែរបង តែបើយើងដើរឆ្លងចូលដីគេហើយ យើងគេចៗខ្លួនហ្នឹងហើយខ្លាចគេឃើញអីចឹងហ៉ា»។

ពលករអះអាងដូចៗគ្នាថា បើនៅកម្ពុជា មានការងារ ដែលមានប្រាក់ខែសមរម្យ ឲ្យពួកគាត់រស់នៅប្រកបដោយភាពថ្លៃថ្នូរ គ្មានពលករ ខ្មែរណាម្នាក់ ចំណាកស្រុកឆ្ងាយផ្ទះសម្បែង សាច់ញាតិបងប្អូននោះទេ។ ពួកគេស្នើដល់រដ្ឋាភិបាលថ្មីដឹកនាំដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែតបង្កើតឱកាសការងារក្នុងប្រទេស ដើម្បីឲ្យពលករចំណាកស្រុកក្រៅប្រទេស ត្រឡប់មកធ្វើការជិតផ្ទះ និងបានជួបជុំក្រុមគ្រួសារវិញ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ថ្លែងពីការធ្វើចំណាកស្រុករបស់ពលរដ្ឋនៅបណ្ដាលប្រទេសនានា គឺដើម្បីទទួលបានប្រាក់ចំណូលច្រើន ក្នុងនោះសហរដ្ឋអាមេរិក និងកូរ៉េខាងត្បូងក៏មានពលករចំណាកស្រុកស្វែងរកការងារនៅក្រៅប្រទេសផងដែរ។ លោកក៏ថ្លែងទទួលស្គាល់ថា មន្ត្រីត្រួតពិនិត្យច្រកព្រំដែនគិតសេវាក្រៅផ្លូវការពីពលរដ្ឋ។ លោក ហ៊ុន ម៉ាណែត បន្តថា រដ្ឋាភិបាលអនុញ្ញាតឲ្យរៀបចំធ្វើលិខិតឆ្លងដែន ជូនពលករខ្មែរនៅក្រៅប្រទេស ចាប់ផ្ដើមពីប្រទេសកូរ៉េខាងត្បូង និងណែនាំដល់ក្រសួងការបរទេស បង្កើតកុងស៊ុលនៅភាគខាងត្បូងប្រទេសថៃ ដើម្បីពង្រីកសេវានានាជូនពលករខ្មែរ។

លោក ហ៊ុន ម៉ាណែត៖ «ពលករយើងបង្កើតទាំងក្នុងប្រទេសទាំងក្រៅប្រទេស មិនមែនយើងជំរុញពលរដ្ឋយើងទៅធ្វើខ្ញុំគេទេណា។ យើងបង្កើនការងារដើម្បីប្រជាពលរដ្ឋយើងមានជម្រើស។

យើងខិតខំបង្កើតផ្ទៃក្នុងដើម្បីឲ្យបងប្អូនយើងមានឱកាស តែយើងក៏មិនហាមឃាត់បងប្អូនទៅក្រៅប្រទេសដែរ។ ហើយនៅលើពិភពលោកនេះ គ្មានគោលនយោបាយណាមួយ ដែលហាមឃាត់ប្រជាពលរដ្ឋពលករមិនឲ្យចេញទៅក្រៅប្រទេសធ្វើការនោះទេ លើកលែងតែប្រទេសខ្លះ ដែលពាក់ព័ន្ធរឿងការដាក់ទណ្ឌកម្ម ដោយយូអ៊ិន(UN-អង្គការសហប្រជាជាតិ) គេបិទមិនឲ្យកូរ៉េខាងជើងមិនអាចចេញបាន តែគ្រប់ប្រទេសទាំងអស់ ឥឡូវគ្រប់ប្រទេសទាំងអស់ខិតខំនាំគ្នាជំរុញគេហៅ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី»។

ឆ្លើយតបនឹងការលើកឡើងនេះ មន្ត្រីគម្រោង នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស អង្គការសង់ត្រាល់ (CENTRAL) លោក លឹង សុផុន មានប្រសាសន៍ថា លោកត្រេកអរចំពោះនាយករដ្ឋមន្ត្រីថ្មី ដែលរៀបចំធ្វើលិខិតឆ្លងដែននៅក្រៅប្រទេស ដោយសារកន្លងទៅពលករខ្មែរចំណាកស្រុកទៅក្រៅប្រទេស រួមទាំងប្រទេសថៃ តែងជួបបញ្ហាឯកសារដូចជា លិខិតឆ្លងដែន និងទិដ្ឋាការការងារជាដើម។ លោក លឹង សុផុន៖ «ពួកគាត់ភាគច្រើន ដែលចូលមក(ប្រទេសថៃ)គឺដោយសារតែជីវភាពខ្វះខាត ជីវភាព ដែលពួកគាត់មិនអាចទ្រទ្រង់បានដូចជា គាត់មានបញ្ហាបំណុលធនាគារ គាត់មានប្រាក់ចំណូលតិចជាងប្រាក់ចំណាយអីចឹងហាណាបាទ ។ ហើយធ្វើឲ្យគាត់ហូរចូល តែប្រសិនបើរដ្ឋាភិបាលមានវិធានការដើម្បីឲ្យមានការងារច្រើនពួកគាត់មិនចូលមកប្រទេសថៃទេ»។

របាយការណ៍ក្រសួងការងារបង្ហាញថា មកទល់ពេលនេះ ពលករកម្ពុជា កំពុងធ្វើការនៅក្រៅប្រទេសជាង១លាន ៣សែននាក់ (១.៣២១.៩០៦) ក្នុងនោះនៅប្រទេសថៃមានចំនួនជាង ១លាន ២សែននាក់ និងនៅប្រទេសកូរ៉េខាងត្បូងមានចំនួនជិត៥ម៉ឺននាក់។ ប៉ុន្តែអង្គការសង្គមស៊ីវិលផ្នែកការពារសិទ្ធិពលករវិញបង្ហាញថា ចំនួនពលករកម្ពុជានៅក្រៅប្រទេសអាចមានទៅដល់ជាង ២លាននាក់ដោយរាប់ទាំងពលករស្របច្បាប់ និងមិនស្របច្បាប់៕

# ថ្ងៃទី១៨ ខែ កញ្ញា ឆ្នាំ២០២៣

## ប្រធានាធិបតី ចិន
## បង្ហាញឆន្ទៈបន្តកិច្ចសហប្រតិបត្តិការបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែនជាមួយ កម្ពុជា

https://www.kampucheathmey.com/politics/578976 ថ្ងៃសុក្រ ១៥ កញ្ញា ២០២៣ដោយ Sok Chivon

ប្រធានាធិបតីចិនលោក ស៊ី ជីនពីង មានប្រសាសន៍ថា ប្រទេសចិនមានឆន្ទៈក្នុងការធ្វើការជាមួយកម្ពុជាលើការអនុវត្តច្បាប់ និងកិច្ចសហប្រតិបត្តិការសន្តិសុខ ហើយបន្តការបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែន ដូចជា ល្បែងស៊ីសងតាមអនឡាញ និងការបោកប្រាស់តាមទូរគមនាគមន៍ជាដើម ។

ប្រធានាធិបតីចិនលោក ស៊ី ជីនពីង បានលើកឡើងបែបនេះក្នុងជំនួបជាមួយសម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងរដ្ឋធានីប៉េកាំងនៅថ្ងៃទី១៥ ខែកញ្ញា នេះ ។ យោងតាមប្រព័ន្ធផ្សព្វផ្សាយរដ្ឋចិនបានរាយការណ៍នៅថ្ងៃសុក្រនេះថា ប្រទេសចិនក៏មានឆន្ទៈក្នុងការរក្សាទំនាក់ទំនងជាយុទ្ធសាស្ត្រ និងធ្វើឲ្យមានការផ្លាស់ប្ដូរកាន់តែស៊ីជម្រៅលើអភិបាលកិច្ចជាមួយព្រះរាជាណាចក្រកម្ពុជាផងដែរ ។

គួរបញ្ជាក់ថា នេះជាដំណើរទស្សនកិច្ចផ្លូវការលើកដំបូងរបស់សម្ដេចធិបតី ហ៊ុន ម៉ាណែត ទៅកាន់ប្រទេសចិន បន្ទាប់ពីសម្ដេចចូលកាន់តំណែង ហើយក៏បង្ហាញពីសារៈសំខាន់ដ៏ធំធេងដែលរដ្ឋាភិបាលថ្មីរបស់កម្ពុជាបានផ្សារភ្ជាប់ទំនាក់ទំនងចិន-កម្ពុជា ។ ម្យ៉ាងឆ្នាំនេះក៏ជាខួបលើកទី ៦៥ នៃការបង្កើតទំនាក់ទំនងការទូតចិន-កម្ពុជា និងឆ្នាំមិត្តភាពចិន-កម្ពុជាផងដែរ ៕

## នគរបាលកម្ពុជា-វៀតណាម ប្ដេជ្ញារួមគ្នាប្រយុទ្ធប្រឆាំង និងបង្ក្រាបបទល្មើសតាមព្រំដែន

https://www.kampucheathmey.com/local-news/579433 ថ្ងៃសៅរ៍ ១៦ កញ្ញា ២០២៣ដោយ Thoeun Vansong

នគរបាលជាតិកម្ពុជា និងនគរបាលវៀតណាម ប្ដេជ្ញាបន្តសហការរួមគ្នាលើការប្រយុទ្ធប្រឆាំង និងបង្ក្រាបបទល្មើសតាមព្រំដែននៃប្រទេសទាំងពីរ ក៏ដូចជាការស្វែងរកចាប់មុខសញ្ញាដែលបានរត់គេចខ្លួន។ ការប្ដេជ្ញារបស់នគរបាលទាំងពីរ ធ្វើឡើងដោយលោកនាយឧត្តមសេនីយ៍ ស ថេត និងលោកប្រធានស្ថានតំណាងក្រសួងនគរបាលអមស្ថានទូតវៀតណាមប្រចាំកម្ពុជា។

ក្នុងជំនួបសម្ដែងការគួរសម កាលពីរសៀលថ្ងៃទី១៥ ខែកញ្ញា លោក LE VAN PHUONG ប្រធានស្ថានតំណាងក្រសួងនគរបាលអមស្ថានទូតវៀតណាមប្រចាំកម្ពុជា បានពាំនាំនូវពាក្យពេចន៍ជូនពររបស់ក្រសួងនគរបាលវៀតណាម ជូនលោកនាយឧត្តមសេនីយ៍ ស ថេត ដែលត្រូវតែងតាំងជា អគ្គស្នងការនគរបាលជាតិ។ ក្នុងឱកាសនោះ លោក LE VAN PHUONG បានបង្ហាញការប្ដេជ្ញាបន្តកិច្ចសហប្រតិបត្តិការរវាងនគរបាលវៀតណាម និងនគរបាលជាតិកម្ពុជា លើវិស័យសន្តិសុខ សណ្ដាប់ធ្នាប់ ពិសេសការប្រយុទ្ធប្រឆាំងបង្ក្រាបបទល្មើសតាមបណ្ដោយព្រំដែន នៃប្រទេសទាំងពីរ ដ៏ដូចជាការស្វែងរកចាប់មុខសញ្ញាដែលរត់គេចខ្លួន។

ជាការឆ្លើយតប លោកនាយឧត្តមសេនីយ៍ ស ថេត អគ្គស្នងការនគរបាលជាតិកម្ពុជា បានឯកភាពចំពោះ ការលើកឡើងរបស់លោកប្រធានស្ថានតំណាងក្រសួងនគរបាលអមស្ថានទូតវៀតណាម។ តែយ៉ាងណា លោក ស ថេត បានសង្កត់ធ្ងន់លើការអនុវត្តឱ្យបានខ្ជាប់ខ្ជួន និងមានប្រសិទ្ធភាពស្របតាមផែនការនៃសហប្រតិបត្តិការប្រចាំឆ្នាំរវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងនគរបាលវៀត

ណាម ជាពិសេសបន្តជំរុញយន្តការដែលមានស្រាប់ក្នុងការផ្តល់កិច្ចសហប្រតិបត្តិរវាងកម្ពុជា-វៀតណាមឱ្យកាន់តែស្អិតរមួតបន្ថែមទៀតដើម្បីបម្រើឱ្យវិស័យសន្តិសុខ សណ្តាប់ធ្នាប់នៃប្រទេសទាំងពីរ។

ជាងនេះទៅទៀត លោកនាយឧត្តមសេនីយ៍ អគ្គស្នងការនគរបាលជាតិ បានបញ្ជាក់ជូនលោកប្រធានស្ថានតំណាង អំពីគោលជំហររក្សាសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការជាប្រពៃណីដែលថ្នាក់ដឹកនាំនគរបាលជាតិ នៃប្រទេសទាំងពីរសម្រេចបាន និងប្តេជ្ញាបន្តពូនជ្រុំកិច្ចសហប្រតិបត្តិការនេះឱ្យកាន់តែរឹងមាំ និងជិតស្និទ្ធជារៀងរហូត៕

## ពលរដ្ឋខ្មែរជិត ២ម៉ឺននាក់បន្ថែមទៀត នឹងទទួលបានការងារធ្វើនៅក្រៅប្រទេស

https://www.kampucheathmey.com/business-economic/579528 ថ្ងៃសៅរ៍ ១៦ កញ្ញា ២០២៣

ដោយ Sophal Tuon

ពលករខ្មែរ ប្រមាណជិត២ម៉ឺននាក់បន្ថែមទៀត នឹងទទួលបានការងារធ្វើនៅតាមបណ្តាប្រទេសមួយចំនួន ដែលនឹងជួយលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង។ តាមការប៉ាន់ស្មាន ចាប់ពីខែកញ្ញា ដល់ខែធ្នូ ឆ្នាំ២០២៣ កម្ពុជា គ្រោងនឹងបញ្ជូនពលករទៅធ្វើការនៅបរទេស ចំនួនប្រមាណ ១៩ ០០០នាក់។ នេះជាការបញ្ជាក់របស់លោក កត្តា អ៊ន អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ នៅព្រឹកថ្ងៃទី១៦ កញ្ញានេះ។ លោកបានបន្តថា ពលករទាំងនោះនឹងបញ្ជូនទៅធ្វើការនៅ៣ប្រទេសរួមមានប្រទេសថៃ សាធារណរដ្ឋកូរ៉េ និងប្រទេសជប៉ុន ដែលនឹងជួយលើកស្ទួយដល់ជីវភាពប្រជាពលរដ្ឋក៏ដូចជាសេដ្ឋកិច្ចជាតិ កាន់តែរីកចម្រើនបន្ថែមទៀតផងដែរ។

លោក កត្តា អ៊ន បានបន្តថា គិតត្រឹមខែ សីហា ឆ្នាំ២០២៣នេះ កម្ពុជាមានពលករកំពុងស្នាក់នៅ និងធ្វើការនៅក្រៅប្រទេសចំនួន ១៣២២៩៦៣នាក់ ស្រី ៥២៦៩៨១នាក់ ក្នុងនោះប្រទេសថៃចំនួន១២២៨២២៥នាក់ ស្រី៥០២២៥០នាក់ ប្រទេសម៉ាឡេស៊ីចំនួន ២២៥៧២នាក់២១៦៥២នាក់ ប្រទេសអារ៉ាប៊ីសាអូឌីតមាន២៩នាក់ ប្រទេសជប៉ុន មាន២០៨១២នាក់ស្រី៩៦៧៦នាក់ ប្រទេសសិង្ហបុរីមាន៨៦២នាក់ ស្ត្រីទាំងអស់ កូរ៉េខាងត្បូងមាន ៥០២២៥នាក់និងតំបន់សេដ្ឋកិច្ចពិសេសហុងកុងមាន២១៦នាក់ ស្រីទាំងអស់។

លោកបានបន្តថា ក្នុងចំណោមពលករជាង១លាន៣សែននាក់ ក្នុងនឡទៅធ្វើការផ្នែកកសិកម្មមានចំនួន២៦២៤១៨នាក់ ផ្នែកឧស្សាហកម្មចំនួន៥៦៥៨១០នាក់ ផ្នែកសំណង់ចំនួន៣៧៨៦២១នាក់ ផ្នែកការងារផ្ទះចំនួន១៦៧០៩នាក់ និងការងារផ្សេងៗចំនួន១១៩២០៥នាក់ដោយពួកគេផ្ញើប្រាក់ត្រឡប់មកប្រទេសកម្ពុជាវិញមានចំនួន២៩១៨៨៧២១៩៩ដុល្លារ។

បើតាមលោក កក្កា អ៊ិន ពលករទៅធ្វើការនៅប្រទេសថៃជាមធ្យមទទួលបានប្រាក់ខែ២០០ ដុល្លារក្នុង១ខែ ប្រទេសម៉ាឡេស៊ីទទួលបានប្រាក់ខែ៣២០ដុល្លារ ប្រទេសអារ៉ាប៊ីសាអូឌីតទទួលបាន ប្រាក់ខែ២០០ដុល្លារ ប្រទេសជប៉ុន ទទួលបានប្រាក់ខែ១២០០ដុល្លារ ប្រទេសសិង្ហបុរីទទួលបានប្រាក់ ខែ៥០០ដុល្លារកូរ៉េខាងត្បូងទទួលបានប្រាក់ខែ១៥០០ដុល្លារ និងតំបន់សេដ្ឋកិច្ចពិសេសហុងកុង ទទួលបានប្រាក់ខែ៥៩១ដុល្លារ។ អត្ថបទ៖ សំអឿន

## លិខិតមិត្តអ្នកអាន៖ ការរំកិលសេវាលិខិតឆ្លងដែនដល់កាំជណ្ដើរពលករនៅក្រៅប្រទេស ជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធិភាពថ្មីសម្រាប់ពលករដែលគួរតែសាទរ

https://news.btv.com.kh/article/30521 2023/09/17 04:02:15 pm

នៅក្នុងជំនួបសំណេះសំណាលជាមួយកម្មករ កម្មការិនីជិត ២ម៉ឺននាក់ នៅខេត្តកំពង់ស្ពឺកាល ពីពេលថ្មីៗកន្លងទៅនេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត បានប្រកាសអនុញ្ញាតឱ្យសមត្ថកិច្ច ពាក់ព័ន្ធ រៀបចំធ្វើលិខិតឆ្លងដែនជូនពលករខ្មែរដែលកំពុងស្នាក់នៅ និងធ្វើការក្នុងប្រទេសកូរ៉េខាង ត្បូងដល់ទីតាំងនោះផ្ទាល់តែម្តង ដើម្បីសម្របសម្រួលមធ្យោបាយ កាត់បន្ថយពេលវេលា ការ ចំណាយរបស់ពលករខ្មែរនៅទីនោះ។ លោកនាយករដ្ឋមន្ត្រីមានប្រសាសន៍គូសបញ្ជាក់ថា លោក បានសម្រេចអនុញ្ញាតឱ្យរៀបចំធ្វើលិខិតឆ្លងដែន (Passport) បាននៅក្រៅប្រទេសតែម្តង ដោយចាប់ ផ្តើមពីកូរ៉េខាងត្បូងមុនគេ។

តាមរយៈការលើកឡើងរបស់ប្រមុខរដ្ឋាភិបាលដូច្នេះ ត្រូវគេមើលឃើញថាជារបត់មួយថ្មី បន្ថែមទៀតជាពិសេសពាក់ព័ន្ធនឹងវិស័យការងារកម្ពុជា គឺជាលើកដំបូងហើយ ដែលប្រមុខរដ្ឋាភិបា ល តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមនឹងស្ថាប័នពាក់ព័ន្ធផ្សេងទៀត មានការ គិតគូរដល់សុខទុក្ខ និងបញ្ហាចោទរបស់ពលករខ្មែរនៅក្រៅប្រទេស មិនត្រឹមតែកម្មករនៅក្នុង ប្រទេសនោះទេ។ ជាទូទៅការដែលប្រមុខរដ្ឋាភិបាលកម្ពុជាបង្ហាញនូវសុឆន្ទៈដ៏ម៉ោះមុតក្នុងការធ្វើឲ្យ ប្រសើរឡើងនូវសេវាកម្មធ្វើលិខិតឆ្លងដែនដល់ៗទីកន្លែង ដែលពលករស្នាក់នៅ និងធ្វើការឯក្រៅ ប្រទេសដូច្នេះ វាជាការឆ្លុះបញ្ចាំងនូវទំនុកចិត្តដ៏ខ្ពស់ និងការយកចិត្តទុកដាក់ដ៏ធំធេងទៅលើតម្លៃនៃ កម្លាំងពលកម្ម ខណៈដែលរដ្ឋាភិបាលថ្មីទើបតែចេញដំណើរមិនដល់មួយខែផង។

ជាការពិត ការសម្រេចអនុញ្ញាតឲ្យក្រសួងការងារ ក្រសួងការបរទេស ក្រសួងមហាផ្ទៃរួមនឹង ស្ថាប័នពាក់ព័ន្ធសហការគ្នាផ្តល់លិខិតឆ្លងដែនដល់ពលករនៅក្រៅប្រទេសដល់កន្លែងពួកគេធ្វើការ តែម្តងនោះ គឺជាគុណសម្បត្តិមួយដ៏ធំធេង និងជាការផ្តល់ផលប្រយោជន៍ដ៏ក្រាស់ក្រែលសម្រាប់ ពលករកម្ពុជា ដែលធ្វើចំណាកស្រុកទៅធ្វើការនៅបរទេស។ តួយ៉ាងដូចជានៅប្រទេសកូរ៉េខាងត្បូង ជាដើម ដែលជាការចាប់ផ្តើមមុនគេនេះ គឺពិតជាជួយសម្រួលដល់ពលករខ្មែរដ៏ច្រើនមិនអាចប្រកែក

បាន ខណៈពលករខ្មែរនៅកូរ៉េខាងត្បូងប្រមាណ៦ម៉ឺននាក់នឹងទទួលបានអត្ថប្រយោជន៍នេះយ៉ាង ពិតប្រាកដ។ ផលប្រយោជន៍ដែលពលករខ្មែរទទួលបាននោះគឺការជួយបង្កើនប្រាក់ចំណូលដល់ពួក គេបន្ថែមទៀត នៅពេលដែលការចំណាយមួយចំនួនរបស់ពលករមិនត្រូវបានបាត់បង់តាមរយៈយន្ត ការថ្មីរបស់ប្រមុខរដ្ឋាភិបាល។

តាមសភាពជាក់ស្តែងពលករម្នាក់ៗ ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសកូរ៉េ ពិតជា មានភាពចាំបាច់នឹងត្រូវការជំនួយពីរាជរដ្ឋាភិបាល ដោយហេតុថាពួកគេមានការលំបាកក្នុងការធ្វើ លិខិតឆ្លងដែនថ្មី ខណៈដែលលិខិតឆ្លងដែនចាស់អស់សុពលភាព និងមិនអាចពន្យាបាន ហើយត្រូវ ចំណាយពេលវេលា និងថវិកាធ្វើដំណើរត្រលប់មកប្រទេសកម្ពុជាវិញ ដើម្បីធ្វើលិខិតឆ្លងដែនថ្មី និង ឯកសារផ្សេងៗទៀត ដូចជាលិខិតថ្កោលទោសជាដើម។

មួយវិញទៀត ការដែលត្រូវចាកចេញពីកន្លែងធ្វើការមួយរយៈ ក៏ព្រោះតែដើម្បីវិលត្រលប់ទៅ ប្រទេសកំណើត ដើម្បីធ្វើលិខិតឆ្លងដែន និងលិខិតស្នាមផ្សេងៗ មិនមែនជាការងាយស្រួលទេ។ ពល ករខ្លះបានប្រឈមនឹងការសុំអនុញ្ញាតច្បាប់តឹងតែងពីនិយោជកសហគ្រាស ក្រុមហ៊ុន ឬកសិដ្ឋាន ដោយគេបារម្ភថាអវត្តមានរបស់បុគ្គលិកច្រើន នឹងធ្វើឲ្យប៉ះពាល់ដល់ច្រវ៉ាក់ផលិតកម្មរបស់គេ។ ពេលខ្លះនិយោជកអាចនឹងកាត់ប្រាក់ខែក៏មាន។

ក៏ប៉ុន្តែបញ្ហាលំបាកទាំងនេះ នឹងលែងមានទៀតហើយ ហើយនឹងត្រូវបានដោះស្រាយតាមរ យៈការសម្រេចចិត្តប្រកបដោយគតិបណ្ឌិត និងការគិតគូរដ៏ធំធេង របស់ប្រមុខរដ្ឋាភិបាលកម្ពុជា លោកបណ្ឌិត ហ៊ុន ម៉ាណែត។ ដូច្នេះការដាក់ការិយាល័យនៅតាមទីតាំងការងារពលករ ដែលមាន ចំងាយរាប់ពាន់គីឡូម៉ែត្រពីមាតុប្រទេស ដើម្បីធ្វើលិខិតឆ្លងដែនដល់ពលករនៅប្រទេសកូរ៉េពេល នេះ គឺជាសក្ខីភាពបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលបន្ថែមទៀត បន្ថែមពីលើការ ប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការជួយរកការងារឲ្យពលរដ្ឋរបស់ខ្លួនធ្វើនៅក្រៅប្រទេស ដើម្បី បង្កើនប្រាក់ចំណូលសម្រាប់សេដ្ឋកិច្ចគ្រួសារ។

អតីតអ្នកការទូត ក៏ដូចជាអ្នកតាមដានសង្គមនានាយល់ឃើញប្រហាក់ប្រហែលគ្នាថា ការ សម្រេចចិត្តរបស់លោកបណ្ឌិត ហ៊ុន ម៉ាណែត គឺជាកាយវិការដ៏ឈ្លៀសវៃមួយ ដែលបង្ហាញនូវការ ប្តេជ្ញាចិត្តខ្ពស់នៅចំពោះមុខពលរដ្ឋម្ចាស់ឆ្នោត និងប្រជាជាតិខ្មែរទាំងមូលថារាជរដ្ឋាភិបាលថ្មីដែល ដឹកនាំដោយអ្នកបន្តវេនគណបក្សប្រជាជនកម្ពុជាពិតជាមានសមត្ថភាព និងគុណភាពក្នុងការដឹកនាំ និងដោះស្រាយនូវបញ្ហាប្រឈមនានារបស់ពលរដ្ឋខ្មែរទាំងនៅក្នុង និងក្រៅប្រទេស។ ទោះយ៉ាងណា យន្តការបង្វិតសេវាលិខិតឆ្លងដែនទៅកៀកនឹងកាំជណ្តើររបស់ពលករ ដែល ប្រមុខរដ្ឋាភិបាលកម្ពុជា បានដាក់ចេញពេលនេះ ត្រូវបានគេមើលឃើញថាមិនអាចគេចផុតពីការរិះគន់ពីសំណាក់ពួក

ប្រឆាំងផ្ទាប់មុខមួយចំនួនតូចថាធ្វើឡើងក្នុងគោលបំណងកេងចំណេញនយោបាយ។ ក៏ប៉ុន្តែអ្នកតាមដានសង្គមនានា ក៏ដូចជាអតីតអ្នកការទូតយល់ឃើញថា ដើម្បីប្រយោជន៍របស់ពលរដ្ឋ និងសង្គម ទោះជារងនូវការរិនិច្ឆ័យដោយអយុត្តិធម៌យ៉ាងណា ក៏រាជរដ្ឋាភិបាលមិនរាថយដែរ។

តាមពិតទៅ ការរំកិលសេវាទៅកៀកពលករខ្មែរនៅក្រៅប្រទេស មិនមែនជារូបភាពនយោបាយអ្វីទេ ផ្ទុយទៅវិញ វាជាការប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការយល់ដឹង និងទទួខុសត្រូវពីសុខទុក្ខរបស់ប្រជាពលរដ្ឋ ហើយខិតខំកែលម្អ និងដាក់ចេញនូវគោលនយោបាយឲ្យប្រសើរជាងមុន។ ដូច្នេះ តាមរយៈការចាប់ផ្តើមការរំកិលការធ្វើលិខិតឆ្លងដែននៅដល់ទីកន្លែងធ្វើការរបស់ពលករជាលើកដំបូងនៅកូរ៉េខាងត្បូង ពលករខ្មែរនៅប្រទេសផ្សេងទៀតក៏បានសម្តែងការគាំទ្រ ហើយក៏ទន្ទឹងរង់ចាំយ៉ាងអន្ទះសារផងដែរនូវយន្តការថ្មី ដែលដាក់ចេញដោយប្រមុខរដ្ឋាភិបាលថ្មី ហើយនេះបង្ហាញពីលទ្ធផល និងការតបស្នងដែលបានកើតឡើងពីការគាំទ្រយ៉ាងក្ដូកទឹកក្ដូកដីពីប្រជាពលរដ្ឋកាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ កន្លងទៅ។

តាមការឲ្យដឹងពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពលកររកម្ពុជាប្រមាណជាង១,៣លាននាក់ បាននិងកំពុងបំរើការងារនៅក្រៅប្រទេសចំនួន៧ ក្នុងនោះមានថៃ កូរ៉េ ជប៉ុន សិង្ហបុរី ហុងកុង និងអារ៉ាប៊ីសាអ៊ូឌីត ក្នុងនោះប្រទេសថៃមានពលករខ្មែរច្រើនជាងគេ ដល់ទៅជាង ១,២លាននាក់។ ក្នុងមួយឆ្នាំៗ ពលករខ្មែរដែលបានទៅធ្វើការនៅក្រៅប្រទេសទាំងអស់នេះ បានបញ្ជូនប្រាក់ទៅកាន់ក្រុមគ្រួសាររបស់ពួកគេនៅក្នុងប្រទេសប្រមាណជិត ៣ពាន់លានដូល្លារអាមេរិក។

ជាសរុបមកការរំកិលសេវាធ្វើលិខិតឆ្លងដែនសម្រាប់ពលករដល់ទីតាំងដែលពួកគេធ្វើការនៅក្រៅប្រទេស គឺជាយន្តការមួយដែលមានការសាទរដ៏ច្រើនលើសលប់ ដែលយន្តការនេះជាសញ្ញាមួយបង្ហាញថាការចេញដំណើររបស់រាជរដ្ឋាភិបាលថ្មីក្រោមការដឹកនាំរបស់លោកបណ្ឌិត ហ៊ុន ម៉ាណែត ពិតជាការចេញដំណើរមួយប្រកបដោយភាពត្រឹមត្រូវ មានភាពប្រាកដនិយមច្រើន ដែលលទ្ធផលទាំងអស់នេះស្តែងឲ្យឃើញពីសមត្ថភាពពិតរបស់អ្នកដឹកនាំវ័យក្មេងរបស់គណបក្សប្រជាជនកម្ពុជាប្រកបដោយគុណភាព៕

# ថ្ងៃទី១៩ ខែ កញ្ញា ឆ្នាំ២០២៣

## ឧបនាយករដ្ឋមន្ត្រី នេត សាវឿន ដឹកនាំកិច្ចប្រជុំគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូល របស់ពលករខ្មែរតាមព្រំដែនកម្ពុជា

https://www.information.gov.kh/articles/113823 *ចេញផ្សាយ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០២៣*

*ថ្ងៃទី១៨ ខែ កញ្ញា ឆ្នាំ២០២៣ ឯកឧត្តម សន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី ប្រធានគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូល របស់ពលករខ្មែរតាមព្រំដែនកម្ពុជា បានអញ្ជើញដឹកនាំកិច្ចប្រជុំលើកដំបូង គណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូល របស់ពលករខ្មែរតាមព្រំដែនកម្ពុជានៅទីស្តីការគណៈរដ្ឋមន្ត្រី។*

## ឯកឧត្តម នេត សាវឿន
## ប្រាប់អាជ្ញាធរនៅតាមព្រំដែនជួយដោះស្រាយរាល់បញ្ហាប្រឈមរបស់ពលករខ្មែរ

https://btv.com.kh/article/30583 2023/09/18 03:03:02 pm

*ភ្នំពេញ ៖ ឯកឧត្តម នេត សាវឿន ឧបនាយករដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូលរបស់ពលករខ្មែរតាមព្រំដែនកម្ពុជា បានណែនាំដល់អាជ្ញាធរនៅតាមបណ្តោយព្រំដែន ដែលជាប់នឹងប្រទេសថៃទាំងអស់ ត្រូវជួយដោះស្រាយរាល់បញ្ហាប្រឈមនានារបស់បងប្អូនពលករខ្មែរ ដែលធ្វើការនៅប្រទេសថៃ និងមួយវិញទៀតត្រូវលុបបំបាត់បាតុភាពអសកម្មផ្សេងៗ ដែលបង្កការលំបាកដល់ពួកគាត់ ពេលធ្វើដំណើរចេញ-ចូលជាដើម។ នៅក្នុងកិច្ចប្រជុំគណៈកម្មការចំពោះកិច្ចនាព្រឹកថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣នេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី នេត សាវឿន បានរំលឹកដល់ថ្នាក់ដឹកនាំបណ្តាអង្គភាពផ្សេងៗ នៅក្នុងគណៈកម្មការចំពោះកិច្ចនេះ ពិសេសសមត្ថកិច្ចតាមច្រកទ្វារព្រំដែន ត្រូវតែកែប្រែឥរិយាបថក្នុងការបំពេញការងារ ដោយធ្វើយ៉ាងណាឲ្យពលករដែលត្រូវចំណាកស្រុកចេញទៅក្រៅប្រទេស មានភាពកក់ក្តៅក្នុងការទទួលសេវា និងមិនត្រូវឲ្យពួកគាត់មានការថ្នាំងថ្នាក់អ្វីបន្តទៀតនោះទេ។*

*ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានជំរុញដល់ស្ថាប័នពាក់ព័ន្ធ ដោយក្នុងនោះសំខាន់គឺ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអភិបាលខេត្តជាប់ព្រំដែន ត្រូវជួបធ្វើការជាមួយភាគីថៃ ដើម្បីសម្រួលដល់ការធ្វើដំណើររបស់ពលករចំណាកស្រុក ហើយដើម្បីជាយន្តការមួយផ្តល់ភាពងាយស្រួលដល់ពលករចំណាកស្រុកនោះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី គ្រោងបង្កើតយន្តការពិនិត្យមួយពីថ្នាក់ជាតិ ដើម្បីចុះត្រួតពិនិត្យតាមច្រកទ្វារតែម្តង សំដៅទទួលយកបញ្ហាកង្វល់ និងដាក់ចេញវិធានការដោះស្រាយរបស់ពលករ។ លើសពីនេះ ឯកឧត្តមក៏បានណែនាំឲ្យបង្កើតប្រព័ន្ធទំនាក់ទំនងទាន់ហេតុ*

ការណ៍មួយផងដែរ (Hotline) និងបណ្តាញទំនាក់ទំនងសង្គម ដើម្បីពលករទាំងអស់អាចមានមធ្យោបាយរាយការណ៍មកថ្នាក់ជាតិ ទប់ស្កាត់រាល់បាតុភាពនានាដែលកើតឡើងចំពោះពួកគាត់។

សូមបញ្ជាក់ថាសម្តេចធិបតី ហ៊ុន ម៉ាណែត បានបង្កើតគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូលរបស់ពលករខ្មែរតាមព្រំដែនកាលពីសប្តាហ៍កន្លងទៅនេះ។ គោលបំ ណងដែលបង្កើតគណៈកម្មការនេះឡើង គឺដើម្បីតាមដាន និងត្រួតពិនិត្យការអនុវត្តវិធានការនានាដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ដើម្បីលុបបំបាត់ភាពមិនប្រក្រតី និងបាតុភាពផ្សេងៗ ក៏ដូចជាបញ្ហាប្រឈមនានាចំពោះពលករខ្មែរ ក្នុងការចេញ-ចូល និងឆ្លងកាត់ព្រំដែន។ ជំរុញដល់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៅតាមព្រំដែន ដើម្បីជួយសម្រួលដំណើរចេញ-ចូលរបស់ពលករខ្មែរឲ្យបានត្រឹមត្រូវ។ ទទួល និងដោះស្រាយបណ្តឹងតវ៉ានានារបស់ពលករខ្មែរពាក់ព័ន្ធនឹងដំណើរឆ្លងកាត់ព្រំដែន។ និងបញ្ហាផ្សេងៗចំពោះ បងប្អូនកម្មករជាដើម៕ អត្ថបទ ៖ បាន ចក់

## លោកស្រី ជូ ប៊ុនអេង អញ្ជើញដឹកនាំកិច្ចប្រជុំកែសម្រួលសេចក្តីព្រាង ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

http://nokorwatnews.com/archives/1044587 18/09/2023

ភ្នំពេញ ៖ ទីស្តីការក្រសួងមហាផ្ទៃ នាថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានអញ្ជើញដឹកនាំកិច្ចប្រជុំកែសម្រួលសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ តំណាងអគ្គនាយកដ្ឋាន និងមន្ត្រីជំនាញពាក់ព័ន្ធជាច្រើនរូបផងដែរ។

នាឱកាសនោះដែរ លោកស្រី ជូ ប៊ុនអេង បានមានប្រសាសន៍ឱ្យដឹងថាកិច្ចប្រជុំនេះ គឺដើម្បីពិនិត្យ ពិភាក្សាកែសម្រួលលើព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឱ្យស្របទៅតាមកំណែទម្រង់រាជរដ្ឋាភិបាល អាណត្តិទី៧ និងពិភាក្សាផ្តល់ធាតុចូលព្រមទាំងកែសម្រួលនូវខ្លឹមសារថ្មីមួយចំនួន ដើម្បីធ្វើទំនើបកម្មពាក្យពេចន៍ស្របតាមការវិវត្តន៍នៃសម័យកាល និងការអនុវត្តការងារឱ្យត្រូវតាមបរិបទនៃសង្គមជាតិនាពេលបច្ចុប្បន្ន។ លោកជំទាវបានបន្តថា កិច្ចប្រជុំនេះដែរ ក៏នឹងធ្វើបច្ចុប្បន្នភាពសមាសភាព តួនាទីភារកិច្ចសមាជិក ដែលជាថ្នាក់ដឹកនាំតាមបណ្តាក្រសួង និងស្ថាប័នមួយចំនួន ដើម្បីងាយស្រួលក្នុងការបំពេញការងារឱ្យបានកាន់តែទូលំទូលាយផងដែរ។

សូមបញ្ជាក់ថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្ស គឺជាយន្តការអន្តរស្ថាប័នថ្នាក់ជាតិ ដែលមានតួនាទីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាល ក្នុងការដឹកនាំ សម្របសម្រួល

ប្រមូលផ្តុំការចូលរួមកិច្ចសហការ និងការគាំទ្រពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការសហប្រជាជាតិ អង្គការដៃគូជាតិ អន្តរជាតិ ផ្នែកឯកជនរួមទាំង យន្តការក្នុងតំបន់ និងបណ្តាប្រទេសពាក់ព័ន្ធទាំងឡាយ សម្រាប់ការងារប្រយុទ្ធប្រឆាំង រាល់ទម្រង់នៃអំពើជួញដូរ និងអំពើធ្វើអាជីវកម្មកេងប្រវ័ញ្ចលើមនុស្សគ្រប់រូបភាព ពិសេសលើស្ត្រី និងកុមារដែលកើតមាននៅក្នុងប្រទេសកម្ពុជា និងក្រៅប្រទេសផងដែរ៕

## លោកឧត្តមសេនីយ៍ទោ ជួនណារិទ្ធ សំណូមពរដល់នគរបាលជាតិថៃ បន្តជួយថែទាំប្រជាពលរដ្ឋកម្ពុជា កំពុងរស់នៅធ្វើការងារ និងរកស៊ីនៅប្រទេសថៃឱ្យបានល្អ

http://nokorwatnews.com/archives/1044742 18/09/2023

ភ្នំពេញ៖ ដោយមានការអនុញ្ញាតពីលោកនាយឧត្តមសេនីយ៍ ស ថេត អគ្គស្នងការនគរបាលជាតិ នៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញនាព្រឹកថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ លោកឧត្តមសេនីយ៍ទោ ជួនណារិទ្ធ អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ បានអនុញ្ញាតឱ្យលោកវរសេនីយ៍ឯក បិយវឌ្ឍន៍ កៀតកង ចូលជួបសំដែងការគួរសមពិភាក្សាអំពីកិច្ចសហប្រតិបត្តិការការងាររវាង ស្ថានឯកអគ្គរាជទូតថៃប្រចាំនៅកម្ពុជា និងស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ឱ្យកាន់តែរឹងមាំ។ នៅបន្ទាប់ពីលោកឧត្តមសេនីយ៍ទោ ជួនណារិទ្ធ ទើបតែចូលកាន់មុខតំណែងជាអគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ ចំណែកលោកវរសេនីយ៍ឯក បិយវឌ្ឍន៍ កៀតកង ក៏ទើបតែមកបំពេញការងារជាអនុព័ន្ធនគរបាលអមស្ថានទូតថៃផងដែរ។

លោកឧត្តមសេនីយ៍ទោ ជួន ណារិទ្ធ អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ បានមានប្រសាសន៍ស្វាគមន៍ចំពោះ លោកវរសេនីយ៍ឯកបិយវឌ្ឍន៍ កៀតកង និងប្រតិភូដែលបានអញ្ជើញមកសំដែងការគួរសម និងពិភាក្សាអំពីកិច្ចសហប្រតិបត្តិការការងាររវាងស្ថានឯកអគ្គរាជទូតថៃ និងស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ក្នុងនាមជាប្រទេសជិតខាងបងប្អូនល្អនឹងគ្នា ហើយជាពិសេសពង្រឹងពីកិច្ចសហប្រតិបត្តិការលើការងារថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សុវត្ថិភាព ស្ថិរភាព រវាងប្រទេសទាំងពីរ។

លោកវរសេនីយ៍ឯក បិយវឌ្ឍន៍ កៀតកង អនុព័ន្ធនគរបាលអមស្ថានទូតថៃ ក៏បានលើកឡើងដោយមានការណែនាំ ពីអនុព័ន្ធនគរបាលអមស្ថានទូតថៃចាស់ បានវាយតម្លៃនិងកោតសរសើរចំពោះលោកឧត្តមសេនីយ៍ទោ ជួន ណារិទ្ធ កាលកាន់តំណែងជាស្នងការនគរបាលខេត្តព្រះសីហនុ បានសហការការងារល្អជាមួយស្ថានទូតថៃ ជាពិសេសលើការងារការពារថែរក្សាសន្តិសុខ សុវត្ថិភាព ជូនដល់ជនជាតិថៃ ដែលបានមករកស៊ី ធ្វើការនិងមកទេសចរណ៍កម្សាន្តនៅខេត្តព្រះសីហនុ។

កិច្ចការងារសហប្រតិបត្តិការនេះ គឺនៅតែបន្តឱ្យកាន់តែរឹងមាំថែមទៀត ក្នុងនាមលោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ មកទទួលកាន់តែងថ្មីជាអគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ។ លោកក៏សំណូមពរដល់ឯកឧត្តមស្នងការ បន្តជួយការពារសន្តិសុខ រក្សាសុវត្ថិភាព ដល់ជនជាតិថៃនៅកម្ពុជា ជាពិសេសនៅរាជធានីភ្នំពេញផងដែរ។

លោកវរសេនីយ៍ឯក បិយវឌ្ឍន៍ កៀកកង ក៏បានវាយតម្លៃខ្ពស់ពីកិច្ចសហប្រតិបត្តិការរវាងនគរបាលជាតិថៃ និងនគរបាលជាតិកម្ពុជា ពីមួយថ្ងៃទៅមួយកាន់តែល្អរឹងមាំ ជាពិសេសថ្មីៗនេះ អគ្គស្នងការរងនគរបាលជាតិថៃ និង ឯកអគ្គរាជទូតថៃថ្មី បានអញ្ជើញមកសំដែងការគួរសម និងពិភាក្សាអំពីកិច្ចសហប្រតិបត្តិការ ការងារមួយចំនួនជាមួយ អគ្គស្នងការនគរបាលជាតិកម្ពុជា លោកនាយឧត្តមសេនីយ៍ ស ថេត ផងដែរ។ ជាពិសេសនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ បើគ្មានការប្រែប្រួលនោះទេ ឯកឧត្តម នាយករដ្ឋមន្ត្រីថ្មីថៃ និងមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីពង្រឹងចំណងមិត្តភាពកាន់តែរឹងមាំងរវាងថៃ និងកម្ពុជា។

លោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ ក៏បានលើកឡើងឱ្យដឹងថា៖ កាលពីលោកធ្វើជាស្នងការនគរបាលខេត្តព្រះសីហនុ គឺបានយកចិត្តទុកដាក់ចំពោះភ្ញៀវទេសចរណ៍ អ្នកវិនិយោគ គ្រប់ជាតិសាសន៍។ ដោយឡែអំពីកិច្ចសហប្រតិបត្តិការជាមួយអនុព័ន្ធនគរបាលអមស្ថានទូតថៃកន្លងមក ក៏បានធ្វើកិច្ចការងារជាមួយគ្នាច្រើនហើយដែរ នៅខេត្តព្រះសីហនុ។ ដោយឡែកនៅឯរាជធានីភ្នំពេញនៅតែបន្តធ្វើកិច្ចការងារនេះបន្ថែមទៀតរវាងគ្នា ជាពិសេសគាំទ្ររាល់សកម្មភាពជនជាតិថៃដែលមកធ្វើការងារ រកស៊ី រឺមកទេសចរណ៍កម្សាន្តដោយស្របច្បាប់ ត្រូវតែយកចិត្តទុកដាក់។

លោកស្នងការ ក៏បានអរគុណដល់នគរបាលជាតិថៃ ដែលបានជួយការពារសន្តិសុខ សុវត្ថិភាពជូនដល់ប្រជាពលរដ្ឋកម្ពុជា ដែលបានទៅធ្វើការងារ និងរកស៊ីនៅប្រទេសថៃហើយក៏សំណូមពរដល់នគរបាលជាតិថៃបន្តជួយថែទាំប្រជាពលរដ្ឋកម្ពុជា កំពុងរស់នៅធ្វើការងារនិងរកស៊ីនៅប្រទេសថៃឱ្យបានល្អផងដែរ៕

# អាជ្ញាធរគួរតែទទួលស្គាល់
# និងចាត់វិធានការលើការ «ជួញដូរ និងចាប់ជំរិត» មនុស្សនៅកម្ពុជា

https://www.rfa.org/khmer/news/human-rights/youth-and-civil-society-say-authorities-should-recognize-and-take-actions-on-trafficking-and-kidnapping-in-cambodia-09182023052302.html

*ដោយ យ៉ង់ ចាន់តារា* 2023.09.18

យុវជន និងសង្គមស៊ីវិលថា អាជ្ញាធរគួរតែទទួលស្គាល់ និងចាត់វិធានការចំពោះអំពើជួញដូរមនុស្ស និងចាប់ជំរិតមនុស្សនៅកម្ពុជា ដើម្បីឆ្លើយតបទៅនឹងការរកឃើញរបស់ក្រសួងការ បរទេសសហរដ្ឋអាមេរិក និងអង្គការសហប្រជាជាតិ។ ការលើកឡើងនេះ ក្រោយពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍បានចេញសេចក្ដីបំភ្លឺថា អាជ្ញាធរគ្រប់គ្រងច្រកព្រំដែនអន្តរជាតិកម្ពុជានោះ បានធ្វើការងារយ៉ាងហ្មត់ចត់ និងការខិតខំរឹតបន្តឹងការអនុវត្តច្បាប់អន្តោប្រវេសន៍។ យុវជន និងមន្ត្រីអង្គការសង្គមស៊ីវិលលើកឡើងថា ប្រសិនបើអាជ្ញាធរ នៅតែមិនស្រាវជ្រាវរកជនសង្ស័យ ដែលប្រព្រឹត្តអំពើជួញដូរ និងចាប់ជំរិតមនុស្សនៅកម្ពុជាទេ នោះកេរ្តិ៍ឈ្មោះកម្ពុជានៅលើឆាកអន្តរជាតិ នៅតែបន្តជាប់ឈ្មោះជាប្រទេសអាក្រក់បំផុត នៃអំពើជួញដូរ និងចាប់ជំរិតមនុស្ស។

ពលរដ្ឋខ្មែរនៅជប៉ុនលោកស្រី មាស ភាព៉ា ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី១៧ កញ្ញា ថា លោកស្រីមានការព្រួយបារម្ភថា នៅពេលកម្ពុជា ជាប់ឈ្មោះអាក្រក់បំផុតនៃអំពើជួញដូរមនុស្ស នោះនឹងធ្វើឲ្យពលរដ្ឋខ្មែរនៅក្រៅប្រទេស នឹងពិបាកស្វែងរកការងារធ្វើ។ លោកស្រី មាស ភាព៉ា៖ «គាត់គួរតែងាកមករកផ្លូវត្រូវវិញបានល្អ បើមិនអ៊ីចឹងវាដូចកាន់តែធ្លាក់ចុះដុនដាបកេរ្តិ៍ប្រទេសយើងក៏ដុនដាបចុះ អត់មានស្ដារបានទេបើគាត់អត់ព្រមដើរផ្លូវត្រូវ»។

ការលើកឡើងនេះគឺ ក្រោយពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ បានចេញសេចក្ដីបំភ្លឺមួយ កាលពីថ្ងៃទី១៤ កញ្ញា ថា អាជ្ញាធរបានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព្រំដែនតាមគ្រប់បណ្ដាប៉ុស្តិ៍ត្រួតពិនិត្យទាំង ២៧ប៉ុស្តិ៍ ដើម្បីគ្រប់គ្រងការចេញចូលច្រកទ្វារអន្តរជាតិឲ្យបានហ្មត់ចត់ និងទប់ស្កាត់រាល់មុខសញ្ញាឧក្រិដ្ឋកម្មឆ្លងដែនមកកម្ពុជា។ សេចក្ដីបំភ្លឺដដែលឲ្យដឹងទៀតថា នៅក្នុងរយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ អាជ្ញាធរ បានបដិសេធជនបរទេសជិត ៣ពាន់នាក់(២.៩៧៣) ចូលមកកម្ពុជា ដោយរកឃើញភាពមិនប្រក្រតីមួយចំនួនដូចជា មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌកំណត់ជាដើម។ រយៈពេល ៨ខែ នៃឆ្នាំ២០២៣ អាជ្ញាធរបានបណ្ដេញជនបរទេសជាង ១ពាន់ ៣រយនាក់(១ ៣៦៦)ចេញពីកម្ពុជា ក្រោយពីអាជ្ញាធររឹតបន្តឹងការគ្រប់គ្រងវត្តមានជនបរទេសនៅកម្ពុជា។

បើទោះជាយ៉ាងនេះក្ដី កាលពីចុងខែសីហាកន្លងទៅ អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស បានចេញផ្សាយរបាយការណ៍មួយរកឃើញថា មានមនុស្សរាប់សែននាក់ត្រូវបានក្រុម

ឧក្រិដ្ឋជនបង្ខំឱ្យធ្វើការងារតាមប្រព័ន្ធអ៊ីនធឺណិតនៅតំបន់អាស៊ីអាគ្នេយ៍ ក្នុងនោះនៅកម្ពុជាមានជាង ១០ម៉ឺននាក់។ ប៉ុន្តែរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង បានប្រាប់សារព័ត៌មានក្នុងស្រុកថា ការលើកឡើងរបស់អង្គការសហប្រជាជាតិនេះ មិនឆ្លុះបញ្ចាំងការពិតនោះទេ ហើយអ្នកស្រីថា រឿងនេះជាការធ្វើឱ្យកម្ពុជាបាក់មុខមាត់នៅលើឆាកអន្តរជាតិ។ ការឆបោកតាមអ៊ីនធឺណិតនេះ គឺជាមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើនទៀត ដែលរបាយការណ៍ឆ្នាំ២០២២ របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ដាក់ចំណាត់ថ្នាក់កម្ពុជាអាក្រក់បំផុត នៃអំពើជួញដូរមនុស្ស។

វិទ្យុអាស៊ីសេរីនៅពុំទាន់អាចទាក់ទងអគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ លោក សុខ វាសនា និងរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង ដើម្បីសុំការឆ្លើយតបចំពោះបញ្ហានេះបាននៅឡើយទេ នៅថ្ងៃទី១៧ កញ្ញា។

ជុំវិញរឿងនេះ ប្រធានផ្នែកប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងវេស្សន្តរប្រវេសន៍ នៃអង្គការសង់ត្រាល់ (CENTRAL) លោក ឌី ថេហូយ៉ា មានប្រសាសន៍ថា អាជ្ញាធរគួរតែទទួលស្គាល់ការពិត នៃការរកឃើញរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក និងអង្គការសហប្រជាជាតិ។ លោកបន្ថែមថា ប្រសិនបើរដ្ឋាភិបាលចង់ដោះស្រាយបញ្ហានេះ អាជ្ញាធរគួរតែស្នើសុំកិច្ចសហប្រតិបត្តិការជាមួយអ្នកដែលចេញផ្សាយរបាយការណ៍ទាំងនោះ ដើម្បីសហការគ្នាស្រាវជ្រាវ និងបង្ក្រាបបទល្មើសទាំងនោះ។

លោក ឌី ថេហូយ៉ា៖ «អ៊ីចឹងដើម្បីអាចធ្វើកិច្ចការងារទាំងអស់នេះបាន វាទាល់តែទី១យើងត្រូវទទួលស្គាល់ថា វាមានបញ្ហាហ្នឹងកើតឡើង បើកាលណាយើងឈឺហើយយើងអត់ទទួលស្គាល់ថាខ្លួនឯងឈឺទេ ហើយយើងទៅព្យាបាលម៉េចកើត ខ្លួនយើងមិនគិតខ្លួនឯង។ ដើម្បីព្យាបាលដើម្បីដោះស្រាយបញ្ហានេះបាន វាទាល់តែមានការចូលរួមពីស្ថាប័នពាក់ព័ន្ធជាពិសេសគឺ អង្គការសង្គមស៊ីវិលដែលធ្វើការលើវិស័យហ្នឹង ធ្វើដោយតម្លាភាព ទី១ចង់ដឹងថាអ្នកណា ដែលជាមេបណ្ដាញនៃអំពើជួញដូរ»។

កាលពីថ្ងៃទី១១ កញ្ញា កន្លងទៅ អាជ្ញាធរកម្ពុជា និងថៃ បានសហការគ្នាបង្ក្រាបជនសង្ស័យឆបោកតាមអ៊ីនធឺណិតចំនួន ៤នាក់ នៅក្រុងប៉ោយប៉ែតខេត្តបន្ទាយមានជ័យ ដែលរត់គេចខ្លួនពីការតាមចាប់ក្រោមអំណាចដីការបស់តុលាការប្រទេសថៃ។ ពួកគេទាំង ៤នាក់នេះ គឺស្ថិតនៅក្នុងចំណោមជនសង្ស័យចំនួន ៣០នាក់ ដែលជាប់ពាក់ព័ន្ធនឹងករណីឆបោកតាមអ៊ីនធឺណិត ដែលមានមេក្លោងជាជនជាតិចិន ហើយមានមូលដ្ឋាននៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។ ពួកគេ បាន

ធបោកជនជាតិថៃមួយគ្រួសារ ក្នុងទំហំទឹកប្រាក់ចំនួន ១លាន ៧សែនបាត រហូតបង្កឲ្យមានឃាតកម្មក្នុងគ្រួសារមួយកើតឡើង ដែលប្តីបានសម្លាប់ប្រពន្ធ និងកូនចំនួនពីរនាក់។

# ថ្ងៃទី២១ ខែ កញ្ញា ឆ្នាំ២០២៣

## សម្តេចធិបតី ហ៊ុន ម៉ាណែត ប្រាប់ពលករខ្មែរនៅកូរ៉េ សូមកុំបារម្ភរឿងថ្លៃសេវាធ្វើលិខិតឆ្លងដែនឡើងថ្លៃ រាជរដ្ឋាភិបាលខិតខំសម្រួលឱ្យតម្លៃទាប និងរហ័ស

https://freshnewsasia.com/index.php/en/localnews/310756-2023-09-19-05-22-59.html 2023-09-19 12:22pm

(តាកែវ)៖ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃកម្ពុជា បានប្រកាសប្រាប់ពលករខ្មែរ ដែលកំពុងធ្វើការនៅកូរ៉េខាងត្បូង សូមកុំបារម្ភរឿងថ្លៃសេវាធ្វើលិខិតឆ្លងដែន ឬបន្តសុពលភាពលិខិតឆ្លងដែនឡើងថ្លៃជាងមុនឱ្យសោះ រាជរដ្ឋាភិបាលកម្ពុជាកំពុងខិតខំសម្រួលឱ្យតម្លៃសេវាកម្មនេះនៅទាបក្នុងកម្រិតណាមួយ សម្របសម្រួលជួយក្នុងការបំពេញបែបបទស្នើសុំ និងពន្លឿនឱ្យរហ័សជាងមុន។

ការថ្លែងបែបនេះរបស់សម្តេចធិបតី ហ៊ុន ម៉ាណែត ធ្វើឡើងក្នុងឱកាសជួបសំណេះសំណាលជាមួយកម្មករនិយោជិតជាង១.៨ម៉ឺននាក់ នៅស្រុកបាទី ខេត្តតាកែវ នាព្រឹកថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣។ នាឱកាសនោះ សម្តេចធិបតីនាយករដ្ឋមន្ត្រីបានថ្លែងថា មានប្រជាពលរដ្ឋ ក៏ដូចជាពលករខ្លះបានបង្ហាញការព្រួយបារម្ភចំពោះតម្លៃសេវាធ្វើលិខិតឆ្លងដែន ឬបន្តសុពលភាពលិខិតឆ្លងដែននៅសាធារណរដ្ឋកូរ៉េផ្ទាល់នោះ (នៅស្ថានទូតកម្ពុជា) អាចឡើងថ្លៃជាងមុនទ្វេគុណ គួបផ្សំនឹងការរិះគន់ញុះញង់ពីសំណាក់ក្រុមប្រឆាំងផងដែរ។

សម្តេចធិបតីបានបញ្ជាក់យ៉ាងដូច្នេះថា «ថ្លៃសេវាអត់មានគុណជាពីរនោះទេ គ្រាន់តែអស់ថ្លៃផ្ញើបន្តិចបន្តួចប៉ុណ្ណោះ ព្រោះការបំពេញបែបបទស្នើសុំ (Apply) និងកិច្ចការមួយចំនួនទៀត គឺធ្វើតាម Online ដូច្នេះសូមបងប្អូននៅកូរ៉េខាងត្បូងកុំព្រួយបារម្ភរឿងថ្លៃឡើងគុណជាពីរឱ្យសោះ មិនដូចការរិះគន់របស់ក្រុមប្រឆាំងនោះឡើយ»។ សម្តេចធិបតី ហ៊ុន ម៉ាណែត ថែមទាំងបានណែនាំដល់លោកអូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិភាក្សាជាមួយក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ ដើម្បីរៀបចំលើការស្នើសុំបន្តសុពលភាពលិខិតឆ្លងដែនរបស់ពលករខ្មែរនៅកូរ៉េខាងត្បូងឱ្យកាន់តែងាយស្រួល និងកាត់បន្ថយការចំណាយឱ្យទាបជាងមុន។

សម្តេចធិបតីបានបន្តថា ក្រសួង ស្ថាប័ន អគ្គនាយកដ្ឋាន ស្ថានទូតកម្ពុជា មន្ត្រីបច្ចេកទេសជំនាញជាដើម ក៏ត្រូវរួមគ្នាគិតគូរទាំងពេលវេលាឱ្យលឿនរហ័សជាងមុន ព្រោះជូនកាលពលករខ្លះ

ជិតដល់ពេលចូលធ្វើការ ឬជិតផុតសុពលភាពលិខិតឆ្លងដែនជាដើម ប្រសិនបើមិនពន្លឿនធ្វើជូនពួកគាត់នោះទេ ពួកគាត់អាចនឹងក្លាយទៅជាអ្នកស្នាក់ប្រទេសគេខុសច្បាប់ ដូច្នេះត្រូវផ្តល់សេវាប្រកបដោយកាតយកចិត្តទុកដាក់ ពន្លឿនការងារឱ្យបានឆាប់រហ័ស សម្រួលសម្រួលជូនពួកគាត់ឱ្យអស់លទ្ធភាព ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជា។ សម្តេចធិបតីនាយករដ្ឋមន្ត្រីក៏បានណែនាំដល់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយស្ថានទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ ជួយសម្របសម្រួលជូនពលករខ្មែរយើងផង ប្រសិនបើលើសខ្វះអ្វីបន្តិចបន្តួចជាមួយភាគីកូរ៉េ ពិសេសក៏ត្រូវជួយសម្របសម្រួលក្នុងការបំពេញបែបបទ របស់ពលករខ្មែរនៅទីនោះផងដែរ។

ជាការសង្កត់ធ្ងន់របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ ត្រូវទទួលខុសត្រូវលើការងារគ្រប់គ្រងទិន្នន័យ ព្រោះការងារអត្តសញ្ញាណកម្មនិងលិខិតឆ្លងដែននេះក៏ពាក់ព័ន្ធនឹងសន្តិសុខជាតិផងដែរ។ សម្តេចធិបតីបានបន្ថែមទៀតថា ទាំងនេះហើយគឺជាឆន្ទៈរបស់រាជរដ្ឋាភិបាលក្នុងការជួយប្រជាពលរដ្ឋទាំងក្នុងនិងក្រៅប្រទេស ទាំងការបង្កើតឱកាសការងារក្នុងស្រុក ការស្វែងរកការងារនៅក្រៅប្រទេស ដើម្បីជួយឱ្យប្រជាពលរដ្ឋបង្កើនប្រាក់ចំណូល ព្រមទាំងសម្រួលបែបបទផ្លូវច្បាប់ជូនប្រជាពលរដ្ឋផងដែរ ពិសេសគឺពលករខ្មែរដែលទៅធ្វើការនៅក្រៅប្រទេស៕

## លោក នេត សាវឿន
## ជំរុញអាជ្ញាធរតាមព្រំដែនបង្កើតប្រព័ន្ធ Hotline សម្រាប់ពលកររាយការណ៍ពីមន្ត្រី

https://www.khmertimeskh.com/501363373// ហង្ស ពណ្ណរាយ / Khmer Times September 20, 2023

លោក នេត សាវឿន ឧបនាយករដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញចូលរបស់ពលករខ្មែរតាមព្រំដែនកម្ពុជា បានជំរុញឱ្យភាគីពាក់ព័ន្ធ និងអាជ្ញាធរខេត្តបង្កើតបង្កើតប្រព័ន្ធទំនាក់ទំនងទាន់ហេតុការណ៍ ឬប្រព័ន្ធទូរសព្ទ Hotline ដើម្បីប្រជាពលរដ្ឋរាយការណ៍ពីសកម្មភាពមិនល្អរបស់មន្ត្រី។

ក្នុងកិច្ចប្រជុំគណៈកម្មាធិការចំពោះកិច្ច កាលពីថ្ងៃចន្ទ លោក នេត សាវឿន ណែនាំដល់សមត្ថកិច្ចតាមព្រំដែនទាំងអស់ត្រូវលុបបំបាត់បាតុភាពអសកម្ម និងសកម្មភាពអវិជ្ជមានដែលបង្កការលំបាកដល់ពលករក្នុងពេលធ្វើដំណើរចេញទៅក្រៅ ឬចូលក្នុងប្រទេស។ លោកបញ្ជាក់ថា ដើម្បីជាយន្តការមួយសម្រាប់ផ្តល់ភាពងាយស្រួលដល់ពលករចំណាកស្រុក គណៈកម្មការចំពោះកិច្ច គ្រោងបង្កើតយន្តការពិនិត្យមួយពីថ្នាក់ជាតិ ដើម្បីចុះត្រួតពិនិត្យតាមច្រកទ្វារតែម្តង សំដៅទទួលយកបញ្ហាកង្វល់ និងដាក់ចេញវិធានការដោះស្រាយរបស់ប្រជាពលករ។ ជាពិសេសត្រូវបង្កើតប្រព័ន្ធទំនាក់

ទំនងទាន់ហេតុការណ៍ ឬប្រព័ន្ធ Hotline និងបណ្ដាញទំនាក់ទំនងសង្គមមួយចំនួនទៀត ដើម្បីជាមធ្យោបាយសម្រាប់ពលកររាយការណ៍ ពីភាពមិនល្អ ឬចំណុចអវិជ្ជមានរបស់មន្ត្រីថ្នាក់ក្រោម មកកាន់ថ្នាក់ជាតិ ដើម្បីទប់ស្កាត់រាល់បញ្ហានានាឱ្យបានទាន់ពេលវេលា។

លោក នេត សាវឿន បានដាក់បទបញ្ជាដល់ថ្នាក់ដឹកនាំអង្គភាពពាក់ព័ន្ធ ដែលស្ថិតក្នុងគណៈកម្មការចំពោះកិច្ច ជាពិសេសសមត្ថកិច្ចនៅតាមច្រកទ្វារព្រំដែន ត្រូវកែប្រែឥរិយាបថក្នុងការបំពេញការងារ ដើម្បីផ្ដល់ភាពងាយស្រួលដល់ពលករ ដែលត្រូវចំណាកស្រុកទៅក្រៅប្រទេស ជាពិសេសផ្ដល់ភាពកក់ក្ដៅក្នុងការទទួលសេវា។ ប្រធានគណៈកម្មាធិការចំពោះកិច្ច ក៏បានជំរុញអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអភិបាលខេត្តជាប់តាមព្រំដែន ត្រូវជួបធ្វើការជាមួយភាគីថៃ ដើម្បីសម្រួលដល់ការធ្វើដំណើរចេញ ឬចូលក្នុងប្រទេសរបស់ពលករខ្មែរ ដើម្បីជានាសុខសុវត្ថិភាព និងមានភាពរហ័ស។ លោកបញ្ជាក់ថា កន្លងមកធ្លាប់មានការរិះគន់ជាបុគ្គលពាក់ព័ន្ធការទៅនឹងទទួលកម្រៃក្រៅផ្លូវការពីពលករ ដូច្នេះ ចំណុចបញ្ហាទារកម្រៃក្រៅផ្លូវការពីពលករបែបនេះ ត្រូវលុបបំបាត់ចោលឱ្យមានប្រសិទ្ធភាពចាប់ពីពេលនេះ។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ លោក ងី ច័ន្ទ្រផល បានឱ្យដឹងថា កន្លងមក ក្រសួងបានចាត់តាំងក្រុមការងារចុះពិនិត្យមើលអំពីការផ្ដល់សេវារដ្ឋបាល នៅអង្គភាពច្រកចេញចូលតែមួយ និងសម្រុះសម្រួល ដោះស្រាយបណ្ដឹង របស់ការិយាល័យប្រជាពលរដ្ឋក្នុងខេត្តមួយចំនួន។ លោកថា ក្រោយពីចុះពិនិត្យមើលការផ្ដល់សេវារដ្ឋបាល គឺក្រុមការងាររកឃើញចំណុចអសកម្មមួយចំនួនពាក់ព័ន្ធនឹងការផ្ដល់សេវារដ្ឋបាលនៅអង្គភាពច្រកចេញចូលតែមួយ និងការគាំទ្រដល់ការិយាល័យប្រជាពលរដ្ឋខេត្តផងដែរ។

លោក ជា ពិសិដ្ឋ នាយករដ្ឋបាលសាលាខេត្តឧត្តរមានជ័យ បានឱ្យដឹងថា បច្ចុប្បន្ន រដ្ឋបាលខេត្តបានផ្លាស់ប្ដូរប្រធានអង្គភាពច្រកចេញចូលតែមួយ ដោយដាក់មន្ត្រីថ្មីជំនួសមន្ត្រីចាស់ ដូច្នេះមិនមានបញ្ហាខ្វះចន្លោះ ឬមានករណីទទួលកម្រៃក្រៅផ្លូវការឡើយ។ លោកបញ្ជាក់ថា កាលជំនាន់ផ្ទុះស្ទើយជំងឺកូវីដ-១៩ ជាលើកដំបូង ប្រជាពលរដ្ឋជាច្រើនបានសម្រុកមកធ្វើឯកសារដោយមួយថ្ងៃចន្លោះពី ៥០០នាក់ ទៅ ៦០០នាក់ ដែលធ្វើឱ្យមន្ត្រីពាក់ព័ន្ធពិបាកសម្របសម្រួលនៅផ្នែកជួរខាងមុខ ព្រោះមនុស្សច្រើន ហើយការផ្ដល់សេវាក៏ពុំគ្រប់គ្រាន់។

លោក ជា ពិសិដ្ឋ បន្ថែមថា៖ «នៅពេលមន្ត្រីជួរមុខសម្របសម្រួលពុំគ្រប់គ្រាន់ យើងបានបញ្ជូនមន្ត្រីទៅជួយបន្ថែម ប៉ុន្តែពេលនោះ ក៏មានប្រជាពលរដ្ឋមួយចំនួន មិនចេះសរសេរអក្សរ និងបំពេញឯកសារ គាត់ក៏បានពឹងមន្ត្រីយើងឱ្យជួយផងដែរ»។ លោកបន្តថា នៅពេលពឹងមន្ត្រីឱ្យជួយសរសេរ ឬបំពេញឯកសារ ក៏មានអ្នកខ្លះលើកទឹកចិត្តដល់មន្ត្រីចំនួន ៥ ០០០រៀល ឬ ១០ ០០០រៀល

ដែលបញ្ហាទាំងនេះ ជាផ្នែកមួយធ្វើឱ្យកើតនូវចំណុចអវិជ្ជមាន។ នាយករដ្ឋបាលខេត្តខាងលើបន្តថា បច្ចុប្បន្ន គ្មានភាពខ្វះចន្លោះ ឬមានបាតុភាពមន្ត្រីទទួលកម្រៃក្រៅផ្លូវការឡើយ ហើយការផ្តល់សេវាជូនពលករ ក៏ដូចប្រជាពលរដ្ឋចេញ ឬចូលក្នុងប្រទេសវិញ គឺមានភាពល្អប្រសើរ។

កាលពីខែកក្កដា ឆ្នាំ២០២៣ ក្រសួងមហាផ្ទៃ បានណែនាំរដ្ឋបាលខេត្តមួយចំនួននៅតាមច្រកទ្វារព្រំដែន និងភាគីពាក់ព័ន្ធចាត់ វិធានការលុបបំបាត់រាល់មន្ត្រីរត់ការស្នើសុំសេវាជំនួយពីប្រជាពលរដ្ឋក្នុងភូមិសាស្ត្រខេត្តរបស់ខ្លួនឱ្យបានយ៉ាងម៉ឺងម៉ាត់បំផុត។ ចំពោះចំណាត់ការលើមន្ត្រីរត់ការស្នើសុំសេវាជំនួសបន្ថែមនេះ ធ្វើឡើងទាំងមន្ត្រីពេញសិទ្ធិ និងបុគ្គលិកជាប់កិច្ចសន្យារបស់រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ដែលជះឥទ្ធិពលមិនល្អដល់ការធ្វើកំណែទម្រង់របស់រដ្ឋាភិបាល៕

# ថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ២០២៣

## កម្ពុជា-ថៃ
## បានឯកភាពបន្តពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

https://www.tvk.gov.kh/?p=33551 ចេញផ្សាយ ថ្ងៃទី 21 ខែ កញ្ញា ឆ្នាំ 2023 120

ឯកឧត្តម ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងជំនួបជាមួយឯកឧត្តម ឆឹតកៀក អាត់ថាក័រ (Cherdkiat ATTHAKOR) អគ្គរាជទូតថៃប្រចាំព្រះរាជាណាចក្រកម្ពុជា បានឯកភាពបន្តពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃប្រទេសទាំងពីរឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀតដើម្បីរក្សាបានប្រយោជន៍ជូនពលរដ្ឋសងខាង។

ក្នុងជំនួបនៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនាថ្ងៃទី២១ ខែកញ្ញានេះ ឯកឧត្តម ហេង សួរ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលថៃ ដែលបានផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធលើផ្នែកការងារ ដោយបានយកចិត្តទុកដាក់ខ្ពស់ ក្នុងការសម្របសម្រួលដល់ពលករខ្មែរដែលកំពុងធ្វើការ និងរស់នៅប្រទេសថៃ ដែលបច្ចុប្បន្នមានប្រមាណ១,២លាននាក់។

ពីភាគីថៃវិញ ឯកឧត្តមឯកអគ្គរាជទូត ក៏បានថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា លើកិច្ចសហការ និងការយកចិត្តទុកដាក់ខ្ពស់ចំពោះអ្នកជំនាញ និងពលរដ្ឋថៃ ដែលកំពុងធ្វើការ និងស្នាក់នៅកម្ពុជា។ បន្ថែមពីនេះ ភាគីទាំងពីរ បានគូសបញ្ជាក់ថា តាមរយៈកិច្ចសហប្រតិបត្តិការលើផ្នែកការងារដែលមានស្រាប់ នឹងធ្វើឱ្យនិយោជកថៃ មានភាពងាយស្រួលជាងមុនក្នុងការទទួលពលករកម្ពុជាទៅធ្វើការ ហើយពលករកម្ពុជា ក៏អាចទៅធ្វើការដោយស្របច្បាប់នៅប្រទេសថៃដែល

ជាការរក្សាបានប្រយោជន៍ទាំងសងខាង។ ទន្ទឹមនឹងនេះ ប្រទេសទាំងពីរ បានឯកភាពគ្នាមួយចំណុចទៀត គឺការពង្រឹងយន្តការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សស្របតាមស្មារតី នៃអនុស្សរណៈដែលមានស្រាប់ ដើម្បីរក្សាបាននូវការគោរពសិទ្ធិរបស់ពលរដ្ឋ។ ក្នុងនោះ ទាំងកម្ពុជា និង ថៃ សុទ្ធតែមើលឃើញពីការជះឥទ្ធិពលអវិជ្ជមាននៃអំពើជួញដូរមនុស្ស។

យ៉ាងណាក៏ដោយមុននឹងបញ្ចប់ជំនួប ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងឯកឧត្តមឯកអគ្គរាជទូតថៃ បានឯកភាពបន្តពង្រឹងកិច្ចសហប្រតិបត្តិការលើការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈដែលប្រទេសទាំងពីរធ្លាប់បានសហការកន្លងរួចមកហើយ ដើម្បីរួមគ្នាផ្តត់ផ្គង់កម្លាំងជំនាញចូលទីផ្សារការងារដែលកំពុងមានតម្រូវការខ្ពស់៕

## ឯកឧត្តម ហេង សួរ
## អរគុណដល់រាជរដ្ឋាភិបាលថៃ ដែលបានយកចិត្តទុកដាក់ខ្ពស់ ដល់ពលករខ្មែរ

https://www.information.gov.kh/articles/114151 ចេញផ្សាយ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០២៣

ភ្នំពេញ៖ ឯកឧត្តម ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងជំនួបជាមួយឯកឧត្តម ធីតកៀក អាត់ថាក័រ (Cherdkiat ATTHAKOR) អគ្គរាជទូតថៃប្រចាំព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនាថ្ងៃទី២១ ខែកញ្ញានេះ ឯកឧត្តម ហេង សួរ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលថៃ ដែលបានផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធលើផ្នែកការងារដោយបានយកចិត្តទុកដាក់ខ្ពស់ ក្នុងការសម្របសម្រួលដល់ពលករខ្មែរដែលកំពុងធ្វើការ និងរស់នៅប្រទេសថៃ ដែលបច្ចុប្បន្នមានប្រមាណ១,២លាននាក់។

ពីភាគីថៃវិញ ឯកឧត្តមឯកអគ្គរាជទូត ក៏បានថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា លើកិច្ចសហការ និងការយកចិត្តទុកដាក់ខ្ពស់ចំពោះអ្នកជំនាញនិងពលរដ្ឋថៃដែលកំពុងធ្វើការនិងស្នាក់នៅកម្ពុជា។ បន្ថែមពីនេះ ភាគីទាំងពីរ បានគូសបញ្ជាក់ថា តាមរយៈកិច្ចសហប្រតិបត្តិការលើផ្នែកការងារដែលមានស្រាប់ នឹងធ្វើឱ្យនិយោជកថៃ មានភាពងាយស្រួលជាងមុនក្នុងការទទួលពលករកម្ពុជាទៅធ្វើការ ហើយពលករកម្ពុជា ក៏អាចទៅធ្វើការដោយស្របច្បាប់នៅប្រទេសថៃដែលជាការរក្សាបានប្រយោជន៍ទាំងសងខាង។

ទន្ទឹមនឹងនេះ ប្រទេសទាំងពីរ បានឯកភាពគ្នាមួយចំណុចទៀត គឺការពង្រឹងយន្តការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សស្របតាមស្មារតី នៃអនុស្សរណៈដែលមានស្រាប់ដើម្បីរក្សាបាននូវការគោរពសិទ្ធិរបស់ពលរដ្ឋ។ ក្នុងនោះ ទាំងកម្ពុជា និង ថៃ សុទ្ធតែមើលឃើញពីការជះឥទ្ធិពលអវិជ្ជមាននៃអំពើជួញដូរមនុស្ស។

*យ៉ាងណាក៏ដោយមុននឹងបញ្ចប់ជំនួប ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងឯកឧត្តមឯកអគ្គរាជទូតថៃ បានឯកភាពបន្តពង្រឹងកិច្ចសហប្រតិបត្តិការលើការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដែលប្រទេសទាំងពីរធ្លាប់បានសហការកន្លងរួចមកហើយ ដើម្បីរួមគ្នាផ្គត់ផ្គង់កម្លាំងជំនាញចូលទីផ្សារការងារដែលកំពុងមានតម្រូវការខ្ពស់៕*

# ថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០២៣

## បុគ្គល៣រូប ដែលត្រូវឃាត់ខ្លួនសង្ស័យញុះញង់ និងជួញដូរពលកម្មលើកុមារ និងជនពិការ ប្រមូលឲ្យដើរសុំទានតាមភ្លើងស្តុប នៅខណ្ឌសែនសុខ ត្រូវបានដោះលែងត្រឡប់ទៅវិញ

https://freshnewsasia.com/index.php/en/localnews/311258-2023-09-22-08-39-33.html 2023-09-22 03:39pm

*(**ភ្នំពេញ**)៖ ក្រោយបញ្ជូនខ្លួនដល់សាលាដំបូងរាជធានីភ្នំពេញ បុគ្គលចំនួន៣រូប ក្នុងនោះមានស្រី១រូប ដែលសង្ស័យជាប់ពាក់ពន្ធ័រឿងញុះញង់ និងជួញដូរពលកម្មលើកុមារ និងជនពិការ (ប្រមូលឲ្យដើរសុំទានតាមភ្លើងស្តុប) ត្រូវបានតំណាងអយ្យការអនុញ្ញាតឲ្យត្រឡប់ទៅវិញ ក្រោយនគរបាលខណ្ឌសែនសុខ បានឃាត់ខ្លួនបញ្ជូនទៅ។ សូមបញ្ជាក់ថា ករណីនេះមានការចែកចាយពេញបណ្តាញសង្គមហ្វេសបុក ដោយបុរសម្នាក់មកប្រាប់សារព័ត៌មានថា ប្រពន្ធគាត់លក់ត្របែកសុខៗ ត្រូវបានចាប់ខ្លួន។ បុគ្គលទាំង៣រូប មានឈ្មោះ យិន សុផន ភេទប្រុស អាយុ៦២ឆ្នាំ, ឈ្មោះ សំ សុផុន ភេទប្រុស អាយុ៣៧ឆ្នាំ និងឈ្មោះ ចេង ឆេងហៀន ភេទស្រី អាយុ៣៧ឆ្នាំ។*

*សូមបញ្ជាក់ថា កាលពីព្រឹកថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ ដោយបានការអនុញ្ញាតពីអភិបាលខណ្ឌសែនសុខ, ក្រុមការងាររដ្ឋបាលខណ្ឌដឹកនាំដោយលោក ញាណ ចន្ថាវ៉ា អភិបាលរងខណ្ឌ បានចុះប្រមូលជនអនាថា ជនមានពិការភាពដើរសុំលុយ និងអ្នកលក់ផ្លែពុទ្រា នៅតំបន់ស្តុបណាតប្រ៊ីត ផ្លូវលេខ២០០៤ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ចំនួន១៤រូប ស្រីចំនួន០៥រូបក្នុងនោះមាន៖ ជនមានពិការភាព ចំនួន០៥រូបស្រី០១រូប (អាយុពី៣២ឆ្នាំ ដល់អាយុ៦២ឆ្នាំ) ច្រៀងសុំលុយតាមស្តុប មានកុមារាចំនួន០៥រូប កុមារីចំនួន០២រូប (អាយុ០២ឆ្នាំ ដល់អាយុ១៣ឆ្នាំ) លក់ផ្លែពុទ្រាតាមស្តុប មនុស្សពេញវ័យ និងមានកាយសម្បទាមាំមួន ចំនួន០៤រូប ស្រី០២រូប ដើរលក់ផ្លែពុទ្រាតាមស្តុប។*

ចំពោះអ្នកទាំង១៤រូបនោះ គឺរដ្ឋបាលខណ្ឌសែនសុខ បានបញ្ជូនទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ ចំនួន១១រូប (ស្រី៤រូប)ដើម្បីបណ្តុះបណ្តាល។ ដោយឡែកដោយមានការឯកភាពពីលោក សេង ពុទ្ធី ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ, បុគ្គលទាំង៣រូប ត្រូវបានសង្ស័យញុះញង់ និងជួញដូរពលកម្មលើកុមារ និងជនពិការ បានបញ្ជូនទៅប៉ុស្តិ៍នគរបាលរដ្ឋបាល អូរបែកក្អមដើម្បីសាកសួរ និងអនុវត្តតាមនីតិវិធី៕

## បង្ក្រាបហាងការ៉ាអូខប់សេវាកម្មផ្លូវភេទ៣ទីតាំង ឃាត់ខ្លួនមនុស្ស១២នាក់

https://www.kampucheathmey.com/security/584075 ថ្ងៃសៅរ៍ ២៣ កញ្ញា ២០២៣ដោយ Sokhom Khon

កម្លាំងគណៈបញ្ជាការឯកភាពខណ្ឌដូនពេញ បានចុះរដ្ឋបាលពិនិត្យទីតាំងតាមហាងការ៉ាអូខប់សេវាកម្មផ្លូវភេទ នៅចំណុចម្តុំផែថ្ម ចំនួន៣ទីតាំង ដោយឃាត់ខ្លួនជនសង្ស័យចំនួន១២នាក់ កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣។

ទីតាំងទី១ ហាងការ៉ាអូ នៅផ្លូវលេខ៨២ ផ្ទះ១ ភូមិ១៤ សង្កាត់ស្រះចក បានឃាត់ខ្លួនជនសង្ស័យ ចំនួន០៥នាក់ (ស្រី៤) ក្នុងនោះ ម្ចាស់ទីតាំង១នាក់ នារីបំរើ ៣នាក់ និងអ្នកទួលសេវាកម្មផ្លូវភេទ១នាក់។

ទីតាំងទី២នៅផ្លូវលេខ៨០ ផ្ទះលេខ២៣E០ ភូមិ១៤ សង្កាត់ស្រះចក ឃាត់ខ្លួនជនសង្ស័យចំនួន២នាក់ ជាអ្នកបំរើសេវាកម្មផ្លូវភេទ។

ទីតាំងទី៣ ផ្ទះលេខ១៣E០ ផ្លូវព្រះស៊ីសុវត្ថិ ភូមិ១៥ សង្កាត់ស្រះចក បានឃាត់ខ្លួនជនសង្ស័យចំនួន៥នាក់ (ស្រី៤) ក្នុងនោះមានអ្នកអនាម័យម្នាក់ អ្នកយាមម៉ូតូម្នាក់ និងនារីបំរើការសេវាកម្មផ្លូវភេទចំនួន៣នាក់។ ក្រោយឆែកឆេកម្លាំងបានរកឃើញវត្ថុតាងមួយចំនួនដែលបម្រើសេវាកម្មផ្លូវភេទ។

បច្ចុប្បន្នជនសង្ស័យ និងវត្ថុតាងយកមកកាន់អធិការដ្ឋាននគរបាលខណ្ឌដូនពេញ ដើម្បីធ្វើការសាកសួរ។ ដោយឡែក នារីបានដែលបំរើការសេវាកម្មផ្លូវភេទចំនួន៩នាក់ ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ៕ អត្ថបទ៖ សុខា

## ក្រសួងការងារចុះផ្សព្វផ្សាយច្បាប់ប្រឆាំងនឹងពលកម្មកុមារនៅខេត្តកំពង់ចាម

https://btv.com.kh/article/31004 2023/09/23 06:27:27 pm

កំពង់ចាម ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាម បានចុះផ្សព្វផ្សាយគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីទប់ស្កាត់ពលកម្មកុមារ ទៅដល់ពលរដ្ឋក្នុងខេត្តកំពង់ចាម ជាពិសេសម្ចាស់សិប្បកម្មឡឥដ្ឋ ម្ចាស់ចំការកៅស៊ូ អាណាព្យាបាល និងកុមារ រួមទាំងអាជ្ញាធរមូលដ្ឋាន។

កម្មវិធីផ្សព្វផ្សាយនេះ ធ្វើឡើងនៅក្នុងបរិវេណសាលាបឋមសិក្សា ឡុងស្រេងបឹងកេត ភូមិបឹងកេតលើ ឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដែលមានអ្នកចូលរួមសរុប ១៦៩រូប នាព្រឹកថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣។ ក្នុងពិធីផ្សព្វផ្សាយស្តីពីការទប់ស្កាត់នេះ ក្រសួងការងារបានពន្យល់ម្ចាស់សិប្បកម្ម និងអាណាព្យាបាល មិនអនុញ្ញាតឱ្យកុមារធ្វើការក្នុងខ្សែច្រវ៉ាក់ផលិតកម្មដែលច្បាប់បានហាមឃាត់ ខណៈដែលកុមារជាវ័យសិក្សារៀនសូត្រដើម្បីក្លាយជាធនធានមនុស្សដ៏ល្អសម្រាប់អភិវឌ្ឍសង្គមជាតិ។

សូមបញ្ជាក់ថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាល បានខិតខំយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តនូវផែនការសកម្មភាពជាតិ ស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារ តាមរយៈគោលនយោបាយ ២០១៦-២០២៥ និងគោលនយោបាយជាតិនានាដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់ពលកម្មកុមារ និងការងារដោយបង្ខំ៕

## អ្នកទេសចរចិន ខ្លាចរអារក្នុងការធ្វើដំណើរកម្សាន្តមកប្រទេសថៃ ខណៈដែលភាពយន្តឧក្រិដ្ឋកម្មចាប់ជំរិតត្រូវបានផ្សព្វផ្សាយ

https://kohsantepheapdaily.com.kh/article/1808979.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ២៤ ខែ កញ្ញា ឆ្នាំ ២០២៣ ម៉ោង ២០:៥៩

ថ្មីៗនេះរឿងអាស្រូវចចាមអារ៉ាមតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងភាពយន្តចិន ដែលបង្ហាញមុខមាត់របស់ប្រទេសថៃ ថាជាកន្លែងប្រព្រឹត្តអំពើខុសច្បាប់ដ៏គ្រោះថ្នាក់មួយ និងការចាត់ជំរិតដ៏គួរឱ្យភ័យខ្លាចសម្រាប់ក្នុងចំណោមភ្ញៀវទេសចរណ៍ជនជាតិចិនជាច្រើន ដែលវាបានធ្វើឲ្យចំនួនអ្នកធ្វើដំណើរកម្សាន្តមកប្រទេសនេះមានការធ្លាក់ចុះ។ នេះបើយោងតាមការចុះផ្សាយរបស់សារព័ត៌មាន south china morning post និង thaipbsworld បានផ្សាយនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣។

ប្រទេសថៃពឹងផ្អែកយ៉ាងខ្លាំងលើវិស័យទេសចរណ៍ ជាពិសេសពីប្រទេសចិន។ ប្រទេសនេះបានស្វាគមន៍ភ្ញៀវទេសចរចិនច្រើនជាង ១០លាននាក់ជារៀងរាល់ឆ្នាំមុនពេលការរាតត្បាត Covid-19 បន្ទាប់ការរាតត្បាតនៃជម្ងឺចំនួនក៏មានការថយចុះ ។ ឧស្សាហកម្មទេសចរណ៍ដែលកំពុងជួបការលំបាកស្រាប់នេះ ត្រូវបានវាយប្រហារជាថ្មី ដោយពាក្យចចាមអារ៉ាមតាមប្រព័ន្ធផ្សព្វផ្សាយសង្គមដែលអះអាងថា អ្នកទេសចរអាចត្រូវបានចាប់ជំរិត និងបញ្ជូនឆ្លងកាត់ទៅប្រទេសជាប់ព្រំដែន ទៅធ្វើការនៅក្នុងកន្លែងឆបោកដ៏ឃោរឃៅនៅក្នុងប្រទេសមីយ៉ាន់ម៉ា ឬកម្ពុជា។ ចំណុចនេះគឺគេសំដៅទៅដល់ភាពយន្តមួយរបស់ចិនដែលកំពុងតែផ្ទុះមានចំណងជើងថា «No more bets»។

គួររម្លឹកផងដែរថា ភាពយន្តចិន ដែលមានចំណងជើងថា `No more bets` កំពុងតែល្បីកក្រើក ពិសេសគឺជាភាពយន្តដែលអះអាងថា «ផ្អែកលើរឿងពិត»។ ភាពយន្តនេះ បង្ហាញអំពីបទល្មើសឆបោកតាមអនឡាញ ដែលឧក្រិដ្ឋជន យកកម្ពុជាធ្វើជាជម្រកដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មឆបោក ដែលតួអង្គប្រុសជា ដើរតួជា programmer និងតួស្រី ក្នុងសាច់រឿង ជាតារាម៉ូដែល ដែលអ្នកទាំងពីរត្រូវបានបោកបញ្ឆោតជាមួយនឹងការសន្យាថា ទទួលបានការងារមានប្រាក់កម្រៃខ្ពស់ ដែលនោះគឺការបោកបញ្ឆោតដោយក្រុមជើងកាងមួយក្រុម ។ ភាពយន្តនេះ មិនបាននិយាយចំឈ្មោះប្រទេសកម្ពុជា នោះទេ គឺគ្រាន់តែនិយាយថា ឧក្រិដ្ឋកម្មឆបោក កើតមាននៅប្រទេសអាស៊ីអាគ្នេយ៍ តែតួអង្គប្រុស តាមរយៈ Trailer ភាពយន្តនេះ គឺបានពាក់អាវយឺតដែលមានអក្សរខ្មែរ ដែលធ្វើឱ្យពលរដ្ឋចិនយល់ថា ជាប្រទេសកម្ពុជា។ ហេតុដូច្នេះហើយ បានធ្វើឲ្យអ្នកដំណើរមកពីប្រទេសចិនភ័យខ្លាចលែងហ៊ានធ្វើទេសចរណ៍ចូលមកលេងក្នុងប្រទេសកម្ពុជា ដោយសារតែភាពយន្តនេះ បានបង្ហាញថាកម្ពុជានិងភូមា ជាជម្រកឧក្រិដ្ឋជនឆបោកតាមអនឡាញ និងជួញដូរមនុស្ស។

សារព័ត៌មានបានស្រង់សម្តី អ្នកទេសចរចិន Jia Xueqiong បានចំណាយពេលមួយសប្តាហ៍នៅក្នុងប្រទេសថៃជាមួយស្វាមី និងកូនស្រី ទោះបីជាឪពុកម្តាយរបស់នាងមិនយល់ព្រមក៏ដោយ។ គិលានុបដ្ឋាយិកាអាយុ 44 ឆ្នាំបានប្រាប់ AFP នៅខាងក្រៅព្រះបរមរាជវាំងដ៏ស្ងប់ស្ងាត់មិនធម្មតារបស់ទីក្រុងបាងកកថា «ពួកគេមានអារម្មណ៍ថាវាមិនមានសុវត្ថិភាពនៅទីនេះ ហើយបានព្យាយាមបញ្ចុះបញ្ចូលយើងមិនឱ្យមក»។

# ថ្ងៃទី២៦ ខែ កញ្ញា ឆ្នាំ២០២៣

## ក្រសួងការងារ
## បន្តផ្សព្វផ្សាយច្បាប់ការងារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធពលកម្មកុមារ

https://www.postkhmer.com/national/2023-09-24-1833-254715.html *ជា សុខនី* | Publication date 24 September 2023 | 18:33 ICT

***ភ្នំពេញ:*** *ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំពុងបន្តធ្វើការផ្សព្វផ្សាយច្បាប់ការងារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធពលកម្មកុមារ នៅតាមបណ្តាខេត្តនានាទូទាំងប្រទេស ខណៈមន្ត្រីសិទ្ធិមនុស្ស ចង់ឱ្យក្រសួងរឹតបន្តឹងការអនុវត្តច្បាប់ផងដែរ ទៅលើជនដែលប្រើប្រាស់កម្លាំងពលកម្មកុមារ។*

*លោក កត្តា អ៊ិន អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឱ្យដឹងនៅថ្ងៃទី២៤ ខែកញ្ញាថា បច្ចុប្បន្នមានខេត្តចំនួន៥ហើយ ដែលក្រុមការងារក្រសួងបានចុះផ្សព្វផ្សាយ ក្នុងនោះមានខេត្តកំពង់ចាម សៀមរាប បាត់ដំបង ត្បូងឃ្មុំ និងខេត្តកណ្តាល ហើយក្រសួងក៏នឹងបន្តចុះផ្សព្វផ្សាយនៅតាមបណ្តាខេត្តផ្សេងទៀតជាបន្តបន្ទាប់។ លោក កត្តា អ៊ិន បញ្ជាក់ថា៖ «ការផ្សព្វផ្សាយច្បាប់ហ្នឹង គឺយើងមានគោលបំណងចង់បញ្ជ្រាបការយល់ដឹងដល់និយោជក ម្ចាស់សហគ្រាសសិប្បកម្ម ឪពុកម្តាយ និងអាណាព្យាបាល ដឹងពីអាយុនៃការធ្វើការរបស់កុមារ លក្ខខណ្ឌការងារសម្រាប់កុមារដែលច្បាប់អនុញ្ញាតឱ្យធ្វើការ កត្តាអនាម័យ និងសុខភាពជាដើម ដើម្បីលើកកម្ពស់ការគោរពសិទ្ធិកុមារ និងការពារកុមារពីពលកម្មការងារ និងការជួញដូរកម្លាំងពលកម្មកុមារ។ ទន្ទឹមនោះ យើងក៏ពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពថែមទៀតដែរ»។*

*លោកបន្តថា នៅក្នុងការផ្សព្វផ្សាយក្រសួងតែងតែផ្តល់ជាសម្ភារសិក្សាពេញ ១ឆ្នាំ កង់ និងសម្ភារចាំបាច់ផ្សេងៗទៀតដើម្បីធានាថា កុមារដែលជាកូនរបស់កម្មករទ្បូតដ្ឋ និងក្នុងរោងចក្រកសិ-ឧស្សាហកម្ម ដែលមានអាយុក្រោម១៥ឆ្នាំ អាចបន្តសិក្សារៀនសូត្រឡើងវិញបាន។ ដោយឡែកយុវជនដែលមានអាយុ១៥ឆ្នាំឡើង នឹងត្រូវដកហូតចេញពីចង្វាក់ផលិតកម្ម ដោយបញ្ជូនទៅរៀនបច្ចេកទេសវិជ្ជាជីវៈដែលមានរយៈពេល៤ខែ ឬ៦ខែ ដើម្បីឱ្យមានជំនាញ និងអាចទទួលបានឱកាសការងារ។ លោកបន្ថែមថា ក្រោយពីទទួលបានការបណ្តុះបណ្តាលហើយ ខាងមន្ទីរការងារខេត្តក្នុងគោលដៅ នឹងស្វែងរកការងារជូនដល់សិក្ខាកាមដែលបានរៀនចប់ផងដែរ។*

*ក្រសួងការងារបានអះអាងថា ក្រសួងបានខិតខំយកចិត្តទុកដាក់ខ្ពស់ ក្នុងការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្ម*

*កុមារ តាមរយៈគោលនយោបាយឆ្នាំ២០១៦-២០២៥ និងគោលនយោបាយជាតិនានា ដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងនឹងការ ប្រើប្រាស់ពលកម្មកុមារ និងការងារដោយបង្ខំ។*

*ទាក់ទងនឹងការផ្សព្វផ្សាយរបស់ក្រសួងការងារនេះ លោក អំ សំអាត នាយកទទួលបន្ទុកកិច្ចការទូទៅ នៃអង្គការការពារសិទ្ធិមនុស្សលីកាដូ បានឱ្យដឹងថា ទោះបីជារាជរដ្ឋាភិបាល មានការខិតខំប្រឹងប្រែងទប់ស្កាត់ ឬផ្សព្វផ្សាយច្បាប់ដែលទាក់ទងនឹងពលកម្មកុមារជាហូរហែមកក៏ដោយ ក៏លោកនៅតែមើលឃើញថា ការប្រើប្រាស់កម្លាំងពលកម្មកុមារ គឺវានៅបន្តកើតមាន។ ជាពិសេសកុមារដែលពួកគាត់ធ្វើការតាមសិប្បកម្មឡឥដ្ឋ ទោះបីជាតាមច្បាប់ការងារ មិនអនុញ្ញាតឱ្យកុមារធ្វើការក៏ដោយ ប៉ុន្តែនៅតាមសិប្បកម្មឡឥដ្ឋមួយចំនួន គឺអ្នកធ្វើការ ទទួលបានកម្រៃមិនមែនជាប្រាក់ខែទេ គឺពួកគាត់ទទួលបានជាលុយថ្ងៃ ទៅតាមកម្លាំងពលកម្មរបស់ពួកគាត់។*

*លោក អំ សំអាត បញ្ជាក់ថា៖ «អ៊ីចឹង! គ្រួសារដែលធ្វើការឱ្យសិប្បកម្មឡឥដ្ឋហ្នឹង ដើម្បីទទួលបានកម្រៃច្រើន ពួកគាត់នៅតែឆ្លៀតប្រើប្រាស់កម្លាំងពលកម្មកូនរបស់គាត់ ទៅធ្វើការនៅឡឥដ្ឋ និងធ្វើការនៅតាមផ្ទះ ក៏នៅតែបន្តមាន។ ដូច្នេះក្រសួង ត្រូវរឹតបន្តឹងការអនុវត្តច្បាប់ទៅលើម្ចាស់សិប្បកម្មដែលប្រើប្រាស់កម្លាំងពលកម្មកុមារ ហើយនិងដាក់ទោសពួកគាត់ ទៅតាមច្បាប់កំណត់»។ លោកបន្ថែមថា អ្វីដែលក្រសួងការងារកំពុងតែធ្វើនេះ គឺដើម្បីឱ្យឪពុកម្ដាយ ថៅកែ និងអ្នកដែលធ្វើការនៅសិប្បកម្មទាំងនោះ ពួកគាត់បានដឹងថា អ្វីជារឿងខុសច្បាប់លើការប្រើប្រាស់កម្លាំងពលកម្មកុមារ៕*

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្ដឹង ២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ២នាក់

https://freshnewsasia.com/index.php/en/localnews/311564-2023-09-25-08-09-15.html 2023-09-25 03:09pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២១ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០២នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ១០៦២ករណី មានមនុស្ស ២,៦៨៩នាក់។

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ១,០២៦សំណើ និងបិទសំណុំរឿង ៣២៩សំណើ (រកឃើញមនុស្ស ១,៥៨២នាក់, ឃាត់ខ្លួនជនសង្ស័យ ១២២នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ២ទីតាំង)។

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៦ករណី៕

## សមត្ថកិច្ចរៀបចំ

## បញ្ជូនថៅកែហាងកាហ្វេ២នាក់លួចបង្កប់សេវាកម្មបម្រើកម្សាន្តទៅកាន់តុលាការ

https://kohsantepheapdaily.com.kh/article/1809392.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ២៥ ខែ កញ្ញា ឆ្នាំ ២០២៣ ម៉ោង ១៦:២៧

រាជធានីភ្នំពេញ ៖ ស្តីពីករណីគណៈកម្មការឯកភាពខណ្ឌដូនពេញ បានចុះបង្ក្រាបហាងលក់កាហ្វេ ដែលលួ.ចលាក់បង្កប់សេវាកម្មបម្រើកម្សាន្ត និងឃាត់ខ្លួនមនុស្សចំនួន១២នាក់ គិតមកដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ នេះ នៅសល់ជនសង្ស័យតែ២នាក់ និងរៀបចំបញ្ជូនទៅកាន់តុលាការ ខណៈមានពាក្យលេចឮថា «កំពុងតែមានអ្នករត់ការឆ្វេលឆ្វាច ដើម្បីសុំឲ្យដោះលែងម្ចាស់ទីតាំងបង្កប់សេវាកម្មបម្រើកម្សាន្តនោះវិញ» ដូច្នោះរង់ចាំអ៊ុតមើល បើដូចពាក្យគេនិយាយមែន ម្ចាស់ទីតាំងនោះពិតជាខ្លាំង។ ប៉ុន្តែទោះជាយ៉ាងណាក្តី លោកវរសេនីយ៍ឯក ទៀង ច័ន្ទសារ អធិការនគរបាលខណ្ឌដូនពេញ ក៏បានបញ្ជាក់ច្បាស់ៗថា «ជនសង្ស័យពាក់ព័ន្ធបើកទីតាំងបង្កប់សេវាកម្មបម្រើកម្សាន្ត សមត្ថកិច្ចនឹងចាត់ការទៅតាមផ្លូវច្បាប់»។

ជនសង្ស័យទាំង២នាក់ខាងលើនេះ មានម្នាក់ឈ្មោះ កែវ ស្រីមុំ ហៅ កាព្រីង ភេទស្រី អាយុ ៥២ឆ្នាំ មុខរបរម្ចាស់ទីតាំងហាងលក់កាហ្វេបង្កប់សេវាកម្មបម្រើកម្សាន្ត ស្នាក់នៅផ្ទះលេខ១ ផ្លូវលេខ ៨២ ស្ថិតក្នុងភូមិ១២ សង្កាត់ស្រះចក ខណ្ឌពេញ និងម្នាក់ទៀតមានឈ្មោះ កង សារឿន ភេទប្រុស អាយុ២១ឆ្នាំ មុខរបរអ្នកចាត់ចែង នៅហាងលក់កាហ្វេបង្កប់សេវាកម្មបម្រើកម្សាន្ត ស្នាក់នៅផ្ទះលេខ ១៣E0 ផ្លូវលេខ៨០ ស្ថិតក្នុងសង្កាត់ស្រះចក ខណ្ឌដូនពេញ ។

សូមបញ្ជាក់ថា កម្លាំងគណៈបញ្ជាការឯកភាពខណ្ឌដូនពេញ កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ២០២៣ បានចុះបង្ក្រាបហាងកាហ្វេដែលលួ.ចលាក់បង្កប់សេវាកម្មបម្រើកម្សាន្តចំនួន៣ទីតាំង ដោយធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន១២នាក់។ ប្រតិបត្តិការនោះ ដឹកនាំកម្លាំងដោយលោកវរសេនីយ៍ឯក ទៀង ច័ន្ទសារ អធិការនៃអធិការដ្ឋាននគរបាលខណ្ឌដូនពេញ និងលោក ចាប ឌីណា អភិបាលរងនៃគណៈអភិបាលខណ្ឌដូនពេញ ដែលគណៈបញ្ជាការឯកភាពបានចុះទៅធ្វើរដ្ឋបាលពិនិត្យទីតាំងតាមហាងកាហ្វេដែលបង្កប់សេវាកម្មបម្រើកម្សាន្ត នៅចំណុចមុំផែថ្ម ចំនួន៣ទីតាំង និងឃាត់ខ្លួនជនសង្ស័យចំនួន១២នាក់ ។ ទីតាំងទាំង៣នោះមាន ៖

ទី១- ហាងលក់កាហ្វេ នៅចំណុចផ្លូវ៨២ ផ្ទះលេខ១ ស្ថិតក្នុងភូមិ១៤ សង្កាត់ស្រះចក ឃាត់ខ្លួនជនសង្ស័យចំនួន០៥នាក់ (ស្រី៤) ក្នុងនោះមានម្ចាស់ទីតាំងម្នាក់ នារីបម្រើការងារចំនួន៣នាក់ និងម្នាក់ទៀតជាអ្នកធ្វើការសេវាកម្មបម្រើកម្សាន្ត ។

ទី២- ហាងលក់កាហ្វេ ផ្ទះលេខ២៣E០ នៅចំណុចផ្លូវលេខ៨០ ស្ថិតក្នុងភូមិ១៤ សង្កាត់ស្រះចក ឃាត់ខ្លួនជនសង្ស័យចំនួន២នាក់ ជាអ្នកធ្វើការសេវាកម្មបម្រើកម្សាន្ត ។

ទី៣- ផ្ទះលេខ១៣E០ នៅចំណុចផ្លូវព្រះស៊ីសុវត្ថិ ស្ថិតក្នុងភូមិ១៥ សង្កាត់ស្រះចក និងបានឃាត់ខ្លួនជនសង្ស័យចំនួន៥នាក់ (ស្រី៤) ក្នុងនោះមានអ្នកអនាម័យម្នាក់ អ្នកយាមម៉ូតូម្នាក់ និងនារីធ្វើការសេវាកម្មបម្រើកម្សាន្តចំនួន៣នាក់ ។

ចំណែកវត្ថុតាងដែលចាប់យក រួមមាន ៖ សម្ភារៈមួយចំនួនពាក់ព័ន្ធនឹងសេវាកម្មបម្រើកម្សាន្ត (ស្រោមអនាម័យ)។ ក្រោយឃាត់ខ្លួនជនសង្ស័យទាំង១២នាក់ខាងលើ ក៏ត្រូវសមត្ថកិច្ចនាំខ្លួនយកទៅកាន់អធិការដ្ឋាននគរបាលខណ្ឌដូនពេញ ដើម្បីធ្វើការសាកសួរ ចំណែកនារីដែលជាប់ពាក់ព័ន្ធសេវាកម្មបម្រើកម្សាន្តចំនួន៩នាក់ ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ច រាជធានីភ្នំពេញ ដើម្បីធ្វើការអប់រំ។

# ថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ២០២៣

## ចាំមើលថៅកែហាងកាហ្វេ២នាក់បង្កប់សេវាកម្មផ្លូវភេទតើអាចរួចខ្លួនទេ ខណៈដែលសមត្ថកិច្ចរៀបចំបញ្ជូនទៅតុលាការ មានអ្នករត់ការឆ្វេចឆ្វាច

http://nokorwatnews.com/archives/1047556?fbclid=IwAR1jGFG6tKlIJ-8MY2dyB3k0Ze3lZyp_z3hhagJik3XtNQ5OxoQ3jEKKr0w 26/09/2023

ភ្នំពេញ ៖ ចំពោះករណីគណៈកម្មការឯកភាពខណ្ឌដូនពេញ បានចុះបង្ក្រាបហាងលក់កាហ្វេលួចលាក់បង្កប់សេវាកម្មផ្លូវភេទ ឃាត់ខ្លួនមនុស្សចំនួន១២នាក់ គិតមកដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ នេះ នៅសល់ជនសង្ស័យតែ២នាក់ប៉ុណ្ណោះ ដែលសមត្ថកិច្ចបានរៀបចំបញ្ជូនទៅតុលាការ ខណៈដែលមានពាក្យលេចឮថា កំពុងមានអ្នករត់ការឆ្វេចឆ្វាច ដើម្បីសុំឱ្យដោះលែងម្ចាស់ទីតាំងបង្កប់បម្រើសេវាកម្មផ្លូវភេទនោះវិញ ដូច្នេះរង់ចាំអ៊ុតមើលបើដូចពាក្យគេនិយាយមែន ម្ចាស់ទីតាំងបើក"បន"នោះពិតជាខ្លាំងមែនហើយ។ ប៉ុន្តែទោះជាយ៉ាងណាក្តី លោក វរសេនីយ៍ឯក ទៀង ច័ន្ទសារ អធិការនគរបាលខណ្ឌដូនពេញបានបញ្ជាក់ច្បាស់ថា ជនសង្ស័យពាក់ព័ន្ធបើកទីតាំងបង្កប់សេវាកម្មបម្រើផ្លូវភេទ សមត្ថកិច្ចនឹងចាត់ការទៅតាមផ្លូវច្បាប់។

ជនសង្ស័យទាំង២នាក់មានម្នាក់ឈ្មោះ កែវ ស្រីមុំ ហៅ កាព្រីង ភេទស្រី អាយុ៥៤ ឆ្នាំ មុខរបរម្ចាស់ទីតាំងហាងលក់កាហ្វេបង្កប់សេវាកម្មផ្លូវភេទ ស្នាក់នៅផ្ទះលេខ១ ផ្លូវលេខ៤២ ភូមិ១៤ សង្កាត់ស្រះចក ខណ្ឌដូនពេញ និងម្នាក់ទៀតឈ្មោះ កង សារឿន ភេទប្រុស អាយុ២១ឆ្នាំ មុខរបរ អ្នកចាត់ចែងនៅហាងលក់កាហ្វេបង្កប់សេវាកម្មផ្លូវភេទ ផ្ទះលេខ ១៣E0 ផ្លូវលេខ៨០ សង្កាត់ស្រះចក ខណ្ឌដូនពេញ។

សូមបញ្ជាក់ថា កម្លាំងគណៈបញ្ជាការឯកភាពខណ្ឌដូនពេញ កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ២០២៣ បានចុះបង្ក្រាបហាងកាហ្វេបង្កប់សេវាកម្មបម្រើផ្លូវភេទចំនួន៣ទីតាំង ដោយធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន១២នាក់ ។ ប្រតិបត្តិការនោះដឹកនាំកម្លាំងដោយលោកវរសេនីយ៍ឯក ទៀង ច័ន្ទសារ អធិការនៃអធិការដ្ឋាននគរបាលខណ្ឌដូនពេញ និងលោក ចាប ឱណា អភិបាលរងនៃគណៈអភិបាលខណ្ឌដូនពេញ ដែលគណៈបញ្ជាការឯកភាពបានចុះទៅធ្វើរដ្ឋបាលពិនិត្យទីតាំងតាមហាងកាហ្វេបង្កប់សេវាកម្មផ្លូវភេទ នៅចំណុចម្តុំផ្សារថ្មី ចំនួន៣ទីតាំង និងបានឃាត់ខ្លួនជនសង្ស័យចំនួន១២នាក់ ។ ទីតាំងទាំង៣នោះមាន ៖

ទី១.ហាងលក់កាហ្វេ ផ្លូវ៤២ ផ្ទះលេខ១ ភូមិ១៤ ស្ថិតក្នុងសង្កាត់ស្រះចក ឃាត់ខ្លួនជនសង្ស័យចំនួន០៥នាក់ (ស្រី៤) ក្នុងនោះ មានម្ចាស់ទីតាំងម្នាក់ នារីបម្រើការងារ៣នាក់ និងម្នាក់ជាអ្នកទទួលបម្រើសេវាកម្មផ្លូវភេទ ។

ទី២.ហាងលក់កាហ្វេផ្ទះលេខ២៣E០ ផ្លូវលេខ៨០ ភូមិ១៤ សង្កាត់ស្រះចក ឃាត់ខ្លួនជនសង្ស័យចំនួន២នាក់ជាអ្នកបម្រើសេវាកម្មផ្លូវភេទ ។

ទី៣.ផ្ទះលេខ១៣E០ ផ្លូវព្រះស៊ីសុវត្ថិ ភូមិ១៥ សង្កាត់ស្រះចក បានឃាត់ខ្លួនជនសង្ស័យចំនួន៥នាក់ (ស្រី៤) ក្នុងនោះមានអ្នកអនាម័យម្នាក់ អ្នកយាមម៉ូតូម្នាក់ និងនារីបម្រើការសេវាកម្មផ្លូវភេទចំនួន៣ នាក់ ។

វត្ថុតាងចាប់យករួមមានៈសម្ភារមួយចំនួនពាក់ព័ន្ធបម្រើសេវាកម្មផ្លូវភេទ (ស្រោមអនាម័យ) ។ ជនសង្ស័យទាំង១២ នាក់ ត្រូវបានសមត្ថកិច្ចនាំយកទៅកាន់អធិការដ្ឋាននគរបាលខណ្ឌដូនពេញ ដើម្បីធ្វើការសាកសួរ ចំណែកនារីដែលជាប់ពាក់ព័ន្ធបម្រើសេវាកម្មផ្លូវភេទ៩នាក់ ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញដើម្បីធ្វើការអប់រំ ៕

# កម្ពុជាប្រកាសមិនផ្តល់ទិដ្ឋាការចាក់បញ្ចាំងរឿងចិន «No more bets» ជាភាពយន្តរុញទេសចរណ៍ខ្មែរក្នុងរណ្តៅភ្លើង

https://kohsantepheapdaily.com.kh/article/1809701.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ២៦ ខែ កញ្ញា ឆ្នាំ ២០២៣ ម៉ោង ១៤:០៥

រាជធានីភ្នំពេញ ៖ អ្នកនាំពាក្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានថ្លែងប្រាប់ឱ្យដឹងថា ដោយពិនិត្យឃើញថា ភាពយន្តចិន ដែលមានចំណងជើងថា «No more bets» បាននិងកំពុងធ្វើឱ្យប៉ះពាល់ដល់កិត្តិនាមប្រទេសកម្ពុជាធ្ងន់ធ្ងរនោះ កម្ពុជាបានសម្រេចចាត់វិធានការណ៍ជាបន្ទាន់មួយ ដោយបានដាក់លិខិតទៅប្រទេសចិន តាមរយៈស្ថានទូតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា ស្នើសុំឱ្យផ្អាកការចាក់បញ្ចាំងភាពយន្តចិនមួយនេះ។

ឯកឧត្តម ស៊ុំ ម៉ាប់ រដ្ឋលេខាធិការ និងជាប្រធានក្រុមអ្នកនាំពាក្យ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានថ្លែងប្រាប់សារព័ត៌មានកោះសន្តិភាព នៅព្រឹកថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ នេះថា « ភ្លាមៗ ក្រោយពីក្រសួងបានឃើញតាមបណ្តាញសង្គមនៅ Trailer ពាណិជ្ជកម្មរបស់កុនមួយនេះ កម្ពុជាបានចាត់វិធានការភ្លាមៗតែម្តង»។ ឯកឧត្តមបានថ្លែងថា «ជំហររបស់យើង គឺមិនឯកភាពទេ (ចំពោះភាពយន្តនេះ)»។ អ្នកនាំពាក្យក្រសួងវប្បធម៌ មានប្រសាសន៍ថា «អ្វីដែលជាការលើកឡើងរបស់មតិសាធារណៈ ដែលបានបង្ហាញកង្វល់ថា ភាពយន្តចិននេះ ធ្វើឱ្យវិស័យទេសចរណ៍កម្ពុជារងផលប៉ះពាល់ធ្ងន់ធ្ងរ គឺជារឿងត្រឹមត្រូវ។ «ព្រោះចេញភាពយន្តរបៀបអ៊ីចឹង វាប៉ះពាល់ដល់ប្រទេសមួយដែលមានអធិបតេយ្យភាពពេញលេញ»។

នេះជាការថ្លែងរបស់ឯកឧត្តម ស៊ុំ ម៉ាប់ ដោយឯកឧត្តមមានប្រសាសន៍បញ្ជាក់បន្ថែមថា «ខ្ញុំសូមជម្រាបថា ទី១ ជាប្រភេទខ្សែភាពយន្តដែលគេផលិតនៅប្រទេសគេ ដែលវាផុតអំពីការដឹងរបស់យើង។ ពេល (ភាពយន្ត) ចេញហើយ បានយើងដឹង។ អ៊ីចឹងឱ្យមានវិធានការណ៍ណាទប់ស្កាត់ជាមុន ក៏យើងអត់មានដែរ ព្រោះនៅប្រទេសគេ។ យើងបញ្ជាក់ឱ្យច្បាស់»។ ឯកឧត្តម ស៊ុំ ម៉ាប់ បានថ្លែងបន្តថា «ទី២ ភ្លាមៗ នៅពេលយើងបានឃើញឃ្លីបនៅលើយូធូប មុននឹងមានប្រតិកម្មតាមបណ្តាញសង្គមទៅទៀត យើងបានទំនាក់ទំនងធ្វើការជាមួយក្រសួងការបរទេស ហើយបានចេញលិខិតមួយទៅតាមរយៈស្ថានទូតចិនប្រចាំនៅកម្ពុជា ឱ្យទប់ស្កាត់រឿងហ្នឹង។ រឿងនេះ យើងបានធ្វើរួចហើយទៅដល់ស្ថានទូតចិនរួចហើយ»។ ដោយឡែកវិធានការរបស់រដ្ឋាភិបាលគេយ៉ាងម៉េច យើងក៏អត់ទាន់ដឹងដែរ ព្រោះនេះគឺជាសេចក្តីសម្រេចរបស់រដ្ឋាភិបាលរបស់គេ»។

ឯកឧត្តម ស៊ុំ ម៉ាប់ មានប្រសាសន៍បញ្ជាក់បន្ថែមថា ភ្លាមៗ ក្រោយពីបានឃើញ Trailer ភាពយន្តចិនមួយនេះ ខាងភាគីកម្ពុជា ក៏បានស្នើសុំភាពយន្តពេញយកមកពិនិត្យផងដែរ។ «យើងបានស្នើសុំខាងភាគីចិន ដើម្បីបញ្ជូនវីដេអូពេញ ហើយយើងក៏បានអង្គុយមើលដែរ អ្នកជំនាញយើង

*ពិនិត្យឃើញថា តាមកម្មវត្ថុនៃការផលិតរបស់ចិននេះ គឺដើម្បីអប់រំចិនគ្នាគាត់នៅក្នុងស្រុក។ ប៉ុន្តែបំណងរបស់គាត់ដែលអប់រំហ្នឹង វាមានផលប៉ះពាល់ដល់ប្រទេសមួយចំនួន។ អ៊ីចឹង នៅពេលយើងមើលរូបភាពពេញទៅ យើងឃើញថា មិនមែនតែកម្ពុជាមួយទេ បណ្ដាប្រទេសសមាជិកប្រទេសអាស៊ានត្រូវ (ប៉ះពាល់) ទាំងអស់ ប៉ះទាំងអស់ ប៉ះភាគច្រើនតែម្ដង។ រឿងនេះ បើតាមអ្នកជំនាញគាត់មើល គឺបន្ទាប់ពីកើតមានរឿងនៅសាំងហ្គាពួរ បានមានផលិតកម្មនេះចេញមក ដើម្បីអប់រំគ្នាគាត់»។ នេះជាការលើកឡើងរបស់ឯកឧត្តម ស៊ុំ ម៉ាប់។*

*រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានបន្តថា «ទិសដៅអប់រំគ្នាគាត់ មកប៉ះប្រទេសដទៃ ក្នុងនោះយើងឃើញមានទាំងប្រទេសមីយ៉ាន់ម៉ា ទាំងថៃ មិនមែនតែកម្ពុជាមួយទេ តាមពិតទៅ។ ហើយប្រទេសផ្សេង ក៏គេប្រតិកម្មដូចគ្នា ដូចដែលប្រជាជនកម្ពុជាយើងប្រតិកម្មអ៊ីចឹង គឺដូចគ្នា»។ «អ៊ីចឹង វិធានការណ៍របស់យើងដូចខ្ញុំបានជម្រាប ទី១- យើងគាំទ្រ ដូចស្មារតីក្រសួងមហាផ្ទៃបានលើកឡើង ទឹកដីប្រទេសកម្ពុជា មិនមែនទឹកដី មិនមែនរឿងអាក្រក់ៗបែបហ្នឹងទេ។ ហើយកាលដែលគាត់ផលិតហ្នឹង គឺជាផ្ទៃក្នុងរបស់គាត់ ហួសពីការដឹងរបស់យើង»។ «អ៊ីចឹងវិធានការបន្ទាប់មកទៀត គឺយើងមិនអនុញ្ញាតដាច់ខាតឱ្យខ្សែភាពយន្តហ្នឹងចរាចរណ៍នៅក្នុងប្រទេសយើងទេ យើងមិនឱ្យអាជ្ញាបណ្ណចាក់ផ្សាយទេ។ ហើយក្នុងករណីដែលមានការបង្ហោះទៅលើបណ្ដាញសង្គម ឬក៏ប្រព័ន្ធផ្សព្វផ្សាយណាមួយនោះ យើងនឹងស្នើសុំទៅក្រសួងប្រៃសណីយ៍ ដើម្បីទប់ស្កាត់មិនឱ្យមានការផ្សាយ នេះគឺអ្វីដែលយើងអាចធ្វើបាន។ «អ៊ីចឹង ខ្ញុំសង្ខេបឡើងវិញ យើងមិនអនុញ្ញាតឱ្យចរាចរណ៍នៅក្នុងស្រុក យើងនឹងស្នើសុំអន្តរាគមន៍ផ្សេងៗ ដើម្បីទប់ស្កាត់ការផ្សាយតាមបណ្ដាញសង្គម»។*

*នៅពេលសាកសួរថា ចំពោះតួអង្គក្នុងសាច់រឿង ដែលពាក់អាវយឺតមានអក្សរខ្មែរ តើកម្ពុជាយល់យ៉ាងណា ឬមានវិធានការស្នើសុំលុប ឬយ៉ាងណានោះ?*

*ឯកឧត្តម ស៊ុំ ម៉ាប់ ថ្លែងបញ្ជាក់ថា «បាទប្អូន ត្រង់នេះ វាប៉ះពាល់ណាស់ វាមិនត្រឹមតែអត្តាធិប្បាយពាក់ព័ន្ធប្រទេស ក៏ប៉ុន្តែសម្ភារៈប្រើប្រាស់ (ក្នុងភាពយន្តចិន) ក៏ប៉ះពាល់ដែរអាហ្នឹង។ ប៉ុន្តែត្រង់នេះ ដូចខ្ញុំបានជម្រាបជូន គេផលិតលើទឹកដីគេ បានន័យថា បាយហ្នឹងដាំឆ្អិនហើយ បានយើងដឹងណាប្អូន ព្រោះនៅលើទឹកដីគេ យើងអត់មានសមត្ថភាពទៅគ្រប់គ្រងគេមុនទេ។ ហើយក្នុងការស្នើសុំទៅទូតចិន គឺយើងស្នើសុំជារួមឱ្យផ្អាកការផ្សព្វផ្សាយវីដេអូនេះតែម្ដង ប្អូន គឺជារួមតែម្ដង។ ស្នើសុំជារួម វាល្អជាងស្នើសុំរបៀបលម្អិត វាពិបាកណាស់ ព្រោះវាមិនត្រឹមតែអាវ តែគឺវា Content អត្ថន័យនៃភាពយន្តទៀត។ អ៊ីចឹង យើងស្នើសុំជារួមឱ្យទប់ស្កាត់ការផ្សព្វផ្សាយ»។*

*នៅពេលសាកសួរថា មកដល់ពេលនេះ តើកម្ពុជាមានទទួលបានការឆ្លើយតប ឬការបញ្ជាក់បន្ថែមពីស្ថានទូតចិន ប្រចាំប្រទេសកម្ពុជាយ៉ាងណាដែរ ចំពោះការស្នើសុំរបស់កម្ពុជានោះ?*

ឯកឧត្តម ស៊ុំ ម៉ាប់ បានបង្ហាញសុទិដ្ឋិនិយមថា «យើងមានជំនឿថា ស្ថានទូតចិនកំពុងធ្វើការលើរឿងហ្នឹង។ ហើយយើងបន្តធ្វើការជិតស្និទ្ធជាមួយស្ថានទូតចិនប្រចាំនៅកម្ពុជាទៀត»។

សូមបញ្ជាក់ថា រយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះ ផ្ទុះប្រតិកម្មពីប្រជាពលរដ្ឋខ្មែរយ៉ាងខ្លាំងក្លា ជុំវិញភាពយន្តចិនមួយ ដែលមានចំណងជើងថា «No more bets» ហើយភាពយន្តនេះបាននិងកំពុងធ្វើឱ្យវិស័យទេសចរណ៍កម្ពុជាដាក់ក្បាលចុះមួយទំហឹង ដោយសារតែអ្នកទេសចរចិន និងបរទេស ដែលបានទស្សនារឿងនេះ មានការភ័យខ្លាចក្នុងការមកកម្សាន្តនៅកម្ពុជា។ ជាងនេះទៅទៀត ភាពយន្តចិនមួយនេះ ក៏កំពុងធ្វើឱ្យប៉ះពាល់ទឹកចិត្តមហាជនខ្មែរ ព្រោះតែភាពយន្តចិនមួយនេះ អ្នកនិពន្ធបានអះអាងថា ផលិតឡើងមកផ្អែកទៅលើការពិត ដែលបានធ្វើការស្រាវជ្រាវ និងលើកឡើងថា មានបទឧក្រិដ្ឋជាច្រើនកើតមាននៅប្រទេសអាស៊ីអាគ្នេយ៍ មានទាំង កម្ពុជា ថៃ និងប្រទេសមីយ៉ាន់ម៉ា ជាដើម។

រឿង «No More bets» របស់ចិន ដែលរកចំណូលបានខ្ពង់ពានលានដុល្លាអាមេរិក ដោយមានអ្នកទស្សនារាប់រយលានអ្នកជុំវិញពិភពលោក កំពុងធ្វើឲ្យកិត្តិនាមប្រទេសកម្ពុជាធ្លាក់ចុះយ៉ាងគំហុក ដោយសាររឿងនេះ បាននិយាយថា ប្រទេសនៅអាស៊ីអាគ្នេយ៍ មានកម្ពុជា និងមីយ៉ាន់ម៉ា ជាដើម គឺជាប្រភពនៃល្បែ.ងស៊ីសងតាមប្រព័ន្ធអនឡាញ, ការចាប់ជម្រិ.ត, ការជួយដូរមនុស្សតាមអនឡាញ, ការធ្វើទារុ.ណក.ម្មយ៉ាងឃោ.រឃៅ និងការបង្ខំ.ងមនុស្សបង្ខំឲ្យធ្វើការដោយខុសច្បាប់ផងដែរ ។

ហើយរឿងរ៉ាវខាងលើនេះ ធ្វើឱ្យមហាជនកម្ពុជា បានបញ្ចេញកំហឹងយ៉ាងខ្លាំងក្លា ជុំវិញភាពយន្តមួយនេះ និងបានស្នើសុំក្រសួងពាក់ព័ន្ធអន្តរាគមន៍ចំពោះអ្វីដែលមហាមិត្តចិន បានធ្វើឱ្យមានការយល់ច្រឡំ នាំឱ្យប៉ះពាល់ដល់កិត្តិនាមរបស់ប្រទេសកម្ពុជា។

## ប្រតិកម្មក្រសួងមហាផ្ទៃ ៖ រឿងចិន «No more bets» ដែលចោទកម្ពុជា ជាជម្រកនៃល្បែងអនឡាញខុសច្បាប់ ជាការលាបពណ៌

https://kohsantepheapdaily.com.kh/article/1809879.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ២៦ ខែ កញ្ញា ឆ្នាំ ២០២៣ ម៉ោង ២០:១៥

រាជធានីភ្នំពេញ ៖ ថ្មីៗនេះ រឿងអាស្រូវចចាមអារ៉ាមតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងភាពយន្តចិន ដែលបង្ហាញមុខមាត់របស់ប្រទេសកម្ពុជា និងប្រទេសសមាជិកអាស៊ានផ្សេងទៀតថា ជាកន្លែងប្រព្រឹត្តអំពើខុសច្បាប់ដ៏គ្រោះថ្នាក់មួយ ពាក់ព័ន្ធនឹងការចាត់ជម្រិតដ៏គួរឱ្យភ័យខ្លាចសម្រាប់ក្នុងចំណោមភ្ញៀវទេសចរជនជាតិចិនជាច្រើន ដែលវាបានធ្វើឲ្យចំនួនអ្នកធ្វើដំណើរកម្សាន្តមកប្រទេសនេះ មានការធ្លាក់ចុះ។

*រឿង «No More bets» របស់ចិន ដែលរកចំណូលបានខ្ទង់ពាន់លានដុល្លាអាមេរិក ដោយមានអ្នកទស្សនារាប់រយលានអ្នកជុំវិញពិភពលោក កំពុងធ្វើឲ្យកិត្តិនាមប្រទេសកម្ពុជាធ្លាក់ចុះយ៉ាងគំហុក ដោយសាររឿងនេះបាននិយាយថា ប្រទេសនៅអាស៊ីអាគ្នេយ៍ មានកម្ពុជា និងមីយ៉ាន់ម៉ា ជាដើម គឺជាប្រភពនៃល្បែងស៊ីសងតាមប្រព័ន្ធអនឡាញ, ការចាប់ជម្រិត, ការជួញដូរមនុស្សតាមអនឡាញ, ការធ្វើទារុណកម្មយ៉ាងឃោរឃៅ និងការបង្ខាំងមនុស្សបង្ខំឲ្យធ្វើការដោយខុសច្បាប់ផងដែរ។*

មហាជនកម្ពុជា បានបញ្ចេញកំហឹងយ៉ាងខ្លាំងក្លាជុំវិញភាពយន្តមួយនេះ និងបានស្នើសុំក្រសួងពាក់ព័ន្ធអន្តរាគមន៍ ចំពោះអ្វីដែលមហាមិត្តចិន បានធ្វើឱ្យមានការយល់ច្រឡំប៉ះពាល់ដល់កិត្តិនាមប្រទេសកម្ពុជាយ៉ាងធ្ងន់ធ្ងរ រហូតទេសចរចិន និងបរទេសបង្ហាញការភ័យខ្លាចមិនហ៊ានមកលេងកម្សាន្តនៅកម្ពុជា។

ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ លើកឡើងថា នោះជាការលាបពណ៌ ចំពោះករណីចោទកម្ពុជាជាជម្រកនៃហ្គេមអនឡាញខុសច្បាប់។ នេះបើតាមលោកបណ្ឌិត ទូច សុឃៈ អ្នកនាំពាក្យរង ក្រសួងមហាផ្ទៃ ដែលបានថ្លែងប្រាប់សារព័ត៌មានកោះសន្តិភាព នាថ្ងៃទី២៦ ខែកញ្ញា នេះ។ អ្នកនាំពាក្យរងក្រសួងមហាផ្ទៃបានបន្តថា ការដែលលាបពណ៌កម្ពុជាថា ជាជម្រកនៃហ្គេមអនឡាញខុសច្បាប់ អាចជាចេតនាមិនល្អ ពោលគឺអាចជាការកេងចំណេញផ្នែកនយោបាយ និងអាចជាសមរភូមិទេសចរណ៍ដែលបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក កំពុងដណ្តើមទីផ្សារ។ ម្យ៉ាងទៀត យើងដឹងទាំងអស់គ្នាហើយថា និន្នាការពិភពលោកបច្ចុប្បន្ន គឺកំពុងរីកសាយភាពយ៉ាងគំហុកលើវិស័យបច្ចេកវិទ្យា ដែលបណ្តាប្រទេសភាគច្រើនតែងប្រឈមនឹងបញ្ហាអវិជ្ជមានតាមអនឡាញ គ្រាន់តែថា តិច ឬច្រើនប៉ុណ្ណោះ។ ដូច្នេះ កុំព្យាយាមទម្លាក់បន្ទុកនេះលើកម្ពុជា។

អ្នកនាំពាក្យរងក្រសួងមហាផ្ទៃបានបន្តទៀតថា ក្នុងនោះ បើបរទេសមិនការពារយើង យើងជាខ្មែរ គប្បីទុកនិន្នាការមួយឡែក រួមគ្នាបង្ហាញភាពស្អាតស្អំរបស់កម្ពុជាយើង ទៅកាន់មតិអន្តរជាតិកុំឱ្យគិតអវិជ្ជមានលើកម្ពុជា។ យើងនៅចាំទេ កាលពីប៉ុន្មានឆ្នាំមុន នៅពេលក្តាប់ព័ត៌មានបានថា មានករណីកើតមានបញ្ហាអវិជ្ជមានតាមអនឡាញ សម្តេចតេជោ អតីតនាយករដ្ឋមន្ត្រី បានចាត់វិធានការក្តៅគគុកប្រកបដោយប្រសិទ្ធភាព។

*អ្នកនាំពាក្យរងក្រសួងមហាផ្ទៃបានបន្តថា ថ្មីៗនេះដែរ មានផែនការទាញទម្លាក់កម្ពុជា ចូលទៅក្នុងបញ្ជីមិនស្លូវល្អមួយ នៃការជួញដូរមនុស្សតាមគ្រប់រូបភាព សម្តេចក្រឡាហោម ស ខេង អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក៏បានចាត់គ្រប់មធ្យោបាយ រហូតគេដកកម្ពុជាចេញពីបញ្ជីអវិជ្ជមាននោះវិញ។ អ៊ីចឹងហើយ បើគេព្យាយាមទម្លាក់យើងចូលកក់ យើងគប្បីរួមគ្នាទាញឡើងមកវិញ ពោលគឺយើងជឿជាក់លើកម្ពុជា។*

ក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី លោករិះរកគ្រប់យុទ្ធសាស្ត្រលើការគ្រប់គ្រងសន្តិសុខជារួម ក្នុងនោះ ឯកឧត្តម បានចាត់បញ្ជូនអគ្គស្នងការរងម្នាក់ ធ្វើជាស្នងការនគរបាលខេត្តព្រះសីហនុ គឺលោកឧត្តមសេនីយ៍ឯក ស រដ្ឋា ដែលបានទទួលការបណ្ដុះបណ្ដាលជំនាញនគរបាលពីក្រៅប្រទេស និងមានបទពិសោធន៍លើជំនាញសន្តិសុខ ប្រឆាំងភេរវកម្ម អន្តោប្រវេសន៍ជាដើម។ ទន្ទឹមនេះ ឯកឧត្តមអភិសន្តិបណ្ឌិត ក៏បានចាត់អគ្គស្នងការរងម្នាក់ទៀត ជាស្នងការនគរបាលរាជធានីភ្នំពេញ គឺលោកឧត្តមសេនីយ៍ទោ ជួន ណារិន ដែលមហាជនដឹងថា លោកមានជំនាញខាងព្រហ្មទណ្ឌ និងការងារសន្តិសុខ។

លើសពីនេះ ក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាល សម្ដេចធិបតីនាយករដ្ឋមន្ត្រី បានចាត់តាំង ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី ទទួលកិច្ចការសន្តិសុខ និងជាប្រធានអាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលលោកមានជំនាញ និងបទពិសោធន៍ពេញលេញ ព្រោះអតីតជាអគ្គស្នងការនគរបាលជាតិ។ ទាំងនេះបញ្ជាក់ថា កម្ពុជាមិនមែនជាប្រទេសទទួលហ្គេមអនឡាញខុសច្បាប់ ឬឧក្រិ.ដ្ឋជននោះទេ។

ករណីចំណាត់ការលើភាពយន្តចិន ដែលមានអក្សរខ្មែរនោះ លោកបណ្ឌិត ទូច សុឃៈ បានបញ្ជាក់ថា យើងគាំទ្រក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទាំងចំណាត់ការ និងទស្សនៈ ដែលចាត់ទុកថាមានអក្សរខ្មែរក្នុងភាពយន្តនេះ នាំឱ្យមានការភាន់ច្រឡំថា ឈុតឆាកឧក្រិដ្ឋកម្មទាំងនោះកើតឡើងនៅកម្ពុជា ដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស កេរ្តិ៍ឈ្មោះ ជះផលអវិជ្ជមានដល់វិស័យទេសចរណ៍ វិនិយោគជាដើម។ យើងជឿជាក់លើអ្វីដែលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈកំពុងធ្វើថា នឹងទទួលលទ្ធផលជាវិជ្ជមាន។

ទោះបីគ្រាន់តែមានអក្សរខ្មែរក្នុងឈុតឆាក មិនមែនសុទ្ធតែសាច់រឿងពិតកើតឡើងនៅកម្ពុជាក្ដី ក៏បណ្ដាលមានការសន្និដ្ឋានដោយអារម្មណ៍ថា អាចមានពាក់ព័ន្ធនឹងកម្ពុជាកម្រិតណាមួយ ដែលយើងត្រូវរួមគ្នាចាត់វិធានការ។ ក្នុងនោះ យុវជន មហាជន ជាតួអង្គសំខាន់ក្នុងការចូលរួមជួយពន្យល់សាធារណមតិទាំងជាតិ និងអន្តរជាតិ ឱ្យជឿជាក់ថា រឿងនេះមិនកើតនៅកម្ពុជានោះឡើយ។ ជារួម រឿងនេះ គ្រាន់តែជាការសម្ដែងរកចំណូលដែលមិនអាចទទួលយកបាន ក្នុងចេតនាឆ្លៀតផ្សារភ្ជាប់ដោយបំភាន់យកកម្ពុជា ជាប្រធានបទ ព្រោះប្រទេសមួយនេះ កំពុងស្ថិតក្នុងក្រសែភ្នែករបស់អ្នកទេសចរណ៍អន្តរជាតិ និងបណ្ដាប្រទេសក្នុងពិភពលោកកាន់តែច្រើនឡើងៗ។

គួររម្លឹកផងដែរថា ផ្ទុះប្រតិកម្មដូចទឹកបាក់ទំនប់ពីប្រជាពលរដ្ឋខ្មែរ ជុំវិញភាពយន្តចិនមួយដែលមានចំណងជើងថា «No more bets» ហើយភាពយន្តនេះ បាននិងកំពុងធ្វើឱ្យវិស័យទេសចរណ៍កម្ពុជា ដាំក្បាលចុះមួយទំហឹង ដោយសារតែអ្នកទេសចរចិន និងបរទេសដែលបានទ

ស្សនារឿងនេះ មានការភ័យខ្លាចក្នុងការមកកម្សាន្តនៅកម្ពុជា។ ជាងនេះទៅទៀត ភាពយន្តចិនមួយនេះ ក៏កំពុងធ្វើឱ្យប៉ះពាល់ទឹកចិត្តមហាជនខ្មែរ ព្រោះភាពយន្តចិនមួយនេះ អ្នកនិពន្ធបានអះអាងថាផលិតឡើងមកផ្អែកទៅលើការពិត ដែលបានធ្វើការស្រាវជ្រាវ និងលើកឡើងថា មានបទឧក្រិដ្ឋជាច្រើនកើតមាននៅប្រទេសអាស៊ីអាគ្នេយ៍ មានទាំង កម្ពុជា ថៃ និងប្រទេសមីយ៉ាន់ម៉ា ជាដើម។

## វៀតណាមកាត់ទោសមនុស្ស១១នាក់ពីបទជួញដូរមនុស្សខុសច្បាប់ដើម្បីធ្វើការនៅកម្ពុជា

https://kohsantepheapdaily.com.kh/article/1810073.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ២៧ ខែ កញ្ញា ឆ្នាំ ២០២៣ ម៉ោង ០៥:៥២

ថ្មីៗនេះ តុលាការនៅខេត្តដុងណាយ ប្រទេសវៀតណាម សម្រេចផ្តន្ទាទោសជនជាប់ចោទ ១១នាក់ ពីបទជួញដូរមនុស្ស និងដឹកជញ្ជូនមនុស្សឆ្លងដែនខុសច្បាប់ចូលប្រទេសកម្ពុជា។ ចំនួនមនុស្សដែលពួកគេធ្លាប់បានដឹកជញ្ជូនកាលពីពេលកន្លងមកមានរហូតដល់រាប់រយនាក់។ មានន័យថាពួកនេះមានបណ្ដាញដើរឃោសនា និងជួញដូរជាក្រុមសង្គមងងឹត ដែលមានការចាត់តាំងច្បាស់លាស់។

ជនជាប់ចោទឈ្មោះ វឿង វ៉ាន់ថាញ់ អាយុ៣៦ឆ្នាំ ត្រូវតុលាការកាត់ទោសឱ្យជាប់ពន្ធនាគារ ១២ឆ្នាំកន្លះពីបទជួញដូរមនុស្ស។ ជនជាប់ចោទដប់នាក់ទៀតត្រូវជាប់ពន្ធនាគារពី៣ឆ្នាំកន្លះទៅ៨ឆ្នាំពីបទសមគំនិតជាមួយ វឿង វ៉ាន់ថាញ់ នៅក្នុងបណ្ដាញជួញដូរមនុស្ស។ តុលាការរកឃើញថាចាប់ពីខែកុម្ភៈ ដល់ខែមិថុនា ឆ្នាំ២០២២ វឿង វ៉ាន់ថាញ់ និងបក្សពួក៣នាក់ទៀត បានប្រកាសជ្រើសរើសពលករទៅធ្វើការនៅប្រទេសកម្ពុជា។ ពួកគេសន្យាថានឹងទទួលបានប្រាក់ខែច្រើន។

វឿង វ៉ាន់ថាញ់ ទទួលបានប្រាក់៦រយដុល្លារ ពីពលករម្នាក់ៗ។ ក្រោយពេលចេញដំណើរពីវៀតណាម, ពួកគេបញ្ជូនពលករទាំងនោះទៅធ្វើការនៅតាមក្រុមហ៊ុនឯកជនដែលគ្រប់គ្រងដោយជនជាតិចិន។ ពួកគេត្រូវធ្វើការថែមម៉ោង, ត្រូវទាក់ទងអតិថិជនតាមអនឡាញជាលក្ខណៈបោកបញ្ឆោតឱ្យចូលអន្ទាក់របស់ក្រុមហ៊ុនចិន និងនិយាយអូសទាញអ្នកដទៃឱ្យលេងល្បែងអនឡាញ។ ពួកគេត្រូវធ្វើការងារជាច្រើនទៀតដោយមានមេការរបស់ក្រុមហ៊ុនចាំត្រួតពិនិត្យយ៉ាងដិតដល់។ បើនរណាចង់វិលត្រឡប់ទៅវៀតណាមវិញ គ្រួសារពួកគេត្រូវបង់ប្រាក់ជំពាក់ទៅឱ្យក្រុមហ៊ុនចាប់ពី២៥០០ទៅ៥៣០០ដុល្លារក្នុងម្នាក់ៗ។ បណ្ដាញក្រុមសង្គមងងឹតដែលជួញដូរមនុស្សធ្វើការខុសច្បាប់នេះត្រូវបែកធ្លាយ និងឈានដល់ការចាប់ខ្លួនបន្ទាប់ពីជនរងគ្រោះម្នាក់អាចរត់ចេញពីក្រុមហ៊ុន និងស្នើសុំឱ្យគេជួយកាលពីខែកក្កដា ឆ្នាំ២០២២។

នៅក្នុងបន្ទប់សវនាការ, ក្រុមរបស់ វឿង វ៉ាន់ថាញ់ ឆ្លើយសារភាពទទួលកំហុសគ្រប់យ៉ាង។ អាជ្ញាធរវៀតណាមប្រាប់ថា ប្រទេសនេះមានព្រំដែនវែងអន្លាយ និងមានច្រកចេញចូលច្រើន។ ម៉្លោះ

ហើយមិនមែនងាយស្រួលទប់ស្កាត់ការរត់ពន្ធមនុស្សឆ្លងដែនខុសច្បាប់ប៉ុន្មានទេ។ វៀតណាមត្រូវការការចូលរួមសហការពីកម្លាំងខាងក្នុងប្រទេសផង និងកម្លាំងពីខាងក្រៅប្រទេសផងដើម្បីធ្វើកិច្ចការនេះ។

រយៈពេល៤ឆ្នាំចុងក្រោយនេះ អាជ្ញាធរបានជួយសង្គ្រោះជនរងគ្រោះដែលត្រូវគេជួញដូរជាង៣៥០នាក់ និងទទួលបានជនរងគ្រោះដែលអាចរត់គេចខ្លួនត្រឡប់ទៅវៀតណាមវិញ៥៤៥នាក់។ នេះបើយោងតាមគណៈកម្មការយុត្តិកម្មនៃរដ្ឋសភាវៀតណាម។ ប្រភព៖ Vietnam Express

# ថ្ងៃទី២៨ ខែ កញ្ញា ឆ្នាំ២០២៣

## ការឆបោកឆ្លងដែន នឹងមានក្នុងរបៀបវារៈក្នុងជំនួបរវាងនាយករដ្ឋមន្ត្រីកម្ពុជានិងនាយករដ្ឋមន្ត្រីថៃ

https://www.khmertimeskh.com/501367331// Khmer Times September 27, 2023

រដ្ឋមន្ត្រីការបរទេសថៃ លោក ប៉ានព្រី ផាថាណា នុកន (Parnpree Bahiddha-Nukara) បាននិយាយថា ប្រទេសថៃនឹងពិភាក្សាជាមួយកម្ពុជា អំពីករណីក្រុមឆបោកតាមប្រព័ន្ធអ៊ីនធឺណេតដែលប្រតិបត្តិការនៅតាមព្រំដែន នៅពេលដែលនាយករដ្ឋមន្ត្រី នៃប្រទេសទាំងពីរជួបគ្នាក្នុងសប្តាហ៍នេះ។ លោក ប៉ានព្រី បាននិយាយថា ក្រុមឆបោកបានរំខាន និងបានបង្កការខូចខាតជាច្រើនដល់សាធារណជនថៃ ដោយលោកបន្ថែមថា ចាំបាច់ត្រូវធ្វើការបង្ក្រាបជាបន្ទាន់។

នាយករដ្ឋមន្ត្រីថៃ ឯកឧត្តម សេដ្ឋា ថាវីស៊ីន គ្រោងនឹងមកបំពេញទស្សនកិច្ចនៅទីក្រុងភ្នំពេញនៅថ្ងៃព្រហស្បតិ៍សប្តាហ៍នេះ ដែលក្នុងអំឡុងពេលនោះ លោកនឹងជួបពិភាក្សាជាមួយឯកឧត្តមបណ្ឌិតនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត។ កម្ពុជាជាប្រទេសអាស៊ានដំបូងគេដែលឯកឧត្តម សេដ្ឋា ថាវីស៊ីន នឹងធ្វើទស្សនកិច្ចបន្ទាប់ពីចូលកាន់តំណែងជាផ្លូវការកាលពីដើមខែនេះ។

លោក ប៉ានព្រី បាននិយាយថា ប្រទេសថៃចង់បង្ក្រាបប្រតិបត្តិការក្រុមឆបោកទាំងអស់ មិនមែនម្តងមួយៗនោះទេ បើមិនដូច្នោះវានឹងក្លាយជាការងារគ្មានទីបញ្ចប់។ លោក ប៉ានព្រី ដែលក៏ជាឧបនាយករដ្ឋមន្ត្រីផងដែរនោះ បានទៅបំពេញទស្សនកិច្ចនៅព្រំដែនខេត្តស្រះកែវ កាលពីថ្ងៃច័ន្ទដែលលោកបានសង្កេតមើលវឌ្ឍនភាព នៃការសាងសង់ស្ពានមិត្តភាពកម្ពុជា-ថៃ ដែលតភ្ជាប់បានណង់អៀន ក្នុងស្រុកអារញ្ញប្រាថេត ជាមួយស្ទឹងបត់របស់កម្ពុជា ក្នុងខេត្តឧត្តរមានជ័យ។

លោកបានសង្ខេបឱ្យដឹងថា ពាណិជ្ជកម្មព្រំដែនទ្វេភាគីក្នុងខេត្តចន្លោះខែតុលា ឆ្នាំ២០២២ ដល់ខែសីហា ឆ្នាំ២០២៣ មានតម្លៃ ១០៣,៦ ប៊ីលានបាត។ លោករដ្ឋមន្ត្រីបានដកស្រង់សម្តីរបស់កងទ័ពដែលប្រាប់លោកថា ខ្លួនមានទំនួលខុសត្រូវក្នុងការបោសសម្អាតគ្រាប់មីននៅតាមព្រំដែនក្នុងផ្ទៃ

ដីប្រមាណ ១០០ គីឡូម៉ែត្រក្រឡា។ ការងារនេះបាននិងកំពុងដំណើរការ ហើយឥឡូវនៅសល់តែ ៥,៩ គីឡូម៉ែត្រការ៉េប៉ុណ្ណោះ។ លោក ប៉ានព្រី បាននិយាយថា លោកនឹងលើកបញ្ហានេះជាមួយភាគីកម្ពុជា ដើម្បីអភិវឌ្ឍតំបន់សុវត្ថិភាពនាពេលនេះ ដើម្បីជាប្រយោជន៍ដល់ប្រជាជនទាំងពីរ។ លោករដ្ឋមន្ត្រីបានបន្តថា៖ «ប្រទេសថៃបានត្រៀមខ្លួនជាស្រេចក្នុងការអភិវឌ្ឍដីនោះ ហើយយើងនឹងសុំយោបល់ពីភាគីកម្ពុជា។ បើមិនមានបញ្ហាអ្វីនោះទេ ប្រទេសទាំងពីរអាចអភិវឌ្ឍវាទៅជាតំបន់សេដ្ឋកិច្ចបាន»៕ Thai PBS

## សង្ស័យណាស់ស្លាប់ ដោយសារក្រុមជនពាលថៃ វ៉ៃធ្វើបាប

https://kohsantepheapdaily.com.kh/article/1810592.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram បន្ទាយមានជ័យ២៧ ខែ កញ្ញា ឆ្នាំ ២០២៣ ម៉ោង ១៦:២៣

ខេត្តបន្ទាយមានជ័យ ៖ ស្ត្រីម្នាក់សម្រក់ទឹកភ្នែកមុខកូនតូចៗ ប្រុសស្រីចំនួន៤នាក់ ក្បែរមឈូសសពប្ដី ដោយនិយាយរៀបរាប់ថា «ប្ដីនាងបានស្លាប់លើដីថៃ សង្ស័យត្រូវគេប្រើអំពើហិង្សាបណ្ដាលឲ្យស្លាប់»។ ស្ត្រីរូបនេះមានឈ្មោះ ថន ណារ៉ុម អាយុ២៩ឆ្នាំ មានទីលំនៅក្នុងភូមិអូរវែង ស្ថិតនៅឃុំពង្រក្រោម ស្រុកជីក្រែង ខេត្តសៀមរាប និងជាពលករខ្មែរចូលទៅធ្វើការផ្នែកកាប់អំពៅឲ្យជនជាតិថៃ នៅក្នុងស្រុកវ៉ាត់ថាណាណាក់ខន ខេត្តស្រះកែវ។

ស្ត្រីខាងលើ ដែលមានកូនប្រុសស្រីជាប់ខ្លួនចំនួន៤នាក់ ក្នុងនោះប្រុស២នាក់ និងស្រី២នាក់ ដោយកូនប្រុសច្បងអាយុ១១ឆ្នាំ និងកូនប្រុសពៅអាយុទើបតែ៤ខែ។ ស្ត្រីរូបនេះបាននិយាយបន្តថា «ប្ដីនាងដែលស្លាប់នៅលើដីថៃមានឈ្មោះ ការ គង់ អាយុ៣១ឆ្នាំ»។ នាងរៀបរាប់បន្តថា «នាងនឹងប្ដីបាននាំកូនៗចេញពីកម្ពុជា ទៅធ្វើការនៅលើដីថៃ ចំណុចកើតហេតុ ទើបតែបាន៥ទៅ៦ថ្ងៃ តែប៉ុណ្ណោះ ដោយប្រើប្រាស់ប័ណ្ណឆ្លងដែន (Border Pass) តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត»។

ស្ត្រីខាងលើបន្តថា «នៅព្រឹកថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៣ ប្ដីនាងហាក់មានជំងឺចម្លែក ដោយដំបូងនិយាយបែបវង្វេងវង្វាន់ថា ក្ដៅខ្លួន បន្ទាប់មកថា រងារ។ លុះនាងដងទឹកជូតខ្លួនក៏ដេកមួយភ្លែត តែពេលក្រោកពីដេកវិញ ក៏សួររកកូនប្រុសច្បង ប៉ុន្តែនាងក៏ប្រាប់វិញថា កូនយើងទៅស្ទូចត្រីជាមួយកូនគេហើយ»។ ក្រោយពេលស្ដាប់ហើយ ស្រាប់តែប្ដីនាងនិយាយថា «ឮសម្លេងកូនស្រែក» ព្រមទាំងលោតចុះពីលើគ្រែ រួចទាញយកកាំបិតខ្វេវត់កាត់ចម្ការអំពៅទៅរកកូនតែម្ដង។ លុះពេលឃើញប្ដីវង្វេងវង្វាន់ខុសប្រក្រតី នាងក៏បានស្រែកប្រាប់មេការធ្វើការជាមួយគ្នា (ខ្មែរ) ឲ្យជួយ ហើយនាងក៏បានព្យាយាមរត់តាម ដោយកុហកប្ដីថា «កូនប្រុសច្បងមកដល់កន្លែងស្នាក់នៅវិញហើយ» ទើបបុរសជាប្ដី ព្រមវិលត្រឡប់មកវិញ»។

ស្ត្រីជាប្រពន្ធបន្តថា «លុះមកដល់ជិតកន្លែងស្នាក់នៅ ស្រាប់តែឃើញជនជាតិថៃ១ក្រុមចុះពីលើរថយន្ត ពណ៌ស ១គ្រឿង ខ្លះកាន់បន្ទះឬស្សី ឯអ្នកបើកបរកាន់អាវុធវែង១ដើម ដើរតម្រង់មករកពួកនាង។ ដំបូងអ្នកកាន់អាវុធបានបាញ់ឡើងលើ១គ្រាប់ ហើយស្រែកថា «ឯងវាម៉េចញៀនថ្នាំឬអី» នៅពេលប្តីនាងអង្គុយចុះ រួចនិយាយថា «ខ្ញុំមិនបានធ្វើអ្វីខុសទេ» ស្រាប់តែបុរសកាន់អាវុធនោះ ទាត់ប្តីនាង១ជើងចំដើមទ្រូង បណ្តាលឱ្យដួលផ្ងារក្រោយ បន្ទាប់មកគេក៏នាំគ្នាចាប់ចងដៃជើងប្តីនាងនឹងខ្សែដាក់លើឡានតែម្តង»។

មិនត្រឹមតែប៉ុណ្ណោះ នាងបន្តទៀតថា «មានបុរសម្នាក់ ក្នុងចំណោម៥ទៅ៦នាក់នោះ បានយកជើងជាន់ករបស់ប្តីនាងពីខាងក្រោយ នៅពេលប្តីនាងដេកផ្កាប់មុខ។ ខណៈឃើញប្តីមានឈាមហូរចេញតាមមាត់ នាងក៏បានព្យាយាមអង្វរមិនឲ្យធ្វើបាប និងសុំទៅជាមួយប្តី ព្រោះខ្លាចគេធ្វើបាប តែគេមិនអនុញ្ញាតឡើយ»។ នាងបន្តថា «លុះម៉ោងប្រហែល៦ល្ងាចថ្ងៃដដែល ស្រាប់តែតម្រួតថៃបានទូរស័ព្ទប្រាប់នាងថា «ប្តីស្លាប់ហើយ គឺស្លាប់តាំងពីម៉ោងប្រហែល៣រសៀល»។

អ្វីដែលចម្លែក នាងបញ្ជាក់ថា «ដំបូងខាងថៃឲ្យបូជាសពប្តីនៅដីថៃ តែភ្លាមៗក៏សុំឲ្យនាងនាំកូនចេញទៅខ្មែរវិញ ព្រោះខ្លាចគ្មានសុវត្ថិភាព។ បន្ទាប់មក តម្រួតក្នុងស្រុកកើតហេតុក៏យករថយន្តដឹកគាត់ និងកូនៗមកដល់ព្រំដែនច្រកទ្វារអន្តរជាតិខ្លងលឹកប៉ោយប៉ែត ចំណែកឯសពប្តីនាងវិញទើបគេបញ្ជូនឲ្យនៅរសៀលថ្ងៃទី២៧ ខែកញ្ញានេះទេ»។ នាងនិយាយទៀតថា «ចង់យកសពទៅធ្វើបុណ្យនៅស្រុកកំណើត តែគ្មានប្រាក់ ម្យ៉ាងទៀតគ្រួសារនាងក្រីក្រ ផ្ទះតូច និងរស់នៅតំបន់ដាច់ស្រយាលពីគេឯងទៀត។ ដូច្នេះនាងអំពាវនាវ សូមឲ្យក្រសួងពាក់ព័ន្ធកម្ពុជា មេត្តាជួយរកយុត្តិធម៌ឲ្យប្តីនាងផង»។

ជុំវិញករណីខាងលើ អគ្គកុងស៊ុលខ្មែរប្រចាំខេត្តស្រះកែវ មិនអាចទាក់ទងសុំការអត្ថាធិប្បាយបានទេ ដោយសារមិនស្គាល់លេខទូរស័ព្ទ។ ប៉ុន្តែយ៉ាងណាក៏ដោយ ករណីនេះបើតាមរបាយការណ៍របស់មន្ត្រីកុងស៊ុល បានបញ្ជាក់ថា ជនរងគ្រោះគឺស្លាប់ដោយសារជំងឺខ្យល់គរ។

គួរបញ្ជាក់ថា បច្ចុប្បន្ននេះ សពជនរងគ្រោះកំពុងតែតម្កល់នៅវត្តបាលិលេយ្យ ស្ថិតក្នុងក្រុងប៉ោយប៉ែត។ មិនត្រឹមតែប៉ុណ្ណោះ ស្ត្រីខាងលើក៏បានបញ្ជាក់បន្ថែមថា ខាងភាគីថៃ កំពុងតែហៅអ្នកពាក់ព័ន្ធ រួមទាំងក្រុមខ្មែរ ដែលទៅធ្វើការជាមួយគ្នាសួរនាំ ដោយគេទូរស័ព្ទប្រាប់ថា «រយៈពេល៤៥ថ្ងៃក្រោយ គេនឹងជូនដំណឹងពីករណីស៊ើបអង្កេតនេះ»៕

# ថ្ងៃទី២៩ ខែ កញ្ញា ឆ្នាំ២០២៣

## នាយករដ្ឋមន្ត្រីកម្ពុជា និងថៃ អញ្ជើញទទួល និងប្រគល់មជ្ឈមណ្ឌលសំចត និងទទួលជនរងគ្រោះដោយសារការជួញដូរ

https://freshnewsasia.com/index.php/en/localnews/311949-2023-09-28-05-54-32.html 2023-09-28 12:54pm

**(ភ្នំពេញ)៖** *បន្ទាប់ពីជួបពិភាក្សាការងារទ្វេភាគីរួចហើយនោះ នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២៨ ខែកញ្ញា ឆ្នាំ២០២៣នេះ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីកម្ពុជា និងលោក សេដ្ឋា ថាវីស៊ីន នាយករដ្ឋមន្ត្រីថៃ បានអញ្ជើញទទួល និងប្រគល់មជ្ឈមណ្ឌលសំចត និងទទួលជនរងគ្រោះដោយសារការជួញដូរ។ មជ្ឈមណ្ឌលនេះ ត្រូវបានសាងសង់ឡើងក្រោមលជំនួយរបស់រាជរដ្ឋាភិបាលថៃ ដែលមានតម្លៃជាង ២,៣លាន ដុល្លារអាមេរិក។ មជ្ឈមណ្ឌលសំចតសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រុមងាយរងគ្រោះនៅក្រុង ប៉ោយប៉ែត ត្រូវបានសាងសង់ឡើងនៅថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០២២។*

*ការបង្កើតឱ្យមានមជ្ឈមណ្ឌលសំចត និងទទួលជនរងគ្រោះដោយសារការជួញដូរនេះ ជាការបង្ហាញឱ្យឃើញនូវស្មារតីរាជរដ្ឋាភិបាលប្រទេសទាំងពីរ ក្នុងការចូលរួមប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងការជួញដូរកម្លាំងពលកម្ម។ ជាពិសេសជួយដល់ពលរដ្ឋរងគ្រោះពីការជួញដូរនេះ៕*

## មជ្ឈមណ្ឌលសំចត និងស្ដារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត ដាក់ដំណើរការជាផ្លូវការ ហើយដោយនាយករដ្ឋមន្ត្រីកម្ពុជា-ថៃ

https://www.btv.com.kh/article/31407 2023/09/28 06:42:13 pm

*ភ្នំពេញ៖ មជ្ឈមណ្ឌលសំចត និងស្ដារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការហើយ នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៨ ខែកញ្ញា ឆ្នាំ២០២៣ នេះក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់នាយករដ្ឋមន្ត្រីកម្ពុជា សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត និងនាយករដ្ឋមន្ត្រីថៃ ឯកឧត្តម សេដ្ឋា ថាវីស៊ីន* (Srettha THAVISIN) *នៅវិមានសន្តិភាព ក្នុងឱកាសដែលឯកឧត្តមនាយករដ្ឋមន្ត្រីថៃបានអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការនៅកម្ពុជា។*

*រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឯកឧត្តម ជា សុមេធី បានមានវត្តមានអមនាយករដ្ឋមន្ត្រីទាំងពីរក្នុងពិធីដាក់ឱ្យដំណើរការជាផ្លូវការមជ្ឈមណ្ឌលសំចត និងស្ដារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត។*

*បើយោងតាម ឯកឧត្តម ឯម ច័ន្ទមករា អ្នកនាំពាក្យរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បាន ឱ្យដឹងថា មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរង គ្រោះប៉ោយប៉ែត ចាប់ផ្តើមសាងសង់នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២ ហើយបញ្ចប់ជាស្ថាពរនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០២៣ ដែលជាជំនួយរបស់រាជរដ្ឋាភិបាលថៃ។ មានទីតាំងនៅភូមិប្រជាធម្មខាងកើត សង្កាត់អូរឫស្សី ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យមានទំហំដីសរុប ៤.៩០០ ម៉ែត្រការ៉េ (បណ្តោយ ៩៨ ម៉ែត្រ និងទទឹង៥០ ម៉ែត្រ)។ ត្រូវប្រើប្រាស់សម្រាប់ទទួលពលករចំណាកស្រុកមកពីប្រទេសថៃ ក្នុងការកំណត់អត្តសញ្ញាណកម្ម និងផ្តល់សេវាសង្គ្រោះបឋម ។*

*ឯកឧត្តម ឯម ច័ន្ទមករា បានបន្តថា ដោយមើលឃើញពីការយកចិត្តទុកដាក់ជួយដល់ជនងាយរងគ្រោះអំពើជួញដូរមនុស្ស និងចំណាកស្រុក រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ បានផ្តល់ជំនួយសម្រាប់សាងសង់អាគារបន្ថែមលើទំហំដីសរុប ៩,៧៦៨ ម៉ែត្រការ៉េ ដែលបានចំណាយទឹក ប្រាក់អស់ប្រមាណ ២,១៩៩,៩២០ដុល្លារសហរដ្ឋអាមេរិក សម្រាប់ប្រើប្រាស់ក្នុងគោលបំណងផ្តល់សេវាដូចជា ការស្នាក់នៅបណ្តោះអាសន្ន ការហូបចុក ថែទាំសុខភាព អប់រំ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បំណិនជីវិតដល់ជនរង គ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ប្រកបដោយសុខសុវត្ថិភាព និងគ្មានការរើសអើង ជាតិសាសន៍ និងពិការភាព៕ អត្ថបទ.ភារម្យ*

## នាយករដ្ឋមន្ត្រីថៃ៖ ពលករកម្ពុជាបានរួមចំណែកជួយដល់សេដ្ឋកិច្ចថៃ

https://btv.com.kh/article/31426 2023/09/28 10:25:38 pm

*ភ្នំពេញ៖ នៅវិមាន ៧ មករា នារសៀលថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានគណបក្សប្រជាជនកម្ពុជា និងជាប្រធានឧត្តមទីប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ បានអនុញ្ញាតឱ្យឯកឧត្តម សេដ្ឋា ថាវីស៊ីន នាយករដ្ឋមន្ត្រីថៃ ចូលជួបសំដែងការគួរសម ក្នុងឱកាសដែលឯកឧត្តមនាយករដ្ឋមន្ត្រី អញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅ។*

*ក្នុងជំនួបនេះ សម្តេចតេជោ ហ៊ុន សែន បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកឧត្តមនាយករដ្ឋមន្ត្រី និងគណៈប្រតិភូដែលបានអញ្ជើញបំពេញទស្សនកិច្ចក្រៅប្រទេសលើកដំបូងមកកាន់កម្ពុជា។ សម្តេចតេ ជោ បានអបអរសាទរជូនចំពោះឯកឧត្តម សេដ្ឋា ថាវីស៊ីន ដែលត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីថៃ និងគណៈប្រតិភូរាជរដ្ឋាភិបាលថៃថ្មី ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចនៅកម្ពុជា។ ទស្សនកិច្ច នេះ បង្ហាញឱ្យឃើញនូវលក្ខណៈពិសេសនៃទំនាក់ទំនងរបស់ព្រះរាជាណាចក្រទាំងពីរ។*

ឯកឧត្តម សេដ្ឋា ថាវីស៊ីន មានប្រសាសន៍ថា នេះគឺជាកិត្តិយសដ៏ខ្ពង់ខ្ពស់ណាស់ ដែលបានចូលជួប សម្តែងការគួរសមសម្តេចតេជោ និងចូលរួមពិសាអាហារពេលល្ងាច ដែលឯកឧត្តមសូមវាយតម្លៃខ្ពស់ ចំពោះប្រទេសកម្ពុជា ជាប្រទេសទីមួយ ក្នុងការមកបំពេញទស្សនកិច្ច។ ឯកឧត្តមក៏បានលើកឡើងពីលទ្ធផល នៃការពិភាក្សាប្រកបដោយផ្លែផ្កា ជាមួយសម្តេចធិបតីនាយករដ្ឋមន្ត្រី ស្តីពីកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យទាំងអស់ ដើម្បីជំរុញទំនាក់ទំនងល្អប្រសើររវាងប្រទេសទាំងពីរឱ្យកាន់តែរឹងមាំ និងរីកចម្រើនថែមទៀត។

ឯកឧត្តមនាយករដ្ឋមន្ត្រីថៃ បានថ្លែងអំណរគុណ ចំពោះពលករកម្ពុជា ដែលបានទៅធ្វើការនៅប្រទេសថៃ។ កម្លាំងពលករកម្ពុជាទាំងនេះ បានរួមចំណែកដល់សេដ្ឋកិច្ចរបស់ថៃ ហើយឯកឧត្តមបានធានាអះ អាងថា នឹងយកចិត្តទុកដាក់ចំពោះពលករខ្មែរទាំងនោះ។

សម្តេចតេជោ បានវាយតម្លៃខ្ពស់ចំពោះលទ្ធផល នៃការចរចាទ្វេភាគីរវាងឯកឧត្តមនាយករដ្ឋមន្ត្រីថៃ និងសម្តេចធិបតីនាយករដ្ឋមន្ត្រី។ សម្តេចតេជោ ក៏បានលើកឡើងអំពីការសម្រេចចិត្តរបស់សម្តេច ក្នុងការផ្ទេរអំណាចទៅឱ្យយុវជនជំនាន់ក្រោយ ដែលមានសមត្ថភាព ដើម្បីបន្តដឹកនាំប្រទេស រក្សានូវសមិទ្ធផលដែលមានស្រាប់ និងបង្កើនសមិទ្ធផលថ្មីៗ ដើម្បីនាំកម្ពុជាឱ្យមានការរីកចម្រើន និងមានការអភិវឌ្ឍថែមទៀត។ សម្តេចតេជោក៏បានរម្លឹកឡើងវិញ ពីការខិតខំរបស់សម្តេច និងឥស្សរជនកម្ពុជា ក្នុងការបញ្ចប់សង្គ្រាម នាំមកនូវការឯកភាពទឹកដីជាលើកដំបូង ក្នុងប្រវត្តិសាស្ត្រ ៥០០ ឆ្នាំកន្លងមក។

សម្តេចតេ ជោបន្តថា ចាប់តាំពីឆ្នាំ១៩៩៨ ក្រោយបញ្ចប់សង្គ្រាម សម្តេចបានបង្ហាញនូវគោលដៅ២ គឺទី១ ប្រែក្លាយតំបន់សមរភូមិឱ្យទៅជាតំបន់អភិវឌ្ឍន៍ និងទីពីរប្រែក្លាយព្រំដែន ដែលធ្លាប់ភ័យខ្លាចដោយសង្គ្រាមឱ្យទៅជាតំបន់មានសន្តិភាព និងកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ។ សម្តេចតេជោបន្ថែមថា ក្នុងរយៈពេល ២៥ឆ្នាំចុងក្រោយនេះ សម្តេចក្នុងនាមប្រធានគណបក្សប្រជាជនកម្ពុជា និងជាអតីតនាយករដ្ឋមន្ត្រី បានធ្វើការយ៉ាងខ្លាំងក្នុងការធ្វើទំនាក់ទំនងល្អជាមួយបណ្តាប្រទេសជិតខាង បង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្តាខេត្តជាប់គ្នា រវាងកងកម្លាំងប្រដាប់អាវុធទាំងសងខាង មានទំនាក់ទំនងពាណិជ្ជកម្មឆ្លងព្រំដែនរវាងប្រទេសទាំងពីរ ក៏ដូចជាជាមួយបណ្តាប្រទេសឡាវ និងវៀតណាមផងដែរ។

សម្តេចតេជោ មានប្រសាសន៍បន្តថា ប្រទេសជាប់ភូមិផងរបងជាមួយត្រូវមានកិច្ចសហការល្អលើគ្រប់វិស័យ ពិសេសវិស័យពាណិជ្ជកម្ម ការឆ្លងកាត់ទៅវិញទៅមករបស់ប្រជាជន ក៏ដូចជាការធ្វើសមយុទ្ធជួយសង្គ្រោះគ្នា ក្នុងគ្រោះមហន្តរាយធម្មជាតិ មានភ្លើងឆេះព្រៃ មានទឹកជំនន់ និងការជួយ

គ្នាទៅវិញទៅមក ជាពិសេសចំពោះប្រជាជននៅតាមបណ្ដាព្រំដែន សម្រួលការធ្វើកាត់ទំនាក់ទំនង រវាងប្រជាជននិងប្រជាជន ការចេញចូលដើម្បីធ្វើពាណិជ្ជកម្ម ក៏ដូចជាការទៅព្យាបាលជំងឺជាដើម។

ឯកឧត្តមនាយករដ្ឋមន្ត្រីថៃ បានថ្លែងអំណរគុណចំពោះសម្ដេចតេជោ និងបានលើកឡើងថា ឯកឧត្តមបានរៀនសូត្រយ៉ាងច្រើនពីសម្ដេច និងបានកោតសរសើរចំពោះសម្ដេចធិបតីនាយករដ្ឋមន្ត្រី ដែលមានសមត្ថភាព មានកម្លាំងរឹងមាំ មានវ័យក្មេង ហើយសង្ឃឹមថា ទំនាក់ទំនងរវាងប្រទេសទាំងពីរនឹងកាន់តែរឹងមាំខ្ពង់ខ្ពស់ថែមទៀត៕ ដោយៈ គង់ ឌិន